ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា



# ផែនការយុទ្ធសាស្ត្រវិស័យអប់រំ
# ឆ្នាំ ២០១៩-២០២៣

ខែ មិថុនា ឆ្នាំ២០១៩

# អារម្ភកថា

ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ដោយមានការចូលរួមពីសមាជិកក្រុមការងារវិស័យអប់រំ និងអ្នកពាក់ព័ន្ធ។ សមិទ្ធផលធំៗសម្រេចបានគួរឱ្យកត់សម្គាល់ដូចជា ការបន្តបង្កើនការចូលរៀនប្រកបដោយសមធម៌នៅគ្រប់កម្រិត ជាពិសេសការអប់រំមូលដ្ឋានរយៈពេល៩ឆ្នាំ ការបង្កលក្ខណៈសម្បត្តិអនុគ្រោះនានា ដើម្បីឱ្យកុមារនិងយុវជនជួបការលំបាកមានលទ្ធភាពចូលសិក្សានៅគ្រប់កម្រិត ការពង្រឹងនិងពង្រីកអភិបាលកិច្ចនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ ការពង្រឹងគុណភាពអប់រំតាមរយៈការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន និងការបង្កើនអាហារូបករណ៍សម្រាប់សិស្សនិងនិស្សិតក្រីក្រ។ ការអនុវត្តវិធានការលើកកម្ពស់គុណភាព និងភាពឆ្លើយតបរបស់សេវាអប់រំ ជាពិសេសកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងការប្រឡងគ្រប់ប្រភេទបានក្លាយជាចំណុចគន្លឹះឈានដល់ការកំណត់អាទិភាពក្នុងកម្មវិធីកំណែទម្រង់ផ្សេងទៀតដូចជា ការលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ការពិនិត្យឡើងវិញកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល និងកំណែទម្រង់ឧត្តមសិក្សា។ យុវជនកម្ពុជាក៏កាន់តែមានភាពសកម្ម តាមរយៈការទទួលបាននូវអន្តរាគមន៍ និងការគាំទ្រនានាពីគ្រប់អ្នកពាក់ព័ន្ធដូចជា ដំណើរការរបស់ក្រុមប្រឹក្សាកុមារនិងយុវជន យុវជនស្ម័គ្រចិត្ត យុវជនកាកបាទក្រហម និងយុវជនកាយរឹទ្ធិ ព្រមទាំងទទួលបានការផ្តល់ជំនាញបច្ចេកទេសនិងជំនាញទន់ ការផ្តល់ព័ត៌មានទីផ្សារការងារ ការប្រឹក្សាអាជីព និងការតម្រង់ទិសសិក្សា។ វិស័យអប់រំកាយ និងកីឡាបានក្លាយទៅជាវិស័យឈានមុខមួយនិងទទួលការសាទរពីមហាជន និងទទួលបានមេដាយមាសពីការប្រកួតជើងឯកពិភពលោក ជើងឯកអាស៊ី និងជើងឯកអាស៊ីអាគ្នេយ៍ពីការប្រកួតកីឡា អាស៊ីហ្គេម កីឡាស៊ីហ្គេម ព្រមទាំងការប្រកួតកីឡាផ្សេងៗ ជាច្រើនទៀត។

ឆ្លើយតបនឹងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ដោយបានចាត់ទុកការអភិវឌ្ឍធនធានមនុស្សជាអាទិភាពទី១ ក្រសួងអប់រំ យុវជន និងកីឡាប្តេជ្ញាសម្រេចឱ្យបាននូវមុំទី១ ស្តីពី "ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា" ផ្តោតអាទិភាពលើ ១) ការយកចិត្តទុកដាក់លើគ្រូបង្រៀន ២) ការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត ៣) ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន ៤) ការជំរុញការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ៥) ការអប់រំបំណិនឱ្យស្របតាមទីផ្សារការងារ ៦) ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលគ្រប់ជ្រុងជ្រោយ និង ៧) ការត្រៀមប្រកួតកីឡាស៊ីហ្គេម ឆ្នាំ២០២៣។

ដំណាក់កាលបន្ទាប់ ២០១៩-២០២៣ និងឆ្ពោះទៅឆ្នាំ២០៣០ ក្រសួងអប់រំ យុវជន និងកីឡាប្តេជ្ញាសម្រេចឱ្យបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ស្តីពីការអប់រំ ដោយឈរលើគោលការណ៍គុណភាព សមធម៌ បរិយាបន្ន ការសិក្សាពេញមួយជីវិត និងទាំងអស់គ្នា។ ម្យ៉ាងទៀត ក្រសួងបន្តកាត់បន្ថយគម្លាតជំនាញដោយសហការជាមួយអ្នកពាក់ព័ន្ធ ក្នុងការបង្កើនការផ្គត់ផ្គង់ជំនាញដែលមានតម្រូវការខ្ពស់ក្នុងវិស័យអាទិភាពមួយចំនួន ដោយដាក់ចេញនូវការអប់រំតាមបែបឌីជីថល ដើម្បីឆ្លើយតបនឹងគោល-នយោបាយ និងទិសដៅនៃសេដ្ឋកិច្ចឌីជីថលកម្ពុជា។

ឈរលើមូលដ្ឋាននេះ ក្រសួងបានកំណត់គោលនយោបាយពីរគឺ ១) ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និង ២) ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ត្រូវបានរៀបចំឡើងក្នុងគោលដៅបន្តអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា និងបង្កើតមូលដ្ឋានរឹងមាំសម្រាប់ឆ្ពោះទៅឆ្នាំ២០៣០ ព្រមទាំងឆ្លើយតបនឹងចក្ខុវិស័យអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា និងកម្មវិធីកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលកម្ពុជា។ ផែនការនេះនៅបន្តរក្សាទម្រង់នៃការគ្រប់គ្រងតាមបែបអនុវិស័យ ដើម្បីបង្ហាញពីទំនាក់ទំនងច្បាស់លាស់រវាងវត្ថុបំណងរបស់អនុវិស័យ ក្របខណ្ឌយុទ្ធសាស្ត្រ សកម្មភាពគោល និងតម្រូវការធនធាន ព្រមទាំងផ្តល់ភាពងាយស្រួលក្នុងការពិនិត្យតាមដាននិងវាយតម្លៃ រួមជាមួយនឹងយន្តការសម្រាប់ផ្តល់ព័ត៌មានត្រឡប់ និងការពិនិត្យឡើងវិញផងដែរ។

ក្រសួងអប់រំ យុវជន និងកីឡា សូមសំដែងនូវការកោតសរសើរដ៏ស្មោះចំពោះថ្នាក់ដឹកនាំ និងមន្ត្រីអប់រំ គ្រប់លំដាប់ថ្នាក់ ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធផ្សេងទៀត ដែលបានចូលរួមគាំទ្រនិងរួមចំណែកដល់ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ឱ្យសម្រេចបានជាស្ថាពរ។ ក្រសួងសង្ឃឹមថាអ្នកពាក់ព័ន្ធទាំងអស់នឹងបន្តប្រមូលផ្តុំកម្លាំងជាធ្លុងមួយ ចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំឱ្យទទួលបានផ្លែផ្កា ដើម្បីអនាគតរបស់កុមារនិងយុវជនកម្ពុជា និងការអភិវឌ្ឍប្រទេស។

ថ្ងៃ ចន្ទ ១៥កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# មាតិកា

ទំព័រ


## ជំពូកទី ១ សេចក្តីផ្តើម និងការវិភាគការបំពេញការងារ ២០១៤-២០១៨

១.១ សេចក្តីផ្តើម និងការវិភាគការបំពេញការងារវិស័យអប់រំ ២០១៤-២០១៨ ១

១.២ ការវិភាគវឌ្ឍនភាពតាមអនុវិស័យ ៤

១.៣ វឌ្ឍនភាពនៃការអនុវត្តអាទិភាពកំណែទម្រង់វិស័យអប់រំក្នុងក្របខណ្ឌសសរស្តម្ភទាំង៥ ១៣

១.៤ ការវិភាគអំពី សមត្ថភាព និងការគ្រប់គ្រង ១៦

១.៥ បញ្ហាប្រឈម ១៨

## ជំពូកទី ២ ក្របខណ្ឌនៃការអភិវឌ្ឍជាតិ

២.១ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ២០១៦-២០៣០ ២០

២.២ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ២០

២.៣ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា ២២

២.៤ ចក្ខុវិស័យ បេសកកម្ម របស់ក្រសួងអប់រំ យុវជន និងកីឡា ២៦

២.៥ គោលនយោបាយអប់រំ សូចនាករស្នូល និងចំណុចដៅ ២៧

## ជំពូកទី ៣ ផែនការតាមអនុវិស័យឆ្នាំ ២០១៩-២០២៣

៣.១ អនុវិស័យ ការអប់រំកុមារតូច ៣០

៣.២ អនុវិស័យ ការអប់រំបឋមសិក្សា ៣៧

៣.៣ អនុវិស័យ ការអប់រំមធ្យមសិក្សា និងការអប់រំបច្ចេកទេស ៤៦

៣.៤ អនុវិស័យ ការអប់រំឧត្តមសិក្សា ៥៦

៣.៥ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ ៦១

៣.៦ អនុវិស័យ ការអភិវឌ្ឍយុវជន ៦៦

៣.៧ អនុវិស័យ ការអប់រំកាយ និងកីឡា ៧២

## ជំពូកទី ៤ យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា


| | | |
|---|---|---|
| ៤.១ | ការជានាសង្គតិភាពនៃកំណែទម្រង់គោលនយោបាយអប់រំថ្នាក់ជាតិ កំណែទម្រង់ការបណ្តុះបណ្តាលគ្រូ និងកំណែទម្រង់កម្រិតសាលារៀន | ៧៨ |
| ៤.២ | អាទិភាពកំណែទម្រង់គោលនយោបាយអប់រំក្នុងក្របខណ្ឌសសរស្តម្ភទាំង៥ | ៧៨ |
| ៤.៣ | យុទ្ធសាស្ត្រកំណែទម្រង់គ្រប់គ្រងអប់រំ | ៨១ |
| ៤.៤ | កំណែទម្រង់ការអប់រំគ្រូបង្រៀននៅតាមសាលាគរុកោសល្យ | ៨៣ |
| ៤.៥ | កំណែទម្រង់សាលារៀន | ៨៤ |
| ៤.៦ | កំណែទម្រង់ការអភិវឌ្ឍយុវជន | ៨៤ |
| ៤.៧ | កំណែទម្រង់ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា | ៨៤ |
| ៤.៨ | ការលើកកម្ពស់ការអប់រំតាមបែបឌីជីថល | ៨៤ |
| ៤.៩ | ការបញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ | ៨៥ |
| ៤.១០ | កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | ៨៦ |


## ជំពូកទី ៥ ផែនការហិរញ្ញប្បទានឆ្នាំ ២០១៩-២០២៣


| | | |
|---|---|---|
| ៥.១ | កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ៩០ |
| ៥.២ | ការប៉ាន់ស្មានធនធានដែលមាន សម្រាប់វិស័យអប់រំ | ៩២ |
| ៥.៣ | ការព្យាករណ៍តម្រូវការថវិកា សម្រាប់វិស័យអប់រំ | ៩៣ |
| ៥.៤ | ការប៉ាន់ស្មានគម្លាតថវិកា និងយុទ្ធសាស្ត្រកៀរគរថវិកា | ៩៤ |


## ជំពូកទី ៦ ការពិនិត្យតាមដាន និងវាយតម្លៃ


| | | |
|---|---|---|
| ៦.១ | ការពិនិត្យតាមដាន និងវាយតម្លៃ | ៩៥ |
| ៦.២ | នីតិវិធីនៃការពិគ្រោះយោបល់ | ១០១ |

# ឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១ ៖ សូចនាករស្នូល និងចំណុចដៅសម្រាប់ឆ្នាំ២០១៩-២០២៣ ១០៤

ឧបសម្ព័ន្ធទី២ ៖សូចនាករផលសម្រេច និងចំណុចដៅតាមអនុវិស័យឆ្នាំ២០១៩-២០២៣ ១០៦

ឧបសម្ព័ន្ធទី៣ ៖ ចំណោលចំនួនសិស្ស និងតម្រូវការអប់រំ ១១៧

ឧបសម្ព័ន្ធទី៤ ៖ ការព្យាករណ៍ថវិកាសម្រាប់វិស័យអប់រំ ១១៩

ឧបសម្ព័ន្ធទី៥ ៖ យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨-២០២៣ ១២១

ឧបសម្ព័ន្ធទី៦ ៖ ម៉ាទ្រិកសកម្មភាពគោលនយោបាយ ១៥១

# តារាង


| | | ទំព័រ |
|---|---|---|
| តារាងទី១ | វឌ្ឍនភាពនៃសូចនាករស្នូល | ៣ |
| តារាងទី២ | សូចនាករ និងចំណុចដៅ នៃផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជា ឆ្នាំ២០៣០ | ២៥ |
| តារាងទី៣ | សូចនាករស្នូល និងចំណុចដៅឆ្នាំ២០១៩-២០២៣ | ២៨ |
| តារាងទី៤ | សូចនាករផលសម្រេច និងចំណុចដៅឆ្នាំ២០១៩-២០២៣ អនុវិស័យការអប់រំកុមារតូច | ៣១ |
| តារាងទី៥ | សូចនាករផលសម្រេច និងចំណុចដៅឆ្នាំ២០១៩-២០២៣ អនុវិស័យការអប់រំបឋមសិក្សា | ៣៨ |
| តារាងទី៦ | សូចនាករផលសម្រេច និងចំណុចដៅឆ្នាំ២០១៩-២០២៣ អនុវិស័យការអប់រំ មធ្យមសិក្សា និងអប់រំបច្ចេកទេស | ៤៧ |
| តារាងទី៧ | សូចនាករផលសម្រេច និងចំណុចដៅឆ្នាំ២០១៩-២០២៣ អនុវិស័យការអប់រំឧត្តមសិក្សា | ៥៧ |
| តារាងទី៨ | សូចនាករផលសម្រេច និងចំណុចដៅឆ្នាំ២០១៩-២០២៣ អនុវិស័យការអប់រំក្រៅប្រព័ន្ធ | ៦២ |
| តារាងទី៩ | សូចនាករផលសម្រេច និងចំណុចដៅឆ្នាំ២០១៩-២០២៣ អនុវិស័យការអភិវឌ្ឍយុវជន | ៦៧ |
| តារាងទី១០ | សូចនាករផលសម្រេច និងចំណុចដៅឆ្នាំ២០១៩-២០២៣ អនុវិស័យការអប់រំកាយ និងកីឡា | ៧៣ |
| តារាងទី១១ | ការប៉ាន់ស្មានធនធានដែលមាន សម្រាប់វិស័យអប់រំ | ៩៣ |
| តារាងទី១២ | ការព្យាករណ៍តម្រូវការថវិកា តាមអនុវិស័យ | ៩៣ |
| តារាងទី១៣ | ការប៉ាន់ស្មានគម្លាតថវិកា | ៩៤ |

# ជំពូកទី ១

# សេចក្តីផ្តើម និងការវិភាគការបំពេញការងារ ២០១៤-២០១៨

## ១.១ សេចក្តីផ្តើម និងការវិភាគការបំពេញការងារ ២០១៤-២០១៨

ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ និងអាទិភាពកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ព្រមទាំងការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិឆ្នាំ ២០១៦ នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ឆ្លើយតបនឹងគោលនយោបាយ និងយុទ្ធសាស្ត្រអាទិភាពសំខាន់ៗនៅក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ កំណែទម្រង់នានារបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា និងផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា។

ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ក្រសួងសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការបង្កើនការទទួលបានសេវាអប់រំសម្រាប់កុមារកម្ពុជាគ្រប់រូប ការលើកកម្ពស់គុណភាពនៃការសិក្សារបស់សិស្ស និងការផ្តល់សេវាអប់រំប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិឆ្នាំ២០១៦ នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ក្រសួងបានកែសម្រួលគោលនយោបាយអប់រំពីបីមកពីរវិញ ដើម្បីឱ្យមានសង្គតិភាពជាមួយនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា ជាពិសេសឆ្លើយតបនឹងអាទិភាពគោលនយោបាយអប់រំនានា ក្នុងការរួមចំណែកអនុវត្តគោលនយោបាយរួមរបស់រាជរដ្ឋាភិបាលដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព សំដៅសម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ។ គោលនយោបាយអប់រំរយៈពេលមធ្យមពីរគឺ ៖

- **គោលនយោបាយទី១ ៖** ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា
- **គោលនយោបាយទី២ ៖** ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

ក្នុងរយៈពេល៥ឆ្នាំកន្លងមក ក្រសួងនិងដៃគូអភិវឌ្ឍបានរួមគ្នាសម្រេចកិច្ចការធំៗគួរឱ្យកត់សម្គាល់ ដូចជា បន្តបង្កើនការចូលរៀនប្រកបដោយសមធម៌នៅគ្រប់កម្រិត ជាពិសេសការអប់រំមូលដ្ឋានរយៈពេល ៩ឆ្នាំ តាមរយៈការបង្កលក្ខណៈសម្បត្តិអនុគ្រោះនានា ដើម្បីឱ្យកូនចៅប្រជាពលរដ្ឋដែលជួបការលំបាក មានលទ្ធភាពចូលសិក្សា ការពង្រឹងនិងពង្រីកអភិបាលកិច្ចនៅតាមគ្រឹះស្ថានសិក្សារដ្ឋ ការពង្រឹងគុណភាពអប់រំ ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន និងការបង្កើនអាហារូបករណ៍សម្រាប់សិស្ស និងនិស្សិតក្រីក្រ។

ក្រសួងបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា ក្នុងការអនុវត្តវិធានការលើកកម្ពស់គុណភាព និងភាពឆ្លើយតបរបស់សេវាអប់រំ ពិសេសកំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងការ

ប្រឡងគ្រប់ប្រភេទ ការលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន ការអភិវឌ្ឍសមត្ថភាពនិងការលើកទឹកចិត្តបុគ្គលិក ព្រមទាំងការបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងការគ្រប់គ្រងសេវាអប់រំ។ ពីឆ្នាំ ២០១៤ ដល់ ២០១៨ បានបង្ហាញពីដំណាក់កាលការងារដ៏សំខាន់មួយទៀតរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការដាក់ចេញ និងអនុវត្តកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡានៅកម្ពុជា ស្របតាមកំណែទម្រង់នានារបស់រាជរដ្ឋាភិបាលក្នុងអាណត្តិទី៥តាមរយៈវឌ្ឍនភាពនៃការអនុវត្តវិធានការកំណែទម្រង់ ៨ចំណុច នៅឆ្នាំ២០១៤ និងវឌ្ឍនភាពនៃកំណែទម្រង់ ១៥ ចំណុច ពីឆ្នាំ ២០១៥ ដល់ ២០១៨។

ក្រៅពីវឌ្ឍនភាពខាងលើ ក្រសួងក៏បានចលនាឱ្យយុវជនកម្ពុជាកាន់តែសកម្ម តាមរយៈអន្តរាគមន៍និងការគាំទ្រនានាពីគ្រប់អ្នកពាក់ព័ន្ធ ដូចជាដំណើរការរបស់ក្រុមប្រឹក្សាកុមារនិងក្រុមប្រឹក្សាយុវជន ការរៀបចំបណ្តាញយុវជនស្ម័គ្រចិត្តទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ចលនាយុវជនកាកបាទក្រហម និងការបង្កើនសមាជិកចលនាកាយរឹទ្ធិ។ ក្រសួងក៏បានបន្តពង្រឹងជំនាញបច្ចេកទេសនិងជំនាញទន់សម្រាប់យុវជនស្របជាមួយនឹងការផ្តល់ព័ត៌មានទីផ្សារការងារដល់យុវជន ការប្រឹក្សាអាជីព ការតម្រង់ទិសសិក្សានិងការរៀបចំវេទិកាស្តីពីការសិក្សាការងារ។ ក្រសួងក៏បានអប់រំយុវជនអំពីបំណិនជីវិតស្តីពីការការពារជំងឺអេដស៍ ការបំបាត់ការប្រើប្រាស់គ្រឿងញៀន គ្រឿងស្រវឹង ច្បាប់ចរាចរណ៍ និងការបំបាត់អំពើហឹង្សាក្នុងចំណោមយុវជន។

ចំពោះវិស័យអប់រំកាយ និងកីឡា ក្រសួងបានចាត់វិធានការចំទិសដៅ ដែលធ្វើឱ្យវិស័យអប់រំកាយនិងកីឡាត្រូវបានប្រែក្លាយទៅជាវិស័យឈានមុខ និងទទួលការសាទរពីមហាជន ដោយសារកំណែទម្រង់វិស័យអប់រំកាយនិងកីឡា ការសហការជាមួយគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជានិងសហព័ន្ធកីឡាជាតិ និងការធ្វើប្រតិភូកម្មមុខងារ ព្រមទាំងការផ្តល់ថវិកាគាំទ្រទៅឱ្យសហព័ន្ធកីឡាជាតិ។ ការខិតខំធ្វើកំណែទម្រង់គ្រប់ទិដ្ឋភាពទាំងក្នុងក្របខណ្ឌគោលនយោបាយ ទាំងក្នុងក្របខណ្ឌបច្ចេកទេស ព្រមទាំងការអនុវត្តជាក់ស្តែងបានធ្វើឱ្យមាតាបិតា អាណាព្យាបាល សាធារណជន និងប្រជាជនមានជំនឿទុកចិត្ត គាំទ្រ និងចូលរួមលេងកីឡាកាន់តែច្រើន។ លទ្ធផលនៃកំណែទម្រង់កីឡានេះ ក៏បានលើកកម្ពស់កិត្តិយសកម្ពុជាលើឆាកអន្តរជាតិ និងទទួលបានមេដាយមាសពីការប្រកួតជើងឯកពិភពលោក ជើងឯកអាស៊ី និងជើងឯកអាស៊ីអាគ្នេយ៍ពីការប្រកួតកីឡាអាស៊ីហ្គេម កីឡាស៊ីហ្គេម និងការប្រកួតកីឡាផ្សេងៗជាច្រើនទៀត។

វឌ្ឍនភាពនៃការអនុវត្តគោលនយោបាយខាងលើ ត្រូវបានបង្ហាញតាមរយៈសូចនាករស្នូលចំនួន ១០ ដូចក្នុងតារាងខាងក្រោម ៖

សូចនាករស្នូល ៧ លើ ១០ សម្រេចបានតាមចំណុចដៅ។ គោលនយោបាយទី១ មានសូចនាករ ៦ សម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ធៀបនឹងចំណុចដៅ សូចនាករ ១ (ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានធ្វើការវាយតម្លៃ) សម្រេចបានទាបជាងចំណុចដៅ និងមួយសូចនាករទៀត (វាយតម្លៃស្តង់ដាថ្នាក់ជាតិសិស្សថ្នាក់ទី៣លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា)នឹងអនុវត្តនៅឆ្នាំសិក្សា២០១៩-២០២០។ គោល-នយោបាយទី២ មានសូចនាករ ២ សម្រេចបានតាមចំណុចដៅទាំងពីរ។

សូចនាករនៃចំនួនស្រុកដែលសម្រេចបានអត្រាត្រួតថ្នាក់នៅបឋមសិក្សាយ៉ាងតិចជាង ឬ ស្មើ ១០ ភាគរយ មិនមានការកែលម្អទេ ដោយមានសភាពឡើងចុះក្នុងរយៈពេល៥ឆ្នាំកន្លងមក។ ប្រការនេះត្រូវសិក្សាបន្ថែមទៀតចំពោះស្រុកដែលនៅទាបជាងចំណុចដៅ ក៏ដូចជា ការផ្តល់អន្តរាគមន៍នានាផងដែរ។

## តារាងទី១៖ វឌ្ឍនភាពនៃសូចនាករស្នូល

| សូចនាករស្នូល | ឯកតា | ២០១៣-១៤ | ២០១៤-១៥ | ២០១៥-១៦ | ២០១៦-១៧ | ២០១៧-១៨ | | |
|---|---|---|---|---|---|---|---|---|
| | | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ចំណុចដៅ | |
| **គោលនយោបាយទី១÷** ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | | | | |
| ១. ភាគរយកុមារអាយុ៥ឆ្នាំ ក្នុងការអប់រំកុមារតូចគ្រប់រូបភាព | % | ៥៩,៩ | ៦១,៤ | ៦៤,១ | ៦៦,៤ | ៦៨,៥ | ៦៨,០ | ↑ |
| ២. ចំនួនស្រុកដែលមានអត្រាត្រួតថ្នាក់នៅបឋមសិក្សាតិចជាងឬស្មើ ១០ ភាគរយ | % | ១៨៤ | ១៨៤ | ១៧១ | ១៧៣ | ១៧៣ | ១៨២ | → |
| ៣. ចំនួនខេត្តដែលបានសម្រេចអត្រាបញ្ចប់មធ្យមសិក្សាបឋមភូមិយ៉ាងតិច ៤០ ភាគរយ | ចំនួន | ៧ | ៩ | ៨ | ១១ | ១៣ | ១០ | ↑ |
| ៤. អត្រាអក្ខរកម្មជនពេញវ័យ (អាយុ ១៥ឆ្នាំឡើង) | % | | | ៧៨,១ (២០១៤) | ៧៨,១ | ៨២,៥ (២០១៧) | ៨១,៤ | ↑ |
| ៥. វង្វាយតម្លៃតេស្តស្តង់ដាថ្នាក់ជាតិសិស្សថ្នាក់ទី៣ មុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា | | | | | | | | |
| *ការអាន* | | | ៣៥,២ | | | អនុវត្តនៅឆ្នាំសិក្សា ២០១៩-២០ | កើន ៥ពិន្ទុ | |
| *គណិតវិទ្យា* | | | ៤១,០ | | | | កើន ៥ពិន្ទុ | |
| ៦. ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានធ្វើការវាយតម្លៃ | ចំនួន | N/A | N/A | ១០ | ៣៨ | ៥ | ៥០ | ↓ |
| ៧. ភាគរយគ្រូបង្រៀនបឋមសិក្សាមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ+២ | % | N/A | N/A | ៥៧,០ | ៦៩,៦ | ៧២,១ | ៥៩,០ | ↑ |
| ៨. ភាគរយគ្រូឧទ្ទេស (សាលាគរុ. មជ្ឈម. គរុ. និងវិទ្យាស្ថានជាតិអប់រំ) មានបរិញ្ញាបត្រជាន់ខ្ពស់ | % | N/A | N/A | ១០,០ | ២០,២ | ១៨,២ | ១៨ | ↑ |
| **គោលនយោបាយទី២÷** ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | | | | |
| ៩. ចំនួននាយកសាលាបឋមសិក្សា និងមធ្យមសិក្សាបានទទួលការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងតាមសាលារៀន | ចំនួន | N/A | N/A | N/A | ៩៤៨ | ៧៥២ | ៥០០ | ↑ |
| ១០. ភាគរយនៃការទូទាត់ថវិកា | % | ៩៣,២ | ៨៦,១៦ | ៩៤,៣ | ៩៤,០ | ៩៥,១៧ | ៩៥,០ | ↑ |

↑ សម្រេចបានតាមចំណុចដៅ → អាចទទួលយកបាន ↓ មិនសម្រេចបានតាមចំណុចដៅ

*ប្រភព ៖ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៨*

ឆ្នាំ២០១៥ ក្រសួងបានចាប់ផ្តើមធ្វើការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា ហើយមកដល់បច្ចុប្បន្ន គ្រឹះស្ថានឧត្តមសិក្សាចំនួន ៥៣ ត្រូវបានវាយតម្លៃ។ ទោះជាយ៉ាងណា នៅឆ្នាំ ២០១៨ មាន ៥ គ្រឹះស្ថាន ឧត្តមសិក្សាត្រូវបានវាយតម្លៃ ដែលទាបជាងចំណុចដៅកំណត់ចំនួន ៥០។

ជារួម ការអនុវត្តគោលនយោបាយទាំងពីរនេះ មានវឌ្ឍនភាពជាវិជ្ជមានធៀបនឹងចំណុចដៅ និង បង្ហាញឱ្យឃើញពីការរីកចម្រើននៃវិស័យអប់រំ ដែលជាសសរស្តម្ភយ៉ាងសំខាន់ទ្រទ្រង់ដល់ការអភិវឌ្ឍ សង្គមកិច្ច-សេដ្ឋកិច្ចកម្ពុជា។

## ១.២ ការវិភាគវឌ្ឍនភាពតាមអនុវិស័យ

### ១.២.១ អនុវិស័យ ការអប់រំកុមារតូច

*ការវាយតម្លៃអំពីវឌ្ឍនភាពនៃការសម្រេចវត្ថុបំណងគោលនយោបាយទី១*

លទ្ធភាពទទួលសេវាអប់រំរបស់កុមារតូចមានភាពប្រសើរឡើងពីមួយឆ្នាំទៅមួយឆ្នាំ តាមរយៈ យុទ្ធសាស្រ្តអន្តរាគមន៍នានា ការផ្តល់សេវាអប់រំ និងតម្រូវការអប់រំ។ ការចូលរៀនរបស់កុមារអាយុ ៥ឆ្នាំ គ្រប់រូបភាពបានកើនឡើងជាលំដាប់ពី ៥៩,៩៣ ភាគរយ ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ៦៨,៥ ភាគរយ ឆ្នាំសិក្សា២០១៧-២០១៨ ដែលចាត់ទុកថាសម្រេចចំណុចដៅគ្រោងទុក។ ភាគរយកុមារអាយុ ៤ឆ្នាំ បាន ទទួលសេវាអប់រំកុមារតូចគ្រប់រូបភាពបានកើនឡើងជាលំដាប់ពី ២៤,៥ ភាគរយ ដល់ ៣៩,៩ ភាគរយ រយៈពេល ៥ឆ្នាំចុងក្រោយ ដែលចាត់ទុកថាសម្រេចចំណុចដៅ។ ភាគរយកុមារអាយុ ៣ឆ្នាំ ទទួលសេវា អប់រំកុមារតូចគ្រប់រូបភាពមានវឌ្ឍនភាពយឺតដោយបានកើន ៥,១ ភាគរយ ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ ដែលមិនបានសម្រេចចំណុចដៅទេ។ ការចុះឈ្មោះចូលរៀននៅថ្នាក់មត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សា និងមត្តេយ្យសិក្សាសហគមន៍បានផ្តល់អាទិភាពដំបូងដល់កុមារដែលមានអាយុ ៥ឆ្នាំ បន្ទាប់មក កុមារអាយុ ៤ឆ្នាំ និង ៣ឆ្នាំ ដែលនាំការចូលរៀនរបស់កុមារអាយុ ៣ឆ្នាំស្ថិតទាបជាងចំណុចដៅ រួមទាំងចំនួនគ្រូបង្រៀន មត្តេយ្យសិក្សា និងហេដ្ឋារចនាសម្ព័ន្ធមិនទាន់គ្រប់គ្រាន់ឆ្លើយតបទៅនឹងតម្រូវការលើការពង្រីកសេវាអប់រំ។ ការចូលរៀនរបស់កុមារា កុមារីនៅមត្តេយ្យសិក្សាគ្រប់រូបភាព មានភាពប្រហាក់ប្រហែលគ្នា រយៈពេល ៥ ឆ្នាំកន្លងមក ដោយសន្ទស្សន៍យុគភាពយេនឌ័រនៅបន្តស្មើនឹង ១,០។

ក្រសួងបានពង្រីកមត្តេយ្យសិក្សាពី ៥ ៦២៥ សាលា/កន្លែងនៅឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ៧ ៥៨៧ កន្លែងឆ្នាំសិក្សា២០១៧-២០១៨ ដែលបានកើន ៣៤ ភាគរយ រយៈពេល ៥ឆ្នាំកន្លងមក ក្នុងនោះ មត្តេយ្យសិក្សារដ្ឋ ៣១,២ ភាគរយ មត្តេយ្យសិក្សាសហគមន៍ ៣៣,១ភាគរយ និងមត្តេយ្យសិក្សាឯកជន កើនឡើងបន្តិចបន្តួច។ ក្រសួងបានអនុវត្តកម្មវិធីជាច្រើនដូចជា ថវិកាដំណើរការសាលារៀននិងកម្មវិធី ជំនួយកែលម្អសាលារៀន ការអប់រំពហុភាសា ការអប់រំបរិយាបន្ន ការអប់រំមាតាបិតាផ្សារភ្ជាប់មត្តេយ្យសិក្សា សហគមន៍ និងកម្មវិធីមត្តេយ្យសិក្សាបណ្តែតទឹក និងមត្តេយ្យសិក្សាតំបន់លិចទឹក។ កម្មវិធីអប់រំពហុភាសា សម្រាប់កុមារជនជាតិដើមភាគតិចត្រូវបានអនុវត្តនៅក្នុងស្រុក១១ ខេត្តគោលដៅ ៣ ឆ្នាំសិក្សា២០១៣-២០១៤ និងបានពង្រីកនៅក្នុងស្រុក ១៩ លើខេត្តគោលដៅ ៥ ឆ្នាំសិក្សា២០១៧-២០១៨។ ក្រសួងបាន

អនុវត្តកម្មវិធីមត្តេយ្យសិក្សាចល័តក្នុង ៥ ភូមិ ក្នុងឃុំតាវែងក្រោម ឃុំតាវែងលើ ស្រុកតាវែង ឃុំកោះពាក្យ ស្រុកវើនសៃ និងឃុំតាឡាវ ស្រុកអណ្តូងមាស ខេត្តរតនគិរី។

សាលាមត្តេយ្យសិក្សារដ្ឋដែលបានអនុវត្តកម្មវិធីអប់រំបរិយាបន្នកើនពី ២៧ ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ១៨៣ ឆ្នាំសិក្សា២០១៧-២០១៨ និងសាលាមត្តេយ្យសិក្សាសហគមន៍ដែលបានអនុវត្តកម្មវិធីអប់រំបរិយាបន្នកើនពី ១០ កន្លែង ឆ្នាំសិក្សា ២០១៣-២០១៤ ដល់ ៦៤ កន្លែង ឆ្នាំសិក្សា ២០១៧-២០១៨។ កុមារមានពិការភាពទទួលបានសេវាអប់រំបរិយាបន្នកើនពី ៧១ នាក់ ស្រី ៣៥ នាក់ ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ៥០២ នាក់ ស្រី ២១៦ នាក់ ក្នុងឆ្នាំសិក្សា២០១៧-២០១៨។

ភាគរយសេវាអប់រំកុមារតូចគោរពតាមស្តង់ដាគុណភាព ត្រូវបានវាស់វែងតាមរយៈប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃដែលផ្តោតលើការគ្រប់គ្រងបរិយាកាសរៀនសូត្រ ការសហការ និងការបណ្តុះបណ្តាល។ ភាគរយសេវាអប់រំកុមារតូចគោរពតាមស្តង់ដាគុណភាពបានកើនពី ១១ ភាគរយ ឆ្នាំសិក្សា២០១៥-២០១៦ ដល់ ២៣,៥ ភាគរយ ឆ្នាំសិក្សា២០១៧-២០១៨ ដែលចាត់ទុកថានៅទាបជាងចំណុចដៅ (២២,៩ ភាគរយ)។

ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន ៖ ក្រសួងបានបញ្ជូនគ្រូមត្តេយ្យសិក្សាចេញថ្មីប្រមាណ ២០០ នាក់ជារៀងរាល់ឆ្នាំ និងបានជ្រើសរើសគរុសិស្សមត្តេយ្យសិក្សា ២០០នាក់។ ក្រសួងក៏បានបំប៉នសមត្ថភាពនាយកសាលា និងគ្រូបង្រៀន ស្តីពីការរៀបចំថ្នាក់រៀនផ្នែកមត្តេយ្យសិក្សារដ្ឋតាមស្តង់ដាគុណភាព ព្រមទាំងបំប៉នសមត្ថភាពស្តីពីការអប់រំបរិយាបន្ន ដល់គ្រូមត្តេយ្យសិក្សារដ្ឋ និងគ្រូមត្តេយ្យសិក្សាសហគមន៍។

ទោះជាយ៉ាងណា ឧបសគ្គក្នុងការចូលរៀននៅការអប់រំកុមារតូចគឺ ដោយសារចំនួនគ្រូបង្រៀនមត្តេយ្យសិក្សា និងហេដ្ឋារចនាសម្ព័ន្ធមិនទាន់គ្រប់គ្រាន់ឆ្លើយតបទៅនឹងតម្រូវការលើការពង្រីកសេវាអប់រំ។

### *ការវាយតម្លៃអំពីវឌ្ឍនភាពនៃការសម្រេចវត្ថុបំណងគោលនយោបាយទី២*

ទោះបី មិនមានសូចនាករផលសម្រេចទាក់ទងនឹងគោលនយោបាយទី២នេះ ក៏មានយុទ្ធសាស្ត្រ និងកម្មវិធីជាច្រើនបានអនុវត្តដូចជា ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផលសម្រាប់អនុវិស័យត្រូវបានអនុម័ត និងការបំប៉នសមត្ថភាពដល់មន្ត្រីនាយកដ្ឋានអប់រំកុមារតូច។

ជារួម អនុវិស័យការអប់រំកុមារតូច ទទួលសមិទ្ធផលជាច្រើន តាមរយៈការអនុវត្តគោលនយោបាយទាំងពីរ ក្នុងរយៈពេល ៥ឆ្នាំកន្លងមក ទាំងការចូលរៀន គុណភាព និងការងារដឹកនាំនិងគ្រប់គ្រង។ ការទទួលសេវាអប់រំរបស់កុមារអាយុ ៥ ឆ្នាំ និង ៤ឆ្នាំ គ្រប់រូបភាព សម្រេចបានចំណុចដៅ និងកុមារអាយុ ៣ឆ្នាំ សម្រេចបានទាបជាងចំណុចដៅ។ ទោះជាយ៉ាងណា កិច្ចការសំខាន់មួយចំនួនទៀតទាមទារឱ្យប្រឹងប្រែងបន្ថែមដូចជា ការចូលរៀនរបស់កុមារតូច ជាពិសេសកុមារនៅតំបន់ជនបទ កុមារងាយរងគ្រោះ និងកុមារដែលមានកម្រិតស្ថានភាពសេដ្ឋកិច្ច-សង្គមមិនទាន់ឆ្លើយតប ការលើកកម្ពស់គុណភាពនៃការអប់រំកុមារតូចតាមរយៈការពង្រឹងអនុវត្តស្តង់ដាគុណភាពសេវាអប់រំកុមារតូច ការពង្រីកការបណ្តុះបណ្តាលនិងការពង្រាយគ្រូដែលមានគុណវុឌ្ឍិសម្រាប់សាលាមត្តេយ្យសិក្សា និងការរៀបចំបទប្បញ្ញត្តិគាំទ្រ និងលើកកម្ពស់ការចូលរួម និងការទទួលខុសត្រូវរបស់ភាគីពាក់ព័ន្ធដូចជា ការពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ។

### ១.២.២ អនុវិស័យ ការអប់រំបឋមសិក្សា

*ការវាយតម្លៃអំពីវឌ្ឍនភាពនៃការសម្រេចវត្ថុបំណងគោលនយោបាយទី១*

រយៈពេល ៥ឆ្នាំកន្លងមក ការចូលរៀននៅបឋមសិក្សា សម្រេចបានអត្រាពិតនៃការសិក្សាក្នុងរង្វង់ ៩៨ ភាគរយ និងអត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា ក្នុងរង្វង់ ៨០ ភាគរយ។ សាលាបឋមសិក្សាមានស្ទើរគ្រប់ទីតាំងភូមិសាស្ត្រ ដោយចំនួនសាលាបឋមសិក្សាបានកើនឡើងជាបន្តបន្ទាប់ ជាមួយគ្នានេះ ចំនួនសាលារៀនមិនគ្រប់កម្រិតបានថយចុះមក ៥៣២ និងសាលារៀនជួបការលំបាក ៥៨ ក្នុងឆ្នាំសិក្សា ២០១៧-២០១៨។ របាយការណ៍សន្និបាតអប់រំបានបង្ហាញថា ចំនួនសិស្សចូលរៀនតាមអាយុកំណត់បានកើនឡើង ដោយសារមាតាបិតាឱ្យតម្លៃដល់ការអប់រំ ហើយសាលារៀនបានខិតជិតលំនៅដ្ឋានរបស់ពួកគេ និងមានបរិស្ថានជាទីមេត្រី ជាពិសេសនៅតំបន់ដាច់ស្រយាល និងជួបការលំបាក។

ប្រសិទ្ធភាពផ្ទៃក្នុងនៅកម្រិតបឋមសិក្សាបានបង្ហាញឱ្យឃើញតាមរយៈអត្រាបោះបង់ការសិក្សា និងអត្រាត្រួតថ្នាក់ គឺមានភាពប្រសើរឡើងផងដែរក្នុងរយៈពេល ៥ឆ្នាំកន្លងមក ថ្វីបើ ការបោះបង់ការសិក្សានៅមានច្រើននៅថ្នាក់ទី៦។

ក្រសួងបានពង្រឹងវិធីសាស្ត្របង្រៀននិងរៀន តាមការផ្សព្វផ្សាយវីដេអូវិធីសាស្ត្របង្រៀនភាសាខ្មែរថ្នាក់ដំបូងទី១ ទី២ និងទី៣ ផ្សព្វផ្សាយស្តង់ដាអំណានដល់គ្រូថ្នាក់ទី១ ទី២ ទី៣ ដល់នាយកសាលា និងក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ បំប៉នសមត្ថភាពស្តីពីវិធីសាស្ត្របង្រៀនភាសាខ្មែរថ្នាក់ទី១ ទី២ និងទី៣ បំប៉នវិធីសាស្ត្របង្រៀនសិស្សមជ្ឈមណ្ឌល និងវិធីសាស្ត្រដទៃទៀត។

បន្ទាប់ពីអនុវត្តការវាយតម្លៃអំណាននៅកម្រិតថ្នាក់ដំបូង កម្ពុជាបានសាកល្បង និងរៀបចំការវាយតម្លៃគណិតវិទ្យានៅកម្រិតថ្នាក់ដំបូង ដែលជាផ្នែកមួយនៃការវាយតម្លៃថ្នាក់ជាតិ។ កម្ពុជាបានរៀបចំការវាយតម្លៃគណិតវិទ្យានៅកម្រិតថ្នាក់ដំបូងនៅឆ្នាំ២០១៥ ដែលលទ្ធផលបានបង្ហាញថាសិស្សថ្នាក់ទី១ ទី២ និងទី៣នៅខ្វះទស្សនៈយល់ដឹងពីខ្លឹមសារនៃគណិតវិទ្យា ប៉ុន្តែពួកគេពូកែខាងឆ្លើយសំណួរទាក់ទងនឹងនីតិវិធីដោះស្រាយលំហាត់។ សិស្សខ្វះនូវទស្សនៈយល់ដឹងពីខ្លឹមសារ ដែលធ្វើឱ្យការសិក្សារបស់ពួកគេនៅថ្នាក់ទី៦ នៅមានកម្រិតទាប ជាពិសេស ការគណនាប្រភាគ ទសភាគ ភាគរយ និងធរណីមាត្រ។ ជារួម ជំនាញមូលដ្ឋាននៅថ្នាក់ដំបូងលើគណិតវិទ្យាគឺត្រូវការចាំបាច់ ដើម្បីពង្រឹងការអប់រំផ្នែកគណិតវិទ្យាដល់សិស្ស។ បញ្ហាប្រឈមមួយចំនួនគឺ គ្រូមិនបង្រៀនតាមកិច្ចតែងការបង្រៀន ពុំមានសម្ភាររៀន និងបង្រៀនគ្រប់គ្រាន់សម្រាប់គ្រូនិងសិស្ស និងមិនមានសកម្មភាពការសិក្សាតាមបែបស្វាបស្ទង់ និងបែបរិះរក។

បញ្ហានៃការចូលរៀននៅបឋមសិក្សា ជាប់ទាក់ទងនឹងកុមារលើសអាយុដែលបោះបង់ការសិក្សារួមទាំងខ្វះសាលារៀនគ្រប់កម្រិតនៅក្នុងស្រុកមួយចំនួន សមត្ថភាពអំណាន សំណេរ និង គណិតវិទ្យានៅកម្រិតថ្នាក់ដំបូង។ ជាភាពចាំបាច់ ក្រសួងត្រូវពង្រឹងការគ្រប់គ្រងថ្នាក់រៀន ដំណើរការបង្រៀន និងរៀន ការផ្តល់សម្ភារឧបទេស ការលើកកម្ពស់សមត្ថភាពគ្រូបង្រៀន ការបង្កើនការចូលរួមកាន់តែច្រើនពីអ្នកពាក់ព័ន្ធនៅក្នុងដំណើរការសាលារៀន និងផ្តល់អាទិភាពគាំទ្របន្ថែមដល់សិស្សលើការអាន និងសរសេរនៅគ្រប់

កម្រិតថ្នាក់នៃបឋមសិក្សា។ល។ លើសពីនេះ ក្រសួងត្រូវផ្តោតការយកចិត្តទុកដាក់បន្ថែមលើការបង្កើនការចូលរៀននៅបឋមសិក្សា និងមត្តេយ្យសិក្សានៅតាមរាជធានី ខេត្តដែលមានការចុះឈ្មោះចូលរៀនទាប។

### *ការវាយតម្លៃអំពីវឌ្ឍនភាពនៃការសម្រេចវត្ថុបំណងគោលនយោបាយទី២*

ឆ្លើយតបនឹងវត្ថុបំណងគោលនយោបាយទី២ ក្រសួងបានផ្សព្វផ្សាយ និងអនុវត្តការគ្រប់គ្រងតាមសាលារៀនដែលមាន ៤ផ្នែក ៖ ១) ការគ្រប់គ្រងរដ្ឋបាលសាលារៀន ២) ការងាររៀន-បង្រៀន និងការអនុវត្តកម្មវិធីសិក្សា ៣) ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន និងការងារអធិការកិច្ច ៤) ការរៀបចំផែនការអភិវឌ្ឍសាលារៀន និងការគ្រប់គ្រងថវិកាសាលារៀន។

ជារួម អនុវិស័យបឋមសិក្សាសម្រេចបានការចូលរៀននៅបឋមសិក្សាមានកម្រិតខ្ពស់ ក៏ប៉ុន្តែ ត្រូវធ្វើឱ្យប្រសើរឡើងថែមទៀត ចំពោះក្រុមកុមារក្នុងវ័យសិក្សាដែលមិនទាន់បានចូលរៀន ដោយត្រូវកំណត់អត្តសញ្ញាណក្រុមទាំងនោះដូចជា កុមារមានពិការភាព កុមារតំបន់ជនបទ តំបន់ដាច់ស្រយាល ឬ កុមារមានគ្រួសារអន្តោប្រវេសន៍។ ក្រៅពីនេះ តាមរយៈការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សបានបង្ហាញថាសិស្សមិនបានរៀនពេញលេញ សិស្សមានការលំបាក នៅពេលចាប់ផ្តើមថ្នាក់ដំបូង និងចំនួនសមាមាត្រកុមារដែលទទួលបានបំណិនជាមូលដ្ឋានក្នុងការអាន ការសរសេរ និងការគិត នៅមានគម្លាតនៅឡើយ។ ដូចនេះ ត្រូវផ្តោតជាសំខាន់លើការលើកកម្ពស់គុណភាពអប់រំ (កែលម្អការបណ្តុះបណ្តាលគ្រូបង្រៀន និងពង្រាយគ្រូបង្រៀនទៅកន្លែងខ្វះគ្រូ ធានាការផ្គត់ផ្គង់សៀវភៅសិក្សាគោលឱ្យបានគ្រប់គ្រាន់) និងការប្រើប្រាស់លទ្ធផលនៃការវាយតម្លៃនេះ ដើម្បីកែលម្អការសិក្សារបស់សិស្ស។

### ១.២.៣ អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស

### *ការវាយតម្លៃអំពីវឌ្ឍនភាពនៃការសម្រេចវត្ថុបំណងគោលនយោបាយទី ១*

ការចូលរៀននៅមធ្យមសិក្សាបឋមភូមិ មានភាពប្រសើរឡើងដោយអត្រារួមនៃការសិក្សាកើន ៣,៥ ភាគរយ ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ ហើយអត្រានេះបានកើនដល់ ៥៦,៨ ភាគរយ នៅឆ្នាំសិក្សា ២០១៧-២០១៨(ចំណុចដៅ ៥៤,៦ ភាគរយ)។ អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ កើន ២,៥ ភាគរយ និងអត្រានេះសម្រេចបាន ២៨,៥ ភាគរយ ក្នុងឆ្នាំសិក្សា ២០១៧-២០១៨ លើសចំណុចដៅ (ចំណុចដៅ ២៧,៧ ភាគរយ)។

អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិបានថយចុះគួរឱ្យកត់សម្គាល់ពី ២១,២ ភាគរយ មក ១៥,៤ ភាគរយ ប៉ុន្តែអត្រានេះនៅខ្ពស់នៅឡើយ បណ្តាលមកពីសាលារៀននៅឆ្ងាយពីផ្ទះ កង្វះគ្រូដែលមានសមត្ថភាព សៀវភៅសិក្សាគោល វិធីសាស្ត្របង្រៀន និងអាហាររូបករណ៍ ដូចជា កម្មវិធីប្រឹក្សាអាជីព និងការដាក់ឱ្យអនុវត្តកម្មវិធីប្រព័ន្ធរំលឹកជាមុន និងកម្មវិធីទប់ស្កាត់ការបោះបង់ការសិក្សា (កំណត់អត្តសញ្ញាណសិស្សរៀនយឺត ការបង្រៀនបំប៉នបន្ថែម ការតាមដានការសិក្សារបស់សិស្ស និងការជួយសិស្សរៀនយឺត សិស្សប្រឈមនឹងការបោះបង់ការសិក្សា)។ អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិនៅតែខ្ពស់ ដែលនៅឆ្នាំសិក្សា២០១៧-២០១៨ មាន ១៨,៣ ភាគរយ។ អត្រាបោះបង់ការសិក្សាខ្ពស់នៅ

តំបន់ជនបទ ដោយសារសិស្សត្រូវបង្ខំចិត្តបោះបង់ការសិក្សាដើម្បីជួយរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារបន្ថែម។ ការបោះបង់ការសិក្សាអាចបណ្តាលមកពីការផ្តល់សេវាអប់រំមិនគ្រប់គ្រាន់នៅតំបន់ជនបទនិងដាច់ស្រយាល។

អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិមានកម្រិតទាប ពីព្រោះទីតាំងសាលាមធ្យមសិក្សាបឋមភូមិ និងបឋមសិក្សានៅឆ្ងាយពីគ្នា។

ចំនួនសិស្សវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសបានកើនឡើងជាបន្តបន្ទាប់ តាមរយៈកម្មវិធីផ្តល់អាហារូបករណ៍ អន្តរាវិសិកដ្ឋានសម្រាប់សិស្ស និងពង្រឹងការផ្សព្វផ្សាយការយល់ដឹងពីសារៈសំខាន់ និងតម្លៃនៃការអប់រំបច្ចេកទេស។

ការធ្វើតេស្តវាយតម្លៃថ្នាក់ជាតិថ្នាក់ទី៨ រវាងឆ្នាំ២០១៤ និង២០១៧ បានបង្ហាញថា លទ្ធផលតេស្តនៃការសរសេរមានការប្រែប្រួលខ្លាំងកើនឡើង ៩ ភាគរយ នៅកម្រិតមូលដ្ឋាន ក៏ប៉ុន្តែ ៧១ ភាគរយនៃសិស្សដែលបានធ្វើតេស្តការសរសេរស្ថិតនៅក្រោមកម្រិតក្រោមមូលដ្ឋាន និងមិនមានការប្រែប្រួលខ្លាំងក្នុងកម្រិតស្ទាត់ជំនាញនិងកម្រិតខ្ពស់ទេ។ ចំណែកតេស្តអំណានវិញ លទ្ធផលសិស្សមានការថយចុះ ១០ ភាគរយនៅកម្រិតខ្ពស់ និងកើនឡើង៧ ភាគរយនៅកម្រិតក្រោមមូលដ្ឋាន។ លទ្ធផលនៃវាយតម្លៃតេស្តលើមុខវិជ្ជាគណិតវិទ្យាមិនមានការប្រែប្រួលគួរឱ្យកត់សម្គាល់រវាងឆ្នាំ២០១៤ និង២០១៧ទេ ប៉ុន្តែជាការពិតសិស្សដែលបានចូលរួមធ្វើតេស្តជាង ៨០ ភាគរយ គឺស្ថិតនៅកម្រិតមូលដ្ឋាន និងក្រោមមូលដ្ឋាន។ លទ្ធផលនៃវាយតម្លៃតេស្តលើមុខវិជ្ជារូបវិទ្យាក៏មិនសូវមានការប្រែប្រួលផងដែរ ហើយភាគរយនៃសិស្សដែលស្ថិតនៅត្រឹមនិងក្រោមកម្រិតមូលដ្ឋានមានការកើនឡើងខ្ពស់ជាង ៨០ ភាគរយផងដែរ។

ក្រសួងអប់រំ យុវជន និងកីឡាបានអនុម័តក្របខណ្ឌកម្មវិធីសិក្សានៅឆ្នាំ២០១៦ និងកម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជា គ្រប់ភូមិសិក្សានៅឆ្នាំ២០១៨ ដែលផ្តោតលើបញ្ញត្តិ និងគោលវិធីសិស្សមជ្ឈមណ្ឌលដោយប្រើវិធីសាស្ត្របង្រៀនតាមបែបរិះរក និងវិធីសាស្ត្រផ្សេងៗទៀត។ កម្មវិធីសិក្សាលម្អិតនេះចែកជាបីភូមិសិក្សាដាច់ដោយឡែកពីគ្នា តែប្រទាក់ក្រឡា និងគាំទ្រគ្នាពីភូមិសិក្សាមួយទៅភូមិសិក្សាមួយទៀត ពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយទៀតនិងភាពឆ្លើយតបនៃកម្មវិធីសិក្សាពីមធ្យមសិក្សាទៅឧត្តមសិក្សា។ ម៉ោងសិក្សាប្រចាំឆ្នាំនៅកម្រិតមត្តេយ្យសិក្សាមាន ១ ០៥០ ម៉ោង (៣០ម៉ោងក្នុងមួយសប្តាហ៍) កម្រិតបឋមសិក្សាមាន ១ ០៥០ ម៉ោង (៣០ម៉ោងក្នុងមួយសប្តាហ៍) កម្រិតមធ្យមសិក្សាបឋមភូមិមាន ១ ៤០០ ម៉ោង (៤០ម៉ោងក្នុងមួយសប្តាហ៍) និងកម្រិតមធ្យមសិក្សាទុតិយភូមិមាន ១ ៤០០ម៉ោង (៤០ម៉ោងក្នុងមួយសប្តាហ៍)។ មុខវិជ្ជាមួយចំនួនត្រូវបានកែសម្រួលបញ្ចូល និងបំបែកដូចជាមុខវិជ្ជា បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានភាសាបរទេស បំណិនជីវិតតាមមូលដ្ឋាន និងមុខវិជ្ជាអប់រំសុខភាព ជាពិសេសការលើកកម្ពស់មុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។ ការកែទម្រង់កម្មវិធីសិក្សាទាំងបីកម្រិតសំដៅបណ្តុះ-បណ្តាលបុគ្គលិកលក្ខណៈពេញលេញរបស់អ្នកសិក្សាលើផ្នែករាងកាយ បញ្ញា សីលធម៌ តម្លៃ និងបំណិនមូលដ្ឋានសម្រាប់ការអប់រំនៅកម្រិតបន្ត ដើម្បីឱ្យក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក។

ទោះបីជាវឌ្ឍនភាពនៃការចូលរៀននៅមធ្យមសិក្សាសម្រេចតាមចំណុចដៅក៏ដោយ ក្រសួងត្រូវយកចិត្តទុកដាក់បន្ថែមទៀតលើការកាត់បន្ថយការបោះបង់ការសិក្សាដែលសម្រេចបានតិចតួច និងកំណត់ក្រុមមុខសញ្ញា ទីតាំងភូមិសាស្ត្រ មូលហេតុចម្បងៗដែលនាំឱ្យសិស្សមិនអាចបន្តការសិក្សា ព្រមទាំងដាក់ចេញនូវយុទ្ធសាស្ត្រសមស្របដើម្បីជួយឱ្យពួកគេបន្តការសិក្សាទៅមុខទៀត។ យុទ្ធសាស្ត្រ ឬ អន្តរាគមន៍នានាត្រូវបង្កើនបន្ថែមទៀត ដូចជា កម្មវិធីផ្តល់អាហារូបករណ៍ កម្មវិធីប្រព័ន្ធរំលឹកជាមុន ដើម្បីទប់ស្កាត់ការបោះបង់ការសិក្សា ការអនុវត្តការគ្រប់គ្រងសាលារៀន ក៏ដូចជាការគ្រប់គ្រងថ្នាក់រៀននិងការអនុវត្តកម្មវិធីសិក្សា ព្រមទាំងជំរុញឱ្យសិស្សរៀនសូត្រកាន់តែយ៉ាងសកម្មក្នុងថ្នាក់រៀន។

### *ការវាយតម្លៃអំពីវឌ្ឍនភាពនៃការសម្រេចវត្ថុបំណងគោលនយោបាយទី ២*

ក្រសួងបាននិងកំពុងពង្រឹងប្រព័ន្ធគ្រប់គ្រង និងពិនិត្យតាមដានផ្អែកលើលទ្ធផល តាមរយៈការពិនិត្យតាមដានការអនុវត្តកម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រ ពិនិត្យតាមដានការគ្រប់គ្រងការបង្រៀន និងការរៀន ពង្រឹងសមត្ថភាពរបស់គ្រូឧទ្ទេសថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិស្តីពីការប្រើប្រាស់ឯកសារស្តីពីគណៈកម្មការទ្រទ្រង់សាលា និងកម្រងសាលាមធ្យមសិក្សា ការប្រើប្រាស់និងប្រតិបត្តិការសាលាធនធាន ៣៦ នៅក្នុង ២៥ រាជធានី-ខេត្ត។

ជារួម អនុវិស័យនេះមានការរីកចម្រើនទាំងការចូលរៀន គុណភាពអប់រំ និងដំណើរការដឹកនាំគ្រប់គ្រងអនុវិស័យ។ ទោះជាយ៉ាងណា ត្រូវបង្កើនការចូលរៀន និងការបន្តការសិក្សារបស់សិស្សដោយត្រូវកំណត់អត្តសញ្ញាណក្រុមដែលងាយបោះបង់ការសិក្សានៅមធ្យមសិក្សា និងមូលហេតុពាក់ព័ន្ធ ព្រមទាំងរៀបចំយុទ្ធសាស្ត្រប្រកបដោយភាពស័ក្តិសិទ្ធ រួមមានការពិនិត្យឡើងវិញកម្មវិធីផ្តល់អាហារូបករណ៍ ការពង្រឹងការបង្រៀននិងរៀន ការរិះរកវិធីសាស្ត្របង្រៀនបែបថ្មី និងការផ្គត់ផ្គង់សម្ភារសិក្សាឱ្យបានគ្រប់គ្រាន់។ ចំពោះការអប់រំបច្ចេកទេស ត្រូវយកចិត្តទុកដាក់លើការផ្តល់សេវាប្រឹក្សាអាជីព តម្រង់ទិសការសិក្សា ការបង្កើតរោងជាង ការផ្តល់សម្ភារបរិក្ខារ កម្មវិធីហាត់ការ និងកិច្ចសហការជាមួយសហគ្រាស។

## ១.២.៤ អនុវិស័យ ការអប់រំឧត្តមសិក្សា

### *ការវាយតម្លៃអំពីវឌ្ឍនភាពនៃការសម្រេចវត្ថុបំណងគោលនយោបាយទី១*

ការចូលរៀននៅឧត្តមសិក្សាមានស្ថានភាពមិនសូវប្រែប្រួល ដោយអត្រារួមនៃការសិក្សា (១៨-២២ឆ្នាំ) ស្ថិតក្នុងរង្វង់ ១១ ភាគរយ ធៀបនឹងចំណុចដៅ ១៦ ភាគរយ។ ក្រសួងបានជំរុញ និងបង្កើនការចូលរៀនផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (ស្ទែម)នៅឧត្តមសិក្សាតាមរយៈការលើកទឹកចិត្ត និងគាំទ្រការបង្កើតកម្មវិធីបណ្តុះបណ្តាលថ្មី និងគ្រឹះស្ថានឧត្តមសិក្សាថ្មី។ ចំនួននិស្សិតចូលរៀនបរិញ្ញាបត្រផ្នែកស្ទែមបានកើនពី ១៩,៦ ភាគរយ ដល់ ២៧,១ ភាគរយ និងគ្រឹះស្ថានឧត្តមសិក្សាបង្កើតថ្មីដែលផ្តល់ការបណ្តុះបណ្តាលលើមុខជំនាញផ្នែកស្ទែមមាន ៩ ក្នុងនោះ គ្រឹះស្ថានឧត្តមសិក្សារដ្ឋ ៤ (វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ សាកលវិទ្យាល័យក្រចេះ និងសាកលវិទ្យាល័យ **ហេង សំរិន**

ត្បូងឃ្មុំ) និងឯកជន ៥ (សាកលវិទ្យាល័យវិទ្យាសាស្ត្រ វិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ វិទ្យាស្ថានអន្តរជាតិបាជាយ វិទ្យាស្ថានកម្ពុជាបច្ចេកវិទ្យាជប៉ុន និងវិទ្យាស្ថានកសិកម្ម ឧកញ៉ា ម៉ុង ឬទ្ធី)។

ទន្ទឹមនឹងនេះ ហេដ្ឋារចនាសម្ព័ន្ធត្រូវបានវិនិយោគបន្ថែមដូចជា ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារទេពកោសល្យវិស្វកម្ម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងអាគារវិទ្យាសាស្ត្រ មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "**តេជោ**" នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ក្រសួងបានលើកកម្ពស់វប្បធម៌ស្រាវជ្រាវនៅឧត្តមសិក្សា និងបានអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ និងនវានុវត្តន៍ដល់គ្រឹះស្ថានឧត្តមសិក្សា តាមរយៈការផ្តល់មូលនិធិស្រាវជ្រាវ និងកាលានុវត្តភាពកសាងសមត្ថភាព ដោយបានប្រគល់គម្រោងស្រាវជ្រាវចំនួន ៤៥ ជូនគ្រឹះស្ថានឧត្តមសិក្សា ២៤។ ទន្ទឹមនឹងនេះ ក្រសួងក៏បានរៀបចំវេទិកាអ្នកស្រាវជ្រាវ ការបង្ហាញវិស័យអាទិភាពក្នុងការស្រាវជ្រាវឆ្នាំ ២០១៥-២០១៨ និងវេទិកាស្រាវជ្រាវអប់រំកម្ពុជា។ គ្រឹះស្ថានឧត្តមសិក្សាមានសមត្ថភាពក្នុងការទទួលបានគម្រោងស្រាវជ្រាវនានា ដោយសហការជាមួយសាកលវិទ្យាល័យដៃគូនៅបរទេស ក៏ដូចជាក្នុងក្របខណ្ឌអេរ៉ាស្មូសផ្លើសរបស់សហភាពអឺរ៉ុប។

*ការវាយតម្លៃអំពីវឌ្ឍនភាពនៃការសម្រេចគុបំណងគោលនយោបាយទី ២*

ការលើកកម្ពស់អភិបាលកិច្ចនៅគ្រឹះស្ថានឧត្តមសិក្សា ក្រសួងបានបន្តអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា ប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា និងតាមដានការផ្សាយពាណិជ្ជកម្មនៅគ្រឹះស្ថានឧត្តមសិក្សា។

អនុវិស័យឧត្តមសិក្សាត្រូវយកចិត្តទុកដាក់ពង្រឹងយន្តការធានាគុណភាពផ្ទៃក្នុង និងខាងក្រៅ។ និស្សិតត្រូវបានលើកទឹកចិត្ត និងតម្រង់ទិសឱ្យជ្រើសរើសសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យាដែលជាមុខវិជ្ជាអាទិភាពឆ្លើយតបនឹងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា និងជំរុញការងារស្រាវជ្រាវតាមគ្រឹះស្ថានឧត្តមសិក្សា។

## ១.២.៥ អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ

*ការវាយតម្លៃវឌ្ឍនភាពនៃការសម្រេចវត្ថុបំណងគោលនយោបាយទី១*

អត្រាអក្ខរកម្មមនុស្សពេញវ័យ (អាយុ ១៥ឆ្នាំឡើង) បានកើនពី ៧៨,១ ភាគរយ ឆ្នាំ២០១៤ ដល់ ៨២,៥ ភាគរយ ឆ្នាំ២០១៧។ លទ្ធផលនេះទទួលបានពីកិច្ចប្រឹងប្រែងពីក្រសួង ដៃអភិវឌ្ឍ និងអ្នកពាក់ព័ន្ធតាមរយៈយុទ្ធនាការអក្ខរកម្មជាតិនៅឆ្នាំ២០១៥។

ដំណាក់កាលថ្មីនៃការអភិវឌ្ឍអនុវិស័យអប់រំក្រៅប្រព័ន្ធ គឺផ្តោតលើការសិក្សាពេញមួយជីវិតតាមរយៈការអនុវត្តគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិតក្នុងគោលបំណងផ្តល់ឱកាស និងគាំទ្រឱ្យប្រជាជនគ្រប់រូបទទួលបានការសិក្សាតាមគ្រប់រូបភាព និងប្រើប្រាស់ចំណេះដឹងតាមជំនាញដែលទទួលបានដើម្បីបង្កើនប្រសិទ្ធភាព គុណភាព ផលិតភាពការងារ និងប្រាក់ចំណូលស្របតាមយុគសម័យបច្ចេកវិទ្យា

ព័ត៌មាន និងសង្គមពុទ្ធិ។ ក្នុងន័យនេះ ក្រសួងមានផែនការប្រែក្លាយមជ្ឈមណ្ឌលសិក្សាមួយចំនួនដូចជាមជ្ឈមណ្ឌលសិក្សានៅតាមពេងចក្រ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ឱ្យទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត។

*ការវាយតម្លៃវឌ្ឍនភាពនៃការសម្រេចវត្ថុបំណងគោលនយោបាយទី២*

រាជធានី ខេត្តទាំងអស់បានរៀបចំប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធក្នុងឆ្នាំ២០១៥។ វឌ្ឍនភាពនៃការរៀបចំប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ គួរឱ្យកត់សម្គាល់ពីព្រោះបានសម្រេចលើសចំណុចដៅក្នុងឆ្នាំ២០១៤ និងឆ្នាំ២០១៥។

ជារួម អនុវិស័យនេះ មានវឌ្ឍនភាពអាចទទួលយកបាននៅគ្រប់កម្មវិធីអប់រំក្រៅប្រព័ន្ធទាំងអស់។ ជាជំហានបន្ត ត្រូវប្រែក្លាយមជ្ឈមណ្ឌលសិក្សាសហគមន៍ទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត និងសហការជាមួយសហគ្រាស ពេងចក្រ និងវិស័យឯកជនក្នុងការបន្តអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ។

### ១.២.៦ អនុវិស័យ ការអភិវឌ្ឍយុវជន

*ការវាយតម្លៃវឌ្ឍនភាពនៃការសម្រេចវត្ថុបំណងគោលនយោបាយទី១*

ការអភិវឌ្ឍយុវជនកម្ពុជាក៏កាន់តែមានភាពសកម្ម តាមរយៈការទទួលបាននូវអន្តរាគមន៍ និងការគាំទ្រនានាពីគ្រប់អ្នកពាក់ព័ន្ធ ដូចជាដំណើរការរបស់ក្រុមប្រឹក្សាកុមារនិងក្រុមប្រឹក្សាយុវជន យុវជនស្ម័គ្រចិត្ត យុវជនកាកបាទក្រហម និងយុវជនកាយរឹទ្ធិ ព្រមទាំងទទួលបានការផ្ដល់ជំនាញបច្ចេកទេសនិងជំនាញទន់ ការផ្ដល់ព័ត៌មាន ទីផ្សារការងារ ការប្រឹក្សាអាជីព និងការតម្រង់ទិសសិក្សា។

ទោះជាយ៉ាងណា ក្រសួងនៅតែប្រឈមលើការគ្រប់គ្រងមជ្ឈមណ្ឌលយុវជននៅតាមរាជធានី-ខេត្ត និងការផ្ដល់ហេដ្ឋារចនាសម្ព័ន្ធសមស្រប ដែលជាមូលហេតុធ្វើឱ្យចំនួនយុវជនទទួលការបណ្ដុះបណ្ដាលបានថយចុះ និងកម្មវិធីបណ្ដុះបណ្ដាលគួរតែកែលម្អ និងផ្សារភ្ជាប់ជាមួយតម្រូវការទីផ្សារការងារ។

*ការវាយតម្លៃវឌ្ឍនភាពនៃការសម្រេចវត្ថុបំណងគោលនយោបាយទី ២*

រាជរដ្ឋាភិបាលបានអនុម័តគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិ ស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា។ ក្រសួងបានកសាងឯកសារក្របខណ្ឌអភិវឌ្ឍយុវជនថ្នាក់ក្រោមជាតិ ឯកសារសេវាកម្មយុវជនជាតិ ឯកសារគ្រប់គ្រងហានិភ័យក្នុងការអនុវត្ត ស្ដីពីការអភិវឌ្ឍយុវជនកម្ពុជា សេចក្ដីព្រាងគោល-នយោបាយសហគ្រិនភាព និងឯកសារតាមដាន ត្រួតពិនិត្យតាមដាន និងវាយតម្លៃ។

ជារួម អនុវិស័យនេះមានវឌ្ឍនភាពក្នុងការអភិវឌ្ឍក្របខណ្ឌគោលនយោបាយ ការកែលម្អរចនាសម្ព័ន្ធក្រុមប្រឹក្សាកុមារនិងយុវជន ការបង្កើតក្លឹបសិក្សា ការងារស្ម័គ្រចិត្ត ការបណ្ដុះបណ្ដាលជំនាញរឹងនិងទន់ និងការផ្ដល់ប្រឹក្សាអាជីព។ ការរៀបចំយន្តការការអនុវត្តនិងការបង្កើនប្រសិទ្ធភាពការបំពេញការងាររបស់ក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍយុវជន តាមរយៈផែនការសកម្មភាពជាតិសម្រាប់ការអភិវឌ្ឍយុវជន គឺជាអាទិភាព។

### ១.២.៧ អនុវិស័យ ការអប់រំកាយ និងកីឡា

*ការវាយតម្លៃវឌ្ឍនភាពនៃការសម្រេចវត្ថុបំណងគោលនយោបាយទី១*

កំណែទម្រង់អប់រំកាយ និងកីឡាបានលើកកម្ពស់កិត្តិស័ព្ទនិងកិត្តិនាមរបស់កីឡាល្បីៗ ដែលបានទទួលមេដាយមាសពីការប្រកួតកីឡាអាស៊ីហ្គេមលើកទី១៧ នៅសាធារណរដ្ឋកូរ៉េ មេដាយមាសក្នុងការប្រកួតកីឡាប៉េតង់ជើងឯកពិភពលោក និងមេដាយក្នុងការប្រកួតកីឡាផ្សេងទៀតជាច្រើនផងដែរ។ សមិទ្ធផលកីឡាយ៉ាងច្រើនក្នុងការប្រកួតកីឡា ដូចជាការប្រកួតកីឡាជើងឯកកម្រិតតំបន់ ទ្វីប និងពិភពលោកក្នុងការដណ្តើមយកឧត្តមភាពកីឡា និងកិត្យានុភាពជាតិ។

ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើកំណែទម្រង់អនុវិស័យអប់រំកាយ និងកីឡា ដោយប្តូរពីការប្រកួតកីឡាជ្រើសរើសជើងឯកតាមភូមិភាគ និងជើងឯកប្រចាំឆ្នាំមករៀបចំការប្រកួតកីឡាជាតិជាលក្ខណៈហ្គេមស្របតាមស្តង់ដាការប្រកួតកីឡា ក្នុងតំបន់បានចំនួន២លើក។ ក្រសួងបានលើកកម្ពស់សមត្ថភាពកីឡាករ តាមរយៈការប្រមូលផ្តុំក្រុមកីឡាថ្នាល និងក្រុមកីឡាជម្រើសជាតិ ព្រមទាំងបានធ្វើវិសោធនកម្មអនុក្រឹត្យ និងប្រកាសអន្តរក្រសួងស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភ ប្រាក់អាហារូបត្ថម្ភ និងប្រាក់រង្វាន់ជ័យលាភីដល់គ្រូបង្វឹក គ្រូជំនួយ កីឡាករ កីឡាការិនីបង្កើនដល់កម្រិតទ្វេរដង។ ការប្រកួតកីឡាអាស៊ីហ្គេមលើកទី១៧ ទទួលបានមេដាយមាស០១គ្រឿង ការប្រកួតកីឡាអាស៊ីហ្គេមលើកទី១៨ កម្ពុជាទទួលបានមេដាយមាស ០២គ្រឿង និងសំរឹទ្ធ០១គ្រឿង។ ការប្រកួតជើងឯកពិភពលោកប៉េតង់ កីឡាការិនីទទួលបានមេដាយមាស ៣ដងជាប់គ្នា។

*ការវាយតម្លៃវឌ្ឍនភាពនៃការសម្រេចវត្ថុបំណងគោលនយោបាយទី ២*

ក្រសួងបានធ្វើកំណែទម្រង់អប់រំកាយនិងកីឡា ទាំងក្នុងក្របខណ្ឌគោលនយោបាយ និងក្របខណ្ឌបច្ចេកទេស ព្រមទាំងការអនុវត្តជាក់ស្តែង ដើម្បីឱ្យមាតាបិតា អាណាព្យាបាល សាធារណជន មានជំនឿទុកចិត្ត គាំទ្រ និងចូលរួមលេងកីឡា។ ក្រសួងបានរៀបចំកែលម្អកម្មវិធីសិក្សាអប់រំកាយ និងកីឡាបែបថ្មីសម្រាប់គ្រឹះស្ថានបឋមសិក្សា និងមធ្យមសិក្សា និងបានកែលម្អកម្មវិធី និងលើកកម្ពស់ការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំកាយ និងកីឡាដល់កម្រិតបរិញ្ញាបត្រ។

ជារួម អនុវិស័យអប់រំការយនិងកីឡាមានវឌ្ឍនភាពដូចជា ការជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធកីឡាគ្រប់ប្រភេទទាំងនៅតាមគ្រឹះស្ថានសិក្សា រាជធានី ខេត្ត និងថ្នាក់ជាតិសម្រាប់ធ្វើសកម្មភាពអប់រំកាយបែបថ្មីតាមសាលារៀន ហាត់ហ្វឹកហ្វឺនកីឡា និងប្រកួតកីឡា ព្រមទាំងអភិវឌ្ឍធនធានមនុស្ស ដើម្បីចូលរួមនិងរៀបចំការប្រកួតកីឡាទាំងកម្រិតពិភពលោក ទ្វីប តំបន់ និងថ្នាក់ជាតិ។ ដើម្បីពន្លឿនការអភិវឌ្ឍសហព័ន្ធកីឡាជាតិ ក្រសួងបានធ្វើប្រតិភូកម្មមុខងារ និងគាំទ្រថវិកាកីឡាជាតិដែលមាននៅក្នុងកម្មវិធីប្រកួតកីឡាស៊ីហ្គេមឆ្នាំ២០២៣។ ប្រការនេះ អនុវិស័យអប់រំកាយនិងកីឡា ត្រូវយកចិត្តទុកដាក់លើការធ្វើកំណែទម្រង់ការប្រកួតកីឡា ដូចជា ការរៀបចំយន្តការអនុវត្តផែនការគោលនៃការអភិវឌ្ឍកីឡាឆ្ពោះទៅការប្រកួតកីឡាស៊ីហ្គេមឆ្នាំ២០២៣។

## ១.៣ វឌ្ឍនភាពនៃការអនុវត្តអាទិភាពកំណែទម្រង់វិស័យអប់រំក្នុងក្របខណ្ឌសសរស្តម្ភទាំង៥

នៅឆ្នាំ ២០១៤ ក្រសួងបានដាក់ចេញវិធានកំណែទម្រង់ ៨ ចំណុច និងសម្រេចបានលទ្ធផលធំៗ ដូចជា ការផ្ទេរការទទួលខុសត្រូវការប្រឡងថ្នាក់ទី ៩ ដល់ថ្នាក់ក្រោមជាតិ និងការចាប់ផ្តើមរឹតបន្តឹងការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និងផ្តល់លទ្ធភាពដល់បេក្ខជនប្រឡង ២ ដង ដែលលើកទី ១ បេក្ខជនប្រឡងជាប់ ២៥,៧ ភាគរយ និងលើកទី ២ ជាប់បាន ១៧,៩ ភាគរយ។ ក្រសួងបានរៀបចំនិងទទួលការអនុម័តពីរាជរដ្ឋាភិបាលនូវគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិស្តីពីការគាំពារនិងអភិវឌ្ឍន៍កុមារតូច។ ក្រសួងបានសន្សំថវិកាពីការងារលទ្ធកម្ម និងបានស្នើដំឡើងបៀវត្សបុគ្គលិកអប់រំ ពន្លឿនការបើកផ្តល់និងចាប់ផ្តើមការបើកផ្តល់បៀវត្សដល់បុគ្គលិកអប់រំតាមប្រព័ន្ធធនាគារ។ នៅឧត្តមសិក្សា ក្រសួងបានផ្ទេរសិទ្ធិឱ្យគ្រឹះស្ថានឧត្តមសិក្សាទទួលខុសត្រូវក្នុងការចេញសញ្ញាបត្រ។ ក្រសួងបានដំឡើងថវិកាដំណើរការសាលារៀននៅគ្រប់កម្រិត និងថវិកាអប់រំបានកើនដល់ ១៧ ភាគរយនៃថវិកាចរន្តរបស់ជាតិ។ ក្នុងវិស័យកីឡា ក្រសួងបានអនុម័តគោលនយោបាយស្តីពីការអប់រំកាយ និងកីឡា បង្កើនប្រាក់រង្វាន់សម្រាប់ជ័យលាភី និងបង្កើតគណៈកម្មការគ្រប់គ្រងពហុកីឡដ្ឋានជាតិអូឡាំពិក ព្រមទាំងចាប់ផ្តើមអភិវឌ្ឍហេដ្ឋា-រចនាសម្ព័ន្ធរបស់ពហុកីឡដ្ឋានជាតិអូឡាំពិក។

ក្នុងចំណោមកំណែទម្រង់អាទិភាពដែលបានដាក់ចេញ កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមានលទ្ធផលល្អប្រសើរ និងបានជះផលទៅលើការអនុវត្តកំណែទម្រង់ដទៃទៀតដូចជា កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ និងការបង្កើនប្រសិទ្ធផលរបស់បុគ្គលិកអប់រំ។ល។

កត្តាចម្បងដែលវឌ្ឍនភាពរបស់វិស័យអប់រំ យុវជន និងកីឡាមានការកើនឡើងយ៉ាងឆាប់រហ័សនេះ គឺការវិភាជន៍ធនធានកាន់តែច្រើនពីសំណាក់រាជរដ្ឋាភិបាល ក្នុងនោះថវិកាចរន្តបានកើនឡើងពី ១៥,៥២ ភាគរយនៃថវិកាចរន្តរបស់រាជរដ្ឋាភិបាលនៅឆ្នាំ២០១៣ ដល់ ១៨,៣ ភាគរយនៅឆ្នាំ២០១៧។ រាជរដ្ឋាភិបាលនឹងខិតខំបង្កើនថវិកាអប់រំឱ្យដល់ ២០ ភាគរយនៃថវិកាចរន្ត។ ថវិកានឹងកើនខ្ពស់ជាងនេះ ប្រសិនបើ បូកបញ្ចូលថវិកាមូលធនសម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាលារៀនថែមទៀតនោះ។

ផ្អែកលើវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់វិស័យអប់រំឆ្នាំ ២០១៤ ជាពិសេសលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ក្រសួងបានដាក់ចេញកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ១៥ ចំណុច ដោយឈរលើមូលដ្ឋានសសរស្តម្ភ ៥ នៅឆ្នាំ ២០១៥។ នៅឆ្នាំ ២០១៦ ក្រសួងបានពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ និងការធ្វើចំណោលអប់រំដល់ឆ្នាំ ២០២០។

វឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់វិស័យអប់រំរយៈពេល៥ ឆ្នាំកន្លងមក ក្នុងក្របខណ្ឌសសរស្តម្ភទាំង៥ មានដូចខាងក្រោម៖

## *សសរស្តម្ភទី១ ៖ ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន*

- ការអនុម័តស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន
- ការអភិវឌ្ឍមជ្ឈមណ្ឌលគរុកោសល្យភូមិភាគរាជធានីភ្នំពេញ និងភូមិភាគបាត់ដំបងឱ្យក្លាយទៅជាវិទ្យាស្ថានគរុកោសល្យ
- ការដំឡើងកម្រិតបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានពី១២ បូក ២ ទៅ ១២ បូក ៤
- ការបង្កើតវិទ្យាស្ថានជាតិអប់រំពិសេស
- ការបំប៉នគ្រូថ្នាក់ទី ១២ មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រទូទាំងប្រទេស
- ការបណ្តុះបណ្តាលគ្រូឧទ្ទេស ៥៦ នាក់ ស្រី ២០ នាក់ ឱ្យមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់
- ការអនុវត្តប្រព័ន្ធក្រេឌីតសម្រាប់វាយតម្លៃសមត្ថភាពបុគ្គលិកអប់រំ
- ការបណ្តុះបណ្តាលគ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀននៅវិទ្យាល័យ តាមប្រព័ន្ធពន្លឿនដើម្បីឱ្យក្លាយទៅជាគ្រូបង្រៀនកម្រិតឧត្តម ២ ៦៨៦នាក់ ស្រី ៩៣៤នាក់ (៣៤,៧ ភាគរយ)
- ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានឱ្យទទួលបានបរិញ្ញាបត្រអប់រំ ៩៦៥ នាក់ ២១៥ នាក់ស្រី ៣៨០ នាក់ (៣៩,៤ ភាគរយ)
- ការបណ្តុះបណ្តាលគ្រូអប់រំកាយនិងកីឡាតាមរូបមន្ត (១២ បូក ៤)
- គោលការណ៍វាយតម្លៃផ្តល់ឋានៈគ្រូឧទ្ទេសនៅវិទ្យាស្ថានគរុកោសល្យ
- ក្របខណ្ឌគោលនយោបាយ ស្តីពីគន្លងអាជីពគ្រូបង្រៀន។

## *សសរស្តម្ភទី២ ៖ ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងការកែលម្អបរិស្ថានសិក្សា*

- ការអនុម័តក្របខណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស ចាប់ពីមត្តេយ្យសិក្សាដល់មធ្យមសិក្សាទុតិយភូមិ
- ការអនុម័តកម្មវិធីសិក្សាលម្អិតបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ គ្រប់មុខវិជ្ជាគ្រប់កម្រិតថ្នាក់
- ការអនុម័តកម្មវិធីសិក្សា និងដាក់ឱ្យប្រើប្រាស់សៀវភៅសិក្សាអង់គ្លេសថ្មីថ្នាក់ទី ៤ ដល់ទី ៩
- ការបញ្ចប់សេចក្តីព្រាងចុងក្រោយកម្មវិធីអប់រំមាតាបិតា
- ការបញ្ចប់សេចក្តីព្រាងចុងក្រោយក្របខណ្ឌកម្មវិធីសិក្សា និងកម្មវិធីសិក្សាលម្អិតថ្នាក់ពីរភាសា (បារាំង-ខ្មែរ)
- ការរៀបចំសេចក្តីព្រាងឯកសារ ស្តីពីការអប់រំបរិយាបន្នសម្រាប់គរុសិស្សមត្តេយ្យសិក្សា

- ការរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តក្របខណ្ឌកម្មវិធីសិក្សា ២០១៨-២០២៣។

### *សសរស្តម្ភទី ៣ ៖ ការដាក់ឱ្យអនុវត្តអធិការកិច្ច*

- អនុម័តលើបញ្ញត្តិស្តីពីការធានាគុណភាពអប់រំ
- រៀបចំរចនាសម្ព័ន្ធអធិការកិច្ចនៅថ្នាក់ក្រោមជាតិ ជាតំបន់អធិការកិច្ច ៨ តំបន់ រួមមាន តំបន់រាជធានីភ្នំពេញ តាកែវ ព្រះសីហនុ បាត់ដំបង សៀមរាប ព្រៃវែង កំពង់ចាម និងស្ទឹងត្រែង
- ការរៀបចំសៀវភៅណែនាំស្តីពីការធ្វើអធិការកិច្ចតាមកាលកំណត់ និងឧបករណ៍អធិការកិច្ច
- ការបណ្តុះបណ្តាលអធិការថ្មី ១៤៤ នាក់ ស្រី១៦ នាក់ និងអធិការអប់រំដែលមានស្រាប់ ៥១ នាក់ ស្រី ៥ នាក់ នៅវិទ្យាស្ថានជាតិអប់រំ
- ការបំប៉នសមត្ថភាពមន្ត្រីការិយាល័យអធិការកិច្ចដែលមិនមែនអធិការទាំង ២៥ រាជធានី ខេត្ត និងមន្ត្រីនាយកដ្ឋានធានាគុណភាពអប់រំស្តីពីបញ្ញត្តិនៃការធានាគុណភាពអប់រំ បញ្ចប់ម៉ូឌុលទាំង៦ មានអ្នកចូលរួមសរុប១៩៦ នាក់ស្រី៤៥ នាក់
- ការបំប៉នសមត្ថភាពដល់ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ ស្តីពីរបៀបផ្តល់ដំបូន្មានដល់នាយកសាលា និងគ្រូបង្រៀន ២៨១ នាក់ ស្រី ៤៦ នាក់។

### *សសរស្តម្ភទី ៤ ៖ ការពង្រឹងវង្វាយតម្លៃសិក្សាមានរូបភាពផ្សេងៗដូចជា ការប្រឡង ការធ្វើតេស្តវង្វាយតម្លៃថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ*

- បញ្ចប់ឯកសារក្របខណ្ឌវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតមត្តេយ្យសិក្សានិងអប់រំចំណេះទូទៅ
- តេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី៣ ទី៦ ទី៨ និងទី១១
- ការផ្សព្វផ្សាយលទ្ធផលកម្មវិធីអន្តរជាតិស្តីពី វង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍
- ការអនុវត្តសាកល្បងតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សបឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍សម្រាប់សិស្សថ្នាក់ទី៥។

### *សសរស្តម្ភទី ៥ ៖ ការកែទម្រង់ឧត្តមសិក្សា*

- ការអនុម័តស្តង់ដា និងរៀបចំសៀវភៅណែនាំ ស្តីពីការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា
- ការបញ្ចប់សេចក្តីព្រាងស្តង់ដាសម្រាប់ទទួលស្គាល់គុណភាពអប់រំថ្នាក់បណ្ឌិត
- ការវាយតម្លៃសាកល្បងការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា។

## ១.៨ ការវិភាគអំពីសមត្ថភាព និងការគ្រប់គ្រង

### *សមត្ថភាព*

ក្រសួងបានអនុវត្តផែនការគោលស្តីពី ការអភិវឌ្ឍសមត្ថភាពនៅក្នុងវិស័យអប់រំ ក្នុងគោលបំណងធានាឱ្យមន្ត្រីអប់រំនៅគ្រប់លំដាប់ថ្នាក់ ដឹកនាំនិងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព តាមរយៈការប្រើប្រាស់អភិក្រមអភិវឌ្ឍសមត្ថភាព ដែលផ្អែកតាមតម្រូវការជាក់ស្តែង គ្រប់ជ្រុងជ្រោយ លក្ខណៈជាប្រព័ន្ធ និងមាននិរន្តរភាព ក្រោមការដឹកនាំរបស់ក្រសួង។ ដើម្បីសម្រេចគោលដៅទាំងនេះ ក្រសួងបានផ្តោតជាសំខាន់លើ ៥ចំណុចគឺ ១)គោលនយោបាយផ្អែកតាមភស្តុតាងត្រឹមត្រូវ ឈរលើមូលដ្ឋានលើការសិក្សាស្រាវជ្រាវ និងកិច្ចពិគ្រោះយោបល់គ្រប់ជ្រុងជ្រោយ ២)មានការរៀបចំគោលនយោបាយ ផែនការ ពិនិត្យតាមដាន និងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ ផ្តោតលើលទ្ធផលនៅគ្រប់កម្រិត ៣)ការផ្តល់ហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាលផ្អែកតាមគោលការណ៍សមធម៌ និងគុណភាព និងធានាឱ្យមានគណនេយ្យភាពហិរញ្ញវត្ថុខ្ពស់ជាងមុន ៤)ការពង្រឹងការគ្រប់គ្រងបុគ្គលិក និងការពង្រាយគ្រូបង្រៀនកាន់តែមានប្រសិទ្ធភាពជាងមុន តាមរយៈយន្តការអភិវឌ្ឍសមត្ថភាពជាលក្ខណៈប្រព័ន្ធ និង ៥)កែលម្អការផ្តល់សេវាអប់រំ យុវជន និងកីឡា ប្រកបដោយគុណភាព និងសមធម៌។

សមាសភាគនៃការអភិវឌ្ឍសមត្ថភាពជាមូលដ្ឋាន ៤ ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក គឺ ១) បរិយាកាសផ្តល់ភាពអនុគ្រោះ ២) ធនធានមនុស្ស ៣) ប្រព័ន្ធ និង ៤)យន្តការ។

**លក្ខណៈជាប្រព័ន្ធ ៖** ការអភិវឌ្ឍសមត្ថភាពទាមទារឱ្យមានប្រព័ន្ធមួយដែលមានសិទ្ធិអំណាចសមរម្យលើការគ្រប់គ្រងនិងអភិបាលកិច្ចល្អ ព្រមទាំងប្រព័ន្ធលើកទឹកចិត្តដោយផ្អែកលើការបំពេញការងារ។

**បរិការណ៍សង្គម ៖** បរិយាកាសធ្វើឱ្យប្រសើរឡើង៖ ប្រព័ន្ធអប់រំមួយដែលមានដំណើរការក្នុងវប្បធម៌ ទំនាក់ទំនងអំណាច និងបទដ្ឋានសង្គមរបស់ប្រទេសមួយ ដែលការគ្រប់គ្រងជាអន្តរកម្មរវាងមនុស្ស និងស្ថាប័ន។

**ការអភិវឌ្ឍធនធានមនុស្ស ៖** បុគ្គលម្នាក់ៗមានជំនាញ ចំណេះដឹង និងការយល់ដឹងសំខាន់ៗដើម្បីអនុវត្តភារកិច្ច និងតួនាទី លើការងារបច្ចេកទេសរបស់ពួកគេ។ កម្រិតសមត្ថភាព និងចំណេះដឹងទូលំទូលាយជាតម្រូវការចាំបាច់ ព្រមទាំងទាមទារឱ្យមានការប្រកួតប្រជែងបន្ថែមទៀតលើផ្នែកជំនាញ និងចំណេះដឹង។ ការដឹកនាំប្រកបដោយប្រសិទ្ធភាពនៅកម្រិតខ្ពស់ ក៏ដូចជាក្រុមការងាររួមមានស្ថាប័ន និងអង្គភាព គឺមានសារៈសំខាន់។ នៅក្នុងបរិបទនៃការធ្វើកំណែទម្រង់ ជំនាញទាំងនេះរួមមាន "ការគ្រប់គ្រងនៃការផ្លាស់ប្តូរ" ដែលបង្ហាញពីភាពទន់ភ្លន់ និងបត់បែនចំពោះភាពមិនប្រាកដប្រជា។ ការបង្កើតស្ថាប័នមួយប្រកបដោយប្រសិទ្ធភាពត្រូវការលើកទឹកចិត្តជាកត្តាចាំបាច់ ដោយផ្សារភ្ជាប់ទៅនឹងវិសាលភាពដែលមនុស្សក្នុងស្ថាប័ននោះ បានចែករំលែកតម្លៃ និងការយល់ឃើញទូទៅនៃបេសកកម្មនិងគោលបំណងរបស់ស្ថាប័នខ្លួន។

**យន្តការសម្របសម្រួលជាប្រព័ន្ធ ៖** ការកៀរគរធនធានមនុស្សប្រកបដោយប្រសិទ្ធភាព និងការរៀបចំមុខងារប្រព័ន្ធ ត្រូវផ្អែកលើភាពស័ក្តិសិទ្ធិនៃយន្តការដែលមានស្រាប់ ដើម្បីគាំទ្រដល់ការផ្សារភ្ជាប់គ្នា ការសម្របសម្រួល និងកិច្ចសហការគ្នានៅកម្រិតរដ្ឋបាលផ្សេងៗគ្នា។

### *ការគ្រប់គ្រង*

នៅថ្នាក់ជាតិ គណៈកម្មការគ្រប់គ្រងកម្មវិធីបានប្រជុំយ៉ាងទៀងទាត់ដើម្បីពិនិត្យឡើងវិញនូវវឌ្ឍនភាព និងបញ្ហាប្រឈមរបស់វិស័យ និងបានរៀបចំរបាយការណ៍សន្និបាតអប់រំប្រចាំឆ្នាំ។ ក្រសួងបានពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ ឆ្នាំ២០១៦ នៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ដោយបានកែសម្រួលគោលនយោបាយអប់រំរយៈពេលមធ្យមមកត្រឹម ២ វិញ ដើម្បីឱ្យមានសង្គតិភាពជាមួយនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ស្តីពីការអប់រំនៅកម្ពុជា ព្រមទាំងបានកែសម្រួលយុទ្ធសាស្ត្រ ចំណុចដៅ និងធ្វើចំណោលសូចនាករដល់ឆ្នាំ២០២០។ ក្រសួងក៏បានកៀរគរធនធាន និងបន្សុីជាមួយអាទិភាពកំណែទម្រង់ទាំង១៥ ចំណុច។

**អនុវិស័យ ៖** រចនាសម្ព័ន្ធអនុវិស័យត្រូវបានរៀបចំ ដើម្បីសម្របសម្រួលការងារកសាងផែនការ ការងារគ្រប់គ្រង និងពិនិត្យតាមដាន។ ក៏ប៉ុន្តែ ការកសាងផែនការតាមអនុវិស័យមិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា ផែនការប្រតិបត្តិប្រចាំឆ្នាំ និងថវិកាកម្មវិធីនោះទេ។ ការងារគ្រប់គ្រង និងពិនិត្យតាមដានត្រូវបានធ្វើឡើងតាមរយៈការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ និងសន្និបាតអប់រំប្រចាំឆ្នាំ។

**កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ៖** កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការជាការងារចាំបាច់ដើម្បីធានាប្រសិទ្ធភាពនិងឆ្លើយតបទៅនឹងអាទិភាពនៃការផ្តល់សេវាសាធារណៈ ជាពិសេសវិស័យអប់រំ។ បញ្ជីវិភាគមុខងារនិងការពិនិត្យមើលឡើងវិញនូវមុខងារត្រូវបានរៀបចំ ដែលរួមមាន ៥៧៣ មុខងារ និងមុខងាររង។ គោលនយោបាយស្តីពី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំត្រូវបានរៀបចំ។ ឆ្លងតាមការពិនិត្យមើលឡើងវិញនូវមុខងារ និងធនធានវិស័យអប់រំ និងស្របតាមគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំរួចរាល់នូវមុខងារ តួនាទី ភារកិច្ចរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក សម្រាប់ធ្វើសមាហរណកម្ម និងផ្ទេរឱ្យទៅដល់រដ្ឋបាលក្រុង ស្រុក។

**កំណែទម្រង់ការគ្រប់គ្រងបុគ្គលិក៖** ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញវិធានការកំណែទម្រង់ការគ្រប់គ្រងបុគ្គលិក ដើម្បីឆ្លើយតបទៅនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល។ ក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ ការអនុវត្តកម្មវិធីជាតិ និងវិធានការកំណែទម្រង់បានធ្វើឱ្យបុគ្គលិកអប់រំនៅទូទាំងប្រទេស មានការពេញចិត្ត និងបន្តខិតខំបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំនៅគ្រប់ភូមិសិក្សា ជាមួយនឹងការទទួលបានការលើកទឹកចិត្តពីរាជរដ្ឋាភិបាលតាមគ្រប់រូបភាពជាអាទិ៍: ការបើកបៀវត្សមន្ត្រីរាជការនិងមន្ត្រីជាប់កិច្ចសន្យាតាមប្រព័ន្ធធនាគារ និងបានទៀងទាត់នៅសប្តាហ៍ទី៤ ខែនីមួយៗ បៀវត្សបុគ្គលិកអប់រំមានការកើនឡើង៣ដង ក្នុងនោះបៀវត្សអប្បបរមានៃបុគ្គលិកអប់រំកើនឡើងពី ៣១០ ០០០ រៀល ឆ្នាំ២០១៣ រហូតដល់ ១ ២០០ ០០០ រៀលនៅឆ្នាំ២០១៩ ប្រាក់លើកកម្ពស់ជីវភាពបុគ្គលិកអប់រំនៅតំបន់ដាច់ស្រយាលនិងតំបន់ជួបការលំបាកកើនឡើងទ្វេដង និងប្រាក់កម្រៃបង្រៀនរបប

ម៉ោងបន្ថែមក៏មានការកើនឡើងទ្វេផងដែរ។ ទន្ទឹមនឹងនេះ ក្រសួងទទួលបានក្របខណ្ឌថ្មីសម្រាប់ការប្រឡងជ្រើសរើសគ្រូបង្រៀនប្រចាំឆ្នាំចំនួន ៣ ៥០០នាក់ ទៅ ៣ ៦០០នាក់ ដោយបានបែងចែកប្រកបដោយសមធម៌ឱ្យទៅដល់សាលារៀនដែលកំពុងខ្វះគ្រូបង្រៀន និងបានពង្រឹងការគ្រប់គ្រងបុគ្គលិកអប់រំ និងគ្រូបង្រៀន ជាប់កិច្ចសន្យា និងបន្តជំរុញការអនុវត្តវិធានការពង្រាយគ្រូបង្រៀនពីសាលាលើសគ្រូបង្រៀនទៅសាលាខ្វះគ្រូបង្រៀន។ ក្នុងការអនុវត្តគោលការណ៍កំណែទម្រង់សមត្ថភាពស្ថាប័ន និងសមត្ថភាពធនធានមនុស្ស ក្រសួងបានពិនិត្យឡើងវិញរចនាសម្ព័ន្ធនិងមុខងាររបស់អង្គភាព អភិវឌ្ឍសមត្ថភាពមន្ត្រីគ្រប់គ្រងនិងគ្រូបង្រៀនតាមគោលការណ៍ស្តីពីគន្លងអាជីពគ្រូបង្រៀន ដោយប្រើថវិកាជាតិ និងថវិកាគម្រោង ពង្រឹងការតែងតាំងមន្ត្រីគ្រប់គ្រងដោយជ្រើសរើសតាមរូបភាព ៖ វង្វាយតម្លៃគុណផល ការធ្វើតេស្តវាស់ស្ទង់សមត្ថភាព និងការធ្វើសម្ភាសន៍ ការដាក់ឱ្យអនុវត្តប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃ ទាំងការងារបច្ចេកទេស និងការងាររដ្ឋបាលនៅតាមអង្គភាពរដ្ឋបាល និងគ្រឹះស្ថានសិក្សា ព្រមទាំងបានធ្វើបច្ចុប្បន្នភាពនិងដាក់ឱ្យអនុវត្តនិយាមស្តីពីការប្រើប្រាស់បុគ្គលិកអប់រំ បានធ្វើបច្ចុប្បន្នភាពគោលការណ៍អធិការកិច្ច បណ្តុះបណ្តាលអធិការ និងការអនុវត្តវិធានការអធិការកិច្ចជាប្រចាំ។

## ១.៩ បញ្ហាប្រឈម

ទោះបីការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ មានវឌ្ឍនភាពកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងការឆ្ពោះទៅសម្រេចបាននូវវត្ថុបំណងគោលនយោបាយ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ក៏នៅមានចំណុចមួយចំនួនត្រូវបន្តពង្រឹង និងកែលម្អថែមទៀត ដើម្បីសម្រេចគោលដៅនានាខាងមុខ ៖

- **ការអប់រំកុមារតូច** ៖ ការចូលរៀនរបស់កុមារតូចមានវឌ្ឍនភាពវិជ្ជមាន ប៉ុន្តែនៅមានបញ្ហាប្រឈមមួយចំនួនដូចជា កង្វះអាហារូបត្ថម្ភនៅតំបន់ដាច់ស្រយាល កម្មវិធីអប់រំតាមខ្នងផ្ទះផ្តល់សេវានៅមានកម្រិត ការសម្របសម្រួលស្ថាប័នបែបពហុវិស័យ សាលាមត្តេយ្យសិក្សាសហគមន៍មិនទាន់ឆ្លើយតបស្តង់ដាគុណភាព និងកង្វះគ្រូមត្តេយ្យសិក្សា ព្រមទាំងគុណវុឌ្ឍិគ្រូមត្តេយ្យសិក្សាបណ្តុះបណ្តាលមិនទាន់សមស្រប។
- **ការអប់រំបឋមសិក្សា** ៖ ថ្វីត្បិតតែ ក្នុងរយៈពេល៥ឆ្នាំកន្លងមក អត្រាបោះបង់ការសិក្សាបានថយចុះ អត្រាពិតនៃការសិក្សាសម្រេចបាន ៩៨ ភាគរយ និងអត្រាបញ្ចប់ការសិក្សា ៨៣ ភាគរយ ម្យ៉ាងវិញទៀត ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំ ក្រសួងអប់រំ យុវជន និងកីឡាត្រូវពង្រឹងវិធីសាស្ត្រអំណាន និងគណិតវិទ្យាថ្នាក់ដំបូង។
- **ការអប់រំមធ្យមសិក្សានិងអប់រំបច្ចេកទេស** ៖ ការបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិនិងមធ្យមសិក្សាទុតិយភូមិនៅមានកម្រិតខ្ពស់នៅឡើយ។ គ្រឹះស្ថានមធ្យមសិក្សាភាគច្រើនមិនទាន់មានបន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បណ្ណាល័យ សម្ភារឧបទេស រោងជាងស្របតាមកម្មវិធីសិក្សា។

- **ការអប់រំឧត្តមសិក្សា** ៖ គុណភាពនិស្សិតបញ្ចប់ការសិក្សាពុំទាន់ឆ្លើយតបពេញលេញទៅនឹងតម្រូវការនៃទីផ្សារការងារ និងសង្គម និងនៅមានគម្លាតជំនាញនៅឡើយ។ ការរៀបចំប្រព័ន្ធធានាគុណភាពផ្ទៃក្នុងនៅតាមគ្រឹះស្ថានឧត្តមសិក្សាមួយចំនួននៅមិនទាន់ដំណើរការល្អ និងការវាយតម្លៃទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានឧត្តមសិក្សា ដោយគណៈកម្មាធិការទទួលគុណភាពអប់រំ សម្រេចបានប្រមាណត្រឹម ៥៣ គ្រឹះស្ថានឧត្តមសិក្សាលើ ១២៥ ជាពិសេសដោយខ្វះខាតនូវមន្ត្រីវាយតម្លៃដែលមានសមត្ថភាព និងការអនុវត្តអនុសាសន៍វាយតម្លៃនៅមានកម្រិត។ ម្យ៉ាងវិញទៀត ចំនួនសាស្ត្រាចារ្យដែលមានគុណវុឌ្ឍិខ្ពស់ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតត្រូវបន្តបង្កើនថែមទៀត។
- **ការអប់រំក្រៅប្រព័ន្ធ** ៖ ហេដ្ឋារចនាសម្ព័ន្ធនៅតាមមជ្ឈមណ្ឌលសិក្សាសហគមន៍នៅមិនទាន់សមស្របសម្រាប់ការបណ្តុះបណ្តាលអក្ខរកម្មវិជ្ជាជីវៈ ជាពិសេសគ្រូជំនាញមុខរបរមិនមានគុណវុឌ្ឍិគ្រប់គ្រាន់ ដើម្បីឆ្លើយតបនឹងទីផ្សារការងារ។
- **ការអភិវឌ្ឍយុវជន** ៖ ធនធានថវិកាសម្រាប់ការអនុវត្តកម្មវិធីអភិវឌ្ឍយុវជន និងកម្មវិធីកាយរឹទ្ធិកម្មនៅមានកម្រិត។ ដើម្បីពង្រឹងកម្មវិធីបណ្តុះបណ្តាលជំនាញទន់ សហគ្រិនភាព ការបណ្តុះបណ្តាលជំនាញបច្ចេកទេស ទាមទារនូវសម្ភារបរិក្ខារគ្រប់គ្រាន់ និងគ្រូឧទ្ទេសដែលមានគុណវុឌ្ឍិខ្ពស់ ដើម្បីធានាឱ្យការបណ្តុះបណ្តាលនេះឆ្លើយតបនឹងតម្រូវការទីផ្សារនិងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម។
- **ការអប់រំកាយនិងកីឡា** ៖ ដើម្បីត្រៀមខ្លួនធ្វើជាម្ចាស់ផ្ទះ ២០២៣ ទាមទារនូវការវិនិយោគបន្ថែមទៀតលើហេដ្ឋារចនាសម្ព័ន្ធកីឡា សម្ភារៈហ្វឹកហាត់ការប្រកួត ការបន្តពង្រឹងសហព័ន្ធកីឡាជាតិ និងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យអប់រំកាយ និងកីឡា (គ្រូអប់រំកាយនិងកីឡា គ្រូបង្វឹក ចៅក្រម អាជ្ញាកណ្តាលកម្រិតជាតិនិងអន្តរជាតិ និងមន្ត្រីជំនាញវេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រកីឡា)។

# ជំពូកទី ២

# ក្របខណ្ឌនៃការអភិវឌ្ឍជាតិ

## ២.១ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាឆ្នាំ ២០១៦-២០៣០

ក្នុងរយៈពេលមួយទស្សវត្សរ៍កន្លងមកនេះ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានដើរតួយ៉ាងសំខាន់ក្នុងការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា និងទិសដៅសម្រាប់អភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា។ ឈរលើមូលដ្ឋាននេះ កម្ពុជាបានសម្រេចគោលដៅធំៗជាច្រើន ដូចជាសន្តិភាព ស្ថេរភាពនយោបាយ វិបុលភាព និងការកាត់បន្ថយភាពក្រីក្របានយ៉ាងឆាប់រហ័ស។ ទន្ទឹមនឹងនោះ កម្ពុជាបានធ្វើមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សកលទៅជាគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងបានសម្រេចគោលដៅជាច្រើនមុនកាលកំណត់ឆ្នាំ២០១៥។

ដំណាក់កាលថ្មីនេះ រាជរដ្ឋាភិបាលបានបន្តការខិតខំរបស់ខ្លួន ដើម្បីធ្វើមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសកលឱ្យស្របនឹងបរិការណ៍កម្ពុជា និងបានធ្វើសមាហរណកម្មទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ជាពិសេស ប្រើជាធាតុចូលយ៉ាងសំខាន់សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣។

រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ឆ្នាំ២០៣០ នៅចុងឆ្នាំ២០១៨ ដែលមានគោលដៅចំនួន ១៨ ចំណុចដៅចំនួន ៨៨ និងសូចនាករចំនួន ១៤៨ ដោយបានបន្ថែមគោលដៅមួយថ្មី ស្តីពីការបោសសម្អាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះសល់ពីសង្គ្រាម ព្រមទាំងបានរក្សាទុកចំណុចដៅសកលប្រមាណ ៧៥ ភាគរយ ដែលពាក់ព័ន្ធនឹងកម្ពុជា។

## ២.២ យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល

ទិសដៅរួមរបស់រាជរដ្ឋាភិបាលកម្ពុជា គឺកសាងនូវសង្គមកម្ពុជាមួយ ដែលរឹងមាំមានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម មានការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌ ជាមួយនឹងការប្រកាន់ខ្ជាប់យ៉ាងម៉ឺងម៉ាត់នូវគោលការណ៍លទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ជាសង្គមមួយដែលមានកោសិការផ្សារភ្ជាប់គ្នានឹងត្រូវបានពង្រឹងដើម្បីធានាថា ប្រជាជនកម្ពុជាមានចំណេះដឹងខ្ពស់ និងមានសុខភាពល្អ មានជីវភាពសមរម្យ និងមានការរស់នៅប្រកបដោយសុខដុមរមនា ទាំងក្នុងរង្វង់គ្រួសារ និងក្នុងសង្គមជាតិ។

នៅក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភាបានដាក់ចេញនូវចក្ខុវិស័យសេដ្ឋកិច្ច សង្គមកិច្ច ដើម្បីឱ្យកម្ពុជាឈានទៅសម្រេចបានឋានៈជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។ គោលដៅយុទ្ធសាស្ត្រ ៤យ៉ាង គឺ **ដើម្បីកំណើន ការងារ សមធម៌** និង **ប្រសិទ្ធភាព** នៅតែចាំបាច់ និង សមស្របសម្រាប់កម្ពុជាអនុវត្តនៅក្នុងនីតិកាលទី៦ ឆ្នាំ២០១៨-២០២៣ ក្នុងគោលបំណង ១) ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យម

ប្រចាំឆ្នាំ ក្នុងរង្វង់ ៧ ភាគរយ ប្រកបដោយចីរភាព និង ធន់នឹងវិបត្តិ ២) បង្កើតការងារឱ្យបានកាន់តែច្រើន ទាំងបរិមាណ និង គុណភាពជូនដល់ប្រជាជនកម្ពុជា ពិសេសសម្រាប់ស្រទាប់យុវជន ៣) សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រឱ្យស្ថិតនៅក្នុងអត្រាទាបជាង ១០ភាគរយ និង៤) បន្តពង្រឹងសមត្ថភាព និង អភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ដើម្បីធានាបាននូវប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈ។

ស្នូលនៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ គឺ ការបង្កើនល្បឿននៃកំណែទម្រង់អភិបាលកិច្ចដោយផ្ដោតសំខាន់លើ ១) ការកែទម្រង់ និងលើកកម្ពស់សមត្ថភាពស្ថាប័ន ២) ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ ៣) ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តការងារ និង៤) ការពង្រឹងអភិបាលកិច្ចវិស័យឯកជន។

រាជរដ្ឋាភិបាល បាននិងកំពុងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥ ដើម្បីជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា ដែលរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព និងបរិយាបន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព។ គោលនយោបាយនេះមានគោលបំណងកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជាពីឧស្សាហកម្មអតិពលកម្មឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥ តាមរយៈភ្ជាប់ខ្សែចង្វាក់តម្លៃសកល សមាហរណកម្មទៅក្នុងបណ្ដាញផលិតកម្មតំបន់ និងការអភិវឌ្ឍកន្សោមផលិតកម្មប្រទាក់ក្រឡាគ្នា ទន្ទឹមនឹងការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាពឧស្សាហកម្មក្នុងស្រុក។ ក្នុងនោះមានយុទ្ធសាស្ត្រមួយបានផ្ដោតលើការអភិវឌ្ឍធនធានមនុស្ស និងការបណ្ដុះបណ្ដាលបច្ចេកទេស។ ជំនាញ និងបច្ចេកវិទ្យាមនុស្ស គឺមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់ការធ្វើសមាហរណកម្មឱ្យកាន់តែស៊ីជម្រៅរបស់កម្ពុជាទៅក្នុងតំបន់អាស៊ាន។

ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា នឹងឈានដល់ដំណាក់កាល "ប្រែប្រួលថ្មីមួយ"ទៀត ដែលជាអន្តរកាលឆ្ពោះទៅសម្រេចឋានៈប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និង ជាប្រទេសចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលនឹងបន្តផ្ដោតការយកចិត្តទុកដាក់លើ**វិស័យអាទិភាព** ៤ ដោយតម្កល់**មនុស្ស**ជាអាទិភាពទី១ វិញ ហើយ **ផ្លូវ ភ្លើង និងទឹក**ជាអាទិភាពបន្តបន្ទាប់ នៅក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល ក្នុងនីតិកាលទី៦នៃរដ្ឋសភា។ ក្នុងនោះ យុទ្ធសាស្ត្រចតុកោណទី១ ៖ ការអភិវឌ្ឍធនធានមនុស្ស សំដៅលើកកម្ពស់ចំណេះដឹង ជំនាញវិជ្ជាជីវៈ សមត្ថភាព សហគ្រិនភាព ការច្នៃប្រឌិត នវានុវត្តន៍ គុណធម៌ សីលធម៌ មនសិការស្នេហាជាតិ និង ស្មារតីទទួលខុសត្រូវ, សុខភាពល្អ និងកាយសម្បទារឹងមាំ, តួនាទីស្ត្រី និង កិច្ចគាំពារសង្គម។ ការអភិវឌ្ឍធនធានមនុស្ស បន្តផ្ដោតលើ ៖ ១) ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និង បច្ចេកទេសវិទ្យា ២) ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស ៣) ការលើកកម្ពស់សេវាសុខភាពសាធារណៈ និង អាហារូបត្ថម្ភ និង ៤) ការពង្រឹងសមភាពយេនឌ័រ និងការគាំពារសង្គម។

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល គឺអភិវឌ្ឍ "**ប្រព័ន្ធអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន**" ដោយផ្តោតសំខាន់លើវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការតម្រង់ទិសសម្រាប់ទីផ្សារការងារ និងការយកចិត្តទុកដាក់លើការអប់រំកាយ សម្រាប់ទ្រទ្រង់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ ៖ ១) ការយកចិត្តទុកដាក់លើគ្រូបង្រៀន ២) ការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត ៣) ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន ៤) ការជំរុញការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ តាមទស្សនាទាន "ខេត្តមួយមានវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសមួយយ៉ាងតិច សម្រាប់រយៈពេលមធ្យម និងស្រុកមួយមានវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេសមួយយ៉ាងតិច សម្រាប់រយៈពេលវែង" ៥) ការបង្កើនភាពឆ្លើយតបឱ្យកាន់តែពេញលេញនៃការអប់រំទៅនឹងទីផ្សារការងារ និងការរស់នៅ តាមរយៈទស្សនាទាន "យុវជនម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត" ៦) ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលគ្រប់ជ្រុងជ្រោយ និង ៧) ការត្រៀមប្រកួតកីឡាស៊ីហ្គេមឆ្នាំ២០២៣ និងជំរុញចលនា "យុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត"។

## ២.៣ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា

កម្ពុជាបានឈានដល់ដំណាក់កាលថ្មីមួយទៀតនៃការអភិវឌ្ឍវិស័យអប់រំ ឱ្យឆ្លើយតបនឹងបរិបទសកលលោក និងថ្នាក់តំបន់ ដែលមានមហិច្ឆតានិងវិសាលភាពធំទូលាយជាងមុន សំដៅលើកកម្ពស់គុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិតក្នុងក្របខណ្ឌទូលំទូលាយ គ្របដណ្តប់លើគ្រប់ប្រភេទនិងកម្រិតនៃការអប់រំ ជាពិសេស ស្របនឹងទស្សនវិស័យអភិវឌ្ឍន៍កម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ក្រសួងអប់រំ យុវជន និងកីឡាបានអនុម័តផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា នៅដើមឆ្នាំ២០១៩ ដើម្បីធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

ផែនទីបង្ហាញផ្លូវនេះបានកំណត់អាទិភាពគោលនយោបាយអប់រំធំៗចំនួន ៥ គឺ ១) កុមារគ្រប់រូបទទួលបានការគាំពារនិងអភិវឌ្ឍន៍កុមារតូច ការអប់រំកម្រិតមត្តេយ្យសិក្សា ការបញ្ចប់ការអប់រំកម្រិតមូលដ្ឋានដោយឥតបង់ថ្លៃនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ដោយទទួលបានលទ្ធផលសិក្សាប្រកបដោយគុណភាព ប្រសិទ្ធភាព សមធម៌ និងភាពឆ្លើយតប ២)កុមារនិងយុវជនគ្រប់រូបបញ្ចប់ការសិក្សានៅកម្រិតអប់រំមធ្យមសិក្សាទុតិយភូមិ ការអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ ដោយទទួលបានលទ្ធផលសិក្សាប្រកបដោយគុណភាពនិងភាពឆ្លើយតប ៣) ធានាឱ្យអ្នកសិក្សាគ្រប់រូបមានលទ្ធភាពស្មើគ្នាក្នុងការទទួលបានការអប់រំបច្ចេកទេសវិជ្ជាជីវៈនិងឧត្តមសិក្សាប្រកបដោយគុណភាព ៤) យុវជននិងមនុស្សពេញវ័យគ្រប់រូបទទួលបានចំណេះដឹងអក្ខរកម្ម និងលេខនព្វន្ត និងមានឱកាសកាន់តែច្រើនក្នុងការសិក្សាពេញមួយជីវិត និង ៥) អភិបាលកិច្ចនិងការគ្រប់គ្រងវិស័យអប់រំ មានភាពល្អប្រសើរជាងមុននៅគ្រប់កម្រិត។

**គោលដៅនៃការអប់រំជាតិ គឺ ៖**

១. បណ្តុះមនសិការជាតិ មានស្មារតីទទួលខុសត្រូវ ស្មោះត្រង់ និងមោទនភាពជាតិ តាមរយៈការលើកកម្ពស់ការប្រកាន់នូវគំនិត គុណតម្លៃ បំណងប្រាថ្នារួមគ្នា ដើម្បីបង្កើតបាននូវសាមគ្គីភាពជាតិ និងអត្តសញ្ញាណជាតិ។

២. ផ្តល់ការអភិវឌ្ឍគ្រប់ជ្រុងជ្រោយដល់អ្នកសិក្សា ដើម្បីទទួលបានតុល្យភាពរវាងការអភិវឌ្ឍកាយសម្បទា បញ្ញា អារម្មណ៍ សោភណ្ឌភាព និងស្មារតី។

៣. ផលិតធនធានមនុស្សដែលមានចំណេះដឹង បំណិន និងសមត្ថភាព ដែលស្របទៅតាមតម្រូវការទីផ្សារការងារសម្រាប់សេដ្ឋកិច្ចពុទ្ធិប្រកបដោយពិពិធភាព ដែលអាចប្រកួតប្រជែងនៅថ្នាក់តំបន់ និងសកលលោក។

៤. រៀបចំអ្នកសិក្សាពេញមួយជីវិត ដើម្បីឱ្យពួកគេអាចចូលរួមក្នុងពិភពលោក ដែលមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក និងពឹងអាស្រ័យគ្នាទៅវិញទៅមក និងអាចធ្វើសកម្មភាពប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ ថ្នាក់តំបន់ និងសកលលោក ដើម្បីបង្កើតនូវពិភពលោកមួយឱ្យកាន់តែមានសុខសន្តិភាព និងប្រកបដោយចីរភាព។

ផែនទីបង្ហាញផ្លូវ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា បានដាក់ចេញនូវគោលដៅយុទ្ធសាស្ត្រសំខាន់ៗឆ្ពោះទៅសម្រេចគោលដៅអប់រំ ឆ្នាំ២០៣០ ដូចខាងក្រោម ៖

- កម្ពុជាត្រូវមានប្រព័ន្ធអប់រំ រឹងមាំ និងមានសមត្ថភាពប្រកួតប្រជែងថ្នាក់តំបន់សម្រាប់សង្គមពុទ្ធិ។ ប្រព័ន្ធអប់រំ ត្រូវមានធនធានគ្រប់គ្រាន់ មានអភិបាលកិច្ចល្អ និងមានតុល្យភាព ដោយចាត់ទុកថា សមធម៌ បរិយាបន្ន ប្រសិទ្ធភាព និងស្តង់ដាគុណភាពខ្ពស់ជាគោលការណ៍សំខាន់របស់ខ្លួន។ ប្រព័ន្ធអប់រំត្រូវមានលក្ខណៈគ្រប់ជ្រុងជ្រោយទូទាំងវិស័យដែលអនុវិស័យនីមួយៗ និងសមាសភាគទាំងអស់នៃប្រព័ន្ធអប់រំ ត្រូវឆ្លើយតបទៅនឹងតម្រូវការនៃការសិក្សាពេញមួយជីវិតនៅគ្រប់ដំណាក់កាលទាំងអស់នៃជីវិត តាមរយៈបង្កើតឱកាសក្នុងការសិក្សាគ្រប់បរិបទ និងទម្រង់ (ក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ) សម្រាប់ប្រជាពលរដ្ឋគ្រប់វ័យទាំងអស់។
- ក្រសួងអប់រំ យុវជន និងកីឡា គឺជាក្រសួងដែលមានឧត្តមភាពក្នុងការផ្តល់នូវការអប់រំ និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ប្រកបដោយគុណភាព ដើម្បីក្លាយជាចលករក្នុងការឈានទៅសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច។ ក្រសួងត្រូវមានសមត្ថភាពវិជ្ជាជីវៈក្នុងការបំពេញមុខងារទាំងផ្នែកបច្ចេកទេស ដូចជា ការរៀបចំផែនការ ការពិនិត្យតាមដាន ការអភិវឌ្ឍកម្មវិធីសិក្សា ការបណ្តុះបណ្តាលគ្រូ ការវាយតម្លៃ អភិបាលកិច្ចវិស័យ។ល។ ក្រសួងរៀបចំ និងអនុវត្តគោលនយោបាយ ផែនការអប់រំ គោលបំណង និយាម និងស្តង់ដាសម្រាប់គ្រប់កម្រិត និងគ្រប់សមាសភាគនៃការអប់រំ និងសម្របសម្រួលការគ្រប់គ្រងកំណែទម្រង់ដែលជាធាតុផ្សំផ្សេងៗនៃវិស័យអប់រំ (រដ្ឋបាល កិច្ចការសិក្សាធិការ ធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស)។ ក្រសួងរៀបចំទិសដៅនៃការអភិវឌ្ឍវិស័យអប់រំ ហើយធានាឱ្យបាននូវអភិបាលកិច្ចល្អសម្រាប់អ្នកផ្តល់សេវាអប់រំទាំងអស់

និងពិនិត្យតាមដានលទ្ធផលនៃប្រព័ន្ធអប់រំ ដើម្បីសម្រេចឱ្យបាននូវគោលបំណងនៃការអប់រំរបស់ប្រទេស។ ប្រព័ន្ធនេះមានគោលបំណងធានាឱ្យបាននូវភាពប្រសើរឡើងលើការទទួលសេវាប្រកបដោយសមធម៌ គុណភាព និងភាពឆ្លើយតប ក៏ដូចជាអភិបាលកិច្ច និងការគ្រប់គ្រងគ្រឹះស្ថានសិក្សាគ្រប់ប្រភេទទាំងអស់នៅគ្រប់កម្រិតថ្នាក់។

- សាលារៀន គឺជាគ្រឹះស្ថានសិក្សា ដែលធានាបាននូវការអប់រំប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា។ សាលារៀនទាំងអស់នឹងមានស្វ័យភាពផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ និងគណនេយ្យភាពក្នុងការសម្រេចបាននូវលទ្ធផលសិក្សាប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា។ សាលារៀននឹងទទួលបានគ្រូបង្រៀនដែលមានសមត្ថភាពវិជ្ជាជីវៈ និងការលើកទឹកចិត្ត ហើយមានអ្នកដឹកនាំការងារបង្រៀនប្រកបដោយចក្ខុវិស័យ និងផ្តល់នូវបរិយាកាសប្រកបដោយសុវត្ថិភាព អនាម័យ ឆ្លើយតបចំពោះយេនឌ័រ បរិយាបន្ន និងការរៀននិងបង្រៀនប្រកបដោយគុណភាពខ្ពស់ ដោយប្រើប្រាស់បច្ចេកវិទ្យាជាជំនួយ។
- គ្រូបង្រៀនកម្ពុជា មានសមត្ថភាព ទទួលបានការលើកទឹកចិត្ត និងទទួលបានការគាំទ្រគ្រប់គ្រាន់ដើម្បីជួយគាំទ្រដល់អ្នកសិក្សាឱ្យទទួលបានការអប់រំប្រកបដោយគុណភាពខ្ពស់។ ប្រព័ន្ធអប់រំកម្ពុជានឹងមានគ្រូបង្រៀនដែលមានសមត្ថភាពវិជ្ជាជីវៈ ទទួលបានការលើកទឹកចិត្ត ទទួលបានការគាំទ្រ និងការបំប៉នចំណេះដឹងមុខវិជ្ជាជំនាញគ្រប់គ្រាន់ ព្រមទាំងជំនាញគរុកោសល្យ និងស្រលាញ់ការងារបង្រៀន និងសិស្សានុសិស្សរបស់ខ្លួន។ វិជ្ជាជីវៈគ្រូបង្រៀននឹងត្រូវបានលើកកម្ពស់ដើម្បីឱ្យការទាក់ទាញ និងរក្សាបាននូវមនុស្សដែលមានគុណវុឌ្ឍិខ្ពស់បំផុត និងមានទឹកចិត្តបំពេញការងារបានល្អ។ គ្រូបង្រៀននឹងទទួលបានការគាំទ្រជាប្រចាំ ដើម្បីឱ្យពួកគេអាចអភិវឌ្ឍចំណេះដឹង និងសមត្ថភាពសម្រាប់លើកកម្ពស់ការសិក្សារៀនសូត្ររបស់សិស្ស។ ការបង្រៀន គឺជាវិជ្ជាជីវៈប្រកបដោយក្រមសីលធម៌ ក្នុងនោះ គ្រូបង្រៀនត្រូវបំពេញការងារប្រកបដោយស្តង់ដារវិជ្ជាជីវៈ និងសីលធម៌ខ្ពស់បំផុត ដើម្បីធានាឱ្យសិស្សគ្រប់រូបរបស់ខ្លួនអាចទទួលបានជោគជ័យ។
- បន្ទប់រៀនកម្ពុជា ជាបន្ទប់រៀនវៃឆ្លាត ដែលផ្តល់ឱ្យសិស្សនូវឱកាសល្អបំផុតសម្រាប់ការរៀនសូត្រ។ បន្ទប់រៀនត្រូវប្រែក្លាយជាបណ្តើរៗទៅជាបន្ទប់រៀនវៃឆ្លាត ដោយបំពាក់ធនធានអប់រំ និងបច្ចេកវិទ្យាដើម្បីផ្តល់នូវបរិយាកាសសិក្សាដែលមានការរៀបចំដោយប្រយ័ត្នប្រយែង មានសុវត្ថិភាព និងមានលក្ខណៈអំណោយផលសម្រាប់ការសិក្សាសម្រាប់ទាំងអស់គ្នា។ គ្រូបង្រៀននឹងប្តូរតួនាទីទៅជាអ្នកសម្របសម្រួលការរៀនសូត្រ ដោយបំពេញតួនាទីជាអ្នកបង្កើតឱកាសរៀនសូត្រសម្រាប់ទាំងអស់គ្នាតាមរយៈការប្រើប្រាស់វិធីសាស្ត្របង្រៀនតាមបែបអន្តរកម្ម និងបែបសហការ និងវិធីសាស្ត្រចម្រុះ។
- សិស្សមានសុខភាពល្អ មានការលើកទឹកចិត្ត និងមានការប្តេជ្ញាចិត្តសម្រាប់អនាគតរបស់កម្ពុជា។ កម្ពុជានឹងមានសិស្សដែលមានសុខភាពល្អ ត្រៀមខ្លួនបានល្អ និងទទួលបានការលើកទឹកចិត្ត ក៏ដូចជាការប្តេជ្ញាចិត្តសិក្សារៀនសូត្រ ដោយមិនប្រកាន់ពីសាវតារខ្លួន និងទទួលបានបរិយាកាសសិក្សាដែលមានលក្ខណៈអំណោយផល។ សិស្សនឹងទទួលបានការគាំទ្រពីគ្រូបង្រៀនដែលមានសមត្ថភាព

និងគុណវុឌ្ឍិវិជ្ជាជីវៈ ក៏ដូចជាពីសំណាក់សមាជិកគ្រួសារ និងសហគមន៍របស់ពួកគេ។ បន្ទាប់ពីបញ្ចប់ការសិក្សា ពួកគេនឹងមានជំនាញទាំងរឹង ទាំងទន់ ចេះធ្វើការវិនិច្ឆ័យប្រកបដោយក្រមសីលធម៌បានល្អ មានភាពវៃឆ្លាតខាងអារម្មណ៍ ក៏ដូចជាមានស្មារតីជាតិ និងភាពជាប្រជាពលរដ្ឋសកលក្នុងកម្រិតមួយខ្ពស់ ដែលផ្ដល់លទ្ធភាពឱ្យពួកគេអាចរួមចំណែក និងចូលរួមក្នុងសង្គមយ៉ាងសកម្ម។

អាទិភាពគោលនយោបាយទាំងនេះ នឹងត្រូវអនុវត្តតាមដំណាក់កាលនីមួយៗនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ រហូតដល់ ឆ្នាំ២០៣០ ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពស្ដីពីការអប់រំ នៅកម្ពុជា ដោយមានកំណត់យន្តការ យុទ្ធសាស្ត្រ និងកម្មវិធី ព្រមទាំងការគាំទ្រហិរញ្ញវត្ថុសម្រាប់ការអនុវត្តផងដែរ។

### តារាងទី២៖ សូចនាករ និងចំណុចដៅសំខាន់ៗ នៃផែនទីបង្ហាញផ្លូវ ការអប់រំកម្ពុជាឆ្នាំ២០៣០

| សូចនាករ | ទិន្នន័យគោល (២០១៨) | ចំណុចដៅ ២០២៣ | ចំណុចដៅ ២០២៨ | ចំណុចដៅ ២០៣០ |
|---|---|---|---|---|
| អត្រារួមនៃការសិក្សានៅមត្តេយ្យសិក្សា | ៤១,៣% | ៤៥,៧% | ៥០,១% | ៥១,៨% |
| អត្រាចូលរៀនកុមារអាយុ ៥ ឆ្នាំ គ្រប់រូបភាព | ៦៨,៥% | ៧៦,០% | ៨១,៥% | ៨៤,១% |
| ភាគរយសិស្សថ្នាក់ទី១ បានឆ្លងកាត់កម្មវិធីអប់រំកុមារតូចគ្រប់រូបភាព | ៦៥% | ៧៤,៥% | ៨០,៣% | ៨២,៨% |
| ភាគរយសាលាមត្តេយ្យសិក្សា ដែលមានទឹកស្អាតសម្រាប់ទទួលទាន សម្ភារអនាម័យ និងកន្លែងលាងដៃ | ៣០,៥% | ៥៥,៣% | ៧២,៩% | ៨០,០% |
| ភាគរយនៃសាលារៀន ដែលមានអគ្គិសនី អ៊ិនធឺណិតសម្រាប់ បង្រៀននិងរៀន និងកុំព្យូទ័រសម្រាប់មត្តេយ្យសិក្សា | ២០,៤% | ៣៥,២% | ៤៥,៨% | ៥០,០% |
| ភាគរយគ្រូបង្រៀននៅមត្តេយ្យសិក្សាដែលមានគុណវុឌ្ឍិស្របតាមស្តង់ដាជាតិ | ៥៧,៦% | ៦២,៤% | ៧៦,៨% | ៨០,០% |
| ផលធៀបសិស្ស-គ្រូនៅមត្តេយ្យសិក្សា | ៣៨ | ៣២ | ២៧ | ២៥ |
| ភាគរយគ្រូបង្រៀននៅមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សា ដែលឆ្លងកាត់ការបណ្តុះបណ្តាល និងទទួលវិក្រឹតការ | ៩៩% | ៩៩,៥% | ៩៩,៩% | ១០០% |
| អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | ៨២,៧% | ៨៦,២% | ៨៩,៧% | ៩១,១% |
| ភាគរយសាលាបឋមសិក្សា ដែលមានទឹកស្អាតសម្រាប់ទទួលទាន សម្ភារអនាម័យ និងកន្លែងលាងដៃ | ៦០,២% | ៨០,១% | ៩៤,៣% | ១០០% |
| ភាគរយនៃសាលារៀន ដែលមានអគ្គិសនី អ៊ិនធឺណិតសម្រាប់បង្រៀននិងរៀន និងកុំព្យូទ័រសម្រាប់បឋមសិក្សា | ៣៦,៥% | ៥៣,២% | ៦៥,២% | ៧០,០% |

| | | | | |
|---|---|---|---|---|
| ភាគរយគ្រូបង្រៀន នៅបឋមសិក្សាដែលមានគុណវុឌ្ឍិស្របតាមស្តង់ដាជាតិ | ៦២,៩% | ៧៦,៥% | ៨១,៦% | ៩០,០% |
| អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | ៤៦,៥% | ៥២,៦% | ៥៨,៧% | ៦១,១% |
| ភាគរយនៃសាលាមធ្យមសិក្សា ដែលមានអគ្គិសនី អ៊ិនធឺណិតសម្រាប់បង្រៀននិងរៀន និងកុំព្យូទ័រ | ៣៣,០% | ៤៧,៦% | ៥៦,៥% | ៦០,០% |
| ភាគរយនៃសាលាបឋមសិក្សា និងមធ្យមសិក្សា ដែលមានជម្រាលសម្រាប់ជនពិការ | 0% | ១០,៧% | ១៧,៣% | ២០,០% |
| ភាគរយគ្រូមធ្យមសិក្សា ដែលទទួលវិក្រឹតការ | ៣,៩% | ១៦,៩% | ២៦,៣% | ៣០,០% |
| អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | ២៣,៦% | ៣២,៥% | ៤១,៤% | ៤៥,០% |
| ភាគរយសាលាមធ្យមសិក្សាទុតិយភូមិ ដែលមានទឹកស្អាតសម្រាប់ទទួលទាន សម្ភារអនាម័យ និងកន្លែងលាងដៃ | ៥៩,៤% | ៧៤,៧% | ៨៥,៦% | ៩០,០% |
| ភាគរយនៃសាលាមធ្យមសិក្សាដែលមានអគ្គិសនី អ៊ិនធឺណិតសម្រាប់បង្រៀន និងរៀន និងកុំព្យូទ័រ | ៦២,៤% | ៨០,១% | ៩២,៩% | ៩៨,០% |
| ភាគរយគ្រូបង្រៀននៅមធ្យមសិក្សា ដែលមានគុណវុឌ្ឍិស្របតាមស្តង់ដាជាតិ | ៩៨% | ៩៨,៥% | ៩៨,៩% | ៩៩,០% |
| អត្រារួមនៃការសិក្សានៅឧត្តមសិក្សា | ១១,៦% | ១៦,៩% | ២២,៧% | ២៥,០% |

## ២.៤ ចក្ខុវិស័យ បេសកកម្ម របស់ក្រសួងអប់រំ យុវជន និងកីឡា

ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺ កសាង និង អភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឱ្យក្លាយទៅជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

បេសកកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា ៖ ដឹកនាំគ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា ឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌របស់កម្ពុជា និងការរីកចម្រើននៅក្នុងតំបន់ និងសកលលោក។

វត្ថុបំណងរយៈពេលវែងរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺអភិវឌ្ឍយុវជនកម្ពុជាលើគ្រប់វិស័យ និងបណ្ដុះស្មារតីយុវជន យុវតីកម្ពុជាគ្រប់រូបឱ្យមានមនសិការស្នេហាជាតិ មោទនភាពជាតិ សីលធម៌ល្អ និងគុណធម៌ខ្ពស់ ព្រមទាំងមានសុទិដ្ឋិនិយមចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន។

វត្ថុបំណងចំពោះមុខរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺធានាថាយុវជននិងកុមារកម្ពុជាគ្រប់រូបមានឱកាសស្មើគ្នា ក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពស្របតាមរដ្ឋធម្មនុញ្ញ និងការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ ពោលគឺគោលការណ៍មិនរើសអើងអំពីស្ថានភាពសង្គម ភូមិសាស្ត្រ ជនជាតិ សាសនា ភាសា ភេទ និងកាយសម្បទា។ ក្រសួងសង្ឃឹមទុកថា នៅពេលដែលសិស្ស និស្សិតបានបញ្ចប់ការសិក្សារបស់ខ្លួនពួកគេនឹងមានចំណេះដឹង ជំនាញ

វិជ្ជាជីវៈ សមត្ថភាព គុណធម៌ និងសីលធម៌ល្អ ស្របតាមស្តង់ដាមួយសមស្រប ព្រមទាំងអាចប្រកួតប្រជែងនៅលើទីផ្សារការងារក្នុងតំបន់ និងលើសកលលោក និងអាចក្លាយជាកម្លាំងស្នូលសម្រាប់ជំរុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសជាតិ ។

## ២.៥ គោលនយោបាយអប់រំ សូចនាករស្នូល និងចំណុចដៅ

### ២.៥.១ គោលនយោបាយអប់រំរយៈពេលមធ្យម

ក្នុងគោលបំណងរួមចំណែកសម្រេចយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ រាជរដ្ឋាភិបាល និងអាទិភាពគោលនយោបាយនៃផែនទីបង្ហាញផ្លូវសម្រាប់គោលដៅអភិវឌ្ឍន៍ដោយចីរភាព ឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡាបានប្តូរគោលនយោបាយអប់រំពីបីមកត្រឹមពីរក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដូចខាងក្រោម៖

- **គោលនយោបាយទី១ ៖** ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា
- **គោលនយោបាយទី២ ៖** ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

***វត្ថុបំណងគោលនយោបាយទី១ ៖*** កុមារគ្រប់រូបបានទទួលសេវាអប់រំកុមារតូចតាមគ្រប់រូបភាព បានចូលរៀននៅបឋមសិក្សា មធ្យមសិក្សា និងមានឱកាសបន្តការសិក្សាទៅមុខទៀត ព្រមទាំងផ្តល់នូវជម្រើសផ្សេងទៀតដល់កុមារ និងយុវជនដែលពុំមានលទ្ធភាពទទួលបានសេវាអប់រំក្នុងប្រព័ន្ធ។ កុមារ យុវជនគ្រប់រូបទទួលបានលទ្ធផលសិក្សានៅគ្រប់កម្រិតប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ជាពិសេស កុមារមកពីគ្រួសារជួបការលំបាក យុវជនក្រៅសាលា និងទទួលបាននូវចំណេះដឹង ជំនាញបច្ចេកទេស បំណិនគិត និងបំណិនអរូបវន្ត ឆ្លើយតបនឹងបរិបទសង្គមពុទ្ធិ និងវិបុលភាព និងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស។ ក្របខណ្ឌគុណភាពដែលផ្តល់ដល់អ្នកសិក្សាត្រូវមានការគាំទ្រ និងចូលរួមពីមាតាបិតា សហគមន៍ គ្រូបង្រៀន និងអ្នកគ្រប់គ្រងជាមួយនឹងស្តង់ដានៃផលសម្រេចការពិនិត្យតាមដាន និងរបាយការណ៍។

***វត្ថុបំណងគោលនយោបាយទី២ ៖*** ការផ្តល់សេវាអប់រំអនុវត្តប្រកបដោយប្រសិទ្ធភាព និងទន់ភ្លន់។ ការគ្រប់គ្រងប្រកបដោយភាពស័ក្តិសិទ្ធិផ្តល់នូវតម្លៃដ៏ល្អបំផុត(ផ្តោតលើលទ្ធផល)ទាន់ពេលវេលា ការពិនិត្យតាមដាន និងរបាយការណ៍សមិទ្ធកម្ម និងយោបល់ត្រឡប់ វិធានការប្រកបដោយគណនេយ្យភាព និងយន្តការសម្រាប់កែលម្អគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ។ ការគ្រប់គ្រងគ្រឹះស្ថានសិក្សា ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ត្រូវបង្កើនស្វ័យភាពនិងទទួលខុសត្រូវគណនេយ្យភាពចំពោះលទ្ធផលនៃការសិក្សាប្រកបដោយគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា។

## ២.៤.២ សូចនាករស្នូល និងចំណុចដៅ

ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ក្រសួងបានកំណត់សូចនាករស្នូល ចំនួន ៨ និងចំណុចដៅតាមឆ្នាំនីមួយៗដូចតារាងខាងក្រោម ដើម្បីពិនិត្យតាមដានវឌ្ឍនភាពនៃការសម្រេចគោលនយោបាយទាំងពីរខាងលើ។

### តារាងទី៣៖ សូចនាករស្នូលសម្រាប់ឆ្នាំ២០១៩-២០២៣

| សូចនាករស្នូល | | ឯកតា | ស្ថានភាព ២០១៧-១៨ | ចំណុចដៅ ២០១៨-១៩ | ចំណុចដៅ ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ចំណុចដៅ ២០២១-២២ | ចំណុចដៅ ២០២២-២៣ |
|---|---|---|---|---|---|---|---|---|
| គោលនយោបាយទី ១ ÷ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | | | | |
| ១. | អត្រាចូលរៀនកុមារអាយុ៥ឆ្នាំ គ្រប់រូបភាព (*ម.សិក្សារដ្ឋ សហគមន៍ និងឯកជន*) | % | ៥៨,០ | ៥៩,៣ | ៦០,៦ | ៦១,៩ | ៦៣,២ | ៦៤,៥ |
| | *ប្រុស* | % | ៥៧,៧ | ៥៨,៩ | ៦០,១ | ៦១,៣ | ៦២,៥ | ៦៣,៧ |
| | *ស្រី* | % | ៥៨,៧ | ៦០,០ | ៦១,៣ | ៦២,៧ | ៦៤,០ | ៦៥,៣ |
| ២. | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | % | ៨២,៧ | ៨៣,៤ | ៨៤,១ | ៨៤,៨ | ៨៥,៥ | ៨៦,២ |
| | *ប្រុស* | % | ៧៩,១ | ៨០,៣ | ៨១,៥ | ៨២,៦ | ៨៣,៨ | ៨៥,០ |
| | *ស្រី* | % | ៨៦,៤ | ៨៧,៣ | ៨៨,២ | ៨៩,២ | ៩០,១ | ៩១,០ |
| ៣. | អត្រាបញ្ចប់ការសិក្សានៅ មធ្យមសិក្សាបឋមភូមិ | % | ៤៦,៥ | ៤៧,៧ | ៤៨,៩ | ៥០,២ | ៥១,៤ | ៥២,៦ |
| | *ប្រុស* | % | ៤២,៣ | ៤៣,៨ | ៤៥,៤ | ៤៦,៩ | ៤៨,៥ | ៥០,០ |
| | *ស្រី* | % | ៥១,១ | ៥២,៥ | ៥៣,៤ | ៥៤,៣ | ៥៥,៣ | ៥៦,៣ |
| ៤. | ភាគរយសិស្សសម្រេចបានកម្រិតសមត្ថភាពក្រោមកម្រិតមូលដ្ឋាន មុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា | | | | | | | |
| | *ការអានភាសាខ្មែរថ្នាក់ទី៣* | % | ៥២,៦ (២០១៥) | | ៤៦,៦ | | | |
| | *ការសរសេរភាសាខ្មែរថ្នាក់ទី៣* | % | ៦៤,៨ | | ៥៨,៨ | | | |
| | *គណិតវិទ្យាថ្នាក់ទី៣* | % | ៤៤,៩ | | ៣៨,៩ | | | |
| | *ការអានភាសាខ្មែរថ្នាក់ទី៦* | % | ៣១,៥ (២០១៦) | | | ២៥,៥ | | |
| | *ការសរសេរភាសាខ្មែរថ្នាក់ទី៦* | % | ៣៩,៦ | | | ៣៣,៦ | | |
| | *គណិតវិទ្យាថ្នាក់ទី៦* | % | ៥៣,២ | | | ៤៧,២ | | |
| | *ការអានភាសាខ្មែរថ្នាក់ទី៨* | % | ១៨,៩ (២០១៧) | | | | ១៥,៩ | |
| | *ការសរសេរភាសាខ្មែរថ្នាក់ទី៨* | % | ៧១,០ | | | | ៦៥,០ | |
| | *គណិតវិទ្យាថ្នាក់ទី៨* | % | ៣៦,៣ | | | | ៣០,៣ | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | *រូបវិទ្យាថ្នាក់ទី៨* | % | ៥២,១ | | | | ៤៦,១ | |
| | *ការអានភាសាខ្មែរថ្នាក់ទី១១* | % | ២០,៥ (២០១៨) | | | | | ១៧,៥ |
| | *ការសរសេរភាសាខ្មែរថ្នាក់ទី១១* | % | ៥៨,៩ | | | | | ៥២,៩ |
| | *គណិតវិទ្យាថ្នាក់ទី១១* | % | ៧២,៣ | | | | | ៦៦,៣ |
| | *រូបវិទ្យាថ្នាក់ទី១១* | % | ៧៩,៦ | | | | | ៧៣,៦ |
| ៥. | ភាគរយគ្រូបង្រៀនបឋមសិក្សាមានគុណវុឌ្ឍិតាមស្តង់ដាជាតិ | % | ៧៣,០ | ៧៤,០ | ៧៥,០ | ៧៦,០ | ៧៧,០ | ៧៨,០ |
| ៦. | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (១៨-២២ឆ្នាំ) | % | ១១,៦ | ១២,៤ | ១៣,៣ | ១៤,២ | ១៥,១ | ១៦,០ |
| | *ប្រុស* | % | ១៣,២ | ១៤,៣ | ១៥,៥ | ១៦,៦ | ១៧,៨ | ១៨,៩ |
| | *ស្រី* | % | ១១,៣ | ១១,៦ | ១១,៩ | ១២,៣ | ១២,៧ | ១៣,០ |
| ៧. | អត្រាអក្ខរកម្មពេញវ័យ (អាយុ ១៥ ឆ្នាំឡើង) | % | ៨២,៥ | ៨៣,៦ | ៨៤,៧ | ៨៥,៨ | ៨៦,៩ | ៨៨,០ |
| គោលនយោបាយទី ២ ÷ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | | | | |
| ៨. | ចំនួននាយកសាលាបឋមសិក្សា និងមធ្យមសិក្សាបានទទួលការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងតាមសាលារៀន | ចំនួន | ១ ១៥០ | ៦៧០ | ៧០០ | ៧០០ | ៧០០ | ៧០០ |

# ជំពូកទី ៣
# ផែនការតាមអនុវិស័យឆ្នាំ ២០១៩-២០២៣

## ៣.១ អនុវិស័យ ការអប់រំកុមារតូច

### ៣.១.១ សាវតារ

ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំគោលនយោបាយជាច្រើន ក្នុងគោលបំណងពង្រឹងគុណភាពនៃការអប់រំកុមារតូច និងបានដាក់ចេញនូវអន្តរាគមន៍ជាគោលនយោបាយនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ដែលជាមូលដ្ឋានគ្រឹះជួយលើកកម្ពស់គុណភាពនៃការអប់រំកុមារតូចចាប់ពីឆ្នាំ២០១៩។ គោលនយោបាយទាំងនោះរួមមាន គោលនយោបាយ និងផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូចការធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច អនុក្រឹតស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ ប្រកាសស្តីពីស្តង់ដារអប្បបរមាមត្តេយ្យសិក្សាសហគមន៍ ប្រកាសស្តីពីនីតិវិធីវាយតម្លៃមត្តេយ្យសិក្សាសហគមន៍ ប្រកាសស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាឯកជន ប្រកាសស្តីពីការទទួលស្គាល់គ្រូបង្គោលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ គោលការណ៍ប្រតិបត្តិសម្រាប់មត្តេយ្យសិក្សាសហគមន៍ កម្មវិធីអប់រំមាតាបិតារួមមានស្ត្រីមានផ្ទៃពោះ មាតាបិតាមានកូនអាយុក្រោម ២ ឆ្នាំ និងគោលការណ៍ប្រតិបត្តិសម្រាប់សាលាមត្តេយ្យសិក្សាធនធាន។

ផ្អែកតាមអន្តរាគមន៍ខាងលើ ភាគរយកុមារអាយុ៣-៥ឆ្នាំ ទទួលបានសេវាអប់រំកុមារតូចគ្រប់រូបភាពមានការកើនពីឆ្នាំ២០១៤ ដល់ ២០១៨។ ទោះជាយ៉ាងណា លទ្ធភាពទទួលបានសេវាអប់រំកុមារតូចនៅមានកម្រិតទាប ជាពិសេសកុមាររស់នៅតាមតំបន់ជួបការលំបាក ដោយយោងតាមរបាយការណ៍សន្និបាតអប់រំនៅឆ្នាំ២០១៨។ ដូចនេះ ក្រសួងនឹងរៀបចំយុទ្ធសាស្ត្រសមស្រប ដើម្បីបង្កើនការទទួលសេវាអប់រំកុមារតូចជាពិសេស កុមាររស់នៅក្នុងតំបន់ដាច់ស្រយាល និងតំបន់ជនបទ ឬ កុមារដែលធ្វើចំណាកស្រុក។

ក្រសួងបានដាក់ចេញនូវគោលនយោបាយ និងយុទ្ធសាស្ត្រអាទិភាពនានា ក្នុងគោលបំណងពង្រឹងសេវាអប់រំកុមារតូចឱ្យមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់គុណភាពមត្តេយ្យសិក្សាឱ្យស្របតាមតាមស្តង់ដា ព្រមទាំងពង្រឹងសមត្ថភាពអ្នកគ្រប់គ្រង អនុវិស័យការអប់រំកុមារតូច។

### ៣.១.២ ទិស្តុបំណងអនុវិស័យ

- បង្កើនលទ្ធភាពទទួលបានសេវាអប់រំកុមារតូចប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន
- បន្តអភិវឌ្ឍសាលាមត្តេយ្យសិក្សាស្របតាមស្តង់ដាគុណភាព
- ពង្រឹងសមត្ថភាពអ្នកគ្រប់គ្រងអនុវិស័យការអប់រំកុមារតូច និងអនុវត្តការគ្រប់គ្រងតាមសាលារៀន។

## ៣.១.៣ សូចនាករផលសម្រេច

**តារាងទី៤ ៖ សូចនាករផលសម្រេច និងចំណុចដៅអនុវិស័យ**

| សូចនាករ | ឯកតា | ឆ្នាំគោល ២០១៨ | ចំណុចដៅ ២០២៣ |
|---|---|---|---|
| *គោលនយោបាយទី១ ៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិត សម្រាប់ទាំងអស់គ្នា* | | | |
| វត្ថុបំណងអនុវិស័យទី១៖ បង្កើនលទ្ធភាពទទួលបានសេវាអប់រំកុមារតូចប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន | | | |
| ១. អត្រាចូលរៀនកុមារអាយុ៥ឆ្នាំ គ្រប់រូបភាព *(មត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ មត្តេយ្យសិក្សាឯកជន)* | % | ៥៨,០ | ៦៤,៥ |
| *ប្រុស* | % | ៥៧,៧ | ៦៣,៧ |
| *ស្រី* | % | ៥៨,៧ | ៦៥,៣ |
| ២. អត្រាចូលរៀនកុមារអាយុ៤ឆ្នាំ គ្រប់រូបភាព *(មត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ មត្តេយ្យសិក្សាឯកជន)* | % | ៣៤,០ | ៤៥,០ |
| *ប្រុស* | % | ៣២,២ | ៤៤,៤ |
| *ស្រី* | % | ៣៥,៣ | ៤៥,៦ |
| ៣. អត្រាចូលរៀនកុមារអាយុ៣ឆ្នាំ តូចគ្រប់រូបភាព *(មត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ មត្តេយ្យសិក្សាឯកជន)* | % | ១២,៦ | ២៧,០ |
| *ប្រុស* | % | ១១,៧ | ២៦,០ |
| *ស្រី* | % | ១៣,៤ | ២៨,១ |
| ៤. អត្រារួមនៃការសិក្សា *(មត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍ មត្តេយ្យសិក្សាឯកជន)* | % | ៣៥,៨ | ៤៦,០ |
| *ប្រុស* | % | ៣៤,៩ | ៤៥,៦ |
| *ស្រី* | % | ៣៧,០ | ៤៨,៣ |
| ៥. ភាគរយសាលាមត្តេយ្យសិក្សាមានអគ្គិសនី (មត្តេយ្យសិក្សារដ្ឋ) | % | ៣១,៧ | ៤១,០ |
| ៦. ភាគរយសាលាមត្តេយ្យសិក្សាបានអនុវត្តលក្ខខណ្ឌអប្បបរមាស្តីពីទឹកស្អាត និងអនាម័យតាមសាលារៀន *(មត្តេយ្យសិក្សារដ្ឋដាច់ដោយឡែក)* | | | |
| *កម្រិត ១* | % | ៣៥,៤ | ៥០,០ |
| *កម្រិត ២* | % | ២៤,៧ | ២៨,៥ |
| *កម្រិត ៣* | % | ១,១ | ១,៥ |
| ៧. ភាគរយសាលាមត្តេយ្យសិក្សាមាន*(មត្តេយ្យសិក្សារដ្ឋដាច់ដោយឡែក)* | | | |
| *បង្គន់អនាម័យ* | % | ២២,០ | ៨០,០ |
| *ទឹកស្អាតសម្រាប់ទទួលទាន* | % | ៣០,២ | ៦០,០ |
| *កន្លែងលាងដៃ* | % | ២៨,៨ | ៦០,០ |
| *ប្រអប់សង្គ្រោះបឋម* | % | ៦,៣ | ២៥,០ |

| | | | |
|---|---|---|---|
| វត្ថុបំណងអនុវិស័យទី២ ៖ បន្តអភិវឌ្ឍសាលាមត្តេយ្យសិក្សាស្របតាមស្តង់ដាគុណភាព | | | |
| ៨. ភាគរយសាលាមត្តេយ្យសិក្សារដ្ឋសម្រេចបានតាមស្តង់ដាអប្បបរមា *(មត្តេយ្យសិក្សារដ្ឋដាច់ដោយឡែក)* | % | ០,០ | ៣០,០ |
| ៩. ចំនួនសាលាមត្តេយ្យសិក្សាសហគមន៍សម្រេចបានតាមស្តង់ដាអប្បបរមា | ចំនួន | ៦០០ | ១ ៥០០ |
| ១០. ភាគរយសាលាមត្តេយ្យសិក្សារដ្ឋ និងសហគមន៍បានធ្វើតេស្តសមត្ថភាពកុមារអាយុ៥ឆ្នាំ | % | ៣៩,២ | ៤៩,០ |
| ១១. ភាគរយកុមារសាលាមត្តេយ្យសិក្សាមានស្ថានភាពអាហារូបត្ថម្ភប្រសើរឡើង *(មត្តេយ្យសិក្សារដ្ឋ មត្តេយ្យសិក្សាសហគមន៍)* | % | ៣០,០ | ៤០,០ |
| ១២. ភាគរយគ្រូមត្តេយ្យសិក្សាមានគុណវុឌ្ឍិស្របតាមស្តង់ដាជាតិ (រូបមន្ត១២+២) | % | ៦៤,០ | ៧៤,០ |
| ១៣. ចំនួនគ្រូបង្រៀនអប់រំពហុភាសានៅមត្តេយ្យសិក្សា | ចំនួន | ៩៤ | ១២៧ |
| ១៤. ផលធៀបសិស្ស-គ្រូមត្តេយ្យសិក្សារដ្ឋ | ផលធៀប | ៤០,០ | ២៥,០ |
| *គោលនយោបាយទី ២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់* | | | |
| វត្ថុបំណងអនុវិស័យទី៣ ៖ ពង្រឹងសមត្ថភាពអ្នកគ្រប់គ្រងអនុវិស័យ ការអប់រំកុមារតូច និងអនុវត្តការគ្រប់គ្រងតាមសាលារៀន | | | |
| ១៥. ចំនួននាយកសាលាមត្តេយ្យសិក្សារដ្ឋបានទទួលការបំប៉នស្តីពីការគ្រប់គ្រងតាមសាលារៀន( *មត្តេយ្យសិក្សារដ្ឋដាច់ដោយឡែក*) | ចំនួន | ០ | ២០០ |
| ១៦. ចំនួនសាលាមត្តេយ្យសិក្សារដ្ឋបានអនុវត្តការគ្រប់គ្រងតាមសាលារៀន ( *មត្តេយ្យសិក្សារដ្ឋដាច់ដោយឡែក*) | ចំនួន | ៣១ | ៧៩ |

## ៣.១.៤ សកម្មភាពគោលនយោបាយ

*គោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា*

- រៀបចំអនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅតាមស្ថាប័នរដ្ឋ រោងចក្រ សហគ្រាសនៅឆ្នាំ២០២០ (អកត/នក)
- រៀបចំសៀវភៅណែនាំប្រតិបត្តិស្តីពីការអនុវត្តកម្មវិធីអប់រំមាតាបិតានៅឆ្នាំ២០១៩ (អកត)
- រៀបចំប្រកាសស្តីពីការអនុវត្តសាលាមត្តេយ្យសិក្សារដ្ឋនៅឆ្នាំ២០១៩ (អកត/នក)
- រៀបចំសេចក្តីណែនាំស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់គ្រូមត្តេយ្យសិក្សាបង្រៀនពីរវេននៅឆ្នាំ២០១៩ (អកត និងបល)
- រៀបចំសេចក្តីណែនាំស្តីពីការបង្កើតថ្នាក់មត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សានៅឆ្នាំ២០១៩ (អកត/នក)។

*គោលនយោបាយទី ២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់*

- រៀបចំលក្ខខណ្ឌការងារស្តីពីតួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីអប់រំកុមារតូចគ្រប់លំដាប់ថ្នាក់ នៅឆ្នាំ២០១៩ (អកត/បល)
- រៀបចំសេចក្តីណែនាំស្តីពីស្តង់ដាអប្បបរមាសាលាមត្តេយ្យសិក្សានិងថ្នាក់មត្តេយ្យសិក្សារដ្ឋ នៅឆ្នាំ ២០១៩ (អកត)
- រៀបចំសេចក្តីណែនាំស្តីពី ការប្រែក្លាយមត្តេយ្យសិក្សាសហគមន៍ដែលមានស្តង់ដាទៅជាឧបសម្ព័ន្ធនៃគ្រឹះស្ថានសិក្សារដ្ឋ នៅឆ្នាំ២០១៩ (អកត/នក)។

## ៣.១.៥ យុទ្ធសាស្ត្រ និងសកម្មភាព

### វត្ថុបំណងអនុវិស័យទី ១ ៖ បង្កើនលទ្ធភាពទទួលបានសេវាអប់រំកុមារតូចប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន

*យុទ្ធសាស្ត្រ១.១៖ បន្តបង្កើតថ្នាក់មត្តេយ្យសិក្សានៅតាមសាលាបឋមសិក្សា និងអភិវឌ្ឍសាលាមត្តេយ្យសិក្សារដ្ឋ*

- សិក្សាពីតម្រូវការសាងសង់រួមទាំងទឹកស្អាតនិងសម្ភាររូបវន្តអនាម័យ និងសួនកុមារស្របតាមស្តង់ដាសាលាមត្តេយ្យសិក្សា
- ជំរុញការបង្កើតថ្នាក់មត្តេយ្យសិក្សាក្នុងសាលាបឋមសិក្សា
- បង្កើតហេដ្ឋារចនាសម្ព័ន្ធមត្តេយ្យសិក្សានៅតាមតំបន់លិចទឹក និងតំបន់ដាច់ស្រយាលជួបការលំបាក
- សាងសង់ថ្មី និងកែលម្អសម្ភាររូបវន្ត រួមទាំងទឹកស្អាត និងសម្ភាររូបវន្តអនាម័យ សួនកុមារ បំពាក់ឧបករណ៍ការពាររន្ទះ និងឧបករណ៍ស្របតាមស្តង់ដា
- កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសម្ភាររូបវន្តនៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម។

*យុទ្ធសាស្ត្រ១.២៖ អភិវឌ្ឍមត្តេយ្យសិក្សាសហគមន៍ដែលមានស្តង់ដាទៅជាឧបសម្ព័ន្ធនៃគ្រឹះស្ថានសិក្សារដ្ឋ និងប្រែក្លាយមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដាឱ្យទៅជាមត្តេយ្យសិក្សារដ្ឋ*

- ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំស្តីពីការប្រែក្លាយមត្តេយ្យសិក្សាសហគមន៍ទៅជាឧបសម្ព័ន្ធនៃគ្រឹះស្ថានសិក្សារដ្ឋដល់មន្ទីរ និងការិយាល័យអប់រំ យុវជន និងកីឡា
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ សង្ហារិម សួនកុមារ និងសម្ភារក្មេងលេង តាមស្តង់ដារមត្តេយ្យសិក្សា
- អភិវឌ្ឍសមត្ថភាពគ្រូមត្តេយ្យសិក្សាលើការបង្រៀននិងរៀនតាមរយៈវិក្រឹតការ
- រៀបចំផែនទីសិក្សាសម្រាប់ពង្រីកកម្មវិធីអប់រំពហុភាសានៅមត្តេយ្យសិក្សាសហគមន៍។

យុទ្ធសាស្ត្រ១.៣៖ លើកកម្ពស់កម្មវិធីអប់រំមាតាបិតាតាមគ្រឹះស្ថានសិក្សាសាធារណៈ ជាពិសេស អន្តរាគមន៍ការគាំពារកុមារក្នុងរយៈ ពេល ១០០០ថ្ងៃដំបូងនៃកំណើត (អាយុ ០ ទៅ ៣ឆ្នាំ)

- បង្កើតទារកដ្ឋានសម្រាប់កុមារអាយុពី ១ឆ្នាំ ដល់ ៣ឆ្នាំ និងមណ្ឌលថែទាំកុមារ ព្រមទាំងផ្តល់ការពិគ្រោះយោបល់ដល់ស្ត្រីមានផ្ទៃពោះ
- រៀបចំកម្មវិធីប្រឹក្សាយោបល់ពាក់ព័ន្ធការថែទាំនិងអប់រំកូន និងការថែទាំស្ត្រីមានផ្ទៃពោះតាមសាលាមត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសិក្សាសហគមន៍
- ជំរុញការបង្កើតទារកដ្ឋាននៅតាមរោងចក្រ សហគ្រាស និងគ្រឹះស្ថានរដ្ឋ
- រៀបចំកម្មវិធីអប់រំមាតាបិតាឱ្យជួយអប់រំកុមារតូចនៅតំបន់ជនបទ។

យុទ្ធសាស្ត្រ១.៤៖ ពង្រីកកម្មវិធីអប់រំបរិយាបន្នសម្រាប់កុមារមានពិការភាពនៅមត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសិក្សាសហគមន៍

- បំប៉នសមត្ថភាពគ្រូបង្គោល និងគ្រូមត្តេយ្យសិក្សាស្តីពីការអប់រំបរិយាបន្ន
- បង្កើតឧបករណ៍ប្រមូលទិន្នន័យសម្រាប់កម្មវិធីអប់រំបរិយាបន្ននៅតាមសាលាមត្តេយ្យសិក្សា។

យុទ្ធសាស្ត្រ១.៥៖ ផ្តល់ទឹកស្អាត អនាម័យ និងអាហារូបត្ថម្ភ ព្រមទាំងលើកកម្ពស់សុខភាពនៅតាមសាលាមត្តេយ្យសិក្សា

- ពង្រីកការអនុវត្តកម្មវិធីទឹកស្អាត និងអនាម័យនៅតាមសាលាមត្តេយ្យសិក្សា
- សម្របសម្រួលសេវាថែទាំសុខភាពជាមូលដ្ឋានដល់កុមារ និងគ្រូបង្រៀន
- អនុវត្តសាកល្បងកម្មវិធីផ្តល់អាហារនៅតាមសាលាមត្តេយ្យសិក្សា
- ផ្សព្វផ្សាយសេចក្តីណែនាំអំពីសុវត្ថិភាពចំណីអាហារ និងអាហារមានគុណភាព
- ពិនិត្យតាមដាន និងចាត់វិធានការការពារជំងឺឆ្លងនានានៅតាមគ្រឹះស្ថានសិក្សា និងជំរុញការថែទាំបង្គន់អនាម័យ។

**វត្ថុបំណងអនុវិស័យទី ២៖ បន្តអភិវឌ្ឍសាលាមត្តេយ្យសិក្សាឱ្យស្របតាមស្តង់ដាគុណភាព**

យុទ្ធសាស្ត្រទី២.១៖ ពង្រឹងគុណភាពនៃការបណ្តុះបណ្តាល និងរិក្រឹតការគ្រូមត្តេយ្យសិក្សាឱ្យឆ្លើយតបតាមស្តង់ដា

- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាឱ្យស្របតាមក្របខណ្ឌកម្មវិធីសិក្សា និងប្រព័ន្ធក្រេឌីត
- អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាឱ្យឆ្លើយតបបំណិនសតវត្សទី២១ រួមទាំងជំនាញទន់សម្រាប់មត្តេយ្យសិក្សារដ្ឋ និងឯកជន
- អភិវឌ្ឍសមត្ថភាពគ្រូមត្តេយ្យសិក្សារដ្ឋស្តីពីមូលដ្ឋានគ្រឹះនៃការសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា
- រៀបចំសៀវភៅណែនាំសម្រាប់ការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា

- ពិនិត្យតាមដាន និងវាយតម្លៃសមត្ថភាពវិជ្ជាជីវៈរបស់គ្រូមត្តេយ្យសិក្សាចេញថ្មី
- បង្កើនការជ្រើសរើសគ្រូមត្តេយ្យសិក្សាសម្រាប់សាលាមត្តេយ្យសិក្សារដ្ឋ
- បន្តសហការជាមួយដៃគូអភិវឌ្ឍ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសហគមន៍
- គ្រប់គ្រងទិន្នន័យលើការបណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សា
- ជ្រើសរើសសាលាមត្តេយ្យសិក្សាដែលមានសក្តានុពល និងប្រែក្លាយទៅជាមត្តេយ្យសិក្សាធនធាន
- បណ្តុះបណ្តាលគ្រូមត្តេយ្យសិក្សាសម្រាប់សាលាមត្តេយ្យសិក្សាឯកជន និងសហគមន៍។

យុទ្ធសាស្ត្រ២.២៖ ពង្រឹងអធិការកិច្ច និងវាយតម្លៃប្រព័ន្ធសេវាអប់រំកុមារតូច

- អភិវឌ្ឍសមត្ថភាពអធិការស្តីពីអធិការកិច្ចតាមប្រធានបទនិងតាមកាលកំណត់
- អភិវឌ្ឍសមត្ថភាពនាយកសាលាមត្តេយ្យសិក្សាលើស្វ័យវង្វាយតម្លៃសាលារៀន
- អភិវឌ្ឍប្រព័ន្ធធ្វើតេស្តកុមារ (អាយុ៥ឆ្នាំ) ស្របតាមសេចក្តីណែនាំកម្មវិធីសិក្សាថ្មី
- អភិវឌ្ឍប្រព័ន្ធទទួលមតិយោបល់ត្រឡប់ពីរបាយការណ៍អធិការកិច្ច និងវង្វាយតម្លៃ កម្មវិធីសិក្សា ការបណ្តុះបណ្តាលគ្រូ និងការបង្រៀន និងការរៀន។

យុទ្ធសាស្ត្រ ២.៣៖ ពង្រឹងការអនុវត្តកម្មវិធីសិក្សា ការប្រើប្រាស់សម្ភារបង្រៀន និងរៀនសម្រាប់ការអប់រំកុមារតូច ស្របតាមស្តង់ដា

- អភិវឌ្ឍសមត្ថភាពគ្រូមត្តេយ្យសិក្សាស្តីពីការអនុវត្តកម្មវិធីសិក្សាថ្មី
- កែសម្រួលសៀវភៅសិក្សាគោលស្របតាមកម្មវិធីសិក្សាថ្មី
- ពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តម៉ោងសិក្សាគ្រប់មុខវិជ្ជានិងវិធីសាស្ត្របង្រៀន ស្របតាមកម្មវិធីសិក្សាលម្អិត។

**វត្ថុបំណងអនុវិស័យទី៣៖ ពង្រឹងសមត្ថភាពអ្នកគ្រប់គ្រងអនុវិស័យ ការអប់រំកុមារតូចនិងអនុវត្តការគ្រប់គ្រងតាមសាលារៀន**

យុទ្ធសាស្ត្រ៣.១៖ អភិវឌ្ឍសមត្ថភាព និងពង្រឹងយន្តការអនុវត្តតួនាទីនិងទំនួលខុសត្រូវរបស់មន្ត្រីគ្រប់គ្រងអនុវិស័យ ការអប់រំកុមារតូច

- រៀបចំពិពណ៌អំពីតួនាទី មុខតំណែង និងទំនួលខុសត្រូវឱ្យបានច្បាស់លាស់សម្រាប់មន្ត្រីគ្រប់គ្រង
- រៀបចំផែនការអភិវឌ្ឍសមត្ថភាពសម្រាប់មន្ត្រីគ្រប់គ្រងអនុវិស័យការអប់រំកុមារតូច
- រៀបចំប្រព័ន្ធវាយតម្លៃការគ្រប់គ្រងការបំពេញការងារមន្ត្រីអប់រំកុមារតូចគ្រប់លំដាប់ថ្នាក់តាមប្រព័ន្ធព័ត៌មានវិទ្យា
- អភិវឌ្ឍប្រព័ន្ធប្រឹក្សាយោបល់ និងការហ្វឹកហាត់លើការងារគ្រប់គ្រងអប់រំកុមារតូច។

យុទ្ធសាស្ត្រ៣.២៖ ពង្រឹងអភិបាលកិច្ចល្អលើការងារអប់រំកុមារតូច និងការរៀបចំផែនការផ្អែកលើលទ្ធផល ការគ្រប់គ្រង និងការពិនិត្យតាមដាន និងវាយតម្លៃតាមរយៈការអនុវត្តការគ្រប់គ្រងតាមសាលារៀន

- ពង្រឹងប្រព័ន្ធរាយការណ៍លើការរៀបចំផែនការផ្អែកលើលទ្ធផល ការគ្រប់គ្រង និងការពិនិត្យតាមដាន និងវាយតម្លៃ
- អភិវឌ្ឍសមត្ថភាពក្នុងភាពជាអ្នកដឹកនាំនិងគ្រប់គ្រង ការរៀបចំផែនការ ការពិនិត្យតាមដាន និងវាយតម្លៃផ្តោតលើលទ្ធផលមត្តេយ្យសិក្សារដ្ឋ
- អភិវឌ្ឍសមត្ថភាពមន្ត្រីទទួលបន្ទុកការងារអប់រំកុមារតូច និងនាយក នាយិកាសាលាមត្តេយ្យសិក្សាស្តីពីការអនុវត្តការគ្រប់គ្រងសាលារៀន
- អនុវត្តការគ្រប់គ្រងតាមសាលារៀនមត្តេយ្យសិក្សារដ្ឋ។

## ៣.២ អនុវិស័យ ការអប់រំបឋមសិក្សា

### ៣.២.១ ស្ថានភាព

អត្រាចុះឈ្មោះចូលរៀននៅបឋមសិក្សាខ្ពស់ជាង ៩៥ ភាគរយ និងអត្រាពិតនៃការសិក្សាលើស ៩៨ ភាគរយ ចន្លោះពីឆ្នាំសិក្សា ២០១៣-២០១៤ ដល់ឆ្នាំសិក្សា ២០១៧-២០១៨ និងពុំមានគម្លាតរវាងសិស្សស្រី និងសិស្សប្រុស។ អត្រាសិស្សបោះបង់ការសិក្សាបានថយចុះពី ១០,៥ ភាគរយ ឆ្នាំសិក្សា២០១៣-២០១៤ មកត្រឹម ៤,១ ភាគរយ ឆ្នាំសិក្សា ២០១៧-២០១៨ និងអត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិកើនពី ៧៦,៨ ភាគរយ ឆ្នាំសិក្សា២០១៣-២០១៤ ដល់ ៨៦ ភាគរយ ឆ្នាំសិក្សា ២០១៧-២០១៨។

សាលាបឋមសិក្សា ៧៣ ភាគរយ បានអនុវត្តគោលនយោបាយសាលាកុមារមេត្រីកម្រិតមធ្យម និងកម្រិតអភិវឌ្ឍ។ ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សបានបង្ហាញថា ការសិក្សារបស់សិស្សមានភាពល្អប្រសើរ ជាពិសេសមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាថ្នាក់ដំបូង។ ដើម្បីធានាបាននូវការអប់រំបរិយាបន្ន ក្រសួងអប់រំ យុវជន និងកីឡាបានអនុម័ត និងអនុវត្តផែនការសកម្មភាពការអប់រំពហុភាសា និងបានផ្ទេរសាលាពហុភាសាសហគមន៍ ៨០ ឱ្យទៅជាគ្រឹះស្ថានសិក្សារដ្ឋ និងមានផែនការបង្កើនការបង្រៀនភាសាជនជាតិដើមភាគតិចពី ៥ ទៅ ៦ ភាសា ទន្ទឹមនឹងនេះ ក្រសួងបានដាក់ចេញនូវវិធានការបង្កើនចំនួនថ្នាក់ពន្លឿន និងការចូលរៀនឡើងវិញ ដើម្បីធានាបាននូវការអប់រំប្រកបដោយសមធម៌។ ការអប់រំពហុភាសាបាននិងកំពុងពង្រីក ក៏ដូចគ្នាថ្នាក់ពន្លឿនការអប់រំផងដែរ។ សាលារៀនបឋមសិក្សាចំនួន ៣ បានអនុវត្តសាកល្បងការរៀនពេញមួយថ្ងៃ ដោយបានផ្តល់អាហារថ្ងៃត្រង់តាមរយៈការប្រើប្រាស់ស្បៀងអាហារកសិផលសហគមន៍។ ក្រសួងបានសហការជាមួយដៃគូអភិវឌ្ឍ ដើម្បីរៀបចំឱ្យមានសង្គតិភាពនូវវិធីសាស្ត្រអំណាន និងគណិតវិទ្យាដំបូង និងបានរៀបចំកញ្ចប់សម្ភារអំណាន និងបានអនុវត្តសាកល្បងនៅខេត្តចំនួន២ កំពង់ធំ និងសៀមរាប។

ក្រសួងក៏បានបំប៉នគ្រូបង្រៀន អំពីប្រសិទ្ធភាពនៃការរៀននិងបង្រៀន ដូចជា វិធីបង្រៀនតាមបែបការអប់រំវិន័យវិជ្ជមាន និងនាយកសាលាមួយចំនួនបានទទួលការបំប៉នស្តីពីការគ្រប់គ្រងសាលារៀន។

នាយកសាលារៀនបានបំប៉នបន្ថែម អំពីជំនាញដឹកនាំគ្រប់គ្រងសាលារៀន ដើម្បីធានាបានគណនេយ្យភាពក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្តការវាយតម្លៃលទ្ធផលសិក្សា និងស្វ័យភាពក្នុងការប្រើប្រាស់ធនធានសាលារៀន។ ទន្ទឹមនឹងនេះ សុក្រឹតភាពរបស់ទិន្នន័យទាមទារឱ្យមានការខិតខំបន្ថែមទៀត និងសុខដុមនីយកម្មរវាងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំជាមួយនឹងប្រព័ន្ធធានាគុណភាពអប់រំ។

អាទិភាពរបស់អនុវិស័យបានផ្តោតលើការកែលម្អការទទួលបានសេវាអប់រំ ការបញ្ចប់ការសិក្សារបស់សិស្សបឋមសិក្សា ជាពិសេសក្រុមកុមារជួបការលំបាក និងការពង្រឹងគុណភាពអប់រំតាមរយៈកម្មវិធីពង្រឹងការរៀនថ្នាក់ដំបូងរួមមានភាសាខ្មែរ គណិតវិទ្យា និងការជួយគ្រូតាមមុខវិជ្ជា ព្រមទាំងគុណវុឌ្ឍិគ្រូបង្រៀន តាមរយៈការអនុវត្តការគ្រប់គ្រងសាលារៀន។

### ៣.២.២ វត្ថុបំណងអនុវិស័យ

- លើកកម្ពស់ការចូលរៀនរហូតដល់ចប់ថ្នាក់ទី៦នៃបឋមសិក្សាសម្រាប់កុមារទាំងអស់ ជាពិសេសក្រុមកុមារជួបការលំបាក
- កែលម្អការផ្ដល់ជាតុចូលប្រកបដោយគុណភាពនៅបឋមសិក្សា ជាពិសេសកម្មវិធីអំណាន និងគណិតវិទ្យាថ្នាក់ដំបូង
- ពង្រឹងការអនុវត្តស្តង់ដាសាលាបឋមសិក្សាតាមរយៈការគ្រប់គ្រងសាលារៀន។

### ៣.១.២ សូចនាករផលសម្រេច

**តារាងទី៥ ៖ សូចនាករផលសម្រេច និងចំណុចដៅអនុវិស័យ**

| សូចនាករ | ឯកតា | ឆ្នាំគោល ២០១៨ | ចំណុចដៅ ២០២៣ |
|---|---|---|---|
| *គោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា* | | | |
| វត្ថុបំណងអនុវិស័យទី១ ៖ លើកកម្ពស់ការចូលរៀនរហូតដល់ចប់ថ្នាក់ទី៦នៃបឋមសិក្សាសម្រាប់កុមារទាំងអស់ ជាពិសេសក្រុមកុមារជួបការលំបាក | | | |
| ១. អត្រាពិតចូលរៀនថ្មី | % | ៩៥,២ | ៩៨,៥ |
| *ប្រុស* | % | ៩៥,២ | ៩៨,៥ |
| *ស្រី* | % | ៩៥,១ | ៩៨,៥ |
| ២. អត្រាពិតនៃការសិក្សា | % | ៩៧,៨ | ៩៨,៥ |
| *ប្រុស* | % | ៩៧,៦ | ៩៨,៥ |
| *ស្រី* | % | ៩៨,១ | ៩៩,០ |
| ៣. អត្រាបោះបង់ការសិក្សា | % | ៤,១ | ២,៥ |
| *ប្រុស* | % | ៤,៧ | ២,៦ |
| *ស្រី* | % | ៣,៥ | ២,០ |
| ៤. អត្រាត្រួតថ្នាក់ | % | ៦,៥ | ៤,៥ |
| *ប្រុស* | % | ៨,០ | ៥,០ |
| *ស្រី* | % | ៤,៩ | ៣,០ |
| ៥. ចំនួនស្រុកដែលសម្រេចបានអត្រាត្រួតថ្នាក់នៅបឋមសិក្សាតិចជាង ឬស្មើ ១០ ភាគរយ | ចំនួន | ១៧៣ | ១៨៣ |
| ៦. អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | % | ៨២,៧ | ៨៦,២ |
| *ប្រុស* | % | ៧៩,១ | ៨៥,០ |
| *ស្រី* | % | ៨៦,៤ | ៩១,០ |

| | | | |
|---|---|---|---|
| ៧. អត្រាគង់វង្សនៅបឋមសិក្សា | % | ៧៩,៩ | ៨៦,០ |
| *ប្រុស* | % | ៧៦,៥ | ៨៤,៥ |
| *ស្រី* | % | ៨៣,៥ | ៨៩,០ |
| ៨. អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ | % | ៨៦,០ | ៨៩,០ |
| *ប្រុស* | % | ៨៣,៤ | ៨៦,៩ |
| *ស្រី* | % | ៨៨,៥ | ៩១,០ |
| ៩. ភាគរយសិស្សថ្មីថ្នាក់ទី១ ដែលបានឆ្លងកាត់មត្តេយ្យសិក្សា | % | ៦៥,០ | ៧៤,៥ |
| ១០. ភាគរយសាលាកុមារមេត្រី កម្រិតមធ្យមនិងកម្រិតអភិវឌ្ឍ | % | ៨១,៣ | ៨៤,០ |
| ១១. ភាគរយសាលារៀនបឋមសិក្សាមានអគ្គិសនីប្រើប្រាស់ | % | ៤៩,៦ | ៦៥,០ |
| ១២. ភាគរយសាលាបឋមសិក្សាបានអនុវត្តលក្ខខណ្ឌអប្បបរមា ស្ដីពីទឹកស្អាត និងអនាម័យតាមសាលារៀន | | | |
| *កម្រិត ១* | % | ៤៥,៣ | ៥៤,២ |
| *កម្រិត ២* | % | ២២,៤ | ២៤,០ |
| *កម្រិត ៣* | % | ១,៤ | ១,៨ |
| ១៣. ភាគរយសាលាបឋមសិក្សាមាន | | | |
| *បង្គន់អនាម័យ* | % | ៩០,៦ | ៩៥,០ |
| *ទឹកស្អាតសម្រាប់ទទួលទាន* | % | ៥៩,៣ | ៦៥,០ |
| *កន្លែងសម្អាតដៃ* | % | ៥៦,៧ | ៦៥,០ |
| *ប្រអប់សង្គ្រោះបឋម* | % | ៥៤,០ | ៦០,០ |
| ១៤. ចំនួនសិស្សបឋមសិក្សាបានទទួលអាហារនៅតាមសាលារៀន | ចំនួន | ៤០ ០០០ | ១៦០ ០០០ |
| ១៥. ចំនួនសិស្សទទួលអាហារូបករណ៍នៅបឋមសិក្សា | ចំនួន | ៨៦ ១២៦ | ១០០ ០០០ |
| ១៦. ចំនួនគ្រូបង្រៀនអប់រំពហុភាសានៅបឋមសិក្សា | ចំនួន | ១៩៧ | ២៥៣ |
| ១៧. ចំនួនគ្រូបង្រៀនទទួលបានការបណ្ដុះបណ្ដាលកម្រិតឌីផ្លូម៉ាស្ដីពីការអប់រំពិសេស នៅវិទ្យាស្ថានជាតិអប់រំពិសេស | ចំនួន | - | ១០០ |
| **វត្ថុបំណងអនុវិស័យទី ២៖ កែលម្អការផ្ដល់ធាតុចូលប្រកបដោយគុណភាពនៅបឋមសិក្សា** | | | |
| ១៨. ផលធៀបសិស្ស-គ្រូមានគុណវុឌ្ឍិ | ផលធៀប | ៦១ | ៤០ |
| ១៩. ភាគរយគ្រូបង្រៀនបឋមសិក្សាមានសញ្ញាបត្រតាមស្តង់ដា (សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ + ២) | % | ៧៣,០ | ៧៨,០ |
| ២០. ចំនួនគ្រូបង្រៀនបឋមសិក្សាទទួលការបំប៉នសមត្ថភាពបន្ថែម ក្នុងឆ្នាំនីមួយៗ | | | |
| *កញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង* | ចំនួន | ១ ៤៣០ | ១៨ ៩៣០ |
| *កញ្ចប់សម្ភារៈគណិតវិទ្យាថ្នាក់ដំបូង* | ចំនួន | ១៤៧ | ១៤ ៩៩៧ |
| *ការបំប៉នសមត្ថភាពផ្សេងទៀត* | ចំនួន | ២៥០ | ១៥ ២៥០ |
| ២១. ភាគរយគ្រូបង្រៀនបឋមសិក្សាដែលបានបញ្ចប់បរិញ្ញាបត្រនៅវិទ្យាស្ថានគរុកោសល្យ | % | 0.0 | ៧,០ |

| | | | |
|---|---|---|---|
| ២២. ភាគរយសិស្សបឋមសិក្សាទទួលបានសៀវភៅសិក្សាគោល ១ សម្រាប់ ក្នុងម្នាក់ | % | ៩០,០ | ១០០ |
| ២៣. ចំនួនសាលាបឋមសិក្សាមានបន្ទប់កុំព្យូទ័រសម្រាប់សិស្ស | ចំនួន | ២០ | ៥២០ |
| ២៤. ចំនួនសាលាបឋមសិក្សាមានបណ្ណាល័យតាមស្តង់ដា | ចំនួន | ១ ៥០០ | ៤ ០០០ |
| *គោលនយោបាយទី២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់* | | | |
| វត្ថុបំណងអនុវិស័យទី ៣៖ ពង្រឹងការអនុវត្តស្តង់ដាបឋមសិក្សាតាមរយៈការគ្រប់គ្រងតាមសាលារៀន | | | |
| ២៥. ចំនួននាយកបឋមសិក្សាបានទទួលការបំប៉នស្តីពីការគ្រប់គ្រងតាមសាលារៀន | ចំនួន | ៤៧២ | ២ ៤៧២ |
| ២៦. ចំនួនសាលាបឋមសិក្សាអនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀនពេញលេញ | ចំនួន | ០ | ៥០០ |

### ៣.១.៣ សកម្មភាពគោលនយោបាយ

*គោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា*

- រៀបចំលក្ខន្តិកៈស្តីពីការបង្កើតគ្រឹះស្ថានបឋមសិក្សារដ្ឋ និងឯកជននៅឆ្នាំ២០១៩ (នក)
- ពិនិត្យឡើងវិញនូវការគ្រប់គ្រង និងការបែងចែកសៀវភៅសិក្សាគោលនៅឆ្នាំ២០១៩ (បស)
- អភិវឌ្ឍក្របខណ្ឌជាតិស្តីពីអាហារូបករណ៍នៅឆ្នាំ២០១៩ (បស/គនប)
- រៀបចំគោលនយោបាយស្តីពីអាហារូបករណ៍នៅឆ្នាំ ២០១៩ (គនប/បស)
- អភិវឌ្ឍស្តង់ដាអេកូមេត្រីសម្រាប់មត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សានៅឆ្នាំ២០២០ (សណ)
- រៀបចំសេចក្តីណែនាំស្តីពីការបង្រៀន និងរៀនពេញមួយថ្ងៃនៅសាលាបឋមសិក្សានៅឆ្នាំ ២០២០ (បស)
- អភិវឌ្ឍគោលនយោបាយស្តីពីសាលាបឋមសិក្សាជំនាន់ថ្មី ឱ្យឆ្លើយតបនឹងស្តង់ដាសាលាបឋមសិក្សា នៅឆ្នាំ២០២០ (បស/គនប)
- រៀបចំកែលម្អគោលនយោបាយស្តីពីកម្មវិធីសាលាកុមារមេត្រី ផ្សារភ្ជាប់ទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ នៅឆ្នាំ២០២០ (បស/គនប)
- រៀបចំគោលនយោបាយស្តីពីស្បៀងអាហារតាមសាលារៀន និងអាហារូបត្ថម្ភប្រើប្រាស់កសិផលសហគមន៍ នៅឆ្នាំ២០២០ (គនប/បស)
- អភិវឌ្ឍគោលនយោបាយ ស្តីពីនីតិវិធីការពារសុវត្ថិភាពកុមារសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា នៅឆ្នាំ២០២២ (គនប/បស)
- រៀបចំគោលការណ៍ណែនាំស្តីពីការប្រើប្រាស់គ្រូបង្រៀន និងការរៀបចំថ្នាក់មុខវិជ្ជាសម្រាប់ការបង្រៀនភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មានថ្នាក់ទី ៤ ដល់ ៦ នៅឆ្នាំ២០២០ (បស)

- រៀបចំឯកសារណែនាំស្តីពីការកែលម្អការរៀន និងបង្រៀនមុខវិជ្ជាគោល (៤មុខវិជ្ជា) នៅឆ្នាំ ២០២០ (បស)
- រៀបចំឯកសារណែនាំស្តីពីការកែលម្អការរៀន និងបង្រៀនភាសាបរទេសនៅឆ្នាំ២០២១ (បស)
- រៀបចំឯកសារណែនាំស្តីពីការកែលម្អការរៀននិងបង្រៀនបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ នៅឆ្នាំ២០២១ (បស)
- រៀបចំផែនការសកម្មភាពស្តីពី ការអប់រំពហុភាសា ២០១៩-២០២៣ នៅឆ្នាំ២០១៩ (អព)
- រៀបចំផែនការសកម្មភាពស្តីពី ការអប់រំបរិយាបន្ន ២០១៩-២០២៣ នៅឆ្នាំ២០១៩ (អព)។

*គោលនយោបាយទី២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់*

- កែសម្រួលគោលនយោបាយស្តីពី គន្លងអាជីពគ្រូបង្រៀន នៅឆ្នាំ២០២០ (បវ)
- រៀបចំសេចក្តីណែនាំស្តីពី ការបង្កើតនិងដំណើរការមុខងារគណៈកម្មការគ្រប់គ្រងសាលារៀន នៅឆ្នាំ២០២០ (បស)
- ពិនិត្យឡើងវិញគោលនយោបាយ និងផែនការសកម្មភាពរបស់សាលាកុមារមេត្រីនៅក្នុងបរិបទគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព-ការអប់រំ ដោយពង្រឹងក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ និងកម្រងសាលារៀន (បស)
- រៀបចំសេចក្តីណែនាំស្តីពី សៀវភៅបញ្ជាក់អាជីព និងប្រព័ន្ធក្រេឌីត នៅឆ្នាំ២០២០ (បវ)។

## ៣.១.៤ យុទ្ធសាស្ត្រ និងសកម្មភាព

**វត្ថុបំណងអនុវិស័យទី ១៖ លើកកម្ពស់ការចូលរៀនរហូតដល់ចប់ថ្នាក់ទី៦នៃបឋមសិក្សាសម្រាប់កុមារទាំងអស់ ជាពិសេសក្រុមកុមារជួបការលំបាក**

យុទ្ធសាស្ត្រ១.១៖ ពង្រីកវិធានការនានាដើម្បីបង្កើនការចូលរៀន វត្តមានទៀងទាត់ និងរៀនចប់បឋមសិក្សា ជាពិសេសក្រុមកុមារជួបការលំបាក

- ផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ សិស្សពូកែ និងសិស្សមានពិការភាព
- ពង្រីក និងការធានានិរន្តរភាព និងកម្មវិធីផ្តល់ស្បៀងអាហារតាមសាលារៀន
- ពង្រីកការផ្តល់អាហារនៅតាមសាលារៀនបឋមសិក្សា ជាពិសេសសម្រាប់កុមារជួបការលំបាក
- ធ្វើបច្ចុប្បន្នកម្មផែនទីខ្នងផ្ទះ ដែលបង្ហាញកុមារក្នុងវ័យសិក្សា តាមរយៈកិច្ចសហការជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់
- អនុវត្តកម្មវិធីជួយសិស្សរៀនយឺត
- លើកកម្ពស់ការរៀបចំព្រឹត្តិការណ៍សាលារៀនជាមួយសហគមន៍ (ដូចជាទិវាអំណានជាតិ ពិធីបុណ្យភូមិមានព្រះសង្ឃ ឬជួបជាមួយជនល្បីឈ្មោះជាដើម)
- អនុវត្តកម្មវិធីអប់រំបរិយាបន្នសម្រាប់កុមារមានពិការភាព

- អនុវត្តកម្មវិធីពន្លឿនការសិក្សា
- អនុវត្តកម្មវិធីអប់រំពហុភាសាសម្រាប់កុមារជនជាតិដើមភាគតិច។

យុទ្ធសាស្ត្រ១.២៖ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបរិស្ថានសិក្សាស្អាតនិងមានសុវត្ថិភាពស្របតាមស្តង់ដាសាលាបឋមសិក្សាជាពិសេសសាលារៀនមិនគ្រប់កម្រិតនិងសាលារៀនជួបការលំបាក

- បន្តចលនាប្រឡងប្រណាំងសាលារៀនស្អាត
- ដំណើការវិទ្យាស្ថានអប់រំពិសេស និងការធានានិរន្តរភាព វិទ្យាល័យអប់រំពិសេស
- បន្តពង្រឹងកម្មវិធីអប់រំពហុភាសា និងការបន្តផ្ទេរសាលាពហុភាសាស្តង់ដាទៅជាគ្រឹះស្ថានសិក្សារដ្ឋ
- ផ្តល់ឧបករណ៍គ្រប់គ្រាន់ស្របតាមស្តង់ដាដល់សាលារៀនរួមមាន បន្ទប់រៀន សម្ភារ រដ្ឋបាល និងសួនកុមារ
- ធ្វើឱ្យប្រសើរឡើងនូវទឹកស្អាត និងអនាម័យ ដោយរួមបញ្ចូលទាំងការផ្តល់សម្ភាររូបវន្តចាំបាច់ និងប្រអប់សង្គ្រោះបឋមតាមសាលារៀន និងការពង្រឹងការអប់រំពីសុខភាពផ្លូវភេទនិងសុខភាពបន្តពូជជាផ្នែកមួយនៃមុខវិជ្ជាអប់រំសុខភាព
- កែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសម្ភារបរិក្ខារសម្រាប់សាលាបឋមសិក្សា ជាពិសេសសម្រាប់សាលារៀនមិនគ្រប់កម្រិតនិងសាលារៀនជួបការលំបាក
- បន្តអនុវត្តកម្មវិធីសុវត្ថិភាព និងសុខុមាលភាពចំណីអាហារតាមគ្រឹះស្ថានសិក្សា
- បំពាក់ឧបករណ៍ការពាររន្ទះ
- កែលម្អបរិស្ថានសាលារៀនតាមរយៈការផ្តល់សួនកុមារ ការគ្រប់គ្រងសំរាម និងសួនបន្លែជីវៈចម្រុះ។

យុទ្ធសាស្ត្រ១.៣៖ លើកកម្ពស់សុខភាពរបស់កុមារនៅតាមសាលាបឋមសិក្សា

- អនុវត្តឱ្យមានប្រសិទ្ធភាពនៃគោលនយោបាយជាតិស្តីពីសុខភាពសិក្សា
- បំប៉នគ្រូទទួលបន្ទុកការងារសុខភាពសិក្សា ដើម្បីបង្រៀនមុខវិជ្ជា អប់រំសុខភាព ដោយរួមបញ្ចូលទាំងការអប់រំសុខភាពបន្តពូជនិងសុខភាពផ្លូវភេទ
- អនុវត្តកម្មវិធីគាំទ្រកុមារខ្សោយគំហើញនិងស្តាប់
- ផ្តល់សេវាថែរក្សាសុខភាពចាំបាច់ សហការជាមួយមណ្ឌលសុខភាព ពិនិត្យសុខភាព ចាក់វ៉ាក់សាំង និងថ្នាំបង្ការ ...)។

## វត្ថុបំណងអនុវិស័យទី ២៖ កែលម្អការផ្តល់ជាតុចូលប្រកបដោយគុណភាពនៅបឋមសិក្សា

យុទ្ធសាស្ត្រ២.១៖ លើកកម្ពស់គុណវុឌ្ឍិរបស់គ្រូបង្រៀនដែលមានស្រាប់និងពង្រឹងការពង្រាយគ្រូ

- បន្តអនុវត្តប្រព័ន្ធបណ្តុះបណ្តាលគ្រូបង្រៀន ១២ បូក ២ និង ១២ បូក ៤
- អភិវឌ្ឍកម្មវិធីសិក្សាបណ្តុះបណ្តាលគ្រូស្របតាមក្របខណ្ឌការអប់រំចំណេះទូទៅ
- ពង្រឹងសមត្ថភាពសាលាគរុកោសល្យ និងវិក្រឹតការ វិទ្យាស្ថានគរុកោសល្យ
- ពិនិត្យគោលការណ៍ យន្តការ និងសេចក្តីណែនាំស្តីពីការពង្រាយគ្រូ

- ផ្តល់ការបណ្តុះបណ្តាលស្តីពីការអប់រំបរិយាបន្នដល់គរុសិស្ស
- ការបញ្ចូលការបណ្តុះបណ្តាលវិធីសាស្ត្រអំណានដំបូង គណិតវិទ្យាដំបូង និងការគ្រប់គ្រងតាមសាលារៀនទៅក្នុងកម្មវិធីអប់រំគ្រូបង្រៀននៅតាមសាលាគរុកោសល្យ និងវិក្រឹតការខេត្ត
- បន្តចលនាប្រឡងប្រណាំងគ្រូបង្រៀនល្អ។

## យុទ្ធសាស្ត្រ២.២៖ ពង្រឹងគុណភាពនៃការបណ្តុះបណ្តាលសម្រាប់គ្រូបឋមសិក្សា

- បណ្តុះបណ្តាលវិធីសាស្ត្រអំណាន និងគណិតវិទ្យាដំបូងដល់គ្រូបង្រៀនបឋមសិក្សា
- បណ្តុះបណ្តាលស្តីពីការគ្រប់គ្រងតាមសាលារៀនប្រកបដោយប្រសិទ្ធភាពខ្ពស់
- អនុវត្តគោលនយោបាយគន្លងអាជីពរបស់គ្រូបង្រៀន និងគោលនយោបាយអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនជាប្រចាំ
- រៀបចំឯកសារគាំទ្រការបង្រៀន និងការរៀនសម្រាប់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន
- អនុវត្តកម្មវិធីរយៈពេលខ្លីនិងវែងស្តីពីការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនជាប្រចាំ
- ស្រាវជ្រាវនិងអភិវឌ្ឍវិធីសាស្ត្របង្រៀនបច្ចុប្បន្នរួមមានបំណិនគិតលំដាប់ខ្ពស់ (ការគិតហ្មត់ចត់ និងបង្កើតថ្មី) ការសិក្សាតាមបែបរិះរក គោលវិធីបង្រៀនស្វែម ស្របតាមក្របខណ្ឌសមត្ថភាពគ្រូបង្រៀននៃសតវត្សរ៍ទី ២១
- អភិវឌ្ឍសៀវភៅណែនាំស្តីពីវិធីសាស្ត្របង្រៀនតាមមុខវិជ្ជា
- អនុវត្តវិធីសាស្ត្របង្រៀន និងរៀនអំណាន និងគណិតវិទ្យាថ្នាក់ដំបូង (ទី១ ទី២ និងទី៣)
- បណ្តុះបណ្តាលគ្រូភាសាអង់គ្លេសសម្រាប់សាលាបឋមសិក្សា (ថ្នាក់ទី ៤ ដល់ទី ៦)
- ចងក្រងមេរៀន និងចែករំលែកបទពិសោធន៍អំពីវិធីសាស្ត្របង្រៀនល្អៗ ការផ្លាស់ប្តូរបទពិសោធន៍គ្នាក្នុងចំណោមគ្រូបង្រៀន និងទស្សនកិច្ចសិក្សា
- បំប៉នគ្រូបឋមសិក្សាស្តីពីការអប់រំបរិយាបន្ន
- អនុវត្តកម្មវិធីគ្រូជួយគ្រូដើម្បីធានាដល់ការអភិវឌ្ឍវិជ្ជាជីវៈ និងការអនុវត្តចំណេះដឹងទទួលបានប្រើយន្តការគ្រូជួយគ្រូក្នុងកម្រងសាលារៀន។

## យុទ្ធសាស្ត្រ២.៣៖ កែលម្អការផ្គត់ផ្គង់ និងការប្រើប្រាស់សៀវភៅសិក្សាគោលនិងសម្ភាររៀន និងបង្រៀន

- ប្រមូលទិន្នន័យស្តីពីការប្រើប្រាស់សៀវភៅសិក្សាគោលតាមមុខវិជ្ជា
- អនុវត្តគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងសៀវភៅសិក្សាគោល
- កៀរគរសប្បុរសជនដើម្បីជួយឧបត្ថម្ភសៀវភៅសិក្សានិងសៀវភៅអានបន្ថែម
- វិភាជន៍ថវិកាសម្រាប់ទិញសម្ភារអំណាននៅតាមសាលារៀន
- រៀបចំដាក់ឱ្យប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានក្នុងការអភិវឌ្ឍ និងផ្គត់ផ្គង់សៀវភៅសិក្សាគោល
- សាលារៀនត្រូវរៀបចំកន្លែងអាន ឬ បណ្ណាល័យឱ្យបានសមស្រប ដើម្បីឱ្យសិស្សអាន និងចូលចិត្តអានសៀវភៅ

- ផ្តល់សម្ភារបង្រៀន-រៀនសម្បូរបែបគ្រប់មុខវិជ្ជាដល់គ្រូ និងសិស្សទាំងអស់ រួមទាំងឧបករណ៍ជំនួយដល់សិស្សមានតម្រូវការពិសេស
- អភិវឌ្ឍសម្ភារអំណានបន្ថែម និងជំរុញគ្រូឱ្យប្រើប្រាស់។

យុទ្ធសាស្ត្រ២.៤៖ ពង្រឹងការអនុវត្តអធិការកិច្ចផ្ទៃក្នុង អធិការកិច្ចផ្ទៃក្រៅ និងអធិការកិច្ចតាមតំបន់

- បង្កើនចំនួនអធិការផ្តោតលើតំបន់មានតម្រូវការច្រើនជាងគេ
- កែលម្អឧបករណ៍អធិការកិច្ចស្របតាមស្តង់ដាសាលាបឋមសិក្សា
- ដាក់ឱ្យអនុវត្តឧបករណ៍ជាបណ្តើរៗដោយផ្តោតលើស្តង់ដាសាលាបឋមសិក្សា
- បណ្តុះបណ្តាលអធិការស្តីពីប្រព័ន្ធអធិការកិច្ចក្នុងបរិបទតំបន់និងសកលលោក
- បណ្តុះបណ្តាលអធិការអប់រំថ្មី តាមរយៈកិច្ចសហប្រតិបត្តិការរវាងនាយកដ្ឋានធានាគុណភាពអប់រំ និងវិទ្យាស្ថានជាតិអប់រំ
- ពង្រឹងសមត្ថភាពក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌស្តីពីប្រព័ន្ធអធិការកិច្ចធានាគុណភាពអប់រំ សម្រាប់រាជធានី ខេត្ត
- ផ្សព្វផ្សាយរបាយការណ៍លទ្ធផលអធិការកិច្ច និងការវាយតម្លៃលទ្ធផលសិក្សាដល់នាយកដ្ឋានជំនាញ ដើម្បីកែលម្អការបង្រៀននិងរៀននៅសាលារៀន
- វង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី ៣ និង ៦ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា
- វង្វាយតម្លៃអំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ទី១ ទី២ និងទី៣ វង្វាយតម្លៃថ្នាក់រៀន និងសាលារៀន
- ប្រើប្រាស់ស្វ័យវង្វាយតម្លៃសាលារៀន ដើម្បីកែលម្អផែនការអភិវឌ្ឍសាលារៀន។

យុទ្ធសាស្ត្រ២.៥៖ ពង្រឹងតួនាទីនិងការទទួលខុសត្រូវរបស់ក្រុមការងារបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុកក្នុងការពិនិត្យតាមដាន និងវាយតម្លៃការងាររបស់គណៈកម្មការគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសិស្ស

- បំប៉នក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុក ស្តីពីការប្រើឧបករណ៍ពិនិត្យតាមដាននិងវាយតម្លៃផ្អែកលើលទ្ធផល
- ផ្សព្វផ្សាយរបាយការណ៍លទ្ធផលស្តីពីការពិនិត្យតាមដានថ្នាក់រាជធានី ខេត្ត តាមដានការបំពេញការងារក្រុមការងារបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុក
- ពិនិត្យឡើងវិញនូវលទ្ធផលការងារប្រចាំឆមាស និងប្រចាំឆ្នាំរបស់ក្រុមការងារបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុក
- ផ្លាស់ប្តូរបទពិសោធន៍ជាមួយក្រុមការងារបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុកនៅតាមរាជធានី-ខេត្ត។

### វត្ថុបំណងអនុវិស័យទី៣ ៖ ពង្រឹងការអនុវត្តស្តង់ដាសាលាបឋមសិក្សាតាមរយៈការអនុវត្តការគ្រប់គ្រងសាលារៀន

យុទ្ធសាស្ត្រ៣.១៖ រៀបចំ និងចាប់ផ្តើមអនុវត្តក្របខណ្ឌការគ្រប់គ្រងតាមសាលារៀននៅសាលាបឋមសិក្សាគោលដៅ

- ពង្រីកការអនុវត្តការគ្រប់គ្រងសាលារៀននៅតាមគ្រឹះស្ថានសិក្សាគោលដៅ
- បណ្តុះបណ្តាលនាយកសាលារៀន ស្តីពីភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងសាលារៀន
- បន្តចលនាប្រឡងប្រណាំងនាយកល្អ
- ពង្រឹងសមត្ថភាពស្ថាប័ននៃនាយកដ្ឋានជំនាញ ជាពិសេសអ្នកឯកទេសផ្នែកអំណាន និងគណិតវិទ្យាថ្នាក់ដំបូង
- បណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ជាតិ ដើម្បីពង្រឹងការគ្រប់គ្រងអប់រំគ្រប់កម្រិត
- រៀបចំផែនការសម្រាប់អនុវត្តការគ្រប់គ្រងតាមសាលារៀន
- ផលិតសៀវភៅណែនាំស្តីពី ការគ្រប់គ្រងតាមសាលារៀនដោយផ្សារភ្ជាប់ជាមួយនឹងស្តង់ដាសាលាបឋមសិក្សា
- បំប៉នបុគ្គលិកគ្រប់គ្រង និងគណៈកម្មការគ្រប់គ្រងសាលារៀនស្តីពីការគ្រប់គ្រងសាលារៀន
- បំប៉នគណៈកម្មការគ្រប់គ្រងសាលារៀនស្តីពីសហគមន៍ចូលរួមរៀបចំផែនការអភិវឌ្ឍសាលារៀនតាមស្តង់ដា។

យុទ្ធសាស្ត្រ៣.២៖ ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធដើម្បីគាំទ្រ និងកៀរគរធនធានសម្រាប់ការអភិវឌ្ឍសាលារៀន

- រៀបចំបណ្តាញជាមួយសហគមន៍ អាជ្ញាធរ និងម្ចាស់ជំនួយ ដើម្បីចូលរួមអភិវឌ្ឍសាលារៀន
- បំប៉នគណៈកម្មការគ្រប់គ្រងសាលារៀនដើម្បីកៀរគរធនធានពីសហគមន៍ អ្នកផ្តល់ជំនួយ និងដៃគូអភិវឌ្ឍនានា
- បង្កើតនិងកំណត់តួនាទីភារកិច្ចរបស់គណៈកម្មការគ្រប់គ្រងសាលារៀន ដើម្បីទទួលនិងបែងចែកថវិកាសម្រាប់អភិវឌ្ឍសាលារៀន
- ផ្សព្វផ្សាយជាសាធារណៈស្តីពីគោលការណ៍អភិបាលកិច្ចសាលារៀន (តម្លាភាព និងគណនេយ្យភាព)
- បង្កើតសាកល្បងក្រុមប្រឹក្សាភិបាលសាលារៀននៅ៖ (១) សាលារៀនជំនាន់ថ្មី (២) សាលារៀនពេញមួយថ្ងៃ (៣) សាលារៀនមាននាយកល្អ គ្រូល្អ និងសាលារៀនស្អាត
- រៀបចំផែនការអភិវឌ្ឍសាលារៀនដោយមានការចូលរួមពីវិស័យសាធារណៈ ឯកជន ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធ
- ផ្សព្វផ្សាយជាសាធារណៈស្តីពីការវាយតម្លៃលទ្ធផលសិក្សាប្រចាំខែ យ៉ាងតិច២ដងក្នុងមួយឆ្នាំ
- សហគមន៍ពិនិត្យតាមដានគ្រប់សកម្មភាពសាលារៀនដើម្បីធានាភាពជាម្ចាស់។

## ៣.៣ អនុវិស័យការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស

### ៣.៣.១ សាវតារ

ការអនុវត្តកំណែទម្រង់ប្រឡងបានលើកទឹកចិត្តឱ្យគ្រូខំប្រឹងបង្រៀន សិស្សខំប្រឹងរៀន មាតាបិតាជួយគាំទ្រ និងអាជ្ញាធរគ្រប់កម្រិតបានចូលរួម ក្នុងការកែលម្អគុណភាពអប់រំនៅកម្រិតមធ្យមសិក្សា។

ការគ្រប់គ្រងសាលារៀននៅតាមគ្រឹះស្ថានសិក្សាចំនួន ១០០ បាននាំមកនូវលទ្ធផលវិជ្ជមាន និងក្លាយជាគំរូសម្រាប់អនុវត្តនៅតាមគ្រឹះស្ថានសិក្សាដទៃទៀត។

រយៈពេល៥ឆ្នាំកន្លងមក ក្រសួងបានយកចិត្តទុកដាក់ដល់ការបង្កើនការចូលរៀន សមធម៌ក្នុងការចូលរៀនកម្រិតមធ្យមសិក្សា និងការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ និងការផ្តល់ប្រឹក្សាអាជីព ដើម្បីកាត់បន្ថយការបោះបង់ការសិក្សា។ ជាលទ្ធផល ការចូលរៀនមានការកើនឡើង សិស្សក្រីក្របានទទួលអាហារូបករណ៍តាំងពីថ្នាក់ទី៧ និងបន្តការសិក្សារហូតដល់ទី១២ និងអត្រាបោះបង់ការសិក្សាបានថយចុះ។ ក្រសួងបានធ្វើតេស្តវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិសិស្សថ្នាក់ទី៨ លើមុខវិជ្ជា ភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា និងបានចូលរួមកម្មវិធីអន្តរជាតិស្តីពីវាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍ ដោយទទួលលទ្ធផលថា សិស្សកម្ពុជាអាយុ១៥ឆ្នាំ មានសមត្ថភាពអំណានទាបជាងមធ្យមភាគនៃប្រទេសកំពុងអភិវឌ្ឍជាសមាជិកចំនួន៩ ប៉ុន្តែលើសកម្រិតនៃប្រទេសនៅទ្វីបអាហ្វ្រិក និងមានសមត្ថភាពខាងផ្នែកវិទ្យាសាស្ត្រ និងគណិតវិទ្យា ស្មើនឹងមធ្យមភាគ។

ក្នុងរយៈពេល ៥ឆ្នាំបន្ទាប់ អនុវិស័យការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេសបន្តកែលម្អគុណភាពនៃការអប់រំ ដោយផ្តោតលើកិច្ចការចម្បងៗគឺ (១) ការគ្រប់គ្រងសាលារៀនផ្តោតការបង្រៀនលើវិទ្យាសាស្ត្របច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (២) សាលារៀនជំនាន់ថ្មី (៣) បំណិនការងារនៅសាលាមធ្យមសិក្សា និង (៤) ភាសាអង់គ្លេស និងភាសាបរទេសផ្សេងទៀត តាមតម្រូវការនៅមូលដ្ឋានសាលារៀនរួមជាមួយបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។

### ៣.៣.២ ទិសដៅគោលនយោបាយអនុវិស័យ

- លើកកម្ពស់ការចូលរៀន និងរក្សាសិស្សឱ្យបានគង់វង្ស ប្រកបដោយសមធម៌ និងបរិយាបន្ននៅមធ្យមសិក្សា
- កែលម្អគុណភាពបង្រៀននិងរៀនឱ្យស្របតាមជំនាញសតវត្សទី២១
- ពង្រឹងភាពជាអ្នកដឹកនាំ និងគ្រប់គ្រងនៅមធ្យមសិក្សា។

## ៣.៣.៣ សូចនាករផលសម្រេច

### តារាងទី៦ ៖ សូចនាករផលសម្រេច និងចំណុចដៅអនុវិស័យ

| សូចនាករ | | ឯកតា | ឆ្នាំគោល ២០១៨ | ចំណុចដៅ ២០២៣ |
|---|---|---|---|---|
| *គោលនយោបាយទី១ ៖ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា* | | | | |
| វត្ថុបំណងអនុវិស័យទី ១៖ លើកកម្ពស់ការចូលរៀននិងរក្សាសិស្សឱ្យបានគង់វង្ស ប្រកបដោយសមធម៌ និងបរិយាបន្ន នៅមធ្យមសិក្សា | | | | |
| ១. | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | % | ៥៩,២ | ៦៦,៧ |
| | *ប្រុស* | % | ៥៥,២ | ៦៥,០ |
| | *ស្រី* | % | ៦៣,៤ | ៧២,០ |
| ២. | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | % | ២៨,៥ | ៣៨,០ |
| | *ប្រុស* | % | ២៦,៣ | ៣៦,១ |
| | *ស្រី* | % | ៣០,៩ | ៤០,០ |
| ៣. | អត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅទុតិយភូមិ | % | ៧៦,៨ | ៨៦,០ |
| | *ប្រុស* | % | ៧៤,២ | ៨៥,០ |
| | *ស្រី* | % | ៧៩,២ | ៨៧,០ |
| ៤. | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | % | ៤៦,៥ | ៥២,៦ |
| | *ប្រុស* | % | ៤២,៣ | ៥០,០ |
| | *ស្រី* | % | ៥១,១ | ៥៦,៣ |
| ៥. | អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | % | ១៥,៤ | ៩,០ |
| | *ប្រុស* | % | ១៦,៦ | ៩,៥ |
| | *ស្រី* | % | ១៤,២ | ៨,០ |
| ៦. | អត្រាគង់វង្សនៅមធ្យមសិក្សាបឋមភូមិ | % | ៥៣,១ | ៥៧,៦ |
| | *ប្រុស* | % | ៤៨,៣ | ៥៣,១ |
| | *ស្រី* | % | ៥៨,២ | ៦២,៥ |
| ៧. | អត្រាគង់វង្សនៅមធ្យមសិក្សាទុតិយភូមិ | % | ៣៤,៩ | ៤១,២ |
| | *ប្រុស* | % | ៣០,៤ | ៤០,៦ |
| | *ស្រី* | % | ៣៩,៨ | ៤៣,៥ |
| ៨. | ចំនួនក្រុង-ស្រុកដែលមានអត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិច្រើនជាង ១៨,៩ ភាគរយ | ចំនួន | ៥០ | ២១ |
| ៩. | ចំនួនសិស្សអាហារូបករណ៍នៅមធ្យមសិក្សាបឋមភូមិ | ចំនួន | ៧២ ០៧១ | ៧៧ ៤១៨ |
| ១០. | ភាគរយសាលាមធ្យមសិក្សាអនុវត្តសាលាកុមារមេត្រី | % | ២៣,៥ | ២៥,០ |

| | | | |
|---|---|---|---|
| ១១. ភាគរយសាលាមធ្យមសិក្សាបានអនុវត្តលក្ខខណ្ឌអប្បបរមា ស្តីពីទឹកស្អាត និងអនាម័យតាមសាលារៀន | | | |
| អនុវិទ្យាល័យ | | | |
| *កម្រិត ១* | % | ៤៨,៣ | ៦៦,០ |
| *កម្រិត ២* | % | ១២,៥ | ១៤,០ |
| *កម្រិត ៣* | % | ១,៥ | ២,០ |
| វិទ្យាល័យ | | | |
| *កម្រិត ១* | % | ៤៨,៨ | ៥០,០ |
| *កម្រិត ២* | % | ២៤,៨ | ២៨,០ |
| *កម្រិត ៣* | % | ១,៨ | ២,០ |
| ១២. ភាគរយអនុវិទ្យាល័យមាន ៖ | | | |
| *បង្គន់អនាម័យ* | % | ៩០,៣ | ៩៥,០ |
| *ទឹកស្អាតសម្រាប់ទទួលទាន* | % | ៤២,៤ | ៥០,០ |
| *ឧបករណ៍លាងសម្អាតដៃ* | % | ៤០,៩ | ៤៥,០ |
| *ប្រអប់សង្គ្រោះបឋម* | % | ២២,០ | ៣០,០ |
| ១៣. ភាគរយវិទ្យាល័យមាន ៖ | | | |
| *បង្គន់អនាម័យ* | % | ៩៧,១ | ១០០ |
| *ទឹកស្អាតសម្រាប់ទទួលទាន* | % | ៥៤,៦ | ៦០,០ |
| *ឧបករណ៍លាងសម្អាតដៃ* | % | ៥៤,៩ | ៦០,០ |
| *ប្រអប់សង្គ្រោះបឋម* | % | ២២,០ | ៣០,០ |
| ១៤. ភាគរយនៃសាលាមធ្យមសិក្សាដែលមានអគ្គិសនីប្រើប្រាស់ ៖ | | | |
| *អនុវិទ្យាល័យ* | % | ៣០,០ | ៣៥,០ |
| *វិទ្យាល័យ* | % | ៩១,៨ | ៩៥,០ |
| ១៥. សាលាជំនាន់ថ្មី | ចំនួន | ៥ | ១០ |
| ១៦. ចំនួនវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស | ចំនួន | ៩ | ១៩ |
| ១៧. ចំនួនសិស្សក្នុងការអប់រំបច្ចេកទេស | ចំនួន | ១ ៤៣១ | ៣ ០០០ |
| *ចំនួនសិស្សក្នុងការអប់រំបច្ចេកទេស (ស្រី)* | ចំនួន | ៥២៦ | ៦២១ |
| ១៨. ចំនួនសាលារៀនអនុវត្តកម្មវិធីមគ្គុទ្ទេសក៏អាជីព និងការផ្តល់ប្រឹក្សា | ចំនួន | ៣៥ | ២៨៥ |
| ១៩. ចំនួនសាលារៀនអនុវត្តកម្មវិធីជំនាញជីវិតតាមមូលដ្ឋាន | ចំនួន | ៣៩១ | ១ ០៥២ |
| វត្ថុបំណងអនុវិស័យទី២៖ កែលម្អគុណភាពបង្រៀននិងរៀនឱ្យស្របតាមជំនាញសតវត្សទី២១ | | | |
| ២០. ភាគរយគ្រូមធ្យមសិក្សាបឋមភូមិមានគុណវុឌ្ឍិស្របតាមស្តង់ដាជាតិតាមរូបមន្ត ១២+២ | % | ៨៦,០ | ៩៦,០ |
| ២១. ចំនួនគ្រូមធ្យមសិក្សាបានទទួលការធ្វើវិក្រឹតការ | ចំនួន | ១ ៦៩១ | ៦ ៦៥៦ |
| ២២. ភាគរយមធ្យមសិក្សាទុតិយភូមិប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់គាំទ្រការបង្រៀន និងរៀន | % | ៥,០ | ២៥,០ |

| | | | |
|---|---|---|---|
| ២៣. ភាគរយគ្រូបង្រៀនកម្រិតមូលដ្ឋានទទួលបានបរិញ្ញាបត្រ តាមរយៈកម្មវិធីអប់រំគ្រូបង្រៀន | ភាគរយ | ៦,៧ | ១៥,០ |
| *គោលនយោបាយទី២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់* | | | |
| វត្ថុបំណងរបស់អនុវិស័យទី ៣៖ ពង្រឹងភាពជាអ្នកដឹកនាំ និងគ្រប់គ្រងនៅមធ្យមសិក្សា | | | |
| ២៤. ចំនួននាយកសាលាមធ្យមសិក្សាបានទទួលការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងតាមសាលារៀន | ចំនួន | ៦៧៨ | ១ ៦៤៨ |
| ២៥. ចំនួនសាលាមធ្យមសិក្សាអនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀនពេញលេញ | ចំនួន | ១៥០ | ៣០០ |

### ៣.៣.៤ សកម្មភាពគោលនយោបាយ

*គោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា*

- រៀបចំលិខិតបទដ្ឋានគតិយុត្តនិងយន្តការស្តីពីការពង្រីកមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសនៅឆ្នាំ២០១៩ (តទវ/នក)
- រៀបចំលិខិតបទដ្ឋានគតិយុត្តនិងយន្តការ និងក្របខណ្ឌការងារសម្រាប់ផ្តល់ឱកាសដល់សិស្សបោះបង់ការសិក្សានៅមធ្យមសិក្សា ទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈនៅសាលាមធ្យមសិក្សាចំណេះទូទៅ និងសាលាអប់រំបច្ចេកទេសនៅឆ្នាំ២០២០ (តទវ/នក)
- អភិវឌ្ឍក្របខណ្ឌធានាគុណភាពតាមរយៈការផ្តល់សេវាអប់រំបច្ចេកទេសនៅឆ្នាំ២០២១ (តទវ)
- រៀបចំ និងពិនិត្យឡើងវិញលិខិតបទដ្ឋានគតិយុត្ត ដើម្បីគាំទ្រការអនុវត្តការងារប្រឹក្សាយោបល់នៅតាមសាលារៀនក្នុងឆ្នាំ២០១៩ (តទវ)
- រៀបចំគោលនយោបាយស្តីពីការផ្តល់ប្រឹក្សាយោបល់នៅតាមសាលារៀនក្នុងឆ្នាំ២០២១ (តទវ)
- រៀបចំ និងពិនិត្យឡើងវិញលិខិតបទដ្ឋានគតិយុត្ត ដើម្បីគាំទ្រការអនុវត្តកម្មវិធីបំណិននៅតាមសាលារៀនក្នុងឆ្នាំ២០១៩ (តទវ/នក)
- ធ្វើបច្ចុប្បន្នកម្មផែនការគោលសម្រាប់អភិវឌ្ឍការអប់រំបច្ចេកទេសនៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំ២០២០ (តទវ)
- រៀបចំសៀវភៅណែនាំស្តីពីអនុវត្តស្តង់ដាមធ្យមសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស ឆ្នាំ២០២០ (តទវ)
- រៀបចំសេចក្តីណែនាំស្តីពីស្វ័យភាពនិងគណនេយ្យភាពសម្រាប់សាលាមធ្យមសិក្សាក្នុង ឆ្នាំ២០២០ (មបទ)
- រៀបចំលិខិតបទដ្ឋានគតិយុត្ត និងយន្តការស្តីពីការរៀបចំនិងការប្រព្រឹត្តទៅការប្រឡងនៅវិទ្យាល័យចំណេះទូទៅ និងអប់រំបច្ចេកទេស នៅឆ្នាំ២០២១ (តទវ/នក)
- រៀបចំសេចក្តីណែនាំស្តីពីការគ្រប់គ្រងនិងការប្រើប្រាស់សៀវភៅសិក្សាគោលនៅឆ្នាំ២០២០(អសក)

- រៀបចំឯកសារណែនាំស្តីពីការអនុវត្តនៃការបង្រៀន និងរៀនសម្រាប់គ្រប់មុខវិជ្ជាឱ្យស្របតាមកម្មវិធីសិក្សានៅឆ្នាំ២០២០(អសក)។

*គោលនយោបាយទី២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់*

- រៀបចំសេចក្តីណែនាំស្តីពីអភិបាលកិច្ចល្អនៅតាមសាលាមធ្យមសិក្សាចំណេះទូទៅ និងសាលាអប់រំបច្ចេកទេសក្នុងឆ្នាំ២០១៩ (នក)
- រៀបចំសេចក្តីណែនាំប្រតិបត្តិស្តីពីការអនុវត្តការគ្រប់គ្រងសាលារៀនក្នុងឆ្នាំ២០២១ ( មចទ)
- រៀបចំសេចក្តីណែនាំសម្រាប់ការអនុវត្តប្រព័ន្ធគ្រប់គ្រងសិស្សតាមរយៈបច្ចេកវិទ្យាព័ត៌មានក្នុងឆ្នាំ ២០២០ (មចទ)
- រៀបចំសេចក្តីណែនាំស្តីពីប្រភេទគ្រឹះស្ថានសិក្សាក្នុងឆ្នាំ២០២០ (នក)
- ធ្វើបច្ចុប្បន្នកម្មគោលនយោបាយស្តីពីសៀវភៅសិក្សាគោលនិងសៀវភៅគ្រូ ដើម្បីអភិវឌ្ឍសៀវភៅសិក្សាគោលក្នុងឆ្នាំ២០១៩ (អកស)
- រៀបចំប្រកាសស្តីពីការគ្រប់គ្រងគ្រឹះស្ថានមធ្យមសិក្សាក្នុងឆ្នាំ២០២៣ (មចទ)
- រៀបចំប្រកាសស្តីពីការផ្តល់និងលុបវិញ្ញាបនបត្រនៅតាមសាលាមធ្យមសិក្សាក្នុងឆ្នាំ២០២២ (មចទ)
- រៀបចំប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សាលាមធ្យមសិក្សាក្នុងឆ្នាំ២០២២(មចទ)
- កែសម្រួលប្រកាស ស្តីពីសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិត៣ នៅ ឆ្នាំ២០២១ (តទវ/នក)
- រៀបចំប្រកាសស្តីពីការប្រើប្រាស់ឯកសារណែនាំកម្មសិក្សាសិស្សផ្នែកអប់រំបច្ចេកទេស ឆ្នាំ២០២២ (តទវ/នក)។

## ៣.៣.៥ យុទ្ធសាស្ត្រ និងសកម្មភាពគោល

### វត្ថុបំណងអនុវិស័យទី ១៖ លើកកម្ពស់ការចូលរៀន និងរក្សាឱ្យបានគង់វង្សប្រកបដោយសមធម៌ និងបរិយាបន្ននៅមធ្យមសិក្សា

យុទ្ធសាស្ត្រ១.១៖ ពង្រីកវិធានការដើម្បីកែលម្អការចូលរៀននិងរក្សាឱ្យបានគង់វង្សនៅមធ្យមសិក្សា ជាពិសេសក្រុមជួបការលំបាក

- បន្តការសាងសង់អគារសិក្សាដើម្បីបង្កិតសាលារៀនឱ្យជិតលំនៅដ្ឋានរបស់សិស្ស
- ពង្រាយគ្រូឱ្យបានដល់គ្រប់គ្រឹះស្ថានសិក្សា តាមរយៈការអនុវត្តគោលការណ៍ជ្រើសរើសគ្រូបង្រៀនតាមតម្រូវការជាក់ស្តែងរបស់គ្រឹះស្ថានសិក្សា
- ពិនិត្យឡើងវិញកម្មវិធីអាហារូបករណ៍ និងកម្មវិធីគាំទ្រដទៃទៀតសម្រាប់សិស្សក្រីក្រនិងសិស្សមានពិការភាព
- អនុវត្តប្រព័ន្ធរំលឹកជាមុន(កំណត់អត្តសញ្ញាណសិស្សងាយរងគ្រោះនិងបោះបង់ការសិក្សា)
- លើកកម្ពស់ការចូលរួមរបស់សហគមន៍ មាតាបិតាសិស្ស អាជ្ញាធរ សិស្ស គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនដើម្បីតាមដានវត្តមានសិស្ស និងលទ្ធផលសិក្សា

- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងសិស្សដើម្បីអន្តរាគមន៍ទាន់ពេលវេលា
- អភិវឌ្ឍនិងធ្វើឱ្យប្រសើរឡើងនូវកម្មវិធីសុខភាពសិក្សានិងការអប់រំសុខភាព ដោយរួមបញ្ចូលការលើកកម្ពស់សិទ្ធិទទួលបានការអប់រំសុខភាពបន្តពូជ និងផ្លូវភេទ ព្រមទាំងការអប់រំបង្ការគ្រឿងញៀន)។

យុទ្ធសាស្ត្រ១.២៖ ពង្រីកភាពជាដៃគូរជាមួយវិស័យឯកជននិងសហគ្រាសដើម្បីពង្រឹងការអប់រំបច្ចេកទេស

- ពង្រីកភាពជាដៃគូរវាងសាលារៀន និងវិស័យឯកជនស្តីពីតម្រូវការជំនាញ
- អនុវត្តការហ្វឹកហាត់ការងារ និងធ្វើកម្មសិក្សាជាមួយភាគីអ្នកពាក់ព័ន្ធ។

យុទ្ធសាស្ត្រ១.៣៖ ពង្រីកហេដ្ឋារចនាសម្ព័ន្ធ និងសម្ភាររូបវន្តសម្រាប់សាលាមធ្យមសិក្សា

- រៀបចំបន្ទប់ពិសោធន៍ និងបណ្ណាល័យស្តង់ដានៅសាលាមធ្យមសិក្សា និងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
- ផ្តល់សម្ភារបរិក្ខារបច្ចេកទេស និងសម្ភារពិសោធន៍ដែលមានគុណភាពដល់សាលាមធ្យមសិក្សាចំណេះទូទៅ និងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសស្របតាមស្តង់ដា
- សាងសង់អន្តេវាសិកដ្ឋាននៅវិទ្យាល័យចំណេះទូទៅ និងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
- រៀបចំកសិដ្ឋានសម្រាប់វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសដែលផ្តល់ជំនាញផ្នែកកសិកម្ម
- បង្កើត និងរៀបចំរោងជាងជំនាញបច្ចេកទេស និងរោងជាងអប់រំបំណិនជីវិតតាមគ្រឹះស្ថានមធ្យមសិក្សា និងវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
- បំពាក់សម្ភារ និងឧបករណ៍រោងជាងអប់រំបំណិនជីវិតតាមមុខជំនាញសិក្សា
- បំពាក់សម្ភារបរិក្ខារសម្រាប់បន្ទប់ប្រឹក្សាអាជីពនៅតាមសាលារៀន
- សាងសង់និងជួសជុលហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅតាមវិទ្យាស្ថានគរុកោសល្យស្របតាមស្តង់ដានៃការបណ្តុះបណ្តាលគ្រូ
- បំពាក់សម្ភារឧបទេសសម្រាប់គាំទ្រដល់ការបង្រៀន និងរៀននៅតាមវិទ្យាស្ថានគរុកោសល្យ
- សាងសង់បង្គន់អនាម័យ កម្មវិធីអនាម័យទឹកស្អាត និងផ្តល់ឧបករណ៍សង្គ្រោះបឋម ឧបករណ៍ការពារវន្ទះនៅតាមសាលាមធ្យមសិក្សា។

## វត្ថុបំណងអនុវិស័យទី ២៖ កែលម្អគុណភាពបង្រៀននិងរៀនឱ្យស្របតាមជំនាញសតវត្សទី២១

យុទ្ធសាស្ត្រ២.១៖ ពង្រឹងនិងពង្រីកមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា និងភាសាបរទេសដើម្បីឆ្លើយតបក្របខណ្ឌជំនាញសតវត្សទី២១

- អនុវត្តវិធីសាស្ត្របង្រៀនវិទ្យាសាស្ត្រផ្អែកលើគោលវិធីស្ទែម (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា) រួមមាន ការប្រើប្រាស់រោងជាង កុំព្យូទ័រ និងបន្ទប់ពិសោធន៍
- អនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលតាមរយៈការសិក្សាផ្អែកលើបញ្ញត្តិបែបរិះរក និងដោះស្រាយបញ្ហានិងវិធីសាស្ត្របង្រៀនបែបថ្មីសម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ

- បំប៉នសមត្ថភាពគ្រូ ដើម្បីអប់រំបច្ចេកទេសស្តីពីកម្មវិធីសិក្សាផ្អែកលើសមត្ថភាព និងការប្រើប្រាស់សម្ភារឧបទេសដើម្បីគាំទ្រដល់ការបង្រៀននិងរៀន
- បញ្ចូលវិធីសាស្ត្របង្រៀនតាមបែបសិស្សមជ្ឈមណ្ឌល និងការគ្រប់គ្រងតាមសាលារៀនទៅក្នុងកម្មវិធីអប់រំគ្រូនៅវិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ
- បំប៉នគ្រូនិងគរុសិស្សស្តីពីការអប់រំបរិយាបន្ន
- ផ្គត់ផ្គង់សៀវភៅសិក្សាគោលស្របតាមក្របខណ្ឌកម្មវិធីសិក្សាថ្មី
- អភិវឌ្ឍប្រព័ន្ធការសិក្សាអប់រំពីចម្ងាយ កម្មវិធីទូរស័ព្ទដៃ ធនធានអប់រំបើកទូលាយ និងបរិបទឌីជីថល ដើម្បីលើកកម្ពស់ការសិក្សាពេញមួយជីវិត
- រៀបចំទិវាវិទ្យាសាស្ត្រនៅសាលារៀនគ្រប់កម្រិត
- បង្កើតកម្មវិធីប្រកួតប្រជែងស្នាដៃ(គណៈគ្រប់គ្រង គ្រូបង្រៀន សិស្ស) ស្តីពីការអប់រំបច្ចេកទេស
- រៀបចំបណ្ណាល័យទំនើប៖ ការប្រើប្រាស់ អ៊ីប៊ុក អ៊ិនធឺណិត និងកុំព្យូទ័រ
- ជំរុញឱ្យមានការតាំងពិព័រណ៍នៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
- ពិនិត្យតាមដាន និងវាយតម្លៃថ្នាក់ពីរភាសាបារាំង-ខ្មែរ
- លើកកម្ពស់ការអប់រំបែបឌីជីថល។

### យុទ្ធសាស្ត្រ២.២៖ ពង្រឹងការតម្រង់ទិសការសិក្សាឆ្ពោះទៅរកអាជីព និងពង្រីកការអប់រំបច្ចេកទេស

- ពង្រីកវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
- បង្កើតជំនាញថ្មីនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារ
- ធ្វើបច្ចុប្បន្នកម្មនិងអនុវត្តផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ
- ពិនិត្យតាមដាន និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តស្តង់ដាវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
- អនុវត្តកម្មវិធីស្ពានចម្លងនៅវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
- អនុវត្តកម្មវិធីអប់រំសហគ្រិនភាពនៅគ្រឹះស្ថានមធ្យមសិក្សា
- ពង្រីកវេទិកាអប់រំតម្រង់ទិសវិជ្ជាជីវៈ និងជំនាញទន់សម្រាប់សិស្ស និងនិស្សិត
- ពង្រីកការផ្សព្វផ្សាយកម្មវិធីផ្តល់ប្រឹក្សាអេឡិចត្រូនិច «ត្រីវិស័យ»សម្រាប់សិស្សមធ្យមសិក្សា
- រៀបចំពិព័រណ៍អប់រំតម្រង់ទិសវិជ្ជាជីវៈ និងការសិក្សាជំនាញ
- កសាងឯកសារស្តីពី «មូលដ្ឋានក្នុងការជ្រើសរើសជំនាញសិក្សា និងអាជីព សម្រាប់មធ្យមសិក្សាទុតិយភូមិ»
- បណ្តុះបណ្តាលនាយកសាលាស្តីពីការប្រើប្រាស់ឯកសារស្តីពី«មូលដ្ឋានក្នុងការជ្រើសរើសជំនាញសិក្សា និងអាជីព សម្រាប់មធ្យមសិក្សាទុតិយភូមិ»
- បណ្តុះបណ្តាលគ្រូប្រឹក្សាអាជីពថ្មី ដើម្បីអនុវត្តសេវាមគ្គុទ្ទេសក៍អាជីព និងការផ្តល់ប្រឹក្សា
- បន្តកៀរគរ និងសម្របសម្រួលដៃគូពាក់ព័ន្ធ ដើម្បីពង្រីកការងារតម្រង់ទិសសិស្ស និស្សិត និងការងារប្រឹក្សាអាជីព

- បង្កើតគេហទំព័រជាឧបករណ៍គាំទ្រការងារប្រឹក្សាអាជីព
- ធ្វើបច្ចុប្បន្នកម្ម និងអភិវឌ្ឍមាតិកាផ្តល់ប្រឹក្សាអេឡិចត្រូនិក «ត្រីវិស័យ»
- អភិវឌ្ឍសមត្ថភាពគ្រូទទួលបន្ទុកអប់រំបំណិនជីវិត និងគ្រូប្រឹក្សាអាជីព
- ផ្តល់ប្រឹក្សាអាជីព និងសេវាជួយរកការងារឱ្យសិស្សមានពិការភាព។

### យុទ្ធសាស្ត្រ២.៣៖ ជំរុញការអនុវត្តកម្មវិធីសិក្សាថ្មីប្រកបដោយប្រសិទ្ធភាព

- រៀបចំសេចក្តីណែនាំទូទៅ និងសេចក្តីណែនាំប្រតិបត្តិស្តីពីការអនុវត្តកម្មវិធីសិក្សាថ្មី
- អនុវត្តកម្មវិធីសិក្សាថ្មី៖ ការបំប៉នគ្រូឧទ្ទេសថ្នាក់ជាតិលើវិធីសាស្ត្របង្រៀន ការរៀបចំសៀវភៅណែនាំគ្រូ និងការពិនិត្យឡើងវិញសៀវភៅសិក្សាគោល
- ដាក់ឱ្យអនុវត្តមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវគរុកោសល្យដើម្បីកែលម្អគុណភាពនៃការបង្រៀន និងរៀន
- រៀបចំបណ្ណាល័យស្តង់ដា និងការផ្តល់សៀវភៅ និងឯកសារសំបូរបែបសម្រាប់អនុវត្តវិធីសាស្ត្របង្រៀនថ្មី
- រៀបចំសេចក្តីណែនាំដើម្បីអនុវត្តកម្មវិធីអប់រំបំណិនជីវិត
- រៀបចំយន្តការដើម្បីអនុវត្តគោលនយោបាយអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំក្នុងក្របខណ្ឌកម្មវិធីសិក្សាថ្មី
- អនុវត្តកម្មវិធីផ្លាស់ប្តូរបទពិសោធន៍ «សាលាជួយសាលា» និង «ខេត្តជួយខេត្ត »
- ផ្សព្វផ្សាយកម្មវិធីសិក្សាដល់គ្រូបង្រៀនទូទាំងប្រទេស
- ជំរុញការអប់រំពលរដ្ឋសកល
- ពង្រឹងវិធីសាស្ត្របង្រៀនតាមបែបរិះរក និងវិធីសាស្ត្រផ្សេងៗទៀតដែលបម្រើឱ្យគោលវិធីសិស្សមជ្ឈមណ្ឌល។

## វត្ថុបំណងអនុវិស័យទី ៣៖ ពង្រឹងភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងនៅមធ្យមសិក្សា

### យុទ្ធសាស្ត្រ៣.១៖ ពង្រឹងអភិក្រមការគ្រប់គ្រងតាមសាលារៀននៅកម្រិតសាលារៀន

- រៀបចំយន្តការដើម្បីអនុវត្តការគ្រប់គ្រងតាមសាលារៀន៖ (១) ការរៀបចំការធ្វើតេស្តវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស (២) ការរៀបចំផែនការកែលម្អសាលារៀន (៣) ការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន
- ពង្រឹង និងពង្រីកការអនុវត្តការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព
- ពង្រីកការអនុវត្តការគ្រប់គ្រងតាមសាលារៀននៅតាមគ្រឹះស្ថានគោលដៅ
- បណ្តុះបណ្តាលនាយកសាលារៀន ស្តីពីភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងសាលារៀន
- បន្តចលនាប្រឡងប្រណាំងនាយកល្អ
- ពង្រឹងសមត្ថភាពស្ថាប័ន នៃនាយកដ្ឋានជំនាញលើការអនុវត្តកម្មវិធីសិក្សាថ្មី
- បណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ជាតិ និងអធិការ ដើម្បីពង្រឹងការគ្រប់គ្រងអប់រំ
- ណែនាំនិងបង្វឹកបុគ្គលិកនៅសាលារៀនស្តីពីការគ្រប់គ្រងសាលារៀន
- អនុវត្តស្វ័យវាយតម្លៃសាលារៀនតាមរយៈការប្រើប្រាស់ស្តង់ដាសាលារៀនមានប្រសិទ្ធភាព

- បំប៉ននៅនឹងកន្លែងដល់គណៈគ្រប់គ្រងសាលារៀនស្តីការគ្រប់គ្រងតាមសាលារៀន
- ពង្រីកការអនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀន ចំនួន ១០០ សាលាមធ្យមសិក្សាក្នុងមួយឆ្នាំ។

យុទ្ធសាស្ត្រ៣.២៖ ពង្រីកការអនុវត្តស្តង់ដាគំរូសាលារៀនជំនាន់ថ្មី

- ពង្រឹង និងបន្តពង្រីកសាលារៀនជំនាន់ថ្មី ដើម្បីប្រើប្រាស់ជាសាលាអនុវត្តសម្រាប់ការអនុវត្តកម្មវិធី-សិក្សាផ្តោតលើបញ្ញត្តិ និងវិធីសាស្ត្របង្រៀនតាមបែបសិស្សមជ្ឈមណ្ឌល (ការសិក្សាផ្អែកលើបញ្ញត្តិ បែបរិះរក និងដោះស្រាយបញ្ហា)
- អភិវឌ្ឍផែនការវិនិយោគដើម្បីពង្រីកសាលារៀនជំនាន់ថ្មី
- បំពាក់សម្ភារបរិក្ខារសាលាធនធានមធ្យមសិក្សាដើម្បីប្រែក្លាយទៅជាសាលារៀនជំនាន់ថ្មី (ក្នុងមួយខេត្ត មួយសាលាយ៉ាងតិច)
- ពង្រឹងកិច្ចសហប្រតិបត្តិរវាងសាលារៀន ដៃគូអភិវឌ្ឍន៍ សហគមន៍ សប្បុរសជន និងវិស័យឯកជន។

យុទ្ធសាស្ត្រ៣.៣៖ អភិវឌ្ឍក្របខណ្ឌធានាគុណភាពអប់រំរបស់សាលារៀននៅមធ្យមសិក្សា

- អភិវឌ្ឍក្របខណ្ឌធានាគុណភាពអប់រំរបស់សាលារៀន រួមទាំងតួនាទីរបស់ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ស្រុក និងការិយាល័យជំនាញ
- អភិវឌ្ឍក្របខណ្ឌធានាគុណភាពការផ្តល់សេវាអប់រំបច្ចេកទេសកម្រិតមធ្យមសិក្សា
- រៀបចំប្រព័ន្ធណែនាំនិងបង្វឹកក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ស្រុក
- អភិវឌ្ឍសមត្ថភាពក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុក ដើម្បីលើកកម្ពស់ចំណេះដឹង និងជំនាញស្តីពីអ្នកណែនាំជាកម្រង និងស្វ័យវាយតម្លៃសាលារៀន
- បណ្តុះបណ្តាលនាយកសាលាស្តីពីស្វ័យវាយតម្លៃសាលារៀន
- ពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំឱ្យឆ្លើយតបគុណភាពអប់រំនៅមធ្យមសិក្សា
- ផ្សព្វផ្សាយក្របខណ្ឌវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅ
- វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៨ និងទី១១ លើមុខវិជ្ជាគណិតវិទ្យា រូបវិទ្យា និងភាសាខ្មែរ
- វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតកម្មវិធីអន្តរជាតិ ឆ្នាំ២០២១
- ផ្សព្វផ្សាយលទ្ធផលវាយតម្លៃប្រចាំខែ ២ដងក្នុងមួយឆ្នាំ
- រៀបចំរបាយការណ៍និងការពិនិត្យតាមដានលើយន្តការការបង្រៀននិងរៀនឱ្យស្របតាមកម្មវិធីសិក្សា។

### យុទ្ធសាស្ត្រ ៣.៤៖ ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការងារអធិការកិច្ចនៅតាមសាលារៀន

- អភិវឌ្ឍប្រព័ន្ធពិនិត្យតាមដានប្រតិបត្តិការតាមសាលារៀន និងការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលាពីថ្នាក់ជាតិ
- រៀបចំវគ្គតម្រង់ទិសណែនាំសម្រាប់គ្រូចេញថ្មីនៅតាមសាលារៀន
- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការអប់រំបរិយាបន្នសម្រាប់សិស្សនៅមធ្យមសិក្សា
- ធ្វើសុខដុមនីយកម្មឧបករណ៍ការងារអធិការកិច្ច ដោយបញ្ចូលឧបករណ៍វង្វាយតម្លៃសាលាកុមារមេត្រី និងឧបករណ៍ពិនិត្យតាមដានការគ្រប់គ្រងតាមសាលារៀន
- ប្រើប្រាស់របាយការណ៍អធិការកិច្ច និងលទ្ធផលវាយតម្លៃដើម្បីរៀបចំធ្វើផែនការអភិវឌ្ឍសាលារៀន
- កែសម្រួលកម្មវិធីសិក្សាសម្រាប់បណ្ដុះបណ្ដាលអធិការកិច្ចអប់រំ។

## ៣.៤ អនុវិស័យឧត្តមសិក្សា

### ៣.៤.១ ស្ថានភាព

ក្នុងអំឡុងឆ្នាំ២០១៤-២០១៨ ចំនួនគ្រឹះស្ថានឧត្តមសិក្សាបានកើនឡើងពី១១០ ដល់ ១២៥ គ្រឹះស្ថានសិក្សា ក្នុងនោះគ្រឹះស្ថានសិក្សារដ្ឋ ៤៨ និងឯកជន ៧៧ ដែលមានទីតាំងនៅ ២០ រាជធានី-ខេត្ត។ ចំនួននិស្សិតចូលរៀនមានការថយចុះពី ២៤៩ ០៩២នាក់ មក ២១១ ៤៨៤នាក់ ស្មើ ១៥ ភាគរយ។ ចំនួននិស្សិតទទួលបានអាហារូបករណ៍នៅតាមគ្រឹះស្ថានសិក្សារដ្ឋ និងឯកជនបានថយចុះពី ៣០ ៣០៨នាក់ មក ២៧ ៥២២ នាក់ ស្មើ ៩ ភាគរយ។ ចំនួនបុគ្គលិកអប់រំនៅឧត្តមសិក្សាបានកើនពី ១១ ៣៦២នាក់ ដល់ ១៦ ១៦៧នាក់ ស្មើ ៤២ ភាគរយ ក្នុងនោះគ្រូបង្រៀនបានកើនឡើងពី ៨ ៩៥៣នាក់ ទៅ ១២ ៥៣៩ នាក់ ស្មើ ៤០ ភាគរយ។ នៅឆ្នាំ២០១៨ គ្រូបង្រៀនដែលមានបរិញ្ញាបត្រមាន ១ ៩៤៧ ស្មើ ១៥,៥ ភាគរយ បរិញ្ញាបត្រជាន់ខ្ពស់ ៨ ៧៥១នាក់ ស្មើ ៦៩,៨ ភាគរយ និងថ្នាក់បណ្ឌិតមានចំនួន ១ ០៩០នាក់ ស្មើ ៨,៧ ភាគរយ ធៀបនឹងចំនួនគ្រូបង្រៀនសរុប។

ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តនូវគោលនយោបាយសំខាន់ៗមួយចំនួន ដូចជា គោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សា២០៣០ គោលនយោបាយស្តីពីអភិបាលកិច្ចនិងហិរញ្ញប្បទាន នៅឧត្តមសិក្សាសម្រាប់កម្ពុជា និងផែនទីបង្ហាញផ្លូវនៅឧត្តមសិក្សាកម្ពុជាឆ្នាំ២០៣០ និងក្រោយឆ្នាំ២០៣០។ គោលនយោបាយទាំងនេះ គឺផ្តោតទៅលើការលើកកម្ពស់គុណភាពអប់រំ និងប្រសិទ្ធភាពនៃអភិបាលកិច្ច និងការគ្រប់គ្រងនៅឧត្តមសិក្សា។

ការធ្វើសមាហរណកម្មអាស៊ាន និងដំណាក់កាលនៃបដិវត្តន៍ឧស្សាហកម្មទី៤ បានផ្តល់ទាំង កាលានុវត្តភាព និងទាំងបញ្ហាប្រឈមសម្រាប់អនុវិស័យនេះ។ បញ្ហាប្រឈមដែលត្រូវដោះស្រាយ រួមមាន ការកែលម្អគុណភាពអប់រំនៅឧត្តមសិក្សា និងភាពឆ្លើយតប តាមរយៈការកែទម្រង់លើការបង្រៀននិងរៀន និងការស្រាវជ្រាវ។ កត្តានេះ ទាមទារយ៉ាងចាំបាច់ឱ្យមានការវិនិយោគខ្ពស់សម្រាប់បង្កើនចំនួនសាស្ត្រាចារ្យ ពេញម៉ោង និងសាស្ត្រាចារ្យថ្នាក់បណ្ឌិតនៅតាមគ្រឹះស្ថានឧត្តមសិក្សា ដើម្បីផលិតអ្នកបញ្ចប់ការសិក្សាឱ្យ មានគុណភាពឆ្លើយតបទៅនឹងតម្រូវការរបស់ទីផ្សារនិងសង្គម និងស្តង់ដាអន្តរជាតិ។ បញ្ហាប្រឈមមួយ ទៀត គឺប្រសិទ្ធភាពនៃអភិបាលកិច្ច និងការគ្រប់គ្រងនៅឧត្តមសិក្សា ដែលចាំបាច់ត្រូវកែលម្អប្រព័ន្ធគ្រប់ គ្រងហិរញ្ញវត្ថុ និងធនធានមនុស្សឱ្យមានសុខុមាលភាពល្អ ដើម្បីឱ្យគ្រឹះស្ថានឧត្តមសិក្សាអាចធានាបាន នូវនិរន្តរភាព និងភាពរឹងមាំនៃធនធាន។

ក្នុងការពង្រឹង និងលើកកម្ពស់គុណភាពអប់រំនៅឧត្តមសិក្សាឆ្ពោះទៅរកស្តង់ដាថ្នាក់តំបន់ និង អន្តរជាតិ និងឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលក្នុងអាណត្តិថ្មី ក្រសួងអប់រំ យុវជន និងកីឡាកំណត់គោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ ដើម្បីធានា ឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន។

### ៣.៤.២ វត្ថុបំណងអនុវិស័យ

- លើកកម្ពស់ការចូលរៀន និងកែលម្អគុណភាពនៃកម្មវិធីបណ្ដុះបណ្ដាលនៅឧត្តមសិក្សាឆ្ពោះទៅការទទួលស្គាល់គុណភាពកម្រិតជាតិ និងអន្តរជាតិ
- អភិវឌ្ឍប្រព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រង សម្រាប់គាំទ្រគ្រឹះស្ថានឧត្តមសិក្សាឱ្យទទួលបានស្វ័យភាពពេញលេញ។

### ៣.៤.៣ សូចនាករផលសម្រេច

**តារាងទី៧ ៖ សូចនាករផលសម្រេច និងចំណុចដៅអនុវិស័យ**

| សូចនាករ | ឯកតា | ឆ្នាំគោល ២០១៨ | ចំណុចដៅ ២០២៣ |
|---|---|---|---|
| *គោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា* | | | |
| វត្ថុបំណងអនុវិស័យទី១៖ លើកកម្ពស់ការចូលរៀន និងកែលម្អគុណភាពនៃកម្មវិធីបណ្ដុះបណ្ដាលនៅឧត្តមសិក្សាឆ្ពោះទៅការទទួលស្គាល់គុណភាពកម្រិតជាតិ និងអន្តរជាតិ | | | |
| ១. អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (អាយុ១៨-២២ឆ្នាំ) | % | ១១,៦ | ១៦,០ |
| *ប្រុស* | % | ១៣,២ | ១៨,៩ |
| *ស្រី* | % | ១១,៣ | ១៣,០ |
| ២. ភាគរយនិស្សិតចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្ដុះបណ្ដាលផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា | % | ២៧,១ | ៣២,០ |
| *ប្រុស* | % | ៣៦,៧ | ៣៨,៦ |
| *ស្រី* | % | ១៧,៤ | ២២,៥ |
| ៣. ចំនួនមជ្ឈមណ្ឌលឧត្តមភាព | ចំនួន | ០ | ៣ |
| ៤. ភាគរយបុគ្គលិកសិក្សាពេញម៉ោងមានគុណវុឌ្ឍិថ្នាក់បណ្ឌិត | % | ៣,៤ | ៥,០ |
| *ស្រី* | % | ១៤,៧ | ១៧,០ |
| ៥. ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានធ្វើការសិក្សាពីស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា | ចំនួន | ០ | ១០ |
| *គោលនយោបាយទី២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់* | | | |
| វត្ថុបំណងអនុវិស័យទី២៖ អភិវឌ្ឍប្រព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រងសម្រាប់គាំទ្រគ្រឹះស្ថានឧត្តមសិក្សាឱ្យទទួលបានស្វ័យភាពពេញលេញ | | | |
| ៦. ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង | ចំនួន | ០ | ២៥ |
| ៧. ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានការទទួលស្គាល់គុណភាពអប់រំ | ចំនួន | ០ | ២៥ |

| | | | |
|---|---|---|---|
| ៨. ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យឧត្តមសិក្សា | ចំនួន | ០ | ៤០ |

### ៣.៤.៤ សកម្មភាពគោលនយោបាយ

*គោលនយោបាយទី១៖ ធានាឱ្យមានការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា*

- រៀបចំគោលការណ៍ណែនាំស្តីពីការអនុវត្តភាពជាដៃគូឧត្តមសិក្សា សម្រាប់កែលម្អសមត្ថភាពនៅគ្រឹះស្ថានឧត្តមសិក្សា នៅឆ្នាំ២០១៩ (ឧស)
- រៀបចំប្រកាសស្តីពីបុគ្គលិកសិក្សាពេញម៉ោងនៅតាមគ្រឹះស្ថានឧត្តមសិក្សានៅឆ្នាំ២០១៩(ឧស/បល)
- រៀបចំប្រកាសអន្តរក្រសួងស្តីពីការបង្កើតមូលនិធិស្រាវជ្រាវសម្រាប់ឧត្តមសិក្សានៅឆ្នាំ២០២០(ឧស)
- រៀបចំគោលការណ៍ណែនាំស្តីពីការអនុវត្តមូលនិធិស្រាវជ្រាវសម្រាប់ឧត្តមសិក្សានៅឆ្នាំ២០២០(ឧស)
- រៀបចំប្រកាសអន្តរក្រសួងស្តីពីមូលនិធិអាហារូបករណ៍សម្រាប់និស្សិតនៅឧត្តមសិក្សា នៅឆ្នាំ២០២២ (ឧស/ហវ)។

*គោលនយោបាយទី២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់*

- រៀបចំគោលការណ៍ណែនាំស្តីពីការតវ៉ា ការដាក់ពាក្យបណ្តឹង និងការដោះស្រាយវិវាទសម្រាប់និស្សិតនៅក្នុងគ្រឹះស្ថានឧត្តមសិក្សា នៅឆ្នាំ២០១៩ (ឧស/នក)
- រៀបចំសេចក្តីណែនាំស្តីពី ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាគ្រប់ជ្រុងជ្រោយ នៅឆ្នាំ២០២១ (ឧស/ហវ/អគផ)
- រៀបចំប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបប្រព័ន្ធថវិកាជាកញ្ចប់នៅតាមគ្រឹះស្ថានឧត្តមសិក្សារដ្ឋនៅឆ្នាំ២០២២ (ឧស/ហវ)
- រៀបចំប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងធនធានមនុស្ស នៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនៅឆ្នាំ២០២២ (ឧស/បល)
- រៀបចំព្រះរាជក្រឹត្យស្តីពីអភិបាលកិច្ច និងការគ្រប់គ្រងនៅឧត្តមសិក្សា នៅឆ្នាំ២០២៣ (ឧស/នក)។

### ៣.៤.៥ យុទ្ធសាស្ត្រ និងសកម្មភាព

**វត្ថុបំណងអនុវិស័យទី ១៖ លើកកម្ពស់ការចូលរៀន និងកែលម្អគុណភាពនៃកម្មវិធីបណ្តុះបណ្តាលនៅឧត្តមសិក្សា ឆ្ពោះទៅបានការទទួលស្គាល់គុណភាពកម្រិតជាតិ និងអន្តរជាតិ**

យុទ្ធសាស្ត្រ១.១៖ បង្កើនការវិនិយោគលើកម្មវិធីអប់រំឧត្តមសិក្សាអាទិភាព ដោយផ្អែកលើលទ្ធផល

- ផ្តល់ថវិកាជាកញ្ចប់ដល់គ្រឹះស្ថានឧត្តមសិក្សាដែលមានកម្មវិធីបណ្តុះបណ្តាលអាទិភាពនៅឧត្តមសិក្សា ឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម
- សាងសង់អន្តេវាសិកដ្ឋាន ដើម្បីលើកកម្ពស់ការចូលរៀន និងសមធម៌នៅឧត្តមសិក្សា។

### យុទ្ធសាស្ត្រ១.២៖ លើកកម្ពស់ការបង្រៀននិងរៀន និងការស្រាវជ្រាវតាមរយៈការបង្កើតភាពជាដៃគូឧត្តមសិក្សា

- កែលម្អកម្មវិធីសិក្សាដោយសហការជាមួយគ្រឹះស្ថានឧត្តមសិក្សាដៃគូទាំងក្នុង និងក្រៅប្រទេស
- បង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅតាមគ្រឹះស្ថានឧត្តមសិក្សា
- អភិវឌ្ឍគុណវុឌ្ឍិបុគ្គលិកអប់រំលើការបង្រៀននិងរៀន និងការស្រាវជ្រាវដោយសហការជាមួយគ្រឹះស្ថានឧត្តមសិក្សាដៃគូទាំងក្នុង និងក្រៅប្រទេស
- សាងសង់បន្ទប់សិក្សា និងបន្ទប់ពិសោធន៍
- ចូលរួមកម្មវិធីចល័តនិស្សិតអន្តរជាតិអាស៊ាន
- រៀបចំកម្មវិធីថ្នាក់ក្រោយបរិញ្ញាបត្រឱ្យមានការទទួលស្គាល់គុណភាពជាអន្តរជាតិ តាមរយៈកិច្ចសហការជាមួយសាកលវិទ្យាល័យដៃគូ ក្នុង និងក្រៅប្រទេស
- រៀបចំគម្រោងស្រាវជ្រាវដោយសហការជាមួយផ្នែកឧស្សាហកម្ម និងគ្រឹះស្ថានឧត្តមសិក្សា ដៃគូទាំងក្នុង និងក្រៅប្រទេស
- រៀបចំប្រព័ន្ធសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សាមានការងារធ្វើ។

### យុទ្ធសាស្ត្រ ១.៣៖ បង្កើនបុគ្គលិកសិក្សាពេញម៉ោងដែលមានគុណវុឌ្ឍិថ្នាក់បណ្ឌិត

- រៀបចំនិងអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់បុគ្គលិកអប់រំ
- អនុវត្តប្រព័ន្ធវាយតម្លៃការងារ និងផ្តល់លាភការដល់បុគ្គលិកអប់រំដោយផ្អែកលើការបំពេញការងារ។

## វត្ថុបំណងអនុវិស័យទី ២៖ អភិវឌ្ឍប្រព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រងសម្រាប់គាំទ្រគ្រឹះស្ថានឧត្តមសិក្សាឱ្យទទួលបានស្វ័យភាពពេញលេញ

### យុទ្ធសាស្ត្រ២.១៖ ពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានមនុស្សរបស់គ្រឹះស្ថានឧត្តមសិក្សាឆ្ពោះទៅទទួលបានស្វ័យភាពពេញលេញ

- ផ្តល់ស្វ័យភាពពេញលេញដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ តាមរយៈការអនុវត្តសាកល្បងប្រព័ន្ធថវិកាជាកញ្ចប់
- ផ្តល់ស្វ័យភាពពេញលេញដល់គ្រឹះស្ថានឧត្តមសិក្សារដ្ឋក្នុងការគ្រប់គ្រងធនធានមនុស្ស។

### យុទ្ធសាស្ត្រ ២.២៖ កែលម្អប្រព័ន្ធធានាគុណភាពអប់រំនៅឧត្តមសិក្សា

- រៀបចំប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងសម្រាប់គ្រឹះស្ថានឧត្តមសិក្សា
- រៀបចំយន្តការផ្តល់ការគាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សាក្នុងការអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង
- វាយតម្លៃការអនុវត្តរបស់គ្រឹះស្ថានឧត្តមសិក្សាដើម្បីផ្តល់ការទទួលស្គាល់គុណភាពអប់រំ
- បណ្តុះបណ្តាលមន្ត្រីគ្រប់គ្រង និងមន្ត្រីទទួលបន្ទុកប្រព័ន្ធធានាគុណភាពអប់រំ
- អនុវត្តសាកល្បងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យឧត្តមសិក្សា
- រៀបចំយន្តការផ្តល់ការគាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សាក្នុងការអនុវត្តប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យ

- បណ្តុះបណ្តាលមន្ត្រីគ្រប់គ្រង និងមន្ត្រីទទួលបន្ទុកប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យឧត្តមសិក្សា
- រៀបចំផែនការ និងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល
- បណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកការរៀបចំផែនការ និងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃផ្អែកលើលទ្ធផល
- កសាងផែនការយុទ្ធសាស្ត្រថវិកា សម្រាប់ការអភិវឌ្ឍរបស់គ្រឹះស្ថានឧត្តមសិក្សា។

## ៣.៥ អនុវិស័យការអប់រំក្រៅប្រព័ន្ធ

### ៣.៥.១ សាវតារ

នៅក្នុងឆ្នាំ ២០១៤-២០១៨ អនុវិស័យអប់រំក្រៅប្រព័ន្ធបានផ្លាស់ប្តូរ និងរីកចម្រើន ជាពិសេសអត្រាអក្ខរកម្មយុវជនអាយុ ១៥-២៤ឆ្នាំ មាន ៩៤,៦ ភាគរយ និងអត្រាអក្ខរកម្មជនពេញវ័យ (អាយុ ១៥ឆ្នាំឡើង) មាន ៨២,៥ ភាគរយ នៅឆ្នាំ ២០១៧ (របាយការណ៍អង្កេតសង្គម-សេដ្ឋកិច្ចនៅកម្ពុជា ឆ្នាំ២០១៨)។

ក្នុងរយៈពេល៥ឆ្នាំនេះ ថ្នាក់អក្ខរកម្មសរុបមាន ៧ ៨១៩ថ្នាក់ ចំនួនអនក្ខរជនបានចូលរៀនក្នុងកម្មវិធីអក្ខរកម្ម ១៦៥ ០០១នាក់។ ថ្នាក់សមមូលបឋមសិក្សាអប់រំក្រៅប្រព័ន្ធសរុប ១ ២៧៩ថ្នាក់ ចំនួនសិស្សចូលរៀន ២៥ ៦០៨នាក់។ ថ្នាក់កម្មវិធីចូលរៀនឡើងវិញ(ថ្នាក់ទី៣ ដល់ទី៦) ថយចុះពី ១ ០៥៩ថ្នាក់ នៅឆ្នាំ២០១៤ មក ៦៣៦ ថ្នាក់ នៅឆ្នាំ២០១៨។ ចំនួនសិស្សបានបំប៉នបានថយចុះ ១៧ ៩៣៨ នាក់ នៅឆ្នាំ២០១៤ មក ១១ ៤០៤នាក់ នៅឆ្នាំ២០១៨។ ចំនួនមជ្ឈមណ្ឌលសិក្សាសហគមន៍បានកើនពី៣៤៧កន្លែង នៅឆ្នាំ២០១៤ ដល់ ៣៥៦កន្លែងនៅឆ្នាំ២០១៨។ ថ្នាក់បណ្តុះបណ្តាលជំនាញសរុប ២ ៩៩១ ថ្នាក់ មានអ្នកសិក្សាបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញ ៤១ ២៤៦នាក់។

ទន្ទឹមនឹងសមិទ្ធផលខាងលើ ក៏តម្រូវឱ្យបន្តពង្រឹងសមត្ថភាពគ្រប់គ្រងនិងដឹកនាំក្នុងការអនុវត្តកម្មវិធីរបស់មន្ត្រីអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់ថ្នាក់ និងការអភិវឌ្ឍមជ្ឈមណ្ឌលសិក្សាសហគមន៍ឱ្យមានដំណើរការល្អ ឆ្លើយតបនឹងតម្រូវការមូលដ្ឋាន។ ក្របខណ្ឌការងារអប់រំក្រៅប្រព័ន្ធត្រូវបានពង្រឹងតាមរយៈការពិនិត្យឡើងវិញនូវគោលនយោបាយអប់រំក្រៅប្រព័ន្ធ ការរៀបចំឱ្យមានលិខិតបទដ្ឋានគាំទ្រការអនុវត្ត ការបង្កើតក្រុមការងារអនុវិស័យអប់រំក្រៅប្រព័ន្ធ ដើម្បីពង្រឹងការអនុវត្តនិងវាយតម្លៃសមត្ថភាពអប់រំក្រៅប្រព័ន្ធ និងការពិនិត្យឡើងវិញក្របខណ្ឌកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលនៃកម្មវិធីអប់រំក្រៅប្រព័ន្ធ។

### ៣.៥.២ ទិស្នុំបំណងអនុវិស័យ

- បង្កើនចំនួនអក្ខរជន និងការចូលរៀនក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធ សម្រាប់កុមារ យុវជនក្រៅសាលា និងអនក្ខរជនពេញវ័យ ទទួលបានសេវាអប់រំក្រៅប្រព័ន្ធពេញលេញ ក្នុងក្របខណ្ឌនៃការសិក្សាពេញមួយជីវិតប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា
- ពង្រឹងការអនុវត្តប្រព័ន្ធគ្រប់គ្រងផ្អែកលើលទ្ធផលរបស់កម្មវិធីអប់រំក្រៅប្រព័ន្ធ ឱ្យមានដំណើរការពេញលេញ
- លើកកម្ពស់សមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធ គ្រប់លំដាប់ថ្នាក់។

### ៣.៥.៣ សូចនាករផលសម្រេច

**តារាងទី៨ ៖ សូចនាករផលសម្រេច និងចំណុចដៅអនុវិស័យ**

| សូចនាករ | ឯកតា | ឆ្នាំគោល ២០១៨ | ចំណុចដៅ ២០២៣ |
|---|---|---|---|
| *គោលនយោបាយទី១ ៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា* | | | |
| វត្ថុបំណងអនុវិស័យទី ១៖ បង្កើនចំនួនអក្ខរជន និងការចូលរៀនក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធសម្រាប់កុមារ និងយុវជនក្រៅសាលាព្រមទាំងជនពេញវ័យដែលជាអនក្ខរជន ទទួលបានសេវាអប់រំក្រៅប្រព័ន្ធបានពេញលេញ ក្នុងក្របខណ្ឌការសិក្សាពេញមួយជីវិតប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា | | | |
| ១. ចំនួនប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម | ចំនួន | ១៦ ៨៥០ | ៧២ ០០០ |
| ២. ចំនួនសិស្សចូលរៀនក្នុងកម្មវិធីសមមូល | ចំនួន | ៦ ៣៩៤ | ៤៦ ៥០០ |
| ៣. ចំនួនម.ស.សដែលប្រែក្លាយជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត | ចំនួន | ០ | ៥៥ |
| ៤. ចំនួនកុមារបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញ និងបានបញ្ជូនទៅក្នុងប្រព័ន្ធ | ចំនួន | ១០ ០៩៩ | ៥១ ២០០ |
| ៥. ចំនួនអ្នកបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញមុខរបរ | ចំនួន | ៩ ១៧០ | ៦០ ៥០០ |
| *គោលនយោបាយទី២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់* | | | |
| វត្ថុបំណងអនុវិស័យទី ២៖ ពង្រឹងការអនុវត្តប្រព័ន្ធគ្រប់គ្រងអប់រំក្រៅប្រព័ន្ធផ្អែកលើលទ្ធផលឱ្យមានដំណើរការបានពេញលេញ | | | |
| ៦. ចំនួនខេត្តដែលបានអនុវត្តក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃអប់រំក្រៅប្រព័ន្ធផ្អែកលើលទ្ធផល | ចំនួន | ០ | ២៥ |
| ៧. ចំនួនស្រុកដែលអនុវត្តបានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ | ចំនួន | ០ | ១៥០ |
| វត្ថុបំណងអនុវិស័យទី៣ ៖ ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់មន្ត្រីអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់ថ្នាក់ | | | |
| ៨. ចំនួនមន្ត្រីអប់រំក្រៅប្រព័ន្ធទទួលការបណ្តុះបណ្តាលលើការធ្វើផែនការ និងការគ្រប់គ្រងសេវាអប់រំក្រៅប្រព័ន្ធ | ចំនួន | ០ | ៦៥០ |

### ៣.៥.៤ សកម្មភាពគោលនយោបាយ

*គោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា*

- កសាងគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត នៅឆ្នាំ២០១៩ (អកប/គនប)
- រៀបចំផែនការសកម្មភាពដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត នៅឆ្នាំ ២០២០ (អកប/នក/អគផ)
- រៀបចំសេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីអក្ខរកម្ម នៅឆ្នាំ ២០១៩ (អកប)

- រៀបចំសេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីក្រោយអក្ខរកម្ម នៅឆ្នាំ ២០១៩ (អកប)
- រៀបចំបណ្ណាល័យ និងបណ្ណាល័យចល័ត នៅឆ្នាំ២០២០ (អកប)
- រៀបចំសេចក្តីណែនាំស្តីពីការអនុវត្តកម្មវិធីសមមូលមធ្យមសិក្សាទុតិយភូមិនៅឆ្នាំ២០២០ (អកប)
- រៀបចំសេចក្តីណែនាំស្តីពីការរៀបចំប្រឡងសម្រាប់កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិ នៅឆ្នាំ ២០១៩ (អកប)
- រៀបចំសេចក្តីណែនាំស្តីពីការរៀបចំប្រឡងសម្រាប់កម្មវិធីសមមូលមធ្យមសិក្សាទុតិយភូមិ នៅឆ្នាំ ២០២១ (អកប/កប្រឡ)
- រៀបចំលក្ខណៈវិនិច្ឆ័យចំណាត់ថ្នាក់មជ្ឈមណ្ឌលសិក្សាសហគមន៍ នៅឆ្នាំ២០១៩ (អកប)

*គោលនយោបាយទី២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់*

- រៀបចំសេចក្តីណែនាំស្តីពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ នៅឆ្នាំ២០១៩ (អកប)
- រៀបចំសេចក្តីណែនាំស្តីពីការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធនៅឆ្នាំ ២០១៩ (អកប)
- រៀបចំសេចក្តីណែនាំស្តីពីការគ្រប់គ្រងសាលា/ថ្នាក់ឯកជនបណ្តុះបណ្តាលភាសាបរទេស ឬ ជំនាញងាយៗ នៅឆ្នាំ២០១៩ (អកប)។

### ៣.៥.៥ យុទ្ធសាស្ត្រ និងសកម្មភាព

**វត្ថុបំណងអនុវិស័យទី ១៖ បង្កើនចំនួនអក្ខរជន និងការចូលរៀនក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធសម្រាប់កុមារ យុវជនក្រៅសាលា និងអនក្ខរជនពេញវ័យក្នុងក្របខណ្ឌការសិក្សាពេញមួយជីវិតប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា**

យុទ្ធសាស្ត្រ១.១៖ អភិវឌ្ឍ និងកែលម្អកម្មវិធីអប់រំក្រៅប្រព័ន្ធ

- រៀបចំកម្មវិធីសិក្សាសមមូលមធ្យមសិក្សាទុតិយភូមិ (ដោយដាក់បញ្ចូលខ្លឹមសារ៧០ ភាគរយ ពីកម្មវិធីសិក្សាអប់រំ ក្នុងប្រព័ន្ធ និងដាក់បន្ថែមខ្លឹមសារបំណិនជីវិត ៣០ ភាគរយ)
- កែលម្អកម្មវិធីសិក្សាលម្អិត និងសៀវភៅសិក្សាគោលសម្រាប់កម្មវិធីសមមូលបឋមសិក្សា និង មធ្យមសិក្សាបឋមភូមិ
- រៀបចំកម្មវិធីសិក្សាលម្អិត និងសៀវភៅសិក្សាគោលសម្រាប់ជំនាញមុខរបរងាយៗ
- រៀបចំកម្មវិធីសិក្សា និងឯកសារក្រោយអក្ខរកម្ម
- ធ្វើបច្ចុប្បន្នកម្ម កម្មវិធីសិក្សាចូលរៀនឡើងវិញ។

យុទ្ធសាស្ត្រ១.២៖ លើកកម្ពស់កម្មវិធីអក្ខរកម្មមនុស្សពេញវ័យ

- ផ្សព្វផ្សាយគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត
- ផលិតសៀវភៅសិក្សាគោល សម្ភារបង្រៀននិងរៀន សម្រាប់កម្មវិធីអក្ខរកម្មមនុស្សពេញវ័យ
- ផ្សព្វផ្សាយកម្មវិធីអក្ខរកម្មតាមរោងចក្រ សហគ្រាស និងពន្ធនាគារ
- រៀបចំបណ្ណាល័យ និងបណ្ណាល័យចល័ត

- ប្រារព្ធទិវាអក្ខរកម្មជាតិតាមរាជធានី ខេត្ត និងថ្នាក់ជាតិ។

យុទ្ធសាស្ត្រ១.៣៖ ប្រែក្លាយមជ្ឈមណ្ឌលសិក្សាសហគមន៍ ទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត

- រៀបចំផែនការអភិវឌ្ឍមជ្ឈមណ្ឌលសិក្សាសហគមន៍ឱ្យក្លាយទៅជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត
- ជ្រើសរើសគ្រូឧទ្ទេសសមស្របសម្រាប់កម្មវិធីថ្មីនៅតាមមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត
- ផ្សព្វផ្សាយពីផែនការអភិវឌ្ឍមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត ដល់សហគមន៍ និងអ្នកពាក់ព័ន្ធ
- សិក្សាអំពីស្ថានភាព និងតម្រូវការជាក់ស្តែងរបស់សហគមន៍
- អភិវឌ្ឍសមត្ថភាពគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍ស្តីពី ការគ្រប់គ្រង ការធ្វើផែនការ និងទស្សនាទានការសិក្សាពេញមួយជីវិត
- វិភាជន៍ថវិកាឱ្យដល់គ្រប់មជ្ឈមណ្ឌលសិក្សាសហគមន៍ និងទាន់ពេលវេលា
- បង្កើតឥណទានខ្នាតតូចគាំទ្រមុខរបរសម្រាប់សិស្សរៀនចប់ថ្នាក់ជំនាញ
- ពិនិត្យតាមដាន និងវាយតម្លៃដំណើរការមជ្ឈមណ្ឌលសិក្សាសហគមន៍ ដោយមានការចូលរួមពីសហគមន៍ និងអ្នកពាក់ព័ន្ធ។

យុទ្ធសាស្ត្រ១.៤៖ ជំរុញវិស័យឯកជន ដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល និងការចូលរួមគាំទ្រដល់កម្មវិធីអប់រំក្រៅប្រព័ន្ធរបស់អ្នកពាក់ព័ន្ធ ក្នុងក្របខណ្ឌនៃការសិក្សាពេញមួយជីវិត

- រៀបចំបណ្តាញទំនាក់ទំនងជាមួយវិស័យឯកជន អាជ្ញាធរ អង្គការដៃគូអភិវឌ្ឍ សប្បុរសជន សហគមន៍ និងអ្នកពាក់ព័ន្ធ ដើម្បីគាំទ្រការងារអប់រំក្រៅប្រព័ន្ធ
- លើកកម្ពស់កិច្ចសហការរវាងដៃគូអភិវឌ្ឍ និងវិស័យឯកជន។

## វត្ថុបំណងអនុវិស័យទី ២៖ ពង្រឹងការអនុវត្តប្រព័ន្ធគ្រប់គ្រងអប់រំក្រៅប្រព័ន្ធផ្អែកលើលទ្ធផល

យុទ្ធសាស្ត្រ២.១៖ កែលម្អប្រសិទ្ធភាព និងគុណភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ

- ធ្វើបច្ចុប្បន្នកម្ម ឧបករណ៍ប្រមូលទិន្នន័យ និងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធឱ្យឆ្លើយតបនឹងសូចនាករនៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា
- បន្សីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ ជាមួយប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ
- ពង្រីកវិសាលភាពប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធឱ្យដល់ថ្នាក់ក្រុង ស្រុក ខណ្ឌ
- ផ្សព្វផ្សាយ ប្រើប្រាស់ទិន្នន័យ និងព័ត៌មានអប់រំក្រៅប្រព័ន្ធ ឱ្យបានទូលំទូលាយ
- អនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធទូទាំងប្រទេស។

## វត្ថុបំណងអនុវិស័យទី ៣៖ ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់មន្ត្រីអប់រំក្រៅប្រព័ន្ធ គ្រប់លំដាប់ថ្នាក់

យុទ្ធសាស្ត្រ៣.១៖ អភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធ គ្រប់លំដាប់ថ្នាក់

- សិក្សាពីតម្រូវការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីគ្រប់លំដាប់ថ្នាក់
- អភិវឌ្ឍសមត្ថភាពគ្រូជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ និងគណៈគ្រប់គ្រងមជ្ឈមណ្ឌលសិក្សាសហគមន៍
- បណ្តុះបណ្តាលគ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធនៅតាមសាលាគរុកោសល្យ និងរិក្រឹតការ

ខេត្ត និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ

- លើកកម្ពស់ការបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀន តម្រង់ទិសការអនុវត្ត និងកម្មសិក្សាប្រតិបត្តិ
- កសាងឯកសារគោលបំប៉នសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធ
- អភិវឌ្ឍសមត្ថភាពដល់អ្នកផ្តល់សេវាអំពីបំណិន ជំនាញមុខរបរងាយៗ ជំនាញវិជ្ជាជីវៈដើម្បីជានាដំណើរការនៃការសិក្សាពេញមួយជីវិតប្រកបដោយគុណភាព និងប្រសិទ្ធភាព
- អភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់ថ្នាក់ស្តីពីការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធ
- រៀបចំក្របខណ្ឌកម្មវិធីបណ្តុះបណ្តាលគ្រូអក្ខរកម្មជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធ
- អភិវឌ្ឍសមត្ថភាពរបស់មន្ត្រីអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់ថ្នាក់ និងអ្នកពាក់ព័ន្ធ
- កំណត់គោលដៅក្រុង ស្រុក ខណ្ឌ អនុវត្តប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ។

## ៣.៦ អនុវិស័យការអភិវឌ្ឍយុវជន

### ៣.៦.១ សារធាតុ

ក្រសួងនិងអ្នកពាក់ព័ន្ធបាននិងកំពុងជំរុញការអភិវឌ្ឍយុវជនបែបវិជ្ជមាន និងផ្តល់ឱកាសដល់យុវជនអភិវឌ្ឍសក្តានុពលរបស់ខ្លួនលើការអប់រំ អាជីព ការសម្រេចចិត្ត និងការចូលរួមចំណែកក្នុងការអភិវឌ្ឍគ្រួសាររបស់ពួកគេ សហគមន៍ ប្រទេសជាតិ និងសកលលោក។

នៅឆ្នាំ២០១៨ ក្រសួងបានអនុម័តសន្ទស្សន៍ស្តីពីការអភិវឌ្ឍយុវជនកម្ពុជាដើម្បីជាប្រភពព័ត៌មានក្នុងគោលដៅកៀរគរធនធានថវិកាបន្ថែមទៀតសម្រាប់យកទៅវិនិយោគលើការអភិវឌ្ឍយុវជន។ អនុវិស័យការអភិវឌ្ឍយុវជនសម្រេចបាននូវលទ្ធផលគួរឱ្យកត់សម្គាល់មួយចំនួនៈ ចំនួនយុវជននិងកុមារចូលរួមក្នុងក្រុមប្រឹក្សាយុវជន និងកុមារកម្ពុជានៅតាមគ្រឹះស្ថានសិក្សារដ្ឋមានការកើនឡើង ចំនួនយុវជនដែលទទួលបានការបណ្តុះបណ្តាល ជំនាញរយៈពេលខ្លីលើការងារស្ម័គ្រចិត្ត ភាពជាអ្នកដឹកនាំ សហគ្រិនភាព និងកាយវិទ្ធិកម្ម សម្រេចបានតាមគោលដៅដែលបានកំណត់។

នៅតាមគ្រឹះស្ថានសិក្សារដ្ឋ ភាគរយនៃសិស្សថ្នាក់ទី៤ ដល់៩ ដែលបានក្លាយជាសមាជិកក្រុមប្រឹក្សាកុមារកម្ពុជាបានឆ្លើយតបនឹងចំណុចដៅ។ ចំណែកឯភាគរយនៃការចូលរួមក្នុងក្រុមប្រឹក្សាយុវជនកម្ពុជានៅមធ្យមសិក្សាទុតិយភូមិមានស្ថានភាពមិនប្រែប្រួល និងមានបញ្ហាប្រឈមមួយចំនួន ដែលមិនអាចសម្រេចតាមចំណុចដៅ។ ដូចនេះ ការអភិវឌ្ឍផែនការសកម្មភាពសម្រាប់ដំណើរការក្រុមប្រឹក្សាកុមារកម្ពុជានៅបឋមសិក្សានិងមធ្យមសិក្សាទុតិយភូមិ នឹងត្រូវចាត់ទុកជាសូចនាករសម្រាប់ការពិនិត្យតាមដាន និងវាយតម្លៃនៅពេលអនាគត។

អនុវិស័យការអភិវឌ្ឍយុវជន សម្រេចបាននូវលទ្ធផលវិជ្ជមានមួយចំនួន ជាពិសេស ការពង្រឹងក្រុមប្រឹក្សាយុវជន និងកុមារកម្ពុជានៅតាមគ្រឹះស្ថានសិក្សារដ្ឋ ការបង្កើតក្លឹបសិក្សាតាមមុខវិជ្ជា ការបណ្តុះ-បណ្តាលសហគ្រិនភាព ការងារស្ម័គ្រចិត្ត ភាពជាអ្នកដឹកនាំ ការប្រឹក្សាអាជីព និងការបណ្តុះបណ្តាលជំនាញទន់និងជំនាញបច្ចេកទេស។

### ៣.៦.២ វត្ថុបំណងអនុវិស័យ

- អភិវឌ្ឍកម្មវិធីឌីជីថល សហគ្រិនភាព ភាពជាអ្នកដឹកនាំវ័យក្មេង និងជំនាញទន់ផ្សេងៗសម្រាប់ការអភិវឌ្ឍយុវជន
- ពង្រឹងការអភិវឌ្ឍយុវជនតាមរយៈមជ្ឈមណ្ឌលយុវជន ទីកន្លែង និងបរិក្ខារទាន់សម័យ
- ពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីទទួលបន្ទុកការងារយុវជននៅថ្នាក់ជាតិ និងក្រោមជាតិ។

## ៣.៦.៣ សូចនាករផលសម្រេចនិង ចំណុចដៅ

### តារាងទី៩ ៖ សូចនាករផលសម្រេចនិង ចំណុចដៅអនុវិស័យ

| សូចនាករ | ឯកតា | ឆ្នាំគោល ២០១៨ | ចំណុចដៅ ២០២៣ |
|---|---|---|---|
| *គោលនយោបាយទី១ ៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា* | | | |
| វត្ថុបំណងអនុវិស័យទី១៖ អភិវឌ្ឍកម្មវិធីឱីជីថល សហគ្រិនភាព ភាពជាអ្នកដឹកនាំ និងជំនាញទន់ផ្សេងៗទៀតសម្រាប់ការអភិវឌ្ឍយុវជន | | | |
| ១. ចំនួនយុវជនទទួលបានការបណ្តុះបណ្តាលរយៈពេលខ្លីស្តីពីជំនាញវិជ្ជាជីវៈ ឌីជីថល និងបច្ចេកទេស | ចំនួន | ១ ៦៤៤ | ៨ ២២០ |
| ២. ចំនួនយុវជនទទួលបានការបណ្តុះបណ្តាលស្តីពីការងារស្ម័គ្រចិត្ត | ចំនួន | ១ ២៤៤ | ៦ ២២០ |
| ៣. ចំនួនយុវជនទទួលបានការបណ្តុះបណ្តាលស្តីពី សហគ្រិនភាព ភាពជាអ្នកដឹកនាំ អក្ខរកម្មហិរញ្ញវត្ថុ ការសិក្សា និងការណែនាំការងារ | ចំនួន | ១០ ០៩២ | ៤៧ ៥៥២ |
| ៤. ចំនួនយុវជន និងកុមារទទួលបានប័ណ្ណសរសើរក្នុងការអនុវត្តចលនាប្រឡងប្រណាំងពល្អ "កូនល្អ សិស្សល្អ មិត្តល្អ" | ចំនួន | ៣១៩ | ១ ៥៩៥ |
| ៥. ភាគរយក្រុមប្រឹក្សាកុមារកម្ពុជាដែលកំពុងដំណើរការ | % | ៩,៦ | ២០,០ |
| ៦. ភាគរយក្រុមប្រឹក្សាយុវជនកម្ពុជាដែលកំពុងដំណើរការ | % | ២២,៤ | ៣០,០ |
| ៧. ចំនួនយុវជនកាយរឹទ្ធិនៅបឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា និងសហគមន៍ចូលរួមចលនាកាយរឹទ្ធិ | ចំនួន | ១៥០ ៩៦៣ | ៣៥០ ០០០ |
| ៨. ចំនួនយុវជនក្រៅសាលាចូលរួមសិក្សាក្នុងកម្មវិធីអប់រំសមមូលកម្រិតមូលដ្ឋាន "ប៊ីប" | ចំនួន | ២៥០ | ១ ២៥០ |
| វត្ថុបំណងអនុវិស័យទី ២៖ ពង្រឹងការអភិវឌ្ឍយុវជនតាមរយៈមជ្ឈមណ្ឌលយុវជន ទីកន្លែង និងបរិក្ខារទាន់សម័យ | | | |
| ៩. ចំនួនមជ្ឈមណ្ឌលយុវជនដែលកំពុងដំណើរការ | ចំនួន | ៦ | ៩ |
| *គោលនយោបាយទី២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់* | | | |
| វត្ថុបំណងអនុវិស័យទី ៣ ៖ ពង្រឹងសមត្ថភាពស្ថាប័ននិងមន្ត្រីទទួលបន្ទុកការងារយុវជននៅថ្នាក់ជាតិ និងក្រោមជាតិ | | | |
| ១០. ចំនួនមន្ត្រីទទួលបន្ទុកការងារយុវជនទទួលបានការបណ្តុះបណ្តាល | ចំនួន | ២០០ | ១ ០០០ |
| ១១. ចំនួនក្រុមប្រឹក្សាអភិវឌ្ឍយុវជនតាមក្រសួង ស្ថាប័ន ត្រូវបានបង្កើត | ចំនួន | ០ | ១៦ |
| ១២. ចំនួនក្រុមប្រឹក្សាអភិវឌ្ឍយុវជនតាមរាជធានី-ខេត្ត ត្រូវបានបង្កើត | ចំនួន | ០ | ១២ |

### ៣.៦.៤ សកម្មភាពគោលនយោបាយ

*គោលនយោបាយទី១៖ ធានាការអប់រំឱ្យមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា*

- រៀបចំសេចក្ដីណែនាំស្ដីពីវេទិកាការងារស្ម័គ្រចិត្តនៅឆ្នាំ២០១៩ (អយក)
- រៀបចំសេចក្ដីណែនាំស្ដីពីសុវត្ថិភាពលើការគ្រប់គ្រងគ្រោះថ្នាក់និងហានិភ័យនៅឆ្នាំ២០២០ (អយក)
- រៀបចំសេចក្ដីណែនាំស្ដីពីក្រុមប្រឹក្សាជាតិកាយរឹទ្ធិនៃកាយរឹទ្ធិជាតិនៅឆ្នាំ២០២២ (សករ)
- ធ្វើបច្ចុប្បន្នកម្មសេចក្ដីណែនាំស្ដីពី ចលនាប្រឡងប្រណាំង៣ល្អរបស់ក្រុមប្រឹក្សាយុវជននិងកុមារកម្ពុជានៅឆ្នាំ២០១៩ (យវ)
- រៀបចំសេចក្ដីណែនាំស្ដីពីក្របខណ្ឌទទួលស្គាល់ការងារស្ម័គ្រចិត្តយុវជននៅឆ្នាំ២០២០ (អយក)
- ធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពជាតិស្ដីពី ការអភិវឌ្ឍយុវជនកម្ពុជានៅឆ្នាំ២០២០ (អយក)។

*គោលនយោបាយទី២៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់*

- រៀបចំប្រកាសអន្តរក្រសួងស្ដីពី របបហិរញ្ញវត្ថុរបស់មន្ត្រីទទួលបន្ទុកការងារយុវជននៅឆ្នាំ២០២១ (អយក/ហវ)
- រៀបចំព្រះរាជក្រឹត្យ និងអនុក្រឹត្យស្ដីពីក្រុមប្រឹក្សាជាតិកាយរឹទ្ធិនៃកាយរឹទ្ធិជាតិកម្ពុជានៅឆ្នាំ២០២០ (អយក/នក)
- ធ្វើបច្ចុប្បន្នកម្មសេចក្ដីណែនាំស្ដីពីដំណើរការនៃមជ្ឈមណ្ឌលយុវជន និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងជំនាញទន់នៅឆ្នាំ២០២០ (មយក)
- ធ្វើបច្ចុប្បន្នកម្មគោលនយោបាយនិងផែនការបណ្ដុះបណ្ដាលជាតិកាយរឹទ្ធិជាតិនៅឆ្នាំ២០២១ (សករ)
- ធ្វើបច្ចុប្បន្នភាពគោលនយោបាយធនធានមនុស្សពេញវ័យ និងការស្ម័គ្រចិត្តកាយរឹទ្ធិនៃកាយរឹទ្ធិជាតិនៅឆ្នាំ២០២៣ (អយក)។

### ៣.៦.៥ យុទ្ធសាស្ត្រ និងសកម្មភាពគោល

**វត្ថុបំណងអនុវិស័យទី១៖ អភិវឌ្ឍកម្មវិធីឌីជីថល សហគ្រិនភាព ភាពជាអ្នកដឹកនាំ និងជំនាញទន់ផ្សេងៗ សម្រាប់ការអភិវឌ្ឍយុវជន**

យុទ្ធសាស្ត្រ ១.១៖ ពង្រឹងជំនាញឌីជីថល និងលើកកម្ពស់ចំណេះដឹងអនុវត្តនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យាសម្រាប់យុវជន ដើម្បីឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្មជំណាក់កាលទី៤

- អភិវឌ្ឍសៀវភៅណែនាំស្ដីពីវិធីសាស្ត្របោះជំរំ និងបច្ចេកទេសសម្រាប់ស្វែម និងក្លឹបស្វែមនៅក្នុងក្រុមប្រឹក្សាយុវជននិងកុមារកម្ពុជា
- អនុវត្តកម្មវិធីប្រើប្រាស់ព័ត៌មានវិទ្យា ដើម្បីគាំទ្រដល់ការសិក្សា និងបណ្ដុះបណ្ដាលពីចម្ងាយ
- រៀបចំបោះជំរំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
- អភិវឌ្ឍកម្មវិធីបណ្ដុះបណ្ដាលអក្ខរកម្មឌីជីថល និងជំនាញទន់។

យុទ្ធសាស្ត្រ១.២៖ ពង្រឹងទម្លាប់នៃការគិតបែបច្នៃប្រឌិតនិងបង្កើតថ្មីតាមរយៈស្មារតីសហគ្រិនភាព ការលើកកម្ពស់ការប្រកបមុខរបរដោយខ្លួនឯង និងលទ្ធភាពទទួលបានសេវាណែនាំអាជីវកម្មនិងការងារ និងព័ត៌មានទីផ្សារការងារ

- បណ្តុះបណ្តាលស្តីពី សហគ្រិនភាពដោយប្រើប្រាស់ឧបករណ៍ការអភិវឌ្ឍសហគ្រាសក្នុងសហគមន៍ និងការយល់ដឹងអំពីធុរកិច្ច
- ផ្តល់ការប្រឹក្សានិងលទ្ធភាពទទួលបានព័ត៌មានការងារដល់យុវជន
- រៀបចំវេទិកាស្តីពីតម្រូវការការងារនិងសហគ្រិនភាព
- រៀបចំកម្មវិធីប្រកួតប្រជែងផែនការអាជីវកម្មយុវជន។

យុទ្ធសាស្ត្រ១.៣៖ អភិវឌ្ឍយុវជនឱ្យបានពេញលេញ និងអប់រំពួកគេឱ្យរស់នៅជាមួយគ្នាក្នុងសន្តិភាពនិងសុខដុមនីយកម្ម ប្រកបដោយស្មារតីស្នេហាជាតិ ស្រឡាញ់ប្រជាជន ជឿជាក់និងផ្តល់តម្លៃខ្ពស់ដល់ខ្លួនឯង មានភាពជាអ្នកដឹកនាំ និងការយល់ដឹងទូលំទូលាយអំពីសង្គម

- បង្កើនការយល់ដឹងអំពីសុខភាពបន្តពូជ ផ្លូវចិត្ត សុវត្ថិភាពចរាចរណ៍ និងផលប៉ះពាល់នៃការប្រើប្រាស់គ្រឿងញៀន
- លើកកម្ពស់ការស្ម័គ្រចិត្ត ដើម្បីអភិវឌ្ឍសហគមន៍
- ពង្រឹងភាពជាអ្នកដឹកនាំរបស់យុវជន។

យុទ្ធសាស្ត្រ១.៤៖ បង្កើនការចូលរួមរបស់យុវជនក្នុងការអភិវឌ្ឍសហគមន៍ និងសង្គម

- ផ្តល់ឱកាសឱ្យយុវជនចូលរួម និងរៀបចំកម្មវិធីជាតិ និងអន្តរជាតិ
- បង្កលទ្ធភាពឱ្យយុវជនក្នុងការស្វែងរកការគាំទ្រ
- ជំរុញយុវជនឱ្យចូលរួមក្នុងកិច្ចការពារសុវត្ថិភាពក្នុងសង្គមឌីជីថល។

**វត្ថុបំណងអនុវិស័យទី ២៖ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសម្រាប់សកម្មភាពយុវជន**

យុទ្ធសាស្ត្រ២.១៖ អភិវឌ្ឍមជ្ឈមណ្ឌលយុវជនគំរូ

- ជួសជុល និងបំពាក់សម្ភារបរិក្ខារសម្រាប់បណ្តុះបណ្តាលដល់មជ្ឈមណ្ឌលយុវជន មជ្ឈមណ្ឌលសិក្សា និងទីកន្លែងបោះជំរំ ដើម្បីផ្តល់ឱកាសនិងលទ្ធភាពទទួលបានការសិក្សាពេញមួយជីវិតសម្រាប់យុវជន
- ផលិតសៀវភៅណែនាំស្តីពីជំនាញវិជ្ជាជីវៈមូលដ្ឋានសម្រាប់យុវជន
- ផ្តល់ឱកាសទទួលបានការអប់រំលើកទី២សម្រាប់យុវជនក្រៅសាលាតាមរយៈកម្មវិធីអប់រំសមមូលកម្រិតមូលដ្ឋាន (ប៊ីប)។

## វត្ថុបំណងអនុវិស័យទី ៣៖ ពង្រឹងសមត្ថភាពស្ថាប័ន និងមន្ត្រីទទួលបន្ទុកការងារយុវជននៅថ្នាក់ជាតិ និងក្រោមជាតិ

### យុទ្ធសាស្ត្រ៣.១៖ ពង្រឹងសមត្ថភាពមន្ត្រីទទួលបន្ទុកការងារយុវជននៅគ្រប់លំដាប់ថ្នាក់

- សិក្សាអំពីតម្រូវការបណ្តុះបណ្តាលរបស់មន្ត្រីទទួលបន្ទុកការងារយុវជននិងមនុស្សពេញវ័យលើការងារកាយរឹទ្ធិ
- អភិវឌ្ឍសមត្ថភាពមន្ត្រីទទួលបន្ទុកការងារយុវជន និងក្របខណ្ឌមនុស្សពេញវ័យលើការងារកាយរឹទ្ធិ
- ផលិតសៀវភៅណែនាំការបណ្តុះបណ្តាលស្តីពីការអភិវឌ្ឍសមត្ថភាពយុវជន
- ពិនិត្យឡើងវិញលើផែនការយុទ្ធសាស្ត្រកាយរឹទ្ធិជាតិ បោះពុម្ពសេចក្តីណែនាំនិងសៀវភៅសិក្សាគោល និងវិនិយោគលើសមាជិកភាពកាយរឹទ្ធិថ្មី។

### យុទ្ធសាស្ត្រ៣.២៖ ពង្រឹងសមត្ថភាពស្ថាប័នស្តីពីការអនុវត្តកម្មវិធីការអភិវឌ្ឍយុវជន

- វាយតម្លៃអំពីសមិទ្ធផលរបស់អនុវិស័យ ដើម្បីឆ្លើយតបនឹងគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា តាមរយៈការសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីអភិវឌ្ឍយុវជន
- អភិវឌ្ឍឧបករណ៍និងប្រព័ន្ធដើម្បីពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តកម្មវិធីអភិវឌ្ឍយុវជន
- ប្រមូលនិងចងក្រងទិន្នន័យ និងលទ្ធផលនៃការអភិវឌ្ឍយុវជនពីគ្រប់អ្នកពាក់ព័ន្ធ
- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងព័ត៌មានការអភិវឌ្ឍយុវជន
- ផ្សព្វផ្សាយព័ត៌មានស្តីពីការអភិវឌ្ឍយុវជន រួមទាំងសន្ទស្សន៍ការអភិវឌ្ឍយុវជនកម្ពុជា ក្របខណ្ឌគតិយុត្ត និងទិន្នន័យដទៃទៀតដែលប្រមូលបានដោយប្រព័ន្ធគ្រប់គ្រងព័ត៌មានការអភិវឌ្ឍយុវជនតាមរយៈមធ្យោបាយផ្សេងៗ
- រៀបចំការតម្រង់ទិសស្តីពីតួនាទីក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនតាមក្រសួង ស្ថាប័ន រាជធានី ខេត្ត
- ពិនិត្យឡើងវិញនិងអភិវឌ្ឍឯកសារនិងក្របខណ្ឌគតិយុត្តិពាក់ព័ន្ធនឹងសកម្មភាពនិងកម្មវិធីការអភិវឌ្ឍយុវជន
- ពិនិត្យឡើងវិញលើផែនការសកម្មភាពជាតិ ស្តីពីការអភិវឌ្ឍយុវជនកម្ពុជា និងការចងក្រងឯកសារបច្ចេកទេសសម្រាប់ការអភិវឌ្ឍយុវជន
- រៀបចំផែនការស្រាវជ្រាវអំពីបញ្ហាយុវជន
- អភិវឌ្ឍសមត្ថភាពស្ថាប័នរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន។

យុទ្ធសាស្ត្រ៣.៣៖ កៀរគរកិច្ចខិតខំប្រឹងប្រែងនានារបស់ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល ដែលពាក់ព័ន្ធ សហគមន៍ មាតាបិតា ឬអ្នកអាណាព្យាបាល ដើម្បីអភិវឌ្ឍយុវជន

- សហការយ៉ាងជិតស្និទ្ធជាមួយដៃគូនិងអ្នកពាក់ព័ន្ធនានា ដើម្បីធានាការអនុវត្តកម្មវិធីការអភិវឌ្ឍយុវជនប្រកបដោយប្រសិទ្ធភាព
- សម្របសម្រួលអន្តរកម្មរវាងក្រសួង ស្ថាប័នពាក់ព័ន្ធ រួមទាំងផែនការសកម្មភាពស្តីពីការអភិវឌ្ឍយុវជនដែលអនុវត្តដោយស្ថាប័នទាំងនោះ
- កៀរគរធនធានសម្រាប់សកម្មភាពនិងកម្មវិធីការអភិវឌ្ឍយុវជន និងមជ្ឈមណ្ឌលយុវជន ដោយរួមបញ្ចូលអ្នកពាក់ព័ន្ធ។

## ៣.៧ អនុវិស័យការអប់រំកាយ និងកីឡា

### ៣.៧.១ សាវតារ

រាជរដ្ឋាភិបាលបានអនុម័តគោលនយោបាយជាតិស្តីពី ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡានៅឆ្នាំ២០១៥ ដោយបានកំណត់គោលដៅ វត្ថុបំណង យុទ្ធសាស្ត្រ និងផែនការសកម្មភាពសំខាន់ៗ ឆ្លើយតបនឹងគោលនយោបាយជាតិស្តីពី ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា កំណែទម្រង់ការអប់រំកាយ និងកីឡា ព្រមទាំងលើកកម្ពស់សកម្មភាពអប់រំកាយនិងកីឡានៅក្នុងតំបន់ ដើម្បីត្រៀមខ្លួនធ្វើជាម្ចាស់ផ្ទះប្រកួតកីឡាស៊ីហ្គេមលើកទី៣២ នៅឆ្នាំ២០២៣ និងអាស៊ានប៉ារ៉ាហ្គេម លើកទី១២នៅឆ្នាំ២០២៣នឹងធ្វើជាម្ចាស់ផ្ទះនៃការប្រកួតកីឡាសាកលវិទ្យាល័យអាស៊ាន ឆ្នាំ២០៣០។

ដើម្បីអនុវត្តគោលនយោបាយនេះ អនុក្រឹត្យស្តីពី ការផ្តល់ប្រាក់រង្វាន់ជ័យលាភីត្រូវបានធ្វើវិសោធនកម្មដោយបង្កើនប្រាក់រង្វាន់ទ្វេដង និងបានដំឡើងប្រាក់ឧបត្ថម្ភលើការហូបចុក និងស្នាក់នៅសម្រាប់កីឡាករជម្រើសជាតិ និងក្រុមកីឡាករថ្នាល។ ជាលទ្ធផល ចំនួនជ័យលាភី ប្រកួតលើឆាកជាតិនិងអន្តរជាតិបានកើនឡើង។ កម្ពុជាបានជាប់ចំណាត់ថ្នាក់លេខ៨ ក្នុងចំណោមប្រទេសទាំង១១ ដែលចូលរួមប្រកួតកីឡាស៊ីហ្គេមលើកទី២៩ នៅប្រទេសម៉ាឡេស៊ី ឆ្នាំ២០១៧។ កម្ពុជាទទួលបានមេដាយសរុប១៧ ក្នុងនោះមេដាយមាសចំនួន៣ មេដាយប្រាក់ចំនួន២ មេដាយសំរិទ្ធចំនួន១២។

ម្យ៉ាងវិញទៀត ក្រសួងបានរៀបចំការប្រកួតកីឡាជាតិ ចំនួន២លើក តាមគម្រូនៃការប្រកួតកីឡាស៊ីហ្គេម ដើម្បីត្រៀមលក្ខណៈជាម្ចាស់ផ្ទះកីឡាស៊ីហ្គេម ឆ្នាំ២០២៣។

ទន្ទឹមនឹងវឌ្ឍនភាពគួរឱ្យកត់សម្គាល់ការអប់រំកាយ និងកីឡា នៅមានបញ្ហាប្រឈមក្នុងការកសាងឯកសារគតិយុត្តលើការគ្រប់គ្រង និងការអភិវឌ្ឍការអប់រំកាយ និងកីឡា ការគ្រប់គ្រងធនធានមនុស្ស និងភាពជាអ្នកដឹកនាំ ដើម្បីរៀបចំការប្រកួតថ្នាក់ជាតិ និងអន្តរជាតិ។ ការអនុវត្តសកម្មភាពអប់រំកាយ និងកីឡានៅគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន មិនទាន់បានអនុវត្តពេញលេញ និងល្អប្រសើរដោយសារកង្វះហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឧបករណ៍ និងសម្ភារកីឡាសម្រាប់ធ្វើការហ្វឹកហាត់ទាំងការប្រកួតថ្នាក់ជាតិ និងអន្តរជាតិ។ រចនាសម្ព័ន្ធនៃការប្រកួតមិនទាន់ បំពេញតម្រូវការជាក់ស្តែង និងការប្រកួតនៅក្នុងតំបន់។ ចំណែកសកម្មភាពអប់រំកាយ និងកីឡា និងសកម្មភាពផ្សេងៗ មិនទាន់បានលើកកម្ពស់ឱ្យបានទូលំទូលាយនៅឡើយ។ ការចូលរួមលើកស្ទួយសកម្មភាពអប់រំកាយ និងកីឡាពីផ្នែកឯកជន ម្ចាស់ជំនួយ និងស្ថាប័នពាក់ព័ន្ធនៅមានកម្រិត។

ការអប់រំកាយ និងកីឡារបស់កម្ពុជាមានមហិច្ឆតាចង់បានចំណាត់ថ្នាក់លេខ ៥ ក្នុងចំណោម ១១ ប្រទេសសម្រាប់ការប្រកួតកីឡាស៊ីហ្គេមលើកទី ៣២ ឆ្នាំ២០២៣ នៅប្រទេសកម្ពុជា។

### ៣.៧.២ ទិសដៅបំណងអនុវិស័យ

- បង្កើនលទ្ធភាពទទួលបានការអប់រំកាយ និងកីឡានៅតាមគ្រឹះស្ថានសិក្សា និងសហគមន៍ ដើម្បីលើកកម្ពស់សុខុមាលភាព និងជីវភាពប្រជាជន រស់នៅប្រកបដោយសុខដុមរមនា
- លើកកម្ពស់គុណផលក្រុមកីឡាជម្រើសជាតិដើម្បីដណ្តើមមេដាយមាសឱ្យបានច្រើននៅឆ្នាំ២០២៣
- អភិវឌ្ឍសមត្ថភាពស្ថាប័ន អ្នកគ្រប់គ្រង និងអ្នកបច្ចេកទេសទទួលបន្ទុកអនុវិស័យអប់រំកាយ និងកីឡា ប្រកបដោយគុណភាព ប្រសិទ្ធភាព។

### ៣.៧.៣ សូចនាករផលសម្រេច

**តារាងទី១០ ៖ សូចនាករផលសម្រេចនិង ចំណុចដៅអនុវិស័យ**

| សូចនាករ | ឯកតា | ឆ្នាំគោល ២០១៨ | ចំណុចដៅ ២០២៣ |
|---|---|---|---|
| *គោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា* | | | |
| វត្ថុបំណងអនុវិស័យទី ១៖ បង្កើនលទ្ធភាពទទួលបានការអប់រំកាយ និងកីឡានៅតាមគ្រឹះស្ថានសិក្សា និងសហគមន៍ ដើម្បីលើកកម្ពស់សុខុមាលភាព និងជីវភាពប្រជាជន រស់នៅប្រកបដោយសុខដុមនីយកម្ម | | | |
| ១. ទីលានកីឡា៥កន្លែង ត្រូវបានកែលម្អ | | | |
| *សៀមរាប* | % | ០ | ១០០ |
| *កំពត* | % | ០ | ១០០ |
| *កំពង់ចាម* | % | ០ | ១០០ |
| *បាត់ដំបង* | % | ០ | ១០០ |
| *ភ្នំពេញ* | % | ៥០,០ | ១០០ |
| ២. ភាគរយសាលាបឋមសិក្សាអនុវត្តកម្មវិធីអប់រំកាយ និងកីឡា | % | ៦៥,០ | ៩០,០ |
| ៣. ភាគរយសាលាមធ្យមសិក្សាអនុវត្តកម្មវិធីអប់រំកាយ និងកីឡា | % | ៣០,០ | ៧០,០ |
| ៤. ចំនួនមេដាយក្នុងការប្រកួតអន្តរជាតិក្នុងមួយឆ្នាំ | ចំនួន | ៣២៩ | ៦០០ |
| ៥. ភាគរយប្រជាជនចូលរួមសកម្មភាពអប់រំកាយ និងកីឡា | % | ៧,០ | ២៣,០ |
| វត្ថុបំណងអនុវិស័យទី ២៖ លើកកម្ពស់គុណផលក្រុមកីឡាជម្រើសជាតិដើម្បីដណ្តើមមេដាយមាសឱ្យបានច្រើននៅឆ្នាំ២០២៣ | | | |
| ៦. ចំណាត់ថ្នាក់ស៊ីហ្គេមនៅក្នុងប្រទេសអាស៊ាន | ចំណាត់ថ្នាក់ | ៨ | លេខ ៥ |
| ៧. ចំនួនមេដាយមាសស៊ីហ្គេម ២០២៣ | ចំនួន | ៣ | ៤៥ |
| *គោលនយោបាយទី ២៖ ធានាភាពស័ក្តិសិទ្ធិ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់* | | | |
| វត្ថុបំណងអនុវិស័យទី ៣៖ អភិវឌ្ឍស្ថាប័ន អ្នកគ្រប់គ្រង និងអ្នកបច្ចេកទេសទទួលបន្ទុកអនុវិស័យអប់រំកាយ និងកីឡា ប្រកបដោយប្រសិទ្ធភាព និងគុណភាព | | | |
| ៨. ចំនួនកីឡាករ កីឡាការិនីបានទទួលការបណ្តុះបណ្តាលក្នុងមួយឆ្នាំ | ចំនួន | ៣៣ | ១៣៣ |

| | | | | |
|---|---|---|---|---|
| ៩. | ចំនួនគ្រូអប់រំកាយ និងកីឡាបានទទួលការបណ្តុះបណ្តាលក្នុងមួយឆ្នាំ (រយៈពេលវែង) | ចំនួន | ១០០ | ១៥០ |
| ១០. | ចំនួនគ្រូបង្វឹកបានទទួលការបណ្តុះបណ្តាលក្នុងមួយឆ្នាំ | ចំនួន | ៩១៥ | ១ ៤០០ |
| ១១. | ចំនួនចៅក្រម និងអាជ្ញាកណ្តាលបានទទួលការបណ្តុះ-បណ្តាលក្នុងមួយឆ្នាំ | ចំនួន | ៩២៥ | ១ ៤៥០ |
| ១២. | ចំនួនគ្រូបង្វឹកបានទទួលការបណ្តុះបណ្តាលបច្ចេកទេសកីឡា ផែនការយុទ្ធសាស្ត្រ និងការគ្រប់គ្រង | ចំនួន | ១៤៣ | ២៩៣ |
| ១៣. | ចំនួនគ្រូអប់រំកាយ និងកីឡាបានទទួលការបណ្តុះបណ្តាល (វគ្គខ្លី/វិក្រឹតការ) | ចំនួន | ១៨០ | ៣៦០ |
| ១៤. | ចំនួនមន្ត្រីកីឡាទទួលបានការបណ្តុះបណ្តាលក្នុងមួយឆ្នាំ | ចំនួន | ១៨០ | ៣៦០ |
| ១៥. | ចំនួនអត្តពលិកកម្រិតខ្ពស់ | ចំនួន | ៧០៧ | ១ ០០០ |

### ៣.៧.៤ សកម្មភាពគោលនយោបាយ

*គោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា*

- កែសម្រួលអនុក្រឹត្យ និងប្រកាសស្តីពីគម្រោងផ្តល់អាហារូបត្ថម្ភបន្ថែម និងប្រាក់ឧបត្ថម្ភនៃការបណ្តុះបណ្តាល និងការប្រកួតថ្នាក់ជាតិ និងអន្តរជាតិនៅឆ្នាំ២០១៩ (អកឡ/នក)
- រៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពី ការគ្រប់គ្រងកីឡានៅឆ្នាំ២០១៩ (អកឡ/នក)
- កែសម្រួលស្តង់ដាបច្ចេកទេសស្តីពីការអប់រំកាយ និងកីឡានៅឆ្នាំ២០១៩ (អកឡ)
- រៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពី ការបង្កើតមជ្ឈមណ្ឌលកីឡាភូមិភាគ ដើម្បីគាំទ្រដល់ការប្រមូលផ្តុំប្រកបដោយប្រសិទ្ធភាព និងគុណភាពខ្ពស់នៅឆ្នាំ២០១៩ (អកឡ/នក)។

### ៣.៧.៥ យុទ្ធសាស្ត្រនិង សកម្មភាព

**វត្ថុបំណងអនុវិស័យទី១៖ បង្កើនលទ្ធភាពទទួលបានការអប់រំកាយ និងកីឡានៅតាមគ្រឹះស្ថានសិក្សា និងសហគមន៍ ដើម្បីលើកកម្ពស់សុខុមាលភាព និងជីវភាពប្រជាជន រស់នៅប្រកបដោយសុខដុមរមនា**

យុទ្ធសាស្ត្រ១.១៖ អភិវឌ្ឍបន្ត និងកែលម្អបរិក្ខារកីឡាដែលមានស្រាប់

- អភិវឌ្ឍសមត្ថភាពមន្ត្រីទទួលបន្ទុកការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារកីឡាថ្មី
- ផ្តល់សម្ភារកីឡាដល់អត្តពលិក
- ជំរុញការប្រើប្រាស់ និងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធអប់រំកាយ និងកីឡាឱ្យអស់លទ្ធភាពនៅគ្រប់លំដាប់ថ្នាក់
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំកាយ និងកីឡាគ្រប់ប្រភេទ គ្រប់កម្រិត ឱ្យមានស្តង់ដាច្បាស់លាស់និងប្រកបដោយបរិស្ថានល្អបរិសុទ្ធ

- កសាងផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំកាយ និងកីឡារយៈពេលវែងទាំងនៅថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ
- លើកទឹកចិត្តការផលិតសម្ភារៈកីឡានៅក្នុងប្រទេស។

## យុទ្ធសាស្ត្រ១.២៖ ពង្រឹងការអនុវត្តអប់រំកាយ និងកីឡានៅតាមគ្រឹះស្ថានសិក្សា

- រៀបចំកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រអប់រំកាយ និងវិទ្យាសាស្ត្រកីឡា ដោយធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាបរិញ្ញាបត្ររងអប់រំកាយ និងកីឡា
- អភិវឌ្ឍកម្មវិធីសិក្សាអប់រំកាយ និងកីឡានៅមធ្យមសិក្សា
- ផលិតសៀវភៅណែនាំគ្រូស្តីពីកម្មវិធីសិក្សាថ្មីនៃការអប់រំកាយ និងកីឡា
- បណ្តុះបណ្តាលការប្រើប្រាស់សៀវភៅណែនាំគ្រូស្តីពី ការអប់រំកាយ និងកីឡា
- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីសិក្សាអប់រំកាយ និងកីឡា
- ពង្រឹង និងពង្រីកសមាគម កីឡាសិស្ស-និស្សិត នៅតាមគ្រឹះស្ថានសិក្សារដ្ឋ និងឯកជន
- ប្រារព្ធទិវាជាតិអប់រំកាយ និងកីឡានៅតាមរាជធានី ខេត្ត។

## យុទ្ធសាស្ត្រ១.៣៖ លើកកម្ពស់ការអប់រំកាយ និងកីឡានៅតាមសហគមន៍

- អភិរក្ស និងអភិវឌ្ឍកីឡាប្រពៃណី
- ប្រារព្ធទិវាកីឡា និងព្រឹត្តិការណ៍កីឡា សម្រាប់ទាំងអស់គ្នាតាមសហគមន៍
- អនុវត្តផែនការអាស៊ាន៥ឆ្នាំ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- អនុវត្តសកម្មភាពអប់រំកាយ និងកីឡាដើម្បីគាំទ្រដល់គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព
- បំផុសយុវជនឱ្យចូលរួមក្នុងសកម្មភាពអប់រំកាយ និងកីឡា
- ពង្រឹង និងពង្រីក សមាគមកីឡាមហាជន
- គ្រប់គ្រងសមាគមកីឡាឱ្យមានប្រសិទ្ធភាព។

## យុទ្ធសាស្ត្រ១.៤៖ លើកកម្ពស់ការផ្សព្វផ្សាយកីឡាគ្រប់ប្រភេទដល់សាធារណៈជន

- ផ្សព្វផ្សាយព្រឹត្តិការណ៍កីឡាជាតិ និងអន្តរជាតិតាមប្រព័ន្ធព័ត៌មាន
- ផ្សព្វផ្សាយដល់សារណៈជនឱ្យស្គាល់អត្តពលិកដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ
- ផលិតវីដេអូកីឡាបង្ហាញអំពីសមិទ្ធផល និងអត្ថប្រយោជន៍កីឡា
- ផ្សព្វផ្សាយ ឬ បិទផ្សាយព្រឹត្តិការណ៍កីឡាសំខាន់ៗនៅតាមផ្សារទំនើបធំៗ
- ផ្សព្វផ្សាយផលិតផល ភេសជ្ជៈ ឬ សម្ភារកីឡាគ្រប់ប្រភេទរបស់កម្ពុជា
- ផលិតសម្ភារ និងវត្ថុអនុស្សាវរីយ៍កីឡា
- លើកទឹកចិត្តវិស័យឯកជននិងអ្នកពាក់ព័ន្ធនានាចូលរួមគាំទ្រសកម្មភាពកីឡាសម្រាប់ទាំងអស់គ្នា។

**វត្ថុបំណងអនុវិស័យទី ២៖ លើកកម្ពស់គុណផលក្រុមកីឡាជម្រើសជាតិដើម្បីដណ្ដើមមេដាយមាសឱ្យបានច្រើននៅឆ្នាំ២០២៣**

យុទ្ធសាស្ត្រ ២.១៖ អភិវឌ្ឍសមត្ថភាពកីឡាកម្រិតខ្ពស់

- រៀបចំសាលាថ្នាលនិស្សិតកីឡា និងមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា
- រៀបចំទីកន្លែងហ្វឹកហាត់ និងបំពាក់សម្ភារប្រកបដោយស្តង់ដា
- ជ្រើសរើសកីឡាករ កីឡាការិនីជម្រើសជាតិហាត់ហ្វឹកហ្វឺនក្នុង និងក្រៅប្រទេស
- រៀបចំកម្មវិធីហាត់ហ្វឹកហ្វឺនប្រកបដោយវិទ្យាសាស្ត្រកីឡា
- រៀបចំរបបអាហារ ស្របតាមនិយាមនៃតម្រូវការថាមពលរបស់កីឡាករតាមប្រភេទកីឡា
- រៀបចំគោលនយោបាយលើកទឹកចិត្តអត្តពលិកឆ្នើម។

យុទ្ធសាស្ត្រ ២.២៖ ដំណើរឆ្ពោះទៅកីឡាស៊ីហ្គេមឆ្នាំ២០២៣

- រៀបចំផែនការស្វែងរកមេដាយតាមប្រភេទកីឡាដែលមាននៅក្នុងផែនការមេ
- រៀបចំផែនការជាតិស្វែងរកមេដាយសម្រាប់ប្រកួតកីឡាស៊ីហ្គេម និងការប្រកួតកីឡាអន្តរជាតិនានា
- សិក្សា និងរៀនសូត្របទពិសោធន៍ពីចំណុចខ្លាំងរបស់បណ្ដាប្រទេសនៅក្នុងតំបន់ដែលទទួលបានមេដាយច្រើនក្នុងការប្រកួតកីឡាស៊ីហ្គេម
- រៀបចំមជ្ឈមណ្ឌលវេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រកីឡាសម្រាប់ព្យាបាលកីឡាករ និងកីឡាការិនី។

**វត្ថុបំណងអនុវិស័យទី ៣៖ អភិវឌ្ឍស្ថាប័ន អ្នកគ្រប់គ្រង និងអ្នកបច្ចេកទេសទទួលបន្ទុកអនុវិស័យអប់រំកាយ និងកីឡា ប្រកបដោយប្រសិទ្ធភាពនិងគុណភាព**

យុទ្ធសាស្ត្រ ៣.១៖ ការអភិវឌ្ឍសមត្ថភាពស្ថាប័នរបស់អនុវិស័យអប់រំកាយ និងកីឡា

- រៀបចំក្របខណ្ឌគតិយុត្ត បទបញ្ញត្តិ និងយន្តការគាំទ្រគោលនយោបាយកិច្ចសហប្រតិបត្តិការ និងទំនួលខុសត្រូវពីអ្នកពាក់ព័ន្ធសំខាន់ៗ ប្រកបដោយប្រសិទ្ធភាព
- អនុវត្តគោលនយោបាយ និងក្របខណ្ឌគតិយុត្ត យន្តការដែលមានស្រាប់ និងយន្តការថ្មីៗ
- អភិវឌ្ឍសមត្ថភាពមន្ត្រីគ្រប់គ្រងទទួលបន្ទុកអនុវិស័យអប់រំកាយ និងកីឡា
- អភិវឌ្ឍសមត្ថភាពគ្រប់គ្រង និងបច្ចេកទេសដល់សហព័ន្ធកីឡាជាតិ
- ពិនិត្យតាមដាន និងវាយតម្លៃកម្មវិធីបណ្ដុះបណ្ដាល និងលទ្ធផលការងារ។

យុទ្ធសាស្ត្រ ៣.២៖ អភិវឌ្ឍសមត្ថភាពគ្រូបង្វឹក អាជ្ញាកណ្ដាល ចៅក្រម និងមន្ត្រីបច្ចេកទេសកីឡា

- អភិវឌ្ឍកីឡាថ្នាល និងអត្តពលិកឆ្នើម តាមរយៈការផ្ដល់អាហារូបករណ៍និងឱកាសទទួលបានការបណ្ដុះបណ្ដាលទាំងក្នុង និងក្រៅប្រទេស និងតាមមធ្យោបាយផ្សេងៗ ប្រកបដោយប្រសិទ្ធភាពខ្ពស់
- បណ្ដុះបណ្ដាលមន្ត្រីបច្ចេកទេសកីឡា និងគ្រូបង្វឹក អាជ្ញាកណ្ដាល ចៅក្រម ពិនិត្យតាមដាន ក្រមសីលធម៌ និងវិន័យរបស់អត្តពលិក
- បណ្ដុះបណ្ដាលមន្ត្រីជំនាញផ្នែកប្រយុទ្ធប្រឆាំងនៃការប្រើប្រាស់សារធាតុដូប៉ានៅក្នុងវិស័យកីឡា។

### យុទ្ធសាស្ត្រ ៣.៣៖ លើកកម្ពស់ការប្រកួតកីឡាគ្រប់ប្រភេទប្រកបដោយគុណភាពខ្ពស់

- ពង្រឹង និងពង្រីកសកម្មភាពប្រកួតកីឡានៅតាមគ្រឹះស្ថានសិក្សា
- ពង្រឹងគុណភាពការរៀបចំការប្រកួតកីឡាថ្នាក់រាជធានីខេត្ត
- ការប្រកួតកីឡាសិស្សថ្នាក់ជាតិជាលក្ខណៈហ្គេម
- ការប្រកួតកីឡាសាកលវិទ្យាល័យថ្នាក់ជាតិជាលក្ខណៈហ្គេម
- ពង្រឹងគុណភាពការប្រកួតកីឡាជ្រើសរើសជើងឯកថ្នាក់ជាតិតាមប្រភេទកីឡា
- ពង្រឹងគុណភាពការចូលរួមការប្រកួតទាំងក្នុង និងក្រៅប្រទេស
- ពង្រឹងគុណភាពនៃការរៀបចំការប្រកួតកីឡាជាតិស្របតាមស្តង់ដាតំបន់
- រៀបចំកីឡាស៊ីហ្គេមលើកទី៣២ នៅឆ្នាំ២០២៣ និងការប្រកួតជើងឯកអន្តរជាតិ
- ធ្វើតេស្តដូប៉ាកីឡាករមុនពេល ក្នុង និងក្រោយពេលប្រកួត។

# ជំពូកទី ៤
# យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា

ក្នុងរយៈពេល ៥ ឆ្នាំនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ ក្រសួងនិងដៃគូអភិវឌ្ឍបានរួមគ្នាសម្រេចកិច្ចការធំៗគួរឱ្យកត់សម្គាល់ តាមរយៈការអនុវត្តវិធានការកំណែទម្រង់ ៨ ចំណុចនៅឆ្នាំ២០១៤ និងវឌ្ឍនភាពនៃកំណែទម្រង់ ១៥ ចំណុច ពីឆ្នាំ២០១៥ ដល់ ២០១៨ ជាពិសេសសិស្សខិតខំរៀនសូត្រជាងមុន និងគ្រូបង្រៀនខិតខំបំពេញការងារល្អប្រសើរជាងមុន។ ដំណាក់កាលបន្ទាប់គឺបន្តពង្រឹងការគ្រប់គ្រងសាលារៀន និងសមិទ្ធកម្មនៃការអនុវត្តកម្មវិធីអប់រំគ្រប់រូបភាព។

យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា បានចាត់ទុកថា ការអភិវឌ្ឍធនធានមនុស្សជាអាទិភាពទី១។ ក្រសួងអប់រំ យុវជន និងកីឡានឹងប្តេជ្ញាសម្រេចឱ្យបាននូវមុំទី១ស្តីពី "**ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា**" ដោយផ្តល់អាទិភាពលើ ១) ការយកចិត្តទុកដាក់លើគ្រូបង្រៀន ២) ការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត ៣) ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន ៤) ការជំរុញការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ៥) ការអប់រំបំណិនឱ្យស្របតាមទីផ្សារការងារ ៦) ការអភិវឌ្ឍកម្មវិធីសិក្សានិងសៀវភៅសិក្សាគោលគ្រប់ជ្រុងជ្រោយ និង ៧) ការត្រៀមប្រកួតកីឡាស៊ីហ្គេមឆ្នាំ២០២៣។

## ៤.១ ការធានាសង្គតិភាពនៃកំណែទម្រង់គោលនយោបាយអប់រំថ្នាក់ជាតិ កំណែទម្រង់ការបណ្តុះបណ្តាលគ្រូ និងកំណែទម្រង់កម្រិតសាលារៀន

ដើម្បីធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃកំណែទម្រង់តាមគ្រប់កម្រិត ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវកម្មវិធីកំណែទម្រង់ចំនួន ៣ កម្រិត៖ (១) ការអនុវត្តកំណែទម្រង់គោល-នយោបាយអប់រំកម្រិតជាតិ ក្នុងក្របខណ្ឌសសរស្តម្ភទាំង៥ (២) ការអនុវត្តកំណែទម្រង់គ្រូបង្រៀននៅតាមសាលាគរុកោសល្យ និង(៣) ការអនុវត្តកំណែទម្រង់សាលារៀន។

## ៤.២ អាទិភាពកំណែទម្រង់គោលនយោបាយអប់រំក្នុងក្របខណ្ឌសសរស្តម្ភទាំង៥

ផ្អែកលើវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់វិស័យអប់រំកន្លងមក ក្រសួងអប់រំ យុវជន និងកីឡាបានផ្តោតអាទិភាពកំណែទម្រង់វិស័យអប់រំក្នុងក្របខណ្ឌសសរស្តម្ភទាំង៥ ដូចខាងក្រោម ៖

### សសរស្តម្ភទី ១ ៖ ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន

- ✓ បន្តលើកទឹកចិត្តដល់គ្រូបង្រៀន និងនាយកសាលាដែលមានស្នាដៃ ជ័យលាភីនាយកសាលាល្អ គ្រូបង្រៀនល្អ គ្រូបង្រៀនល្អភាសាខ្មែរថ្នាក់ទី ១ គ្រូបង្រៀនល្អគណិតវិទ្យាថ្នាក់ទី ១
- ✓ អនុវត្តគោលនយោបាយស្តីពី គន្លងអាជីពគ្រូបង្រៀន
- ✓ អនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ សម្រាប់នាយកសាលា និងគ្រូបង្រៀន

- ✓ បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពរបស់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងអភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេស
- ✓ ពង្រឹងសមត្ថភាពគ្រូបង្រៀន និងគរុសិស្សក្នុងការបង្រៀនមុខវិជ្ជាអប់រំសុខភាព ដោយរួមបញ្ចូលទាំងការអប់រំសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ
- ✓ ពិនិត្យសនិទានកម្មគ្រូបង្រៀន និងជំរុញការបែងចែកគ្រូបង្រៀនចេញថ្មីឱ្យកាន់តែមានប្រសិទ្ធភាព។

## សសរស្តម្ភទី ២ ៖ ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងកែលម្អបរិស្ថានសិក្សា

- ✓ អភិវឌ្ឍសៀវភៅសិក្សាគោលគ្រប់មុខវិជ្ជា គ្រប់ភូមិសិក្សា
- ✓ ពង្រឹងវិធីសាស្ត្រអំណាន និងវិធីសាស្ត្របង្រៀនលេខនព្វន្តនៅបឋមសិក្សា និងពង្រឹងវិធីសាស្ត្របង្រៀននៅមធ្យមសិក្សា
- ✓ បណ្តុះទម្លាប់អាននៅក្នុងថ្នាក់រៀន និងនៅក្នុងបណ្ណាល័យ ការប្រារព្ធទិវាជាតិអំណាន ការកែលម្អបណ្ណាល័យនៅតាមគ្រឹះស្ថានសិក្សា និងការបង្កើតបណ្តាញបណ្ណាល័យឌីជីថលនៅគ្រឹះស្ថានឧត្តមសិក្សា និងសាលាគរុកោសល្យ
- ✓ ជំរុញការអនុវត្តគោលនយោបាយអប់រំវិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម និងគណិតវិទ្យា ឬ ការអប់រំតាមបែបឌីជីថល
- ✓ ធ្វើឱ្យប្រសើរឡើងនូវការអនុវត្តមុខវិជ្ជាអប់រំសុខភាព ដោយបញ្ចូលការអប់រំសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ
- ✓ សាងសង់ជំនួស និងជួសជុលអគារសិក្សាទ្រុឌទ្រោម រៀបចំទឹកស្អាត កន្លែងលាងដៃ និងបង្គន់អនាម័យ និងសាងសង់បន្ទប់ពិសោធវិទ្យាសាស្ត្រ និងបន្ទប់កុំព្យូទ័រ។

## សសរស្តម្ភទី ៣ ៖ ការដាក់ឱ្យអនុវត្តអធិការកិច្ច

- ✓ បន្តបណ្តុះបណ្តាលអធិការអប់រំបន្ថែម និងធ្វើអធិការកិច្ចតាមកាលកំណត់ នៅតាមគ្រឹះស្ថានសិក្សាទាំង ២៥ រាជធានី-ខេត្ត
- ✓ សុខដុមនីយកម្មឧបករណ៍ការងារអធិការកិច្ច ដោយបញ្ចូលឧបករណ៍វាយតម្លៃសាលាកុមារមេត្រី និងឧបករណ៍ពិនិត្យតាមដានការគ្រប់គ្រងតាមសាលារៀន
- ✓ ធ្វើអធិការកិច្ចតាមប្រធានបទសំខាន់ៗ ទាក់ទងនឹងកំណែទម្រង់វិស័យអប់រំ
- ✓ ពង្រឹងប្រព័ន្ធអធិការកិច្ចផ្ទៃក្នុងដោយផ្អែកលើការធ្វើស្វ័យវាយតម្លៃរបស់សាលារៀនលើការរៀបចំ និងអនុវត្តការធ្វើអធិការកិច្ចផ្ទៃក្នុងជាប្រចាំ
- ✓ ពង្រឹងតួនាទីរបស់ក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ ក្នុងការវាយតម្លៃលទ្ធផលការងាររបស់សាលារៀន និងថ្នាក់រៀន

- ✓ អនុវត្តប្រព័ន្ធអធិការកិច្ចផ្ទៃក្រៅ ផ្ដែកលើការធ្វើអធិការកិច្ចតាមប្រភេទប្រធានបទ និងការធ្វើអធិការកិច្ចជាប្រចាំនៅកម្រិតរាជធានី-ខេត្ត
- ✓ ឆ្លុះបញ្ចាំងលទ្ធផលនៃការធ្វើអធិការកិច្ចទៅក្នុងការកែលម្អកម្មវិធីសិក្សាការបណ្ដុះបណ្ដាល និងវិក្រឹតការ គ្រូបង្រៀន និងការងារគ្រប់គ្រងដទៃទៀត
- ✓ អភិវឌ្ឍសមត្ថភាពបុគ្គលិកស្ដីពី ការរៀបចំតេស្ដវង្វាយតម្លៃ និងការវិភាគលទ្ធផលតេស្ដ
- ✓ អភិវឌ្ឍ និងបណ្ដុះបណ្ដាលអធិការអប់រំថ្មី និងនាយកសាលាស្ដីពីប្រព័ន្ធអធិការកិច្ចផ្ទៃក្នុងនិងផ្ទៃក្រៅ។

**សសរស្តម្ភទី៤៖ ការពង្រឹងវង្វាយតម្លៃសិក្សាដូចជាការប្រឡង វង្វាយតម្លៃថ្នាក់ជាតិ តំបន់ និងអន្តរជាតិ**

- ✓ បន្តពង្រឹងការប្រឡងគ្រប់ប្រភេទ ជាពិសេសការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ
- ✓ ផ្សព្វផ្សាយក្របខណ្ឌវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតមត្តេយ្យសិក្សានិងអប់រំចំណេះទូទៅ
- ✓ ពង្រឹងការធ្វើតេស្ដវង្វាយតម្លៃថ្នាក់ជាតិ នៅថ្នាក់ទី៣ ទី៦ ទី៨ និងទី១១ លើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា
- ✓ អនុវត្តតេស្ដវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សបឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍សម្រាប់សិស្សថ្នាក់ទី៥
- ✓ ចូលរួមកម្មវិធីអន្តរជាតិស្ដីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស ឆ្នាំ២០២១។

**សសរស្តម្ភទី ៥ ៖ ការកែទម្រង់ឧត្តមសិក្សា**

- ✓ បង្កើនធនធានសម្រាប់ដំណើរការបណ្ដុះបណ្ដាលជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យា ឆ្លើយតបនឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥
- ✓ បង្កើតមូលនិធិសម្រាប់ការស្រាវជ្រាវ
- ✓ វាយតម្លៃការទទួលស្គាល់គុណភាពអប់រំតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន និងពិនិត្យតាមដានលើការបណ្ដុះបណ្ដាលរបស់គ្រឹះស្ថាន
- ✓ លើកកម្ពស់ការចូលរៀននៅឧត្តមសិក្សាប្រកបដោយសមធម៌ បរិយាបន្ន និងការសិក្សាពេញមួយជីវិត
- ✓ ផ្ដល់ថវិកាជាកញ្ចប់ដល់គ្រឹះស្ថានឧត្តមសិក្សា ដែលមានកម្មវិធីបណ្ដុះបណ្ដាលអាទិភាពនៅឧត្តមសិក្សា ឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម
- ✓ សាងសង់អន្តេវាសិកដ្ឋាន ដើម្បីលើកកម្ពស់ការចូលរៀន និងសមធម៌នៅឧត្តមសិក្សា
- ✓ កែលម្អសមត្ថភាពបង្រៀន និងរៀននៅឧត្តមសិក្សា
- ✓ អភិវឌ្ឍកម្មវិធីសិក្សាឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល និងសង្គម

✓ បង្កើនចំនួនសាស្ត្រាចារ្យមានគុណវុឌ្ឍិថ្នាក់បណ្ឌិត ២០ ភាគរយ និងបរិញ្ញាបត្រជាន់ខ្ពស់ ៦០ ភាគរយ។

## ៤.៣ យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងអប់រំ

យុទ្ធសាស្ត្រកំណែទម្រង់គ្រប់គ្រងអប់រំផ្តោតលើសមាសធាតុ ៤ ៖ ១)កំណែទម្រង់ការគ្រប់គ្រងការសិក្សា ២)កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល ៣) កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ និង៤)កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស។ សមាសធាតុរងនៃយុទ្ធសាស្ត្រកំណែទម្រង់នីមួយៗមានដូចខាងក្រោម ៖

### ៤.៣.១. កំណែទម្រង់ការគ្រប់គ្រងការសិក្សា

- អនុវត្តក្របខណ្ឌវាយតម្លៃ ដែលមានប្រព័ន្ធប្រឡងថ្នាក់ជាតិនៅថ្នាក់ទី៩ និង ទី១២ វាយតម្លៃនៅថ្នាក់ទី៣ ទី៦ ទី៨ និងទី១១
- វាយតម្លៃអំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ទី១ ទី២ និងទី៣ វាយតម្លៃថ្នាក់រៀន និងសាលារៀន ក៏ដូចជាប្រព័ន្ធវាយតម្លៃថ្នាក់អន្តរជាតិ និងថ្នាក់តំបន់ដើម្បីវាស់វែងលទ្ធផលសិក្សា និងកែលម្អការបង្រៀននិងរៀន ហើយកំណត់តួនាទីនិងភារកិច្ចនៃរចនាសម្ព័ន្ធគ្រប់គ្រងក្នុងការវាយតម្លៃ
- ពង្រឹងវាយតម្លៃនៅថ្នាក់ទី៣ ទី៦ ទី៨ និងទី១១ លើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា
- រៀបចំឱ្យមានការចូលរួមក្នុងការធ្វើតេស្តថ្នាក់តំបន់ និងអន្តរជាតិ
- កែលម្អគោលការណ៍ណែនាំ ស្តង់ដា និងប្រព័ន្ធពិនិត្យតាមដានការប្រឡងថ្នាក់ជាតិ
- កសាងសមត្ថភាពនិងធ្វើវិមជ្ឈការការទទួលខុសត្រូវលើការប្រឡងថ្នាក់ទី៩ ដល់ថ្នាក់ក្រោមជាតិ
- បង្កើតប្រព័ន្ធលើកទឹកចិត្ត និងការដាក់ពិន័យ ដើម្បីជំរុញការបង្រៀនរបស់គ្រូបង្រៀនឱ្យឆ្លើយតបនឹងស្តង់ដាជាតិ។

### ៤.៣.២. កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល

- អនុវត្តគោលនយោបាយអប់រំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ
- អនុវត្តការគ្រប់គ្រងសាលារៀន
- ធានាការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍មូលដ្ឋាន។

### ៤.៣.៣. កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ

- បង្កើនស្វ័យភាព និងគណនេយ្យភាពហិរញ្ញវត្ថុនៅសាលារៀន
- ធ្វើសវនកម្មថវិកាអប់រំជាទៀងទាត់
- បង្កើនការបែងចែកថវិកាផ្សារភ្ជាប់នឹងគោលនយោបាយអប់រំ។

### ៤.៣.៤. កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស

- អនុវត្តវិធានការកំណែទម្រង់បៀវត្សបានធ្វើឱ្យបៀវត្សបុគ្គលិកអប់រំ កើនឡើងបីដង និងបើកតាមប្រព័ន្ធធនាគារនៅសប្តាហ៍ទី៤នៃខែនីមួយៗ។ ការកើនឡើងទ្វេដងប្រាក់តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក និងការកើនឡើងទ្វេដងនៃប្រាក់បង្រៀនបេបម៉ោងបន្ថែម
- ដាក់ចេញវិធានការដើម្បីពង្រឹងប្រសិទ្ធភាពការគ្រប់គ្រងបុគ្គលិកលើ ៖ ការអនុវត្តភារកិច្ចតាមការពណ៌នាមុខតំណែង ការងារផ្លាស់ប្តូរទីកន្លែងបម្រើការងារ និងការបែងចែកគ្រូបង្រៀនឱ្យទៅដល់សាលារៀនគោលដៅ
- បន្តជំរុញការអនុវត្តវិធានការពង្រាយគ្រូបង្រៀនពីសាលាលើសគ្រូបង្រៀនទៅសាលាខ្វះគ្រូ
- ពង្រឹងប្រសិទ្ធភាពការតែងតាំងមន្ត្រីគ្រប់គ្រងដោយជ្រើសរើសតាមរូបភាព៖ វាយតម្លៃគុណផលការធ្វើតេស្តវាស់ស្ទង់សមត្ថភាព និងការធ្វើសម្ភាសន៍
- បន្តអភិវឌ្ឍមត្ថភាពមន្ត្រីគ្រប់គ្រង និងគ្រូបង្រៀនតាមរយៈការជំរុញអនុវត្តគន្លងអាជីពគ្រូបង្រៀន។

### ៤.៣.៥. គោលនយោបាយ ផែនការ

- ពង្រឹងគុណភាពប្រព័ន្ធគោលនយោបាយ និងផែនការអប់រំឱ្យមានសង្គតិភាពនឹងផែនការថវិកានៅគ្រប់កម្រិតថ្នាក់ដើម្បីកែលម្អប្រព័ន្ធអប់រំនិងរួមចំណែកសម្រេចលទ្ធផលសិក្សារបស់សិស្ស
- អភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំគ្រប់កម្រិតថ្នាក់ស្តីពី ការរៀបចំគោលនយោបាយ និងផែនការអប់រំ និងការគ្រប់គ្រងថវិកានៅគ្រប់កម្រិតថ្នាក់ប្រកបដោយចីរភាព
- ពង្រឹងការរៀបចំថវិកាដោយផ្សារភ្ជាប់នឹងផែនការយុទ្ធសាស្រ្តវិស័យអប់រំ ដើម្បីឱ្យឆ្លើយតបទៅនឹងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ និងទី៤
- ពង្រឹងការរៀបចំផែនការយុទ្ធសាស្រ្ត ផែនការប្រតិបត្តិ និងថវិកានៅថ្នាក់រាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ និងសាលារៀនឱ្យឆ្លើយតបទៅនឹងអាទិភាពនៅក្នុងមូលដ្ឋាន និងអាទិភាពនៅថ្នាក់ជាតិ។

### ៤.៣.៦. ពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ

- អភិវឌ្ឍរចនាសម្ព័ន្ធស្ថិតិអប់រំ ដើម្បីប្រមូលទិន្នន័យទុកចិត្តបាន និងត្រឹមត្រូវពីប្រភពទិន្នន័យផ្សេងៗដោយផ្អែកលើវិធីសាស្រ្តជឿជាក់ដែលអនុលោមតាមបទដ្ឋានអន្តរជាតិ
- លើកកម្ពស់ស្ថាប័ននិងសមត្ថភាពបច្ចេកទេសធ្វើឱ្យទិន្នន័យកាន់តែជាក់លាក់ និងមានប្រសិទ្ធភាព និងធ្វើសុខដុមនីយកម្មប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ
- បន្សុីប្រព័ន្ធព័ត៌មានផ្សេងៗបញ្ចូលគ្នាដូចជា ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ គ្រប់គ្រងធនធានមនុស្ស គ្រប់គ្រងហរិញ្ញវត្ថុ គ្រប់គ្រងអប់រំឧត្តមសិក្សា និងគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ
- លើកកម្ពស់សមត្ថភាពបច្ចេកទេសដើម្បីចងក្រង ផលិត និងផ្សព្វផ្សាយទិន្នន័យ ដែលធ្វើឱ្យទិន្នន័យកាន់តែមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ

- អភិវឌ្ឍ និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធទិន្នន័យអនឡាញ។

## ៤.៤ ទិសដៅទម្រង់ការអប់រំគ្រូបង្រៀននៅតាមសាលាគរុកោសល្យ

### ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន និងមជ្ឈមណ្ឌលអប់រំគ្រូបង្រៀន

- ការពិនិត្យឡើងវិញលើកម្មវិធីបណ្តុះបណ្តាលគ្រូនៅវិទ្យាស្ថានជាតិអប់រំ និងវិទ្យាស្ថានគរុកោសល្យ និងនៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងការធានាសមមូលនៃការបណ្តុះបណ្តាល ជាពិសេសដោយផ្តោតលើមុខវិជ្ជា ស្ទែម បច្ចេកវិទ្យាព័ត៌មាន និងភាសាបរទេស
- ការពង្រឹងសមត្ថភាពគ្រូឧទ្ទេសលើចំណេះមុខវិជ្ជា វិធីសាស្ត្របង្រៀន និងបច្ចេកវិទ្យាព័ត៌មានវិទ្យា
- ពិនិត្យឡើងវិញដំណើការសាលាគរុកោសល្យខេត្ត
- រៀបចំការបណ្តុះបណ្តាលស្តីពីភាពជាអ្នកដឹកនាំសាលារៀន និងបណ្តុះបណ្តាលនាយកសាលា
- ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងការបំពាក់សម្ភារឧបទេសដើម្បីឱ្យការបណ្តុះបណ្តាលមានប្រសិទ្ធភាព
- អភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ និងផ្តល់លក្ខខណ្ឌចាំបាច់ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ
- អភិវឌ្ឍសម្ភាររូបវន្តឱ្យស្របតាមលក្ខណៈវិនិច្ឆ័យកំណត់ស្តង់ដាកម្មវិធីអប់រំគ្រូបង្រៀន
- ប្រែក្លាយមជ្ឈមណ្ឌលគរុកោសល្យភូមិភាគឱ្យទៅជាវិទ្យាស្ថានគរុកោសល្យដែលមានគុណភាពខ្ពស់
- ពង្រឹងមុខងារមជ្ឈមណ្ឌលសម្រាប់អភិវឌ្ឍគ្រូបង្រៀនដើម្បីផ្តល់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈបន្ត
- លើកកម្ពស់ការអភិវឌ្ឍអាជីពតាមរយៈការបង្កើតគន្លងអាជីពច្បាស់លាស់ ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់របស់បុគ្គលិកផ្អែកលើស្នាដៃការងារ និងកម្រិតបៀវត្សតាមរយៈគោលនយោបាយស្តីពីការអភិវឌ្ឍជំនាញវិជ្ជាជីវៈអប់រំ ផែនការគោលស្តីពីការអភិវឌ្ឍជំនាញវិជ្ជាជីវៈបន្ត (រៀបចំប្រព័ន្ធវិក្រឹតការគ្រូបង្រៀន កម្មវិធីគាំទ្រគ្រូបង្រៀននៅតាមសាលារៀន ដើម្បីសម្របសម្រួលជាមួយផ្នែកពាក់ព័ន្ធ ហើយថវិកាគាំទ្រការងារនេះនឹងត្រូវបញ្ចូលទៅក្នុងថវិកាដំណើរការសាលារៀន
- ពិនិត្យឡើងវិញលើលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសគ្រូបង្រៀន តាមរយៈរូបមន្តគ្រូបង្រៀនមត្តេយ្យសិក្សា១២ បូក ២
- កម្មវិធីបណ្តុះបណ្តាលគ្រូតាមស្តង់ដាទំនើបឱ្យស្របតាមតម្រូវការជាតិ ដើម្បីប្រកួតប្រជែងនៅថ្នាក់តំបន់ និងសកលលោកតាមរយៈការអភិវឌ្ឍ ការផ្គត់ផ្គង់ស្តង់ដាអប់រំគ្រូបង្រៀន និងការវាយតម្លៃគុណភាពស្តង់ដាអប់រំគ្រូបង្រៀន និងអភិវឌ្ឍគោលនយោបាយស្តីពី "វិទ្យាស្ថានគរុកោសល្យ" អភិវឌ្ឍផែនការគោលស្តីពី ការអភិវឌ្ឍវិទ្យាស្ថានគរុកោសល្យ ដោយកែសម្រួលតួនាទី ភារកិច្ច ឈ្មោះ និងកំណត់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ សាលាគរុកោសល្យនិងវិក្រឹតការខេត្ត ដើម្បីប្រែក្លាយជាវិទ្យាស្ថានគរុកោសល្យ
- អភិវឌ្ឍការបណ្តុះបណ្តាលដំបូង និងវិក្រឹតការគ្រូបង្រៀននៅវិទ្យាស្ថានគរុកោសល្យ
- រៀបចំប្រព័ន្ធគ្រប់គ្រងគ្រូបង្រៀន និងវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន។

## ៤.៥ កំណែទម្រង់សាលារៀន

ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការផ្តល់សេវាអប់រំនៅកម្រិតសាលារៀន ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវកម្មវិធីកំណែទម្រង់សាលារៀន ដែលមានសមាសភាគដូចតទៅ ៖ (១) ការបង្កើតសាលារៀនជំនាន់ថ្មី (២) ការបង្កើតសាលារៀនគំរូចំនួន ១៥០ តាមរយៈការអនុវត្តការគ្រប់គ្រងតាមសាលារៀន និង(៣) ការលើកទឹកចិត្តឱ្យអនុវត្តការគ្រប់គ្រងតាមសាលារៀននៅតាមគ្រឹះស្ថានសិក្សាដែលមានលក្ខខណ្ឌសមស្រប។

## ៤.៦ កំណែទម្រង់ការអភិវឌ្ឍយុវជន

- ផ្តល់ឱកាសឱ្យយុវជនទទួលបានការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈប្រកបដោយគុណភាព និងសមធម៌
- លើកទឹកចិត្តយុវជនឱ្យមានគំនិតផ្តួចផ្តើម គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព
- អភិវឌ្ឍយុវជនឱ្យមានកាយសម្បទា ចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅល្អ ចេះរួមរស់ជាមួយគ្នាដោយសន្តិភាព និងសុខដុមនីយកម្ម
- បង្កឱកាសឱ្យយុវជនចូលរួមបញ្ចេញមតិ ទស្សនៈ និងធ្វើសេចក្តីសម្រេចចិត្តនានា នៅក្នុងការអភិវឌ្ឍសហគមន៍ និងសង្គមជាតិ
- ពង្រឹងយន្តការគ្រប់គ្រង និងពិនិត្យតាមដានកម្មវិធីអភិវឌ្ឍយុវជន។

## ៤.៧ កំណែទម្រង់ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា

- អភិវឌ្ឍក្របខណ្ឌច្បាប់ និងគតិយុត្តិ
- អភិវឌ្ឍកីឡាកម្រិតខ្ពស់
- ការអភិវឌ្ឍកីឡាសម្រាប់ទាំងអស់គ្នា
- អភិវឌ្ឍវិស័យអប់រំកាយ និងកីឡានៅគ្រប់គ្រឹះស្ថានសិក្សា និងសហគមន៍
- អភិរក្ស និងអភិវឌ្ឍកីឡាគ្រប់ប្រភេទ
- អភិវឌ្ឍឧស្សាហកម្មកីឡា។

## ៤.៨ ការលើកកម្ពស់ការអប់រំតាមបែបឌីជីថល

- បញ្ច្រាបបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍(ប.ព.ស)ឱ្យក្លាយជាឧបករណ៍សម្រាប់បង្រៀន និងរៀន និងចែករំលែកចំណេះដឹងក្នុងវិស័យអប់រំទាំងមូល សំដៅឱ្យសិស្សនិស្សិតនូវចំណេះដឹង និងបំណិនប.ព.ស ដើម្បីធ្វើអន្តរកាលទៅរកពិភពការងារក្នុងសតវត្សរ៍ទី២១
- ប្រើប្រាស់ដំណើរការគ្រប់គ្រង និងបែបបទការងារថ្មី ដើម្បីធ្វើទំនើបកម្មការអនុវត្តការងារ និងបង្កើនប្រសិទ្ធភាព តម្លាភាព និងភាពស័ក្តិសិទ្ធិនៃអភិបាលកិច្ច និងការពិនិត្យតាមដានលទ្ធផលការងារក្នុងវិស័យអប់រំ

- ធានាឱ្យសិស្សនិស្សិតកម្ពុជាគ្រប់រូប បញ្ចប់ការសិក្សាក្នុងប្រព័ន្ធមានចំណេះដឹង និងបំណិន ប.ព.ស. ដើម្បីមានលទ្ធភាពបន្តការសិក្សា និងបំពេញការងារវិជ្ជាជីវៈ
- បង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការបង្រៀន និងរៀននៅតាមសាលាគរុកោសល្យ សាលារៀន និងគ្រឹះស្ថានសិក្សាដទៃទៀត តាមរយៈការប្រើប្រាស់ឧបករណ៍ ប.ព.ស និងធនធានអប់រំអេឡិចត្រូនិច
- ប្រើប្រាស់ការរៀនសូត្រតាមប្រព័ន្ធអេឡិចត្រូនិច (E-Learning) ដើម្បីគាំទ្រឱ្យមានការផ្តល់សេវាអប់រំដល់គ្រប់អនុវិស័យទាំងអស់នៃវិស័យអប់រំសម្រាប់សិស្ស និស្សិត និងការអភិវឌ្ឍសមត្ថភាពស្ថាប័ន ក៏ដូចជាការរៀនពេញមួយជីវិត
- បង្កើនប្រសិទ្ធភាពក៏ដូចជាសមត្ថភាពរបស់ខ្លួន ក្នុងការធ្វើសេចក្តីសម្រេចចិត្តផ្អែកតាមភស្តុតាង និងការចែករំលែកចំណេះដឹង តាមរយៈការប្រើប្រាស់ព័ត៌មានក្នុងលក្ខណៈជាប្រព័ន្ធ ក្នុងពេលតែមួយជាមួយគ្នាដើម្បីបង្កើនសមត្ថភាពរបស់ខ្លួនក្នុងការងាររដ្ឋបាលអប់រំ ប្រតិបត្តិការ និងការប្រមូលទិន្នន័យតាមប្រព័ន្ធឌីជីថល
- បង្កើតស្តង់ដាសម្រាប់ហេដ្ឋារចនាសម្ព័ន្ធ ការភ្ជាប់ទំនាក់ទំនងបណ្តាញអង្គភាពនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិទាំងអស់ទៅក្នុងប្រព័ន្ធតភ្ជាប់ផ្ទៃក្នុង
- ផ្តល់ធនធានហិរញ្ញវត្ថុចាំបាច់ ដើម្បីគាំទ្រដល់ការប្រើប្រាស់ប.ព.ស. ក្នុងវិស័យអប់រំ ដោយប្រើប្រាស់ថវិការបស់រដ្ឋាភិបាល និងធ្វើការសម្របសម្រួលភាពជាដៃគូរវាងវិស័យឯកជន និងវិស័យសាធារណៈ និងការគាំទ្ររបស់ដៃគូអភិវឌ្ឍនានាសម្រាប់រ៉ាប់រងចំណាយមូលធន និងចំណាយចរន្ត។

## ៤.៩. ការបញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ

ការបញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ជាកិច្ចការដ៏សំខាន់ក្នុងការរួមចំណែកអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤របស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រនារីរតនៈ ជាពិសេសការកាត់បន្ថយគម្លាតយេនឌ័រនៅក្នុងវិស័យអប់រំ។ ក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងអនុវត្តផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ២០១៦-២០២០ និងបានបញ្ជ្រាបបញ្ហានេះទៅក្នុងគោលនយោបាយអប់រំគ្រប់អនុវិស័យ រួមបញ្ចូលទាំង ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ផែនការសកម្មភាពគោល-នយោបាយគ្រូបង្រៀន និងបានជំរុញឱ្យអង្គភាពនីមួយៗមានវិធានការជាក់ស្តែងតាមរយៈផែនការគម្រោងកម្មវិធីអប់រំ ការផ្តល់សេវាអប់រំ និងគ្រប់គ្រងដឹកនាំដោយផ្តោតលើការយកចិត្តទុកដាក់ធានាឱ្យកុមារា និងកុមារីបានទទួលលទ្ធភាពចូលរៀនដោយពេញលេញ និងស្មើភាពគ្នា។ ដើម្បីឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ស្តីពីការអប់រំ និងគោលដៅទី៥ស្តីពី សមភាពយេនឌ័រ ក្រសួងអប់រំ យុវជន និងកីឡា មានវិធានការអាទិភាពមួយចំនួន ៖

- ធានាសម្រេចឱ្យបានសមភាពយេនឌ័រក្នុងការចូលរៀន និងរៀនប្រកបដោយគុណភាពនៅគ្រប់សេវាអប់រំទាំងក្នុង និងក្រៅប្រព័ន្ធ
- ធានាបង្កើនការចូលរួមរបស់បុគ្គលិកអប់រំជានារីក្នុងការផ្តល់សេវាអប់រំ
- ធានាកសាងបរិស្ថានអប់រំ និងឥរិយាបថវិជ្ជមានរបស់សង្គម ដើម្បីឆ្លើយតបទៅនឹងយេនឌ័រ

- ចុះអន្តរាគមន៍ និងចាត់វិធានការឱ្យមានប្រសិទ្ធភាព ដើម្បីបង្កើនការទទួលបានការអប់រំសម្រាប់កុមារី រាប់បញ្ចូលទាំងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធនិងបង្កើនចំនួនសាលាមធ្យមសិក្សា ជាពិសេសនៅតាមឃុំ សង្កាត់
- អន្តរាគមន៍ និងចាត់វិធានការនានា សំដៅធានាឱ្យបាននូវការរក្សាសិស្សស្រីនៅក្នុងសាលារៀន ជាពិសេស ការបន្តការសិក្សាពីកម្រិតបឋមសិក្សាទៅមធ្យមសិក្សា និងឧត្តមសិក្សា
- អន្តរាគមន៍ និងចាត់វិធានការនានាសំដៅជំរុញនិងលើកទឹកចិត្តនិស្សិតនារីឱ្យជ្រើសរើសយកមុខវិជ្ជាវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងគណិតវិទ្យា ក៏ដូចជាកម្មវិធីតម្រង់ទិសសិក្សា និងប្រឹក្សាអាជីពដល់សិស្សស្រីនៅមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា
- ការអប់រំអំពីសិទ្ធិផ្លូវភេទ និងសិទ្ធិបន្តពូជនៅតាមសាលារៀន ទំនាក់ទំនងយេនឌ័រ និងការប្រព្រឹត្តផ្លូវភេទ ដែលមានការទទួលខុសត្រូវ ដើម្បីទប់ស្កាត់ការមានគភ៌វ័យក្មេង
- ការលើកកម្ពស់គុណភាពនៃការអប់រំតាមរយៈការបណ្តុះបណ្តាលគ្រូបង្រៀន និងធានាថាគ្រូបង្រៀនទទួលបានប្រាក់បំណាច់គ្រប់គ្រាន់
- ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ២០១៦-២០២០
- រៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ ២០២១-២០២៥
- បន្តបំប៉នសមត្ថភាពស្តីពី«**ការបញ្ជ្រាបយេនឌ័រនៅក្នុងការបណ្តុះបណ្តាលគ្រូបង្រៀន**» ដើម្បីជួយបំប៉នបន្តដល់គណៈគ្រប់គ្រង និងគ្រូឧទ្ទេសនៅតាមវិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងវិក្រឹតការ
- បន្តបំប៉នសមត្ថភាពស្តីពី«**ការបង្កើត និងគ្រប់គ្រងទីប្រឹក្សាកុមារី**» ដល់នាយកសាលា និងទីប្រឹក្សាកុមារី ដើម្បីជួយផ្តល់ប្រឹក្សាដល់កុមារីមានបញ្ហានៅតាមសាលារៀន។

## ៤.១០ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំមានគោលបំណងពង្រឹងស្វ័យភាព និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាសាធារណៈតាមរយៈការផ្ទេរនូវមុខងារ និងធនធាននានាឱ្យទៅដល់ពួកគេ សំដៅធ្វើឱ្យប្រសើរឡើងនូវគុណភាព តម្លាភាព សមធម៌ និងគណនេយ្យភាពក្នុងការផ្តល់សេវាដែលមានគុណភាពជូនប្រជាជន។ ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការពិនិត្យមើលឡើងវិញនូវមុខងារ និងធនធានរបស់ខ្លួនដែលមានកំណត់ដោយច្បាប់ និងបាននិងកំពុងអនុវត្តជាក់ស្តែងនៅក្នុងវិស័យរបស់ខ្លួនទាំងនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ។ តាមរយៈការរៀបចំបញ្ជីមុខងារវិស័យអប់រំបាននឹងកំពុងអនុវត្តមុខងារចម្បងៗប្រមាណ ៥៧៣ មុខងារ ដែលមុខងារទាំងអស់នេះអនុវត្តដោយថ្នាក់សាលារៀនរហូតដល់ថ្នាក់ក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ ក្រសួងអប់រំ យុវជន និងកីឡារក្សាគោលជំហរក្នុងការកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាព ដោយមិនមានការផ្តាច់សាលារៀនពីប្រព័ន្ធគ្រប់គ្រងអប់រំឡើយ។ ក្រសួងនឹង

អនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ ស្របតាមការចង្អុលបង្ហាញនានារបស់រាជរដ្ឋាភិបាល ពិសេសស្របតាមច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានកំណត់ពីជម្រើសនៃការផ្ទេរមុខងារតាមបែបប្រគល់ និងបែបប្រតិភូកម្ម។ កន្លងមកក្រសួងបានធ្វើការពិនិត្យមើលឡើងវិញនូវមុខងាររបស់ខ្លួនរួចរាល់ ដោយបានកំណត់នូវមុខងារ និងធនធាននានាសម្រាប់ធ្វើការផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិតាមផែនការដែលបានកំណត់។

**៤.១០.១ ទីស្តីការក្រសួងអប់រំ យុវជន និងកីឡា៖** ទទួលខុសត្រូវលើការកំណត់គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តិ និងដាក់ចេញនូវផែនការយុទ្ធសាស្ត្រវិស័យអប់រំ ព្រមទាំងកម្មវិធីសិក្សា ការបណ្តុះបណ្តាល និងផ្គត់ផ្គង់គ្រូបង្រៀន។ ក្រសួងមានមុខងារក្នុងការជ្រើសរើស និងផ្តល់ការបណ្តុះបណ្តាល (គរុកោសល្យ) ដល់គ្រូបង្រៀនចេញថ្មី និងផ្តល់វិក្រឹតការដល់គ្រូបង្រៀន និងបុគ្គលិកដែលមានស្រាប់។ ក្រសួងអនុវត្តនូវមុខងារជាច្រើនផ្សេងទៀតក្នុងការធានាឱ្យការផ្តល់សេវាអប់រំមានគុណភាព ជាមួយគ្នានេះដែរ ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រសួងជាអ្នកទទួលខុសត្រូវក្នុងការពិនិត្យមើលឡើងវិញនូវមុខងារ កំណត់មុខងារនិងធនធានសម្រាប់ផ្ទេរឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ធ្វើវិមជ្ឈការបច្ចេកទេសសាលារៀន។ល។ មុខងាររបស់ក្រសួងត្រូវបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

**៤.១០.២ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ៖** ជាសេនាធិការឱ្យដល់ក្រសួងអប់រំ យុវជន និងកីឡា ដែលមានតួនាទី ភារកិច្ច និងមុខងាររបស់ខ្លួនច្បាស់លាស់ដែលបានមកពីការធ្វើប្រតិភូកម្ម ឬ វិសហមជ្ឈការពីក្រសួង។ មន្ទីរអប់រំ យុវជន និងកីឡា ដើរតួជាអន្តរការីរវាងក្រសួង និងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងសាលារៀន ដោយផ្តល់ការសម្របសម្រួល ការគាំទ្រ និងរបបរាយការណ៍ស្ថិតក្នុងដែនសមត្ថកិច្ចរៀងៗ ខ្លួនក្នុងនាមជាអង្គភាពជួរក្រោយគាំទ្រការផ្តល់សេវាអប់រំ។ ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការស្របតាមច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ច្បាប់រៀបចំអង្គការ) មន្ទីរអប់រំ យុវជន និងកីឡាមានតួនាទីភារកិច្ចថ្មីបន្ថែមជាសេនាធិការឱ្យដល់ក្រុមប្រឹក្សា និងគណៈភិបាលរាជធានី ខេត្ត ក្នុងនាមជាសមាជិកនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសថ្នាក់រាជធានី ឬ ខេត្ត (មាត្រា១២៣)។ ក្រសួងអប់រំ យុវជន និងកីឡានឹងធ្វើការពិនិត្យមើល និងកែសម្រួលឡើងវិញនូវតួនាទី ភារកិច្ចរបស់មន្ទីរអប់រំ យុវជន និងកីឡាបន្ទាប់ពីមានការផ្ទេរមុខងារអប់រំ ពិសេសការផ្ទេរការិយាល័យអប់រំ យុវជន និងកីឡាឱ្យទៅដល់រដ្ឋបាលឯកភាពក្រុង ស្រុក។

**៤.១០.៣ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ៖** ដើរតួជាអន្តរការីរវាងក្រសួងនិងសាលារៀន ដោយផ្តល់ការសម្របសម្រួល ការគាំទ្រ និងរបបរាយការណ៍ ស្ថិតក្នុងដែនសមត្ថកិច្ចរៀងៗខ្លួនក្នុងនាមជាអង្គភាពជួរក្រោយគាំទ្រការផ្តល់សេវាអប់រំ។ ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការស្របតាមច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងសេចក្តីសម្រេចនានារបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការរៀបចំឡើងវិញនូវតួនាទី ភារកិច្ច រចនាសម្ព័ន្ធរបស់រដ្ឋបាលឯកភាពក្រុង ស្រុក។

- ក្រសួងអប់រំ យុវជន និងកីឡានឹងផ្ទេរមុខងារទាំងស្រុងរបស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ដែលកំពុងអនុវត្ត និងកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តិរបស់ក្រសួងភ្ជាប់ជាមួយនឹងធនធានមនុស្ស ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ (លើកលែងតែទីតាំងការិយាល័យដែលមានក្នុងសាលារៀន) ឱ្យទៅដល់រដ្ឋបាលឯកភាពក្រុង ស្រុក
- ធ្វើសមាហរណកម្មរចនាសម្ព័ន្ធការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកចូលក្នុងរចនាសម្ព័ន្ធរដ្ឋបាលឯកភាពក្រុង ស្រុក
- រដ្ឋបាលឯកភាពក្រុង ស្រុកមានភាពជាម្ចាស់លើការសម្របសម្រួលអនុវត្តមុខងារអប់រំ យុវជន និងកីឡាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយមានការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ជាសេនាធិការផ្ទាល់
- សាលារៀនមានស្វ័យភាពលើការងារគ្រប់គ្រង និងដឹកនាំទាំងផ្នែកបច្ចេកទេស និងរដ្ឋបាលក្រោមការសម្របសម្រួលការងារ និងការគាំទ្រនានាពីថ្នាក់រដ្ឋបាលឯកភាពក្រុង ស្រុកដែលមានការិយាល័យអប់រំ យុវជន និងកីឡាជាសេនាធិការ
- រដ្ឋបាលឯកភាពក្រុង ស្រុកនឹងត្រូវបានកំណត់ឱ្យមានការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះមុខក្រសួងអប់រំ យុវជន និងកីឡា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាលើការអនុវត្តមុខងារអប់រំ យុវជន និងកីឡាដែលបានប្រគល់ជូន។

៤.១០.៤ **គ្រឹះស្ថានសិក្សា ៖** ជាកន្លែងផ្តល់សេវាអប់រំ គ្រប់គ្រងអប់រំ ការបង្រៀន និងរៀនដោយផ្ទាល់ ក្នុងនាមជាអង្គភាពជួរមុខលើការផ្តល់សេវាអប់រំ។ កន្លងមកក្រសួងបានផ្តល់ធនធានចាំបាច់នានាដូចជា៖ គ្រូបង្រៀន សម្ភារបរិក្ខារ អគារសិក្សា និងថវិកាដំណើរការដល់សាលារៀនផ្ទាល់។ សាលារៀនបានប្រើប្រាស់គណនីធនាគារសម្រាប់លំហូរសាច់ប្រាក់ដើម្បីពន្លឿនការងារ ធានាកាត់បន្ថយការិយាធិបតេយ្យលើបញ្ជីការគណនេយ្យ។ សាលារៀនត្រូវបានផ្តល់នូវស្វ័យភាពក្នុងការរៀបចំផែនការសកម្មភាពអភិវឌ្ឍរបស់ខ្លួន ការគ្រប់គ្រងការងាររដ្ឋបាលសាលារៀន និងការងារបច្ចេកទេសរៀននិងបង្រៀន។ សាលារៀននឹងមានការទទួលខុសត្រូវកាន់តែខ្ពស់តាមរយៈការផ្តល់នូវស្វ័យភាព ដែលបាននឹងកំពុងធ្វើឡើងជាបន្តបន្ទាប់។ ចាប់ពីឆ្នាំ២០០០ ក្រសួងបានផ្ទេរថវិកាដំណើរការដល់សាលារៀនតាមរយៈការផ្ទេរថវិកាពីរតនាគារជាតិដល់សាលារៀន ដោយមិនមានឆ្លងកាត់ថ្នាក់ណាទេ ដើម្បីធានាបាននូវប្រសិទ្ធភាពនៃការផ្តល់សេវា និងកាត់បន្ថយការិយាធិបតេយ្យ។ តាមបទពិសោធន៍នៃការអនុវត្តនៅប្រទេសដទៃ ការប្រមូលថវិកាសាលារៀនមកគ្រប់គ្រងនៅកម្រិតស្រុកនឹងមានបច្ច័យមិនល្អដល់ដំណើរការរបស់សាលារៀន ដែលឈានទៅបង្កើតហានិភ័យដែលមិនអាចព្យាករណ៍បាន។ ជាងនេះទៀត វិស័យអប់រំ គឺជើរត្មយ៉ាងសំខាន់ក្នុងការអភិវឌ្ឍជាតិក្នុងពេលអនាគត ការប្រមូលផ្តុំថវិកាពីថ្នាក់សាលារៀនមករដ្ឋបាលឯកភាពក្រុង ស្រុក នឹងអាចធ្វើឱ្យមានផលប៉ះពាល់អវិជ្ជមាន។

ក្រសួងបានធ្វើវិមជ្ឈការការផ្តល់សេវាសាធារណៈ តាមរយៈការផ្តល់ថវិកាដល់កម្រិតសាលារៀនដោយផ្ទាល់។ ចំណែកឯការងារគ្រប់គ្រងបុគ្គលិក ការតែងតាំងបុគ្គលិក ក៏ត្រូវបានធ្វើវិមជ្ឈការហើយផងដែរ ដោយការតែងតាំងអ្នកគ្រប់គ្រងវិស័យអប់រំថ្នាក់ក្រោមជាតិត្រូវបានអនុវត្តរួចរាល់នៅកម្រិតខេត្ត។ ជាមួយគ្នា

នេះដែរ នៅមានមុខងារនានាផ្សេងទៀតពាក់ព័ន្ធនឹងការសម្របសម្រួលលើដំណើរការសាលារៀនដោយថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុកបាននឹងកំពុងរៀបចំត្រៀមផ្ទេរឱ្យទៅដល់រដ្ឋបាលឯកភាពក្រុង ស្រុក។ ជារួម វិមជ្ឈការបច្ចេកទេសអប់រំដើម្បីពង្រឹងគុណភាពសេវាសាធារណៈក្នុងវិស័យអប់រំ គឺចាំបាច់តម្រូវឱ្យត្រូវពង្រឹងស្វ័យភាពលើការគ្រប់គ្រងសាលារៀននៅថ្នាក់សាលារៀនដោយផ្ទាល់។

ក្រសួងបាននិងកំពុងអនុវត្តគោលវិធី "**ការគ្រប់គ្រងតាមសាលារៀន**" ដែលជាវិធីសាស្ត្រអនុវត្តនូវវិមជ្ឈការនៃការអប់រំកម្រិតរដ្ឋបាលសាលារៀនផ្ទាល់ ដើម្បីឱ្យសេវាអប់រំមានប្រសិទ្ធភាពជំនួសឱ្យការគ្រប់គ្រងពីរដ្ឋបាលអប់រំថ្នាក់កណ្តាល ឬ ថ្នាក់ណាមួយ ដោយត្រូវជំរុញបង្កើតគណៈកម្មការគ្រប់សាលារៀន (ការចូលរួមពីនាយកសាលា គ្រូបង្រៀន អាជ្ញាធរមូលដ្ឋាន ភូមិ ឃុំ មេប៉ុស្តិ៍ អាចារ្យវត្ត មាតាបិតា ក្រុមប្រឹក្សាកុមារ/យុវជន) បង្កើនស្វ័យភាពនិងការទទួលខុសត្រូវរបស់សាលារៀនលើការងាររដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុ បច្ចេកទេសរៀននិងបង្រៀន។ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញជាគោលនយោបាយកំណែទម្រង់វិមជ្ឈការបច្ចេកទេស ក្នុងការផ្តល់ស្វ័យភាពដល់សាលារៀន និងមានផែនការសកម្មភាព និងផែនការអភិវឌ្ឍសមត្ថភាពសម្រាប់អនុវត្តកំណែទម្រង់វិមជ្ឈការនេះច្បាស់លាស់។

**៤.១០.៥ យុទ្ធសាស្ត្រចម្បងៗ និងផែនការសកម្មភាព ៖** ដើម្បីសម្រេចបាននូវប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការវិស័យអប់រំ ក្រសួងអប់រំ យុវជន និងកីឡាត្រូវអនុវត្តយុទ្ធសាស្ត្រសំខាន់ៗដូចខាងក្រោម៖

- រៀបចំក្របខណ្ឌច្បាប់ និងការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ តួនាទីភារកិច្ចស្ថាប័នអប់រំ យុវជន និងកីឡាទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- រៀបចំ និងកំណត់ឡើងវិញនូវខ្សែគណនេយ្យភាពរបស់ស្ថាប័ន និងអង្គភាពថ្នាក់ក្រោមជាតិ ផ្អែកលើការផ្ទេរមុខងារ និងធនធាន
- រៀបចំក្របខណ្ឌច្បាប់ គោលនយោបាយប្រព័ន្ធស្វ័យភាពគ្រឹះស្ថានសិក្សាសាធារណៈ
- ផ្ទេរមុខងារ និងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- អភិវឌ្ឍសមត្ថភាពការងារអប់រំដល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រប់ភាគីពាក់ព័ន្ធ
- រៀបចំផែនការអភិវឌ្ឍសមត្ថភាពបុគ្គលិកនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- លើកកម្ពស់បរិយាបន្ន និងសមធម៌សង្គម
- ពង្រឹងការពិនិត្យតាមដាន និងវាយតម្លៃ។

# ជំពូកទី ៥
# ផែនការហិរញ្ញប្បទានឆ្នាំ ២០១៩-២០២៣

## ៥.១ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យដំណើរការកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងឆ្នាំ២០០៤ ដោយបានកំណត់ជា ៤ ដំណាក់កាលគឺ (១) ការធ្វើឱ្យប្រសើរឡើងនូវភាពជឿជាក់ថវិកា (២) ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ (៣) ការលើកកម្ពស់ទំនាក់ទំនងរវាងគោលនយោបាយ និងថវិកា និង (៤) បង្កើនគណនេយ្យភាពសមិទ្ធកម្ម។ ដំណាក់កាលទី ១ និងទី ២ ត្រូវបានបញ្ចប់ដោយជោគជ័យនៅឆ្នាំ២០០៨ និង២០១៥។ រាជរដ្ឋាភិបាលបានបន្តដាក់ឱ្យអនុវត្តដំណាក់កាលទី៣នៅដើមឆ្នាំ ២០១៦។ រាជរដ្ឋាភិបាលមានគោលបំណងជំរុញឱ្យគ្រប់ក្រសួងទាំងអស់ អនុវត្តកម្មវិធីថវិកាពេញលេញនៅឆ្នាំ២០១៨។

ក្រសួងអប់រំ យុវជន និងកីឡាបាននិងកំពុងអនុវត្តថវិកាកម្មវិធី ព្រមទាំងបានធ្វើបច្ចុប្បន្នកម្មរចនាសម្ព័ន្ធកម្មវិធី និងអនុកម្មវិធី ក៏ដូចជាបង្កើនការទទួលខុសត្រូវរបស់អង្គភាពអនុវត្ត។ លទ្ធផលសំខាន់ៗក្រសួងបាន៖ (១) ធ្វើបច្ចុប្បន្នកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យាលើរបាយការណ៍ហិរញ្ញវត្ថុ (២) ធ្វើបច្ចុប្បន្នកម្មផែនការសកម្មភាពកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (៣) បង្កើតប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់របាយការណ៍សម្រេចទូទាត់ថវិកាជាតិប្រចាំឆ្នាំ (៤) បង្កើតប្រព័ន្ធគ្រោងថវិកា និងរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងមូលនិធិប្រតិបត្តិការសាលារៀន និងការគ្រប់គ្រងបេសកកម្មតាមប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ថ្នាក់រាជធានី ខេត្ត (៥) បង្កើតប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំដោយផ្សារភ្ជាប់ផែនការយុទ្ធសាស្ត្រថវិកា និងផែនការប្រតិបត្តិប្រចាំឆ្នាំ (៦) អនុម័តគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមូលនិធិដំណើរការសាលារៀនរដ្ឋ ដោយបានឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ទន្ទឹមនឹងទទួលបាននូវសមិទ្ធផលខាងលើ ក្រសួងនឹងបន្តពង្រឹងការគ្រោងថវិការបស់អង្គភាពជំនាញឱ្យបន្សុីជាមួយនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ បន្តពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យា បន្តអភិវឌ្ឍសមត្ថភាព និងចំណេះដឹងផ្នែកព័ត៌មានវិទ្យាជូនដល់មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុនៅតាមអង្គភាព និងសាលារៀនរដ្ឋ រៀបចំសៀវភៅណែនាំស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រោងថវិកា និងរបាយការណ៍ហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់អង្គភាពថវិកា និងគ្រឹះស្ថានសិក្សារដ្ឋ។ ម៉្យាងទៀត ក្រសួងបន្តពង្រឹងគុណភាពផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ជាតិ និងរាជធានី ខេត្ត ក៏ដូចជា ថវិកាកម្មវិធី និងផែនការប្រតិបត្តិប្រចាំឆ្នាំ ដើម្បីវិភាជន៍ធនធានឱ្យឆ្លើយតបនឹងវត្ថុបំណងគោលនយោបាយ និងសម្រេចបាននូវសមិទ្ធផលអប់រំ និងយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា។

### ៥.១.១ វត្ថុបំណង

- ពង្រឹងដំណើរការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីអនុវត្តថវិកាប្រកបដោយប្រសិទ្ធភាព
- ផ្សារភ្ជាប់គណនេយ្យភាពហិរញ្ញវត្ថុដោយផ្ទាល់ទៅនឹងគណនេយ្យភាពការបំពេញការងារ។

## ៥.១.២ យុទ្ធសាស្រ្ត និងសកម្មភាព

### វត្ថុបំណងទី ១៖ ពង្រឹងដំណើរការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីអនុវត្តថវិកាប្រកបដោយប្រសិទ្ធភាព

យុទ្ធសាស្រ្ត ១.១៖ ពង្រឹងការរៀបចំផែនការថវិកាផ្អែកលើលទ្ធផលតាមអនុវិស័យ និងប្រព័ន្ធរបាយការណ៍ហិរញ្ញវត្ថុគ្រប់កម្រិត

- អភិវឌ្ឍម៉ូដែលគណនាចំណាយតាមអនុវិស័យផ្អែកលើលទ្ធផល
- លើកកម្ពស់ប្រាក់បៀវត្សបុគ្គលិករដ្ឋបាលរួមទាំងនាយកសាលា
- បន្សុីថវិកាប្រចាំឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំជាមួយនឹងផែនការយុទ្ធសាស្រ្តថវិកា។

យុទ្ធសាស្រ្ត ១.២៖ កែលម្អប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិក្នុងគណនេយ្យភាពហិរញ្ញវត្ថុនិងដំណើរការគ្រប់គ្រង

- ពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ធ្វើការព្យាករណ៍ និងការប្រើប្រាស់ថវិកាអប់រំតាមរយៈការកែលម្អគោលការណ៍ចំណាយនិងលិខិតបទដ្ឋានគតិយុត្តថវិកា
- កែលម្អគោលការណ៍ទូទាត់និងការបើកសាច់ប្រាក់
- កែលម្អប្រព័ន្ធព័ត៌មានសម្រាប់ធ្វើការព្យាករណ៍ចំណាយ និងការវិភាគ
- អនុវត្តគោលការណ៍ដែលបានកែលម្អស្តីពីការបើកសាច់ប្រាក់ និងដំណើរការទូទាត់។

### វត្ថុបំណងទី ២៖ ផ្សារភ្ជាប់គណនេយ្យភាពហិរញ្ញវត្ថុដោយផ្ទាល់ទៅនឹងគណនេយ្យភាពការបំពេញការងារ

យុទ្ធសាស្រ្ត ២.១៖ ពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ធ្វើផែនការ និងពិនិត្យតាមដានការប្រើប្រាស់ថវិកាអប់រំ

- ពង្រីកប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុដោយប្រើប្រាស់កុំព្យូទ័រនៅគ្រប់កម្រិត។

យុទ្ធសាស្រ្ត ២.២៖ ធ្វើវិមជ្ឈការការងារថវិកាទៅថ្នាក់ក្រោមជាតិ

- ពង្រឹងការធ្វើផែនការថវិកា យន្តការ និងប្រព័ន្ធរបាយការណ៍ហិរញ្ញវត្ថុតាមរយៈការអភិវឌ្ឍសមត្ថភាព និងធនធាននៅថ្នាក់ក្រោមជាតិ
- ពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុតាមរយៈការអភិវឌ្ឍម៉ូដែលចំណោល និងការវិភាជន៍ថវិកាសម្រាប់វិស័យអប់រំ
- កែលម្អប្រព័ន្ធគណនី និងរបាយការណ៍តាមរយៈប្រតិបត្តិការប្រព័ន្ធព័ត៌មានស្វ័យប្រវត្តិ
- ពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តថវិកាដោយផ្តោតលើការវិភាគផ្អែកលើលទ្ធផល និងគណនេយ្យភាពការបំពេញការងារ
- ពង្រីកនិងធ្វើឱ្យស្ថាប័នប្រើប្រាស់ប្រព័ន្ធធនាគារ។

យុទ្ធសាស្រ្ត ២.៣៖ ពង្រឹងសវនកម្មផ្ទៃក្នុង

- អភិវឌ្ឍផែនការយុទ្ធសាស្រ្តសវនកម្មផ្ទៃក្នុងរយៈពេល៣ឆ្នាំ
- អភិវឌ្ឍឯកសារណែនាំសវនកម្មផ្ទៃក្នុងស្របតាមឯកសាររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តសវនកម្មផ្ទៃក្នុងជាប្រចាំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- កែសម្រួលនិងពិនិត្យឡើងវិញលិខិតបទដ្ឋានគតិយុត្ត គោលការណ៍ និងច្បាប់ទាក់ទងនឹងសវនកម្មផ្ទៃក្នុងនិងការអភិវឌ្ឍប្រព័ន្ធព័ត៌មានគ្រប់គ្រងស្របតាមគោលការណ៍ណែនាំ និងនីតិវិធីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាកល្បង និងបញ្ចប់កម្មវិធីសវនកម្មផ្ទៃក្នុង
- បណ្តុះបណ្តាលមន្ត្រីសវកម្មផ្ទៃក្នុង។

យុទ្ធសាស្ត្រ ២.៤៖ ពង្រឹងរដ្ឋបាលនិងអធិការកិច្ចហិរញ្ញវត្ថុ

- អធិការកិច្ចផ្លូវការស្តីពីបុគ្គលិក រដ្ឋបាល ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសាលារៀនរដ្ឋនិងឯកជន
- ពិនិត្យតាមដាន និងលើកសំណើឱ្យឆ្លើយតបទៅនឹងករណីនានាដែលពាក់ព័ន្ធនឹងកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ។

## ៥.២ ការប៉ាន់ស្មានធនធានដែលមាន សម្រាប់វិស័យអប់រំ

រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពទី១លើការអភិវឌ្ឍធនធានមនុស្ស។ ចំណុចនេះ វិស័យអប់រំត្រូវមានការវិនិយោគកាន់តែច្រើនក្នុងដំណាក់កាលជាបន្តបន្ទាប់ ក្នុងគោលបំណងសម្រេចនូវអាទិភាពគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធីនៅក្នុងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣។

យន្តការនៃផ្តល់ហិរញ្ញប្បទានប្រកបដោយសមធម៌ និងត្រឹមត្រូវ ត្រូវមានការគិតគូរទាំងការជួយពីសំណាក់រាជរដ្ឋាភិបាល មាតាបិតាសិស្ស និងអ្នកចូលរួមវិភាគទានដ៏មានសក្តានុពលដទៃទៀត។

ទន្ទឹមនោះដែរ គ្រប់ព័ត៌មានហិរញ្ញវត្ថុត្រូវមានព័ត៌មានទាំងអស់ទាក់ទងនឹងចំណាយក្នុងវិស័យអប់រំ ដើម្បីផ្តល់លទ្ធភាពដល់អ្នកពាក់ព័ន្ធធ្វើការវិនិច្ឆ័យនូវតម្លៃនៃការវិនិយោគនាពេលបច្ចុប្បន្ន ក៏ដូចជាអនាគតប្រកបដោយប្រសិទ្ធភាព។ រាជរដ្ឋាភិបាលកម្ពុជាក៏បានលើកទឹកចិត្តដល់វិស័យឯកជនឱ្យចូលរួមចំណែកក្នុងការផ្តល់សេវាអប់រំផងដែរ។

ការប៉ាន់ស្មានថវិកាដែលមាន សម្រាប់ការចំណាយលើវិស័យអប់រំសរុប មាន ៥ ២៥៦ ពាន់លានរៀលនៅឆ្នាំ២០២៣។

### តារាងទី១១ ៖ ការប៉ាន់ស្មានធនធានដែលមាន សម្រាប់វិស័យអប់រំ (គិតជាលានរៀល)

| ការប៉ាន់ស្មានធនធានដែលមាន | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ផ.ស.ស ថ្លៃបច្ចុប្បន្ន | ១០៨ ៥៩០ ៤៤៤ | ១១៩ ០៣៣ ៥៤៨ | ១៣០ ៩១៥ ៨២២ | ១៤៤ ១៦៨ ៣៤៨ | ១៥៨ ៨៨៤ ៣៦៨ |
| អត្រាកំណើន ផ.ស.ស ពិត | ៧,១% | ៦,៥% | ៧,០% | ៧,០% | ៧,០% |
| ផ.ស.ស សម្រាប់ប្រជាជនម្នាក់ៗ | ៦,៨ | ៧,៤ | ៧,៩ | ៨,៧ | ៩,៥ |
| ចំណាយរាជរដ្ឋាភិបាលលើការអប់រំ | ៣ ២២៩ ៦០៤ | ៣ ៥៧៧ ៦៥៥ | ៣ ៩៧៥ ៩៨៨ | ៤ ៤២៣ ៨៤៧ | ៤ ៩២៥ ៤១៥ |
| *ចរន្ត* | *៣ ២១៩ ៦០៤* | *៣ ៥៦៧ ៦៥៥* | *៣ ៩៦៥ ៩៨៨* | *៤ ៤១៣ ៨៤៧* | *៤ ៩១៥ ៤១៥* |
| *មូលធន* | *១០ ០០០* | *១០ ០០០* | *១០ ០០០* | *១០ ០០០* | *១០ ០០០* |
| គិតជាភាគរយនៃផ.ស.ស | ២,៩៧% | ៣,០១% | ៣,០៤% | ៣,០៧% | ៣,១០% |
| ថវិកាអប់រំធៀបនឹងចំណាយរបស់រាជរដ្ឋាភិបាល | ១៨,៤% | ១៨,៦% | ១៨,៨% | ១៨,៩% | ១៩,១% |

## ៥.៣ ការព្យាករណ៍តម្រូវថវិកា សម្រាប់វិស័យអប់រំ

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ បានរំលេចនូវសកម្មភាពអភិវឌ្ឍនៅក្នុងអនុវិស័យទាំង ៧។ តម្រូវការធនធានសរុបសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ មានការកើនឡើងពី ៣ ៨១៧ ពាន់លានរៀលនៅឆ្នាំ២០១៩ ទៅ ៥ ២៨៩ ពាន់លានរៀលនៅឆ្នាំ២០២៣។

ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ និងយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាឱ្យមានប្រសិទ្ធភាព ក្រសួងអប់រំ យុវជន និងកីឡាបន្តធ្វើការងារយ៉ាងជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ ដើម្បីធានាថា ការរៀបចំផែនការចំណាយរយៈពេលមធ្យមសម្រាប់វិស័យអប់រំកាន់តែមានសង្គតិភាព និងស្របតាមក្របខណ្ឌចំណាយរយៈពេលមធ្យមរបស់រាជរដ្ឋាភិបាល ជាពិសេសកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់រដ្ឋបាលសាធារណៈ។

### តារាងទី១២ ៖ ការព្យាករណ៍តម្រូវការថវិកា តាមអនុវិស័យ (គិតជាលានរៀល)

| អនុវិស័យ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ការអប់រំកុមារតូច | ២៤៦ ៧៥១ | ២៧២ ២៤២ | ២៩៦ ២៦១ | ៣០៦ ៩៤៧ | ៣៣៦ ៦៧៣ |
| ការអប់រំបឋមសិក្សា | ១ ៩៦៩ ៥០២ | ២ ១១០ ០៤៦ | ២ ២១៦ ៦៣៦ | ២ ៣៥៥ ៧៧៩ | ២ ៤៩៩ ៧២៤ |
| ការអប់រំមធ្យមសិក្សា | ១ ០៩៣ ៦៣០ | ១ ១៨៩ ៤១៥ | ១ ៣៦២ ៩៧៩ | ១ ៥០០ ៧៥២ | ១ ៦៦២ ១៨៤ |
| ឧត្តមសិក្សា | ៣៦៧ ៤៩៦ | ៤២៨ ៧២២ | ៤៨១ ០០៥ | ៥២៤ ៧៣៦ | ៥៨៥ ៤១៨ |
| ការអប់រំក្រៅប្រព័ន្ធ | ៤២ ០១៦ | ៥៧ ០០៩ | ៦១ ១៥៧ | ៧៣ ៧៧៣ | ៨១ ១៤២ |
| ការអភិវឌ្ឍយុវជន | ២៦ ៥៩៦ | ៣២ ២៧៣ | ៣៤ ៧៧៦ | ៣៥ ៣៦៧ | ៣៨ ០៥៨ |
| ការអប់រំកាយ និងកីឡា | ៧១ ៨៩៤ | ៧៣ ៤៩៦ | ៧៦ ៥៣៥ | ៨០ ៤៨៤ | ៨៦ ៥៦៣ |
| **សរុប** | **៣ ៨១៧ ៨៨៥** | **៤ ១៧៥ ២០៣** | **៤ ៥២៩ ៣៤៩** | **៤ ៨៧៧ ៨៣៨** | **៥ ២៨៩ ៧៦២** |

## ៥.៤ ការប៉ាន់ស្មានគម្លាតថវិកា និងយុទ្ធសាស្ត្រគៀរគរធនធាន

### តារាងទី១៣ ៖ ការប៉ាន់ស្មានគម្លាតថវិកា

| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ចំណាយរាជរដ្ឋាភិបាលលើការអប់រំ (លានរៀល) | ៣ ២២៩ ៦០៤ | ៣ ៥៧៧ ៦៥៥ | ៣ ៩៧៥ ៩៨៨ | ៤ ៤២៣ ៨៤៧ | ៤ ៩២៥ ៤១៥ |
| មូលនិធិក្រៅប្រទេស(ផែនការវិនិយោគវិស័យអប់រំ) | ៥៥៣ ៦៤០ | ៥៨៣ ៣៧១ | ៤៩២ ៥៦១ | ៤០២ ៦៥២ | ៣៣០ ៨០៦ |
| **ធនធានដែលមានសរុប (លានរៀល)** | **៣ ៧៨៣ ៣៨០** | **៤ ១៦១ ០២៦** | **៤ ៤៦៨ ៥៤៩** | **៤ ៨២៦ ៤៤០៩** | **៥ ២៥៦ ២២២** |
| *គិតជាលានដុល្លារ* | ៩៣៣,២៥ | ១ ០២៦,៤០ | ១ ១០២,២៦ | ១ ១៩០,៥៣ | ១ ២៩៦,៥៥ |
| **តម្រូវការថវិកាសរុប (លានរៀល)** | **៣ ៨១៧ ៨៨៥** | **៤ ១៧៥ ២០៣** | **៤ ៥២៩ ៣៤៩** | **៤ ៨៧៧ ៨៣៨** | **៥ ២៨៩ ៧៦២** |
| *គិតជាលានដុល្លារ* | ៩៤១,៧៦ | ១ ០២៩,៩០ | ១ ១១៧,២៥ | ១ ២០៣,២២ | ១ ៣០៤,៨៣ |
| គម្លាតថវិកា (លានរៀល) | -៣៤ ៥០៥ | -១៤ ១៧៧ | -៦០ ៨០០ | -៥១ ៤២៩ | -៣៣ ៥៤០ |
| *គិតជាលានដុល្លារ* | -៨,៥១ | -៣,៥០ | -១៥,០០ | -១២,៦៩ | -៨,២៧ |
| កង្វះថវិកា (%) | -0,៩១% | -0,៣៤% | -១,៣៦% | -១,០៧% | -០,៦៤% |

# ជំពូកទី ៦
# ការពិនិត្យតាមដាន និងវាយតម្លៃ

## ៦.១ ការពិនិត្យតាមដាន និងវាយតម្លៃ

ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ អនុវត្តតាមគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលអាណត្តិទី៦ ដោយផ្ទេរមុខងារ ផ្ទេរធនធានមនុស្ស និងផ្ទេរធនធានហិរញ្ញវត្ថុជាបណ្ដើរៗទៅថ្នាក់រាជធានី-ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងសាលារៀន ឱ្យស្របតាមក្របខណ្ឌច្បាប់គ្រប់គ្រងរដ្ឋបាលផែនដី ក្របខណ្ឌយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ កម្មវិធីជាតិសម្រាប់អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យអប់រំ។

ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ឱ្យទទួលបានជោគជ័យ ត្រូវតែមានការពិនិត្យតាមដាន និងវាយតម្លៃទៅលើការអនុវត្តប្រកបដោយប្រសិទ្ធភាព។

### ៦.១.១ ក្រសួងអប់រំ យុវជន និងកីឡា

ក្រសួងអប់រំ យុវជន និងកីឡាមានការទទួលខុសត្រូវត្រួតពិនិត្យទិដ្ឋភាពបច្ចេកទេសនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ រដ្ឋមន្ត្រី ថ្នាក់ដឹកនាំជាន់ខ្ពស់ និងមន្ត្រីគ្រប់គ្រងជាន់ខ្ពស់ជួបប្រជុំជាទៀងទាត់ តាមរយៈគណៈកម្មការគ្រប់គ្រងកម្មវិធីដើម្បីពិនិត្យឡើងវិញនូវវឌ្ឍនភាពរបស់វិស័យ និងរៀបចំរបាយការណ៍សន្និបាតអប់រំប្រចាំឆ្នាំ។ របាយការណ៍សន្និបាតអប់រំមានទំនាក់ទំនងនឹងក្របខណ្ឌពិនិត្យតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

### ៦.១.២ ការពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិនៃការអនុវត្តផែនការ

ផែនការយុទ្ធសាស្ត្រវិស័យអប់រំនឹងពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិនៅឆ្នាំ២០២១ និងពិនិត្យចុងក្រោយនៅឆ្នាំ២០២៣ ដើម្បីវាយតម្លៃផលសម្រេចរួមនៃយុទ្ធសាស្ត្រនិងកម្មវិធី។ ការវាយតម្លៃពាក់កណ្ដាលអាណត្តិ និងចុងក្រោយនឹងត្រូវចូលរួមយោបល់តាមរយៈរបាយការណ៍វាយតម្លៃឯករាជ្យ។ ការពិនិត្យឡើងវិញនឹងត្រូវគ្រប់គ្រងដោយថ្នាក់ដឹកនាំជាន់ខ្ពស់នៃក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងត្រូវពិនិត្យឡើងវិញនូវហេតុផលនៃគុណភាព និងប្រសិទ្ធភាពកម្មវិធីដែលរួមចំណែកសម្រេចបានផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងចក្ខុវិស័យអភិវឌ្ឍន៍កម្ពុជាឆ្នាំ២០៣០។

ពិនិត្យឡើងវិញពាក់កណ្ដាលអាណត្តិនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ មានគោលបំណងបង្កើនសុក្រឹតភាព និងភាពជឿទុកចិត្តបាននៃផែនការ តាមរយៈការពិនិត្យជាក់ស្ដែងលើសមិទ្ធផលអប់រំសម្រេចបានដូចជា ការផ្ដល់ធាតុចូល កម្មវិធី ការអនុវត្តយុទ្ធសាស្ត្រ និងការធ្វើបច្ចុប្បន្នកម្មដើម្បីឈានទៅសម្រេចវត្ថុបំណងគោលនយោបាយ។ របាយការណ៍នេះនឹងជាឯកសារបំពេញបន្ថែមលើ

ការកែសម្រួលផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងជួយពន្លឿនដល់ការអនុវត្តក្នុងរយៈពេល ២ឆ្នាំកន្លះខាងមុខទៀត។ ផែនការនេះបន្សុីកម្មវិធី អនុកម្មវិធី សូចនាករ និងចំណុចដៅជាមួយនឹងអាទិភាពថ្មីៗ ជាពិសេសកំណែទម្រង់គ្រូបង្រៀន កម្មវិធីសិក្សា បុគ្គលិក គោលនយោបាយ និងផែនការ (ដូចជាវិមជ្ឈការ និងវិសហមជ្ឈការ)។ ផែនការនេះក៏បានបន្សុីជាមួយនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា ដោយសង្កត់ធ្ងន់លើ "ការអប់រំបរិយាបន្ន" និង "ការសិក្សាពេញមួយជីវិត" ដែលជាវត្ថុបំណងគោលនយោបាយសំខាន់។ ជាមួយនោះដែរ ចំណោលប្រជាជននិងសិស្ស ជាតុចូលផ្សេងទៀត និងការព្យាករណ៍តម្រូវការធនធាន និងផែនការហិរញ្ញប្បទានត្រូវបានធ្វើបច្ចុប្បន្នភាពផងដែរនៅឆ្នាំ២០២១ នៅក្នុងរបាយការណ៍ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនេះ។ សុក្រឹតភាពនិងភាពជឿទុកចិត្តបាននៃផែនការនឹងត្រូវបានពង្រឹងផងដែរតាមរយៈក្របខណ្ឌ ឬ គោលការណ៍ណែនាំពិនិត្យតាមដាននិងវាយតម្លៃ ដែលបានបញ្ជាក់យ៉ាងច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់អង្គភាព នាយកដ្ឋានថ្នាក់កណ្តាល និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តផងដែរ។

### ៦.១.៣ អនុវិស័យ

អនុវិស័យត្រូវដឹកនាំដោយរដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការមួយរូប។ អគ្គនាយក ឬអគ្គនាយករងមួយរូបដើរតួនាទីជាជនបង្គោលក្នុងអនុវិស័យដើម្បីជាជំនួយដល់រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ។ អនុវិស័យនីមួយៗនឹងត្រូវដំណើរការការងារ តាមរយៈក្រុមការងារអនុវិស័យដែលរួមបញ្ចូលទាំងនាយកដ្ឋានជំនាញពាក់ព័ន្ធ និងនាយកដ្ឋានទទួលបន្ទុកអនុវត្តក្របខណ្ឌគោលនយោបាយនិងយុទ្ធសាស្ត្រ។ រចនាសម្ព័ន្ធ និងតួនាទីរបស់អនុវិស័យនឹងត្រូវបានកែសម្រួល ដើម្បីឱ្យស្របនឹងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ លក្ខខណ្ឌយោងជាមូលដ្ឋានរបស់អនុវិស័យនីមួយៗនឹងត្រូវពិនិត្យឡើងវិញដោយរួមបញ្ចូលទាំងការរៀបចំផែនការ ការងាររយៈពេលមធ្យមផែនការប្រចាំឆ្នាំ ការពិនិត្យតាមដាន និងវាយតម្លៃ។

### ៦.១.៤ អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ

នាយកដ្ឋានផែនការនៃអគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ នឹងដើរតួនាទីជាអ្នកសម្របសម្រួលក្នុងការរៀបចំរបស់អនុវិស័យ។ នាយកដ្ឋានពិនិត្យតាមដាននិងវាយតម្លៃទទួលខុសត្រូវលើការពិនិត្យតាមដាន ការអនុវត្តគោលនយោបាយ ផែនការ កម្មវិធី និងគម្រោងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡា នៅគ្រប់កម្រិត និងរៀបចំរបាយការណ៍ពិនិត្យតាមដានតាមកាលកំណត់ ព្រមទាំងរៀបចំរបាយការណ៍ស្តីពីសមិទ្ធផលការងារអប់រំ យុវជន និងកីឡា។

ការពិនិត្យតាមដាននិងវាយតម្លៃ គឺជាប្រព័ន្ធការងារផ្លូវការ ដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តកម្មវិធី អនុកម្មវិធីគម្រោងអន្តរាគមន៍សកម្មភាព។ ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃមានគោលដៅប្រមូលផ្តុំប្រព័ន្ធការងារដែលមានស្រាប់ ដើម្បីរៀបចំផែនការផ្តល់សេវាអប់រំ និងពិនិត្យឡើងវិញការបំពេញការងារ ព្រមទាំងវិភាគលើភាពជោគជ័យនៃការអនុវត្តផែនការដែលមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- **ការពិនិត្យតាមដានកម្រិតគោលនយោបាយតាមអនុវិស័យ ៖** នាយកដ្ឋានពិនិត្យតាមដាននិងវាយតម្លៃត្រូវសហការជាមួយនាយកដ្ឋានគោលនយោបាយ និងក្រុមប្រឹក្សាស្រាវជ្រាវអប់រំនឹងត្រូវ

បញ្ចូលនូវខ្លឹមសារនៃការសិក្សាការស្រាវជ្រាវ ដើម្បីជាធាតុចូលដែលឈរលើភស្តុតាងដល់ការវិភាគ និងការផ្តល់អនុសាសន៍លើផ្នែកគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងអន្តរាគមន៍នានា។ នាយកដ្ឋានគោលនយោបាយសហការជាមួយនាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃនឹងត្រូវពិនិត្យវឌ្ឍនភាពនៃការអនុវត្តសកម្មភាពគោលនយោបាយនៅតាមអនុវិស័យ។ របាយការណ៍បូកសរុបលទ្ធផលការងារតាមអនុវិស័យរៀបចំឡើង ក្នុងគោលបំណងពិនិត្យតាមដានវឌ្ឍនភាពនៃការបំពេញការងារតាមអនុវិស័យនីមួយៗនៅថ្នាក់ជាតិ ដោយផ្តោតលើបម្រែបម្រួលទាំងបរិមាណ គុណភាព និងបញ្ហាប្រឈមនានានៃការបំពេញការងារនៅថ្នាក់រាជធានី-ខេត្ត។ របាយការណ៍នេះជាធាតុចូលសម្រាប់របាយការណ៍អនុវិស័យ និងរបាយការណ៍សន្និបាតអប់រំថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលនឹងត្រូវរៀបចំនៅចុងឆ្នាំសារពើពន្ធ។

- **ការពិនិត្យតាមដានអំពីកម្មវិធី អនុកម្មវិធី និងដំណើរការនៅកម្រិតអនុវិស័យ ៖** នាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃទទួលបន្ទុកដឹកនាំការពិនិត្យឡើងវិញលើកម្មវិធី អនុកម្មវិធី និងដំណើរការការងារនៅកម្រិតអនុវិស័យ ក៏ដូចជាវឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ការពិនិត្យឡើងវិញវឌ្ឍនភាពរបស់មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត តាមរយៈរបាយការណ៍សន្និបាតអប់រំ និងព្រឹត្តិការណ៍សន្និបាតអប់រំនៅតាមរាជធានី-ខេត្ត។ នាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃត្រូវបូកសរុបខ្លឹមសារ និងអនុសាសន៍ពីសន្និបាតអប់រំរាជធានី-ខេត្ត ដើម្បីជាធាតុចូលនៅក្នុងរបាយការណ៍សន្និបាតថ្នាក់ជាតិ។ ដោយឡែកការពិនិត្យឡើងវិញប្រចាំឆ្នាំលើគម្រោងនានាចាំបាច់ត្រូវធ្វើឡើងដោយគណៈកម្មការ ដឹកនាំគម្រោង សម្របសម្រួលដោយពិនិត្យតាមដាន និងវាយតម្លៃ។
- **ការពិនិត្យតាមដានលើសមិទ្ធកម្មនៃការអនុវត្តកម្មវិធី អនុកម្មវិធី និងការអនុវត្តមូលនិធិកែលម្អសាលារៀន ៖** នាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃ ទទួលបន្ទុកដឹកនាំការរៀបចំរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកានៅគ្រប់កម្រិត រួមមានថ្នាក់ជាតិ ថ្នាក់ក្រោមជាតិនិងសាលារៀន។ ការតាមដានសមិទ្ធផលនឹងត្រូវធ្វើឡើងដោយផ្អែកលើធាតុចូលនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ និងការអនុវត្តមូលនិធិកែលម្អសាលារៀន។ សាលារៀនត្រូវរៀបចំ និងបញ្ជូនរបាយការណ៍សមិទ្ធកម្មទៅការិយាល័យ អប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើការបូកសរុប ហើយបញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត និងរក្សាទុកសម្រាប់ការងារអធិការកិច្ច។ របាយការណ៍សមិទ្ធកម្មត្រូវបានរៀបចំឡើងរៀងរាល់ត្រីមាសក្នុងគោលបំណង ៖ (១) ពង្រឹងនិងបង្កើនប្រសិទ្ធភាពផលិតភាព និងសមិទ្ធផលនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការអភិវឌ្ឍសាលារៀន និង(២) ពង្រឹងនិងបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាព គណនេយ្យភាព តម្លាភាព ការគ្រប់គ្រងនៃការអនុវត្ត និងការចំណាយថវិកាសម្រាប់អង្គភាពថវិកាក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា។

## ៦.១.៥ នាយកដ្ឋានជំនាញ

ផ្តល់ការគាំទ្រដល់បុគ្គលិករាជធានី-ខេត្ត និងក្រុង ស្រុក ខណ្ឌ ក្នុងការអនុវត្ត និងពិនិត្យតាមដានផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងគាំទ្រការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំសម្រាប់ថ្នាក់រាជធានី-ខេត្ត។

*នាយកដ្ឋានធានាគុណភាពអប់រំ*

នាយកដ្ឋានធានាគុណភាពអប់រំ មានភារកិច្ចទទួលខុសត្រូវដូចខាងក្រោម ៖

- សិក្សា ស្រាវជ្រាវ វិភាគ និងវាយតម្លៃគុណភាព និងប្រសិទ្ធភាពវិស័យអប់រំ
- ពិនិត្យតាមដានការអនុវត្តកម្មវិធី និងការប្រើប្រាស់សម្ភារសិក្សានានានៅគ្រប់គ្រឹះស្ថានរដ្ឋ និងឯកជន
- ពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្ត ឬ ការបំពេញលក្ខខណ្ឌស្តង់ដាជាតិអប់រំរបស់គ្រឹះស្ថានសិក្សានានា
- ធានាការវាស់ស្ទង់សមត្ថភាពកម្រិតសមមូល
- ពិនិត្យតាមដានលើការអនុវត្តជំនាញ យុវជន និងកីឡា
- ពិនិត្យតាមដាន និងលើកសំណើដោះស្រាយករណីមិនប្រក្រតីនានា ដែលពាក់ព័ន្ធនឹងបច្ចេកទេសអប់រំ។

*អធិការដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ*

- ធ្វើអធិការកិច្ចលើដំណើរការងារគ្រប់គ្រង រដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋនៅតាមអង្គភាព និងគ្រឹះស្ថានសិក្សារដ្ឋ និងឯកជន
- ត្រួតពិនិត្យ និងលើកសំណើដោះស្រាយករណីទាំងឡាយ ដែលពាក់ព័ន្ធនឹងការងាររដ្ឋបាល និងហិរញ្ញវត្ថុ។

*នាយកដ្ឋានសវនកម្មផ្ទៃក្នុង*

- ពិនិត្យឡើងវិញនូវភាពដែលអាចជឿទុកចិត្តបានភាពទាន់ពេលវេលា ភាពច្បាស់លាស់នៃព័ត៌មានហិរញ្ញវត្ថុនិងកិច្ចប្រតិបត្តិការ ព្រមទាំងវិធីសាស្ត្រដែលប្រើប្រាស់អនុលោមតាមគោលការណ៍នៃផែនការ នីតិវិធីច្បាប់
- ពិនិត្យឡើងវិញលើការគ្រប់គ្រង ការថែទាំ ការពារទ្រព្យសម្បត្តិ និងធ្វើការផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិឱ្យបានត្រឹមត្រូវ
- វាយតម្លៃភាពសន្សំសំចៃ ប្រសិទ្ធភាព និងភាពផ្តល់ផលវិជ្ជមានពីការប្រើប្រាស់ធនធាន
- ផ្តល់អនុសាសន៍លើចំណុចខ្វះខាត ដើម្បីដោះស្រាយបញ្ហាឱ្យបានសមស្រប
- ពិនិត្យឡើងវិញលើប្រតិបត្តិការកម្មវិធី និងគម្រោងចំណាយអភិវឌ្ឍមូលធន ដើម្បីធានាថាលទ្ធផលស្របតាមកម្មវត្ថុ និងទិសដៅដែលបានកំណត់

- ធ្វើសវនកម្មលើប្រព័ន្ធកុំព្យូទ័រតាមការបរិច្ឆេទ និងធ្វើការវាយតម្លៃលើប្រព័ន្ធដំណើរការទិន្នន័យសំខាន់ៗក្រោយពេលដំឡើងរួច ដើម្បីកំណត់ប្រព័ន្ធនោះឱ្យឆ្លើយតបតាមគោលបំណងនិងគោលដៅដែលបានគ្រោងទុក
- វាយតម្លៃផែនការ ឬសកម្មភាពកែលម្អលើចំណុចរកឃើញរបស់សវនកម្មផ្ទៃក្នុង។

## ៦.១.៦ អង្គសន្និបាតអប់រំប្រចាំឆ្នាំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

*សន្និបាតអប់រំប្រចាំឆ្នាំថ្នាក់ជាតិ*

ក្រសួងអប់រំ យុវជន និងកីឡា បានប្រារព្ធធ្វើអង្គសន្និបាតអប់រំឡើងក្នុងខែមីនា ជារៀងរាល់ឆ្នាំ។ សមាសភាពអញ្ជើញចូលរួមសន្និបាតអប់រំថ្នាក់ជាតិមកពីស្ថាប័នផ្សេងៗនៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ក្រុមប្រឹក្សារាជធានី ខេត្ត ឃុំ សង្កាត់ មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ សាលារៀន វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីពិភាក្សានិងពិគ្រោះយោបល់លើវឌ្ឍនភាព បញ្ហាប្រឈម និងទិសដៅទៅមុខនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងទិសដៅអាទិភាពកំណែទម្រង់វិស័យអប់រំ។

អង្គសន្និបាតអប់រំនេះមានគោលបំណង ពិនិត្យវឌ្ឍនភាពការងារប្រចាំឆ្នាំធៀបទៅនឹងទិសដៅដែលបានដាក់ចេញក្នុងសន្និបាតកន្លង ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ យុទ្ធសាស្ត្រកំណែទម្រង់សំខាន់ៗ និងជាវេទិកាសម្រាប់ពិគ្រោះយោបល់លើការរៀបចំ និងអនុវត្តគោលនយោបាយជាមួយថ្នាក់ក្រោមជាតិ។

របាយការណ៍នេះនឹងបង្ហាញពីការវិភាគស៊ីជម្រៅពីបញ្ហាប្រឈមនានា ដែលជាឧបសគ្គរាំងដល់ការសម្រេចចំណុចដៅ កំណត់វិធានការដើម្បីកែលម្អការបំពេញការងារលើវិស័យអប់រំ ផ្តល់អនុសាសន៍សំខាន់ៗដើម្បីដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រថវិកាយៈពេលមធ្យម និងផែនការប្រតិបត្តិប្រចាំឆ្នាំ។ អ្នកចូលរួមសន្និបាតនឹងពិនិត្យឡើងវិញនូវការបំពេញការងារ ដែលបានអនុវត្តឆ្លើយតបទៅនឹងផលសម្រេចលទ្ធផល និងដំណើរការក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ និងវិស័យដាក់លាក់ដែលបានកំណត់ក្នុងឆ្នាំកន្លងមក និងកំណត់ទិសដៅសម្រាប់ឆ្នាំបន្ទាប់។ សន្និបាតអប់រំផ្តល់ជាកាលានុវត្តភាពសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា បុគ្គលិក ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ក្រសួងពាក់ព័ន្ធ វិស័យឯកជន និងដៃគូអភិវឌ្ឍនានា ពិភាក្សាពីការបំពេញការងារ កំណត់ពីបញ្ហាប្រឈមនិងវិស័យដាក់លាក់សម្រាប់ឆ្នាំខាងមុខ និងឯកភាពលើសកម្មភាពចាំបាច់មួយចំនួន។ សន្និបាតអប់រំ ផ្តល់ជាធាតុចូលសម្រាប់កែលម្អផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

ធាតុចូល និងផលសម្រេច ៖ ក្រុមការងារអនុវិស័យនីមួយៗ ផ្តល់ធាតុចូលដែលមានការវិភាគលម្អិតលើការបំពេញការងារតាមអនុវិស័យទៅក្នុងរបាយការណ៍សន្និបាត។ ធាតុចូលទាំងនេះមានសារៈសំខាន់ក្នុងការពិនិត្យឡើងវិញការបំពេញការងារតាមគោលនយោបាយរបស់អនុវិស័យនីមួយៗ យុទ្ធសាស្ត្រ និងកម្មវិធីធៀបទៅនឹងគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងម៉ាទ្រីកគោល-

នយោបាយ ផែនការប្រតិបត្តិប្រចាំឆ្នាំ និងផែនការការងារផ្សេងៗទៀតនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ការវិភាគនឹងរួមបញ្ចូលទាំងទិដ្ឋភាពនៅកម្រិតសាលារៀន និងក្រុង ស្រុក ខណ្ឌ ដែលទទួលបានពីសន្និបាតថ្នាក់រាជធានី-ខេត្ត ប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ និងប្រព័ន្ធព័ត៌មានគុណភាពអប់រំ ការស្រាវជ្រាវ និងការសិក្សា ការវាយតម្លៃលទ្ធផលនៃការសិក្សារបស់សិស្ស របាយការណ៍ពិនិត្យតាមដាន និងទិន្នន័យពាក់ព័ន្ធ ឬព័ត៌មានដទៃទៀត។ ផលសម្រេចរបស់សន្និបាតគឺជាធាតុចូលសម្រាប់កែលម្អផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងទិសដៅសម្រាប់ឆ្នាំសិក្សាបន្ទាប់។

ដំណើរការពិនិត្យតាមដាន និងវាយតម្លៃ ការគ្រប់គ្រងនិងការរៀបចំឧបករណ៍ពិនិត្យតាមដាន គឺជាការទទួលខុសត្រូវរបស់នាយកដ្ឋានពិនិត្យតាមដាន និងវាយតម្លៃ។ អនុវិស័យនីមួយៗនឹងត្រូវរៀបចំរបាយការណ៍របស់ខ្លួនតាមទម្រង់ដែលបានរៀបចំ។

### *សន្និបាតអប់រំប្រចាំឆ្នាំថ្នាក់រាជធានី ខេត្ត*

- សន្និបាតអប់រំថ្នាក់រាជធានី-ខេត្ត ត្រូវបានប្រារព្ធឡើងរយៈពេលពីរ ឬ បីថ្ងៃ ក្នុងខែមករា មុនពេលសន្និបាតអប់រំថ្នាក់ជាតិ។
- ចាប់ពីឆ្នាំ ២០១៤ រាជធានី-ខេត្តនីមួយៗ បានចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី-ខេត្ត ដែលមានទម្រង់ប្រហាក់ប្រហែលនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់ជាតិ (តាមអនុវិស័យ)។ របាយការណ៍សន្និបាតអប់រំថ្នាក់រាជធានី-ខេត្តនឹងរួមបញ្ចូលទាំងរបាយការណ៍តាមអនុវិស័យ។ សន្និបាតរាជធានី-ខេត្តវិភាគពីទិន្នន័យកម្រិតថ្នាក់រាជធានី-ខេត្ត និងរាយការណ៍ស្តីពីការបំពេញការងារនៃកម្មវិធី និងសកម្មភាពនៃរាជធានី-ខេត្តទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី-ខេត្ត ផែនការប្រតិបត្តិប្រចាំឆ្នាំ និងរបាយការណ៍របស់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ រួមបញ្ចូលទាំងរបាយការណ៍ថវិកាកម្មវិធី ព្រមទាំងមូលនិធិដទៃទៀតនៅសាលារៀននិងការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។
- របាយការណ៍រាជធានី ខេត្តផ្តល់ជាមូលដ្ឋានសម្រាប់កែលម្អនិងកែតម្រូវផែនការការងារប្រចាំឆ្នាំ និងជាធាតុចូលដល់សន្និបាតថ្នាក់ជាតិ។

### *វឌ្ឍនភាពនៃការពិនិត្យតាមដានការអប់រំនៅថ្នាក់ ក្រុង ស្រុក ខណ្ឌ*

- **ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ** ៖ ការពិនិត្យតាមដានត្រូវធ្វើឡើងដើម្បីគាំទ្រនៅកម្រិតសាលារៀនស្តីពីការអនុវត្តសកម្មភាព គោលនយោបាយក៏ដូចជា សកម្មភាពនានារបស់អនុកម្មវិធីត្រូវបានអនុវត្តជាទៀងទាត់។ ការិយាល័យ អប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ទទួលខុសត្រូវលើការពិនិត្យតាមដានប្រភេទនេះ ដោយសហការជាមួយគណៈកម្មការទ្រទ្រង់សាលារៀន និងគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នានៅថ្នាក់ឃុំ សង្កាត់។
- **គណៈកម្មការគ្រប់គ្រងសាលារៀន** ៖ ដោយមានការគាំទ្រពីគណៈកម្មការគ្រប់គ្រងសាលារៀន សាលារៀនបានរៀបចំផែនការអភិវឌ្ឍសាលា និងរៀបចំរបាយការណ៍ចំណាយថវិកាតាមគណនី

សម្រាប់មូលនិធិកម្រិតសាលារៀន (ថវិកាកម្មវិធី និងប្រភពផ្សេងទៀតនៃមូលនិធិ ដូចជា ថវិកាកែលម្អសាលារៀន វឌ្ឍនភាពនៃការត្រួតពិនិត្យ និងរៀបចំរបាយការណ៍សម្រាប់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ។ នៅក្នុងសប្តាហ៍ទីពីរបន្ទាប់ពីពិធីបើកបវេសនកាល សាលារៀនត្រូវបំពេញ និងបញ្ជូនបន្តពីព័ត៌មានជំរឿនអំពីសាលារៀនទៅការិយាល័យប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំថ្នាក់ជាតិ។ ទិន្នន័យជំរឿនសង្ខេបស្តីពីការចុះឈ្មោះចូលរៀន ការបោះបង់ការសិក្សា ការផ្ទេរត្រូវបានប្រមូលនៅពាក់កណ្តាលឆ្នាំសិក្សា និងចុងឆ្នាំសិក្សានឹងត្រូវបញ្ជូនបន្តទៅការិយាល័យប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំថ្នាក់ជាតិ។ ការពិនិត្យតាមដាន ព័ត៌មានត្រឡប់ និងជំនួយត្រូវបានផ្តល់ដោយក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ។

*មន្ទីរអប់រំ យុវជន និងកីឡា*

**មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត** ៖ រៀបចំ និងពិនិត្យតាមដានផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី-ខេត្ត។ វឌ្ឍនភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី-ខេត្តត្រូវបានរាយការណ៍ក្នុងសន្និបាតថ្នាក់រាជធានី-ខេត្ត។ ថ្នាក់រាជធានី-ខេត្តនឹងគ្រប់គ្រងគ្រឹះស្ថានអប់រំមធ្យមសិក្សា និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន រួមបញ្ចូលទាំងការងារវិមជ្ឈការ។ អភិបាលនៃគណៈអភិបាលរាជធានី-ខេត្តជាប្រធាននៃគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នា។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត រៀបចំថវិកាអប់រំថ្នាក់រាជធានី-ខេត្តសម្រាប់បង្ហាញទៅគណៈអភិបាលរាជធានី ខេត្ត។

*ការិយាល័យអប់រំ យុវជន និងកីឡា*

**ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ** ៖ រៀបចំផែនការការងារប្រចាំឆ្នាំដោយផ្អែកលើផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី-ខេត្ត និងរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស។ ក្រុង ស្រុក ខណ្ឌនឹងគ្រប់គ្រងគ្រឹះស្ថានអប់រំបឋមសិក្សាដែលនឹងរួមបញ្ចូលទាំងការងារវិមជ្ឈការ។ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ រៀបចំថវិកាអប់រំស្រុកសម្រាប់បង្ហាញទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត។ ក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌផ្តល់ការគាំទ្រក្នុងការអនុវត្តការត្រួតពិនិត្យ និងរបាយការណ៍នៃផែនការស្រុកនៅកម្រិតសាលារៀន។

## ៦.២ នីតិវិធីនៃការពិគ្រោះយោបល់

### ៦.២.១ អង្គវិបស្សនាអប់រំ

អង្គវិបស្សនាអប់រំ ត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំដោយមានការចូលរួមពីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដៃគូអភិវឌ្ឍ និងតំណាងអង្គការមិនមែនរដ្ឋាភិបាល ក្នុងគោលដៅ ពិភាក្សា ស៊ីជម្រៅលើទិសដៅ និងអាទិភាព ដែលនឹងត្រូវដាក់ចេញ។ អង្គវិបស្សនាអប់រំបានផ្តល់ឱកាសក្នុងការឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពវិស័យអប់រំ និងទិសដៅសំខាន់ៗនៅឆ្នាំខាងមុខ។ ឯកសារសម្រាប់ប្រជុំនៃអង្គវិបស្សនាអប់រំ និងឯកសារស្រាវជ្រាវត្រូវបានរៀបចំដោយក្រុមការងារបច្ចេកទេសវិស័យអប់រំតាមអនុវិស័យ និងនាយកដ្ឋាន

ជំនាញ ដែលមានការយល់ព្រមពីក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ។ ផលសម្រេចនៃអង្គវិបស្សនាអប់រំ គឺជារបាយការណ៍សម្រាប់រៀបចំរបាយការណ៍សន្និបាតអប់រំប្រចាំឆ្នាំ។

ប្រធានបទមួយចំនួនត្រូវបានលើកយកមកពិភាក្សាក្នុងអង្គវិបស្សនាឆ្នាំ២០១៤ រួមមាន ការពិនិត្យលើកំណែទម្រង់កម្មវិធីសិក្សា ហិរញ្ញវត្ថុអប់រំ (កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ) យន្តការក្នុងការពង្រាយគ្រូបង្រៀន វង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងការពិនិត្យតាមដាន រួមទាំងប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ។ អង្គវិបស្សនាអប់រំឆ្នាំ២០១៦ បានពិភាក្សាលើប្រធានបទសំខាន់ពីរ គឺ ១) ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ និង២) ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន និងបញ្ហាប្រឈមមួយចំនួនទៀតត្រូវបានលើកយកមកពិភាក្សាផងដែរនោះ រួមមានសូចនាករស្នូលនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ការគ្រប់គ្រងផ្អែកលើលទ្ធផល កំណែទម្រង់ក្នុងការបណ្តុះបណ្តាលគ្រូ ការអប់រំគ្រូបង្រៀន និងគន្លងអាជីពសម្រាប់គ្រូបង្រៀន។

## ៦.២.២ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ជាតិ

ការប្រជុំ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំមានគោលដៅ ដើម្បីពិនិត្យមើលវឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់តាមអនុវិស័យ និងដើម្បីតម្រង់ទិសការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់ក្រសួងអប់រំ យុវជន និងកីឡាក៏ដូចជាយុទ្ធសាស្ត្រចតុកោណក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពហិរញ្ញប្បទាន និងភាពជាដៃគូ ជាមួយនឹងតួអង្គអភិវឌ្ឍវិស័យអប់រំ។

ម្យ៉ាងទៀត ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ មានគោលដៅលើកកម្ពស់ការអភិវឌ្ឍសហប្រតិបត្តិការឱ្យមានសង្គតិភាពរវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ព្រមទាំងផ្តល់ព័ត៌មានមួយចំនួនស្តីពីមូលនិធិភាពជាដៃគូ និងការគាំទ្រនៃដំណើរការថវិកាដែលរួមបញ្ចូលកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈធានាឱ្យមានសង្គតិភាពរវាងកម្មវិធីអភិវឌ្ឍសមត្ថភាព ផែនការគោលស្តីពីការអភិវឌ្ឍសមត្ថភាព និងរបាយកាណ៍ពិនិត្យឡើងវិញស្តីពីប្រសិទ្ធភាពហិរញ្ញប្បទាននៅក្នុងសន្និបាតប្រចាំឆ្នាំនិងអង្គវិបស្សនា។

ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់ជាតិ បានប្រជុំគ្នាជាទៀងទាត់តាមត្រីមាសនីមួយៗ ដើម្បីពិភាក្សាអំពីការអនុវត្តគោលនយោបាយ ផែនការ កំណែទម្រង់វិស័យអប់រំ ប្រសិទ្ធភាពហិរញ្ញប្បទាន និងវឌ្ឍនភាពសំខាន់ៗ។ យន្តការនេះត្រូវបានប្រើប្រាស់ដើម្បីរៀបចំ និងពិនិត្យឡើងវិញស្តីពីវឌ្ឍនភាពនៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ សន្និបាតអប់រំ និងការកៀរគរធនធានបន្ថែម។ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំក៏បានជួយពង្រឹងសមត្ថភាពបន្ថែមផងដែរ តាមរយៈសិក្ខាសាលាបណ្តុះបណ្តាលប្រចាំឆ្នាំ និងការលើកសំណើដោយផ្ទាល់តាមឆ្នាំនីមួយៗ។

### ៦.២.៣ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី-ខេត្ត

ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី-ខេត្ត គឺគាំទ្រលើការងាររៀបចំផែនការថវិកា និងរបាយការណ៍សម្រាប់រាជធានី-ខេត្ត ក្នុងក្របខណ្ឌផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី-ខេត្ត ជាពិសេសបានផ្តល់ធាតុចូលក្នុងការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ផែនការយុទ្ធសាស្ត្រថវិកា (ពិសេសលើការចំណាយថវិកាកម្មវិធី) និងផែនការសកម្មភាពប្រចាំឆ្នាំ ដោយផ្អែកលើផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី-ខេត្ត និងដើម្បីរៀបចំឯកសារផែនការប្រចាំឆ្នាំតាមអនុវិស័យ។ ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំថ្នាក់រាជធានី-ខេត្ត ទាំង ២៥ រាជធានី-ខេត្ត បានកែលម្អការបំពេញការងាររបស់ពួកគេល្អប្រសើរពីមួយឆ្នាំទៅមួយឆ្នាំ។

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១ ៖ សូចនាករស្នូល និងចំណុចដៅសម្រាប់ឆ្នាំ២០១៩-២០២៣

| សូចនាករស្នូល | | ឯកតា | ស្ថានភាព ២០១៧-១៨ | ចំណុចដៅ ២០១៨-១៩ | ចំណុចដៅ ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ចំណុចដៅ ២០២១-២២ | ចំណុចដៅ ២០២២-២៣ |
|---|---|---|---|---|---|---|---|---|
| គោលនយោបាយទី ១ ÷ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | | | | |
| ១. | អត្រាចូលរៀនកុមារអាយុ៥ឆ្នាំ (ម.សិក្សារដ្ឋ សហគមន៍ និងឯកជន) | % | ៥៨,០ | ៥៩,៣ | ៦០,៦ | ៦១,៩ | ៦៣,២ | ៦៤,៥ |
| | *ប្រុស* | % | ៥៧,៧ | ៥៨,៩ | ៦០,១ | ៦១,៣ | ៦២,៥ | ៦៣,៧ |
| | *ស្រី* | % | ៥៨,៧ | ៦០,០ | ៦១,៣ | ៦២,៧ | ៦៤,០ | ៦៥,៣ |
| ២. | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | % | ៨២,៧ | ៨៣,៤ | ៨៤,១ | ៨៤,៨ | ៨៥,៥ | ៨៦,២ |
| | *ប្រុស* | % | ៧៩,១ | ៨០,៣ | ៨១,៥ | ៨២,៦ | ៨៣,៨ | ៨៥,០ |
| | *ស្រី* | % | ៨៦,៤ | ៨៧,៣ | ៨៨,២ | ៨៩,២ | ៩០,១ | ៩១,០ |
| ៣. | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | % | ៤៦,៥ | ៤៧,៧ | ៤៨,៩ | ៥០,២ | ៥១,៤ | ៥២,៦ |
| | *ប្រុស* | % | ៤២,៣ | ៤៣,៨ | ៤៥,៤ | ៤៦,៩ | ៤៨,៥ | ៥០,០ |
| | *ស្រី* | % | ៥១,១ | ៥២,៥ | ៥៣,៤ | ៥៤,៣ | ៥៥,៣ | ៥៦,៣ |
| ៤. | ភាគរយសិស្សសម្រេចបានកម្រិតសមត្ថភាពក្រោមកម្រិតមូលដ្ឋាន មុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា | | | | | | | |
| | *ការអានភាសាខ្មែរថ្នាក់ទី៣* | % | ៥២,៦ (២០១៥) | | ៤៦,៦ | | | |
| | *ការសរសេរភាសាខ្មែរថ្នាក់ទី៣* | % | ៦៤,៨ | | ៥៨,៨ | | | |
| | *គណិតវិទ្យាថ្នាក់ទី៣* | % | ៤៤,៩ | | ៣៨,៩ | | | |
| | *ការអានភាសាខ្មែរថ្នាក់ទី៦* | % | ៣១,៥ (២០១៦) | | | ២៥,៥ | | |
| | *ការសរសេរភាសាខ្មែរថ្នាក់ទី៦* | % | ៣៩,៦ | | | ៣៣,៦ | | |
| | *គណិតវិទ្យាថ្នាក់ទី៦* | % | ៥៣,២ | | | ៤៧,២ | | |
| | *ការអានភាសាខ្មែរថ្នាក់ទី៨* | % | ១៨,៩ (២០១៧) | | | | ១៥,៩ | |
| | *ការសរសេរភាសាខ្មែរថ្នាក់ទី៨* | % | ៧១,០ | | | | ៦៥,០ | |
| | *គណិតវិទ្យាថ្នាក់ទី៨* | % | ៣៦,៣ | | | | ៣០,៣ | |
| | *រូបវិទ្យាថ្នាក់ទី៨* | % | ៥២,១ | | | | ៤៦,១ | |
| | *ការអានភាសាខ្មែរថ្នាក់ទី១១* | % | ២០,៥ (២០១៨) | | | | | ១៧,៥ |
| | *ការសរសេរភាសាខ្មែរថ្នាក់ទី១១* | % | ៥៨,៩ | | | | | ៥២,៩ |
| | *គណិតវិទ្យាថ្នាក់ទី១១* | % | ៧២,៣ | | | | | ៦៦,៣ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | *វប្បវិទ្យាថ្នាក់ទី១១* | % | ៧៩,៦ | | | | | ៧៣,៦ |
| ៥. | ភាគរយគ្រូបង្រៀនបឋមសិក្សាមានគុណវុឌ្ឍិតាមស្តង់ដាជាតិ | % | ៧៣,០ | ៧៤,០ | ៧៥,០ | ៧៦,០ | ៧៧,០ | ៧៨,០ |
| ៦. | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា (១៨-២២ឆ្នាំ) | % | ១១,៦ | ១២,៤ | ១៣,៣ | ១៤,២ | ១៥,១ | ១៦,០ |
| | *ប្រុស* | % | ១៣,២ | ១៤,៣ | ១៥,៥ | ១៦,៦ | ១៧,៨ | ១៨,៩ |
| | *ស្រី* | % | ១១,៣ | ១១,៦ | ១១,៩ | ១២,៣ | ១២,៧ | ១៣,០ |
| ៧. | អត្រាអក្ខរកម្មពេញវ័យ (អាយុ ១៥ ឆ្នាំឡើង) | % | ៨២,៥ | ៨៣,៦ | ៨៤,៧ | ៨៥,៨ | ៨៦,៩ | ៨៨,០ |
| គោលនយោបាយទី ២ ÷ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | | | | |
| ៨. | ចំនួននាយកសាលាបឋមសិក្សា និងមធ្យមសិក្សាបានទទួលការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងតាមសាលារៀន | ចំនួន | ១ ១៥០ | ៦៧០ | ៧០០ | ៧០០ | ៧០០ | ៧០០ |

# ឧបសម្ព័ន្ធទី ២ ៖ សូចនាករផលសម្រេច និងចំណុចដៅតាមអនុវិស័យ ឆ្នាំ២០១៩-២០២៣

## អនុវិស័យ ការអប់រំកុមារតូច

| | សូចនាករស្នូល | ឯកតា | ស្ថានភាព ២០១៧-១៨ | ចំណុចដៅ ២០១៨-១៩ | ចំណុចដៅ ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ចំណុចដៅ ២០២១-២២ | ចំណុចដៅ ២០២២-២៣ |
|---|---|---|---|---|---|---|---|---|
| គោលនយោបាយទី ១ ÷ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | | | | |
| វត្ថុបំណងអនុវិស័យទី១ ÷ បង្កើនលទ្ធភាពទទួលបានសេវាអប់រំកុមារតូចប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន | | | | | | | | |
| ១. | អត្រាចូលរៀនកុមារអាយុ៥ឆ្នាំ *(ម.សិក្សារដ្ឋ សហគមន៍ និងឯកជន)* | % | ៥៨,០ | ៥៩,៣ | ៦០,៦ | ៦១,៩ | ៦៣,២ | ៦៤,៥ |
| | *ប្រុស* | % | ៥៧,៧ | ៥៨,៩ | ៦០,១ | ៦១,៣ | ៦២,៥ | ៦៣,៧ |
| | *ស្រី* | % | ៥៨,៧ | ៦០,០ | ៦១,៣ | ៦២,៧ | ៦៤,០ | ៦៥,៣ |
| ២. | អត្រាចូលរៀនកុមារអាយុ៤ឆ្នាំ *(ម.សិក្សារដ្ឋ សហគមន៍ និងឯកជន)* | % | ៣៤,០ | ៣៦,២ | ៣៨,៤ | ៤០,៦ | ៤២,៨ | ៤៥,០ |
| | *ប្រុស* | % | ៣២,២ | ៣៤,៦ | ៣៧,១ | ៣៩,៥ | ៤២,០ | ៤៤,៤ |
| | *ស្រី* | % | ៣៥,៣ | ៣៧,៤ | ៣៩,៤ | ៤១,៥ | ៤៣,៥ | ៤៥,៦ |
| ៣. | អត្រាចូលរៀនកុមារអាយុ៣ឆ្នាំ *(ម.សិក្សារដ្ឋ សហគមន៍ និងឯកជន)* | % | ១២,៦ | ១៥,៥ | ១៨,៤ | ២១,២ | ២៤,១ | ២៧,០ |
| | *ប្រុស* | % | ១១,៧ | ១៤,៦ | ១៧,៤ | ២០,៣ | ២៣,១ | ២៦,០ |
| | *ស្រី* | % | ១៣,៤ | ១៦,៣ | ១៩,៣ | ២២,២ | ២៥,២ | ២៨,១ |
| ៤. | អត្រារួមនៃការសិក្សា *(ម.សិក្សារដ្ឋ សហគមន៍ និងឯកជន)* | % | ៣៥,៨ | ៣៧,៨ | ៣៩,៩ | ៤១,៩ | ៤៤,០ | ៤៦,០ |
| | *ប្រុស* | % | ៣៤,៩ | ៣៧,០ | ៣៩,២ | ៤១,៣ | ៤៣,៥ | ៤៥,៦ |
| | *ស្រី* | % | ៣៧,០ | ៣៩,៣ | ៤១,៥ | ៤៣,៨ | ៤៦,០ | ៤៨,៣ |
| ៥. | ភាគរយសាលាមត្តេយ្យសិក្សាមានអគ្គិសនី *(មត្តេយ្យសិក្សារដ្ឋ)* | % | ៣១,៧ | ៣៣,៦ | ៣៥,៤ | ៣៧,៣ | ៣៩,១ | ៤១,០ |
| ៦. | ភាគរយសាលាមត្តេយ្យសិក្សាមានកន្លែងលាងសម្អាតដៃស្តង់ដាអប្បបរមា *(ម.ត.ស.រដ្ឋដាច់ដោយឡែក)* | | | | | | | |
| | *កម្រិត ១* | % | ៣៥,៤ | ៣៨,៣ | ៤១,២ | ៤៤,២ | ៤៧,១ | ៥០,០ |
| | *កម្រិត ២* | % | ២៤,៧ | ២៥,៥ | ២៦,២ | ២៧,០ | ២៧,៧ | ២៨,៥ |
| | *កម្រិត ៣* | % | ១,១ | ១,២ | ១,៣ | ១,៣ | ១,៤ | ១,៥ |
| ៧. | ភាគរយសាលាមត្តេយ្យសិក្សាមាន *(ម.សិក្សារដ្ឋដាច់ដោយឡែក)* | | | | | | | |
| | *បង្គន់អនាម័យ* | % | ២២,០ | ៣៣,៦ | ៤៥,២ | ៥៦,៨ | ៦៨,៤ | ៨០,០ |
| | *ទឹកស្អាតសម្រាប់ទទួលទាន* | % | ៣០,២ | ៣៦,២ | ៤២,១ | ៤៨,១ | ៥៤,០ | ៦០,០ |
| | *កន្លែងលាងដៃ* | % | ២៨,៨ | ៣៥,០ | ៤១,៣ | ៤៧,៥ | ៥៣,៨ | ៦០,០ |
| | *ប្រអប់សង្គ្រោះបឋម* | % | ៦,៣ | ១០,០ | ១៣,៨ | ១៧,៥ | ២១,៣ | ២៥,០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| វត្ថុបំណងអនុវិស័យទី២ ÷ បន្តអភិវឌ្ឍសាលាមត្តេយ្យសិក្សាស្របតាមស្តង់ដាគុណភាព | | | | | | | | |
| ៨. | ភាគរយសាលាមត្តេយ្យសិក្សារដ្ឋសម្រេចបានតាមស្តង់ដាអប្បបរមា *(ម. សិក្សារដ្ឋដាច់ដោយឡែក)* | % | ០,០ | ៦,០ | ១២,០ | ១៨,០ | ២៤,០ | ៣០,០ |
| ៩. | ចំនួនសាលាមត្តេយ្យសិក្សាសហគមន៍សម្រេចបានតាមស្តង់ដាអប្បបរមា | ចំនួន | ៦០០ | ៧៨០ | ៩៦០ | ១ ១៤០ | ១ ៣២០ | ១ ៥០០ |
| ១០. | ភាគរយសាលាមត្តេយ្យសិក្សារដ្ឋ និងសហគមន៍បានធ្វើតេស្តសមត្ថភាពកុមារអាយុ៥ឆ្នាំ | % | ៣៩,២ | ៤១,២ | ៤៣,១ | ៤៥,១ | ៤៧,០ | ៤៩,០ |
| ១១. | ភាគរយកុមារសាលាមត្តេយ្យសិក្សាបានទទួលអាហារូបត្ថម្ភប្រសើរឡើង *(ម. សិក្សារដ្ឋ សហគមន៍ និងឯកជន)* | % | ៣០,០ | ៣២,០ | ៣៤,០ | ៣៦,០ | ៣៨,០ | ៤០,០ |
| ១២. | ភាគរយគ្រូមត្តេយ្យសិក្សាមានគុណវុឌ្ឍិស្របតាមស្តង់ដាជាតិ (រូបមន្ត១២+២) | % | ៦៤,០ | ៦៦,០ | ៦៨,០ | ៧០,០ | ៧២,០ | ៧៤,០ |
| ១៣. | ចំនួនគ្រូបង្រៀនអប់រំពហុភាសា | ចំនួន | ៩៤ | ១០៧ | ១១២ | ១១៩ | ១២៣ | ១២៧ |
| ១៤. | ផលធៀបសិស្ស-គ្រូមត្តេយ្យសិក្សារដ្ឋ | ផលធៀប | ៤០,០ | ៣៧,០ | ៣៤,០ | ៣១,០ | ២៨,០ | ២៥,០ |
| គោលនយោបាយទី ២ ÷ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | | | | |
| វត្ថុបំណងអនុវិស័យទី៣÷ ពង្រឹងសមត្ថភាពអ្នកគ្រប់គ្រងអនុវិស័យ ការអប់រំកុមារតូច និងអនុវត្តការគ្រប់គ្រងតាមសាលារៀន | | | | | | | | |
| ១៥. | ចំនួននាយកសាលាមត្តេយ្យសិក្សារដ្ឋទទួលបានការបណ្តុះបណ្តាល ស្តីពីការគ្រប់គ្រងតាមសាលារៀន *(ម. សិក្សារដ្ឋដាច់ដោយឡែក)* | ចំនួន | ០ | ០ | ៥០ | ៥០ | ៥០ | ៥០ |
| ១៦. | ចំនួនសាលាមត្តេយ្យសិក្សារដ្ឋបានអនុវត្តការគ្រប់គ្រងតាមសាលារៀន *(ម. សិក្សារដ្ឋដាច់ដោយឡែក)* | ចំនួន | ០ | ៣១ | ៤៣ | ៥៥ | ៦៧ | ៧៩ |

## អនុវិស័យ ការអប់រំបឋមសិក្សា

| | សូចនាករស្នូល | ឯកតា | ស្ថានភាព ២០១៧-១៨ | ចំណុចដៅ ២០១៨-១៩ | ចំណុចដៅ ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ចំណុចដៅ ២០២១-២២ | ចំណុចដៅ ២០២២-២៣ |
|---|---|---|---|---|---|---|---|---|
| គោលនយោបាយទី ១ ÷ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | | | | |
| វត្ថុបំណងអនុវិស័យទី១ ÷ កម្ពស់ការចូលរៀនរហូតដល់ចប់ថ្នាក់ទី៦នៃបឋមសិក្សាសម្រាប់កុមារទាំងអស់ ជាពិសេសក្រុមកុមារជួបការលំបាក | | | | | | | | |
| ១. | អត្រាពិតចូលរៀនថ្មី | % | ៩៥,២ | ៩៥,៩ | ៩៦,៥ | ៩៧,២ | ៩៧,៨ | ៩៨,៥ |
| | *ប្រុស* | % | ៩៥,២ | ៩៥,៩ | ៩៦,៥ | ៩៧,២ | ៩៧,៨ | ៩៨,៥ |
| | *ស្រី* | % | ៩៥,១ | ៩៥,៨ | ៩៦,៥ | ៩៧,១ | ៩៧,៨ | ៩៨,៥ |
| ២. | អត្រាពិតនៃការសិក្សា | % | ៩៧,៨ | ៩៧,៩ | ៩៨,១ | ៩៨,២ | ៩៨,៤ | ៩៨,៥ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ប្រុស | % | ៩៧,៦ | ៩៧,៨ | ៩៨,០ | ៩៨,១ | ៩៨,៣ | ៩៨,៥ |
| | ស្រី | % | ៩៨,១ | ៩៨,៣ | ៩៨,៥ | ៩៨,៦ | ៩៨,៨ | ៩៩,០ |
| ៣. | អត្រាបោះបង់ការសិក្សា | % | ៤,១ | ៣,៨ | ៣,៥ | ៣,១ | ២,៨ | ២,៥ |
| | ប្រុស | % | ៤,៧ | ៤,៣ | ៣,៩ | ៣,៤ | ៣,០ | ២,៦ |
| | ស្រី | % | ៣,៥ | ៣,២ | ២,៩ | ២,៦ | ២,៣ | ២,០ |
| ៤. | អត្រាត្រួតថ្នាក់ | % | ៦,៥ | ៦,១ | ៥,៧ | ៥,៣ | ៤,៩ | ៤,៥ |
| | ប្រុស | % | ៨,០ | ៧,៤ | ៦,៨ | ៦,២ | ៥,៦ | ៥,០ |
| | ស្រី | % | ៤,៩ | ៤,៥ | ៤,១ | ៣,៨ | ៣,៤ | ៣,០ |
| ៥. | ចំនួនស្រុកដែលសម្រេចបានអត្រាត្រួតថ្នាក់នៅបឋមសិក្សាតិចជាងឬស្មើ ១០ ភាគរយ | ចំនួន | ១៧៣ | ១៧៥ | ១៧៧ | ១៧៩ | ១៨១ | ១៨៣ |
| ៦. | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | % | ៨២,៧ | ៨៣,៤ | ៨៤,១ | ៨៤,៨ | ៨៥,៥ | ៨៦,២ |
| | ប្រុស | % | ៧៩,១ | ៨០,៣ | ៨១,៥ | ៨២,៦ | ៨៣,៨ | ៨៥,០ |
| | ស្រី | % | ៨៦,៤ | ៨៧,៣ | ៨៨,២ | ៨៩,២ | ៩០,១ | ៩១,០ |
| ៧. | អត្រាគង់វង្សនៅបឋមសិក្សា | % | ៧៩,៩ | ៨១,១ | ៨២,៣ | ៨៣,៦ | ៨៤,៨ | ៨៦,០ |
| | ប្រុស | % | ៧៦,៥ | ៧៨,១ | ៧៩,៧ | ៨១,៣ | ៨២,៩ | ៨៤,៥ |
| | ស្រី | % | ៨៣,៥ | ៨៤,៤ | ៨៥,៣ | ៨៦,២ | ៨៧,១ | ៨៩,០ |
| ៨. | អត្រាឆ្លងភូមិសិក្សាពីបឋមសិក្សាទៅមធ្យមសិក្សាបឋមភូមិ | % | ៨៦,០ | ៨៦,៦ | ៨៧,២ | ៨៧,៨ | ៨៨,៤ | ៨៩,០ |
| | ប្រុស | % | ៨៣,៤ | ៨៤,១ | ៨៤,៨ | ៨៥,៥ | ៨៦,២ | ៨៦,៩ |
| | ស្រី | % | ៨៨,៥ | ៨៩,០ | ៨៩,៥ | ៩០,០ | ៩០,៥ | ៩១,០ |
| ៩. | ភាគរយសិស្សថ្មីថ្នាក់ទី១ ដែលបានឆ្លងកាត់មត្តេយ្យសិក្សា | % | ៦៥,០ | ៦៦,៩ | ៦៨,៨ | ៧០,៧ | ៧២,៦ | ៧៤,៥ |
| ១០. | ភាគរយសាលាកុមារមេត្រី កម្រិតមធ្យមនិងកម្រិតអភិវឌ្ឍ | % | ៨១,៣ | ៨១,៨ | ៨២,៤ | ៨២,៩ | ៨៣,៥ | ៨៤,០ |
| ១១. | ភាគរយសាលារៀនបឋមសិក្សាមានអគ្គិសនីប្រើប្រាស់ | % | ៤៩,៦ | ៥២,៧ | ៥៥,៨ | ៥៨,៨ | ៦១,៩ | ៦៥,០ |
| ១២. | ភាគរយសាលាបឋមសិក្សាអនុវត្តស្តង់ដា ទឹកស្អាត និងអនាម័យ | | | | | | | |
| | *កម្រិត ១* | % | ៤៥,៣ | ៤៧,១ | ៤៨,៩ | ៥០,៦ | ៥២,៤ | ៥៤,២ |
| | *កម្រិត ២* | % | ២២,៤ | ២២,៧ | ២៣,០ | ២៣,៤ | ២៣,៧ | ២៤,០ |
| | *កម្រិត ៣* | % | ១,៤ | ១,៥ | ១,៦ | ១,៦ | ១,៧ | ១,៨ |
| ១៣. | ភាគរយសាលាបឋមសិក្សាមាន | | | | | | | |
| | *បង្គន់អនាម័យ* | % | ៩០,៦ | ៩១,៥ | ៩២,៤ | ៩៣,២ | ៩៤,១ | ៩៥,០ |
| | *ទឹកស្អាតសម្រាប់ទទួលទាន* | % | ៥៩,៣ | ៦០,២ | ៦១,២ | ៦២,១ | ៦៣,១ | ៦៤,០ |
| | *កន្លែងលាងដៃ* | % | ៥៦,៧ | ៥៨,៤ | ៦០,០ | ៦១,៧ | ៦៣,៣ | ៦៥,០ |
| | *ប្រអប់សង្គ្រោះបឋម* | % | ៥៤,០ | ៥៥,២ | ៥៦,៤ | ៥៧,៦ | ៥៨,៨ | ៦០,០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១៤. | ចំនួនសិស្សបឋមសិក្សាបានទទួលអាហារនៅតាមសាលារៀន | ចំនួន | ៤០ ០០០ | ៤០ ០០០ | ៤០ ០០០ | ៤០ ០០០ | ៤០ ០០០ | ៤០ ០០០ |
| ១៥. | ចំនួនសិស្សទទួលអាហារូបករណ៍នៅបឋមសិក្សា | ចំនួន | ៨៦ ១២៦ | ៩៣ ០០០ | ៩៥ ០០០ | ៩៧ ០០០ | ៩៩ ០០០ | ១០០ ០០០ |
| ១៦. | ចំនួនគ្រូបង្រៀនពហុភាសា | ចំនួន | ១៩៧ | ២០៨ | ២១៩ | ២៣១ | ២៤២ | ២៥៣ |
| ១៧. | ចំនួនគ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលកម្រិត ឌីប្លូម៉ាស្តីពីការអប់រំពិសេស នៅវិទ្យាស្ថានជាតិអប់រំពិសេស | ចំនួន | - | ១៨ | ២០ | ២២ | ២០ | ២០ |
| វត្ថុបំណងអនុវិស័យទី២ ÷ កែលម្អការផ្តល់ធាតុចូលប្រកបដោយគុណភាពនៅបឋមសិក្សា | | | | | | | | |
| ១៨. | ផលធៀបសិស្ស-គ្រូមានគុណវុឌ្ឍិ | ផលធៀប | ៦១ | ៥៧ | ៥៣ | ៤៨ | ៤៤ | ៤០ |
| ១៩. | ភាគរយគ្រូបង្រៀនបឋមសិក្សាមានសញ្ញាបត្រតាមស្តង់ដា (សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ + ២) | % | ៧៣,០ | ៧៤,០ | ៧៥,០ | ៧៦,០ | ៧៧,០ | ៧៨,០ |
| ២០. | ចំនួនគ្រូបង្រៀនបឋមសិក្សាទទួលការបំប៉នសមត្ថភាពបន្ថែម | | | | | | | |
| | *កញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង* | ចំនួន | ១ ៤៣០ | ៣ ៥០០ | ៣ ៥០០ | ៣ ៥០០ | ៣ ៥០០ | ៣ ៥០០ |
| | *កញ្ចប់សម្ភារៈគណិតវិទ្យាថ្នាក់ដំបូង* | ចំនួន | ១៤៧ | ៨៥០ | ៣ ៥០០ | ៣ ៥០០ | ៣ ៥០០ | ៣ ៥០០ |
| | *ការបំប៉នសមត្ថភាពផ្សេងទៀត* | ចំនួន | ២៥០ | ៣ ០០០ | ៣ ០០០ | ៣ ០០០ | ៣ ០០០ | ៣ ០០០ |
| ២១. | ភាគរយគ្រូបង្រៀនបឋមសិក្សាដែលបានបញ្ចប់បរិញ្ញាបត្រនៅវិទ្យាស្ថានគរុកោសល្យ | % | ០.០ | ០.០ | ០.០ | ៣.០ | ៥.០ | ៧.០ |
| ២២. | ភាគរយសិស្សបឋមសិក្សាទទួលបានសៀវភៅសិក្សាគោល ១ សម្រាប់ក្នុងម្នាក់ | % | ៩០,០ | ៩២,០ | ៩៤,០ | ៩៦,០ | ៩៨,០ | ១០០ |
| ២៣. | ចំនួនសាលាបឋមសិក្សាមានបន្ទប់កុំព្យូទ័រសម្រាប់សិស្ស | ចំនួន | ២០ | ៧០ | ១២០ | ២២០ | ៣២០ | ៥២០ |
| ២៤. | ចំនួនសាលាបឋមសិក្សាមានបណ្ណាល័យតាមស្តង់ដា | ចំនួន | ១ ៥០០ | ១ ៨០០ | ២ ៣០០ | ២ ៨០០ | ៣ ៣០០ | ៤ ០០០ |
| គោលនយោបាយទី ២ ÷ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | | | | |
| វត្ថុបំណងអនុវិស័យទី៣÷ ពង្រឹងការអនុវត្តស្តង់ដាបឋមសិក្សាតាមរយៈការគ្រប់គ្រងសាលារៀន | | | | | | | | |
| ២៥. | ចំនួននាយកបឋមសិក្សាបានទទួលការបំប៉នស្តីពីការគ្រប់គ្រងតាមសាលារៀន | ចំនួន | ៤៧២ | ៥០០ | ៥០០ | ៥០០ | ៥០០ | ៥០០ |
| ២៦. | ចំនួនសាលាបឋមសិក្សាអនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀនពេញលេញ | ចំនួន | ០ | ៨០ | ១៦០ | ២៦០ | ៣៦០ | ៥០០ |

## អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស

| សូចនាករសូល | | ឯកតា | ស្ថានភាព ២០១៧-១៨ | ចំណុចដៅ ២០១៨-១៩ | ចំណុចដៅ ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ចំណុចដៅ ២០២១-២២ | ចំណុចដៅ ២០២២-២៣ |
|---|---|---|---|---|---|---|---|---|
| គោលនយោបាយទី ១ ÷ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | | | | |
| វត្ថុបំណងអនុវិស័យទី១ ÷ កែលម្អការចូលរៀននិងរក្សាសិស្សឱ្យបានគង់វង្ស ប្រកបដោយសមធម៌ និងបរិយាបន្ននៅមធ្យមសិក្សា | | | | | | | | |
| ១. | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | % | ៥៩,២ | ៦០,៧ | ៦២,២ | ៦៣,៧ | ៦៥,២ | ៦៦,៧ |
| | *ប្រុស* | % | ៥៥,២ | ៥៧,២ | ៥៩,១ | ៦១,១ | ៦៣,០ | ៦៥,០ |
| | *ស្រី* | % | ៦៣,៤ | ៦៥,១ | ៦៦,៨ | ៦៨,៦ | ៧០,៣ | ៧២,០ |
| ២. | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | % | ២៨,៥ | ៣០,៤ | ៣២,៣ | ៣៤,២ | ៣៦,១ | ៣៨,០ |
| | *ប្រុស* | % | ២៦,៣ | ២៨,៣ | ៣០,២ | ៣២,២ | ៣៤,១ | ៣៦,១ |
| | *ស្រី* | % | ៣០,៩ | ៣២,៧ | ៣៤,៥ | ៣៦,៤ | ៣៨,២ | ៤០,០ |
| ៣. | អត្រាឆ្លងភូមិសិក្សាពីមធ្យមសិក្សាបឋមភូមិទៅទុតិយភូមិ | % | ៧៦,៨ | ៧៨,៦ | ៨០,៥ | ៨២,៣ | ៨៤,២ | ៨៦,០ |
| | *ប្រុស* | % | ៧៤,២ | ៧៦,៤ | ៧៨,៥ | ៨០,៧ | ៨២,៨ | ៨៥,០ |
| | *ស្រី* | % | ៧៩,២ | ៨០,៨ | ៨២,៣ | ៨៣,៩ | ៨៥,៤ | ៨៧,០ |
| ៤. | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | % | ៤៦,៥ | ៤៧,៧ | ៤៨,៩ | ៥០,២ | ៥១,៤ | ៥២,៦ |
| | *ប្រុស* | % | ៤២,៣ | ៤៣,៨ | ៤៥,៤ | ៤៦,៩ | ៤៨,៥ | ៥០,០ |
| | *ស្រី* | % | ៥១,១ | ៥២,១ | ៥៣,២ | ៥៤,២ | ៥៥,៣ | ៥៦,៣ |
| ៥. | អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ | % | ១៥,៤ | ១៤,១ | ១២,៨ | ១១,៦ | ១០,៣ | ៩,០ |
| | *ប្រុស* | % | ១៦,៦ | ១៥,២ | ១៣,៨ | ១២,៣ | ១០,៩ | ៩,៥ |
| | *ស្រី* | % | ១៤,២ | ១៣,០ | ១១,៧ | ១០,៥ | ៩,២ | ៨,០ |
| ៦. | អត្រាគង់វង្សនៅមធ្យមសិក្សាបឋមភូមិ | % | ៥៣,១ | ៥៤,០ | ៥៤,៩ | ៥៥,៨ | ៥៦,៧ | ៥៧,៦ |
| | *ប្រុស* | % | ៤៨,៣ | ៤៩,៣ | ៥០,២ | ៥១,២ | ៥២,១ | ៥៣,១ |
| | *ស្រី* | % | ៥៨,២ | ៥៩,១ | ៥៩,៩ | ៦០,៨ | ៦១,៦ | ៦២,៥ |
| ៧. | អត្រាគង់វង្សនៅមធ្យមសិក្សាទុតិយភូមិ | % | ៣៤,៩ | ៣៦,២ | ៣៧,៥ | ៣៨,៧ | ៤០,០ | ៤១,២ |
| | *ប្រុស* | % | ៣០,៤ | ៣២,៥ | ៣៤,៥ | ៣៦,៥ | ៣៨,៦ | ៤០,៦ |
| | *ស្រី* | % | ៣៩,៨ | ៤០,៥ | ៤១,៣ | ៤២,០ | ៤២,៨ | ៤៣,៥ |
| ៨. | ចំនួនក្រុង-ស្រុកដែលមានអត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិច្រើនជាង ១៨,៩ ភាគរយ | ចំនួន | - | ៥០ (២០១៧-២០១៨) | ៤៣ | ៣៦ | ២៦ | ២១ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៩. | ចំនួនសិស្សអាហារូបករណ៍នៅមធ្យមសិក្សាបឋមភូមិ | ចំនួន | ៧២ ០៧១ | ៧៣ ៤១៨ | ៧៤ ៤១៨ | ៧៥ ៤១៨ | ៧៦ ៤១៨ | ៧៧ ៤១៨ |
| ១០. | ភាគរយសាលាមធ្យមសិក្សាអនុវត្តសាលាកុមារមេត្រី | % | ២៣,៥ | ២៣,៨ | ២៤,១ | ២៤,៤ | ២៤,៧ | ២៥,០ |
| ១១. | ភាគរយសាលាមធ្យមសិក្សាឆ្លើយតបនឹងស្តង់ដាអប្បបរមាអនាម័យ ទឹកស្អាត | | | | | | | |
| | អនុវិទ្យាល័យ | | | | | | | |
| | *កម្រិត ១* | % | ៤៨,៣ | ៥១,៨ | ៥៥,៤ | ៥៨,៩ | ៦២,៥ | ៦៦,០ |
| | *កម្រិត ២* | % | ១២,៥ | ១២,៨ | ១៣,១ | ១៣,៤ | ១៣,៧ | ១៤,០ |
| | *កម្រិត ៣* | % | ១,៥ | ១,៦ | ១,៧ | ១,៨ | ១,៩ | ២,០ |
| | វិទ្យាល័យ | | | | | | | |
| | *កម្រិត ១* | % | ៤៨,៨ | ៤៨,៦ | ៤៩,០ | ៤៩,៣ | ៤៩,៧ | ៥០,០ |
| | *កម្រិត ២* | % | ២៤,៨ | ២៥,៤ | ២៦,១ | ២៦,៧ | ២៧,៤ | ២៨,០ |
| | *កម្រិត ៣* | % | ១,៨ | ១,៨ | ១,៩ | ១,៩ | ២,០ | ២,០ |
| ១២. | ភាគរយអនុវិទ្យាល័យមាន | | | | | | | |
| | *បង្គន់អនាម័យ* | % | ៩០,៣ | ៩១,២ | ៩២,២ | ៩៣,១ | ៩៤,១ | ៩៥,០ |
| | *ទឹកស្អាតសម្រាប់ទទួលទាន* | % | ៤២,៤ | ៤៣,៩ | ៤៥,៤ | ៤៧,០ | ៤៨,៥ | ៥០,០ |
| | *កន្លែងលាងដៃ* | % | ៤០,៩ | ៤១,៧ | ៤២,៥ | ៤៣,៤ | ៤៤,២ | ៤៥,០ |
| | *ប្រអប់សង្គ្រោះបឋម* | % | ២២,០ | ៣១,៦ | ៤១,២ | ៥០,៨ | ៦០,៤ | ៧០,០ |
| ១៣. | ភាគរយវិទ្យាល័យមាន | | | | | | | |
| | *បង្គន់អនាម័យ* | % | ៩៧,១ | ៩៧,៧ | ៩៨,៣ | ៩៨,៨ | ៩៩,៤ | ១០០ |
| | *ទឹកស្អាត* | % | ៥៤,៦ | ៥៥,៧ | ៥៦,៨ | ៥៧,៨ | ៥៨,៩ | ៦០,០ |
| | *កន្លែងលាងដៃ* | % | ៥៤,៩ | ៥៥,៩ | ៥៦,៩ | ៥៨,០ | ៥៩,០ | ៦០,០ |
| | *ប្រអប់សង្គ្រោះបឋម* | % | ២២,០ | ៣១,៦ | ៤១,២ | ៥០,៨ | ៦០,៤ | ៧០,០ |
| ១៤. | ភាគរយនៃសាលាមធ្យមសិក្សាដែលមានអគ្គិសនីប្រើប្រាស់ ÷ | | | | | | | |
| | *អនុវិទ្យាល័យ* | % | ៧០,០ | ៧១,០ | ៧២,០ | ៧៣,០ | ៧៤,០ | ៧៥,០ |
| | *វិទ្យាល័យ* | % | ៩១,៨ | ៩២,៤ | ៩៣,១ | ៩៣,៧ | ៩៤,៤ | ៩៥,០ |
| ១៥. | ចំនួនសាលាជំនាន់ថ្មី | ចំនួន | ៥ | ៦ | ៧ | ៨ | ៩ | ១០ |
| ១៦. | ចំនួនវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស | ចំនួន | ៩ | ១១ | ១៣ | ១៥ | ១៧ | ១៩ |
| ១៧. | ចំនួនសិស្សក្នុងការអប់រំបច្ចេកទេស | ចំនួន | ១ ៤៧១ | ១ ៧៧៧ | ២ ០៨៣ | ២ ៣៨៨ | ២ ៦៩៤ | ៣ ០០០ |
| | *ចំនួនសិស្សស្រី* | ចំនួន | ៥២៦ | ៥៤៥ | ៥៦៤ | ៥៨៣ | ៦០២ | ៦២១ |
| ១៨. | ចំនួនសាលារៀនអនុវត្តកម្មវិធីមគ្គុទ្ទេសក៍អាជីពនិងការផ្តល់ប្រឹក្សា | ចំនួន | ៣៥ | ៨៥ | ១៣៥ | ១៨៥ | ២៣៥ | ២៨៥ |
| ១៩. | ចំនួនសាលារៀនអនុវត្តកម្មវិធីជំនាញជីវិតតាមមូលដ្ឋាន | ចំនួន | ៣៩១ | ៥២៣ | ៦៥៥ | ៧៨៨ | ៩២០ | ១០៥២ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| វត្ថុបំណងអនុវិស័យទី២ ÷ កែលម្អគុណភាពបង្រៀននិងរៀនឱ្យស្របតាមជំនាញសតវត្សទី២១ | | | | | | | |
| ២០. | ភាគរយគ្រូមធ្យមសិក្សាបឋមភូមិមានគុណវុឌ្ឍិស្របតាមស្តង់ដាជាតិតាមរូបមន្ត ១២+២ | % | ៨៦,០ | ៨៨,០ | ៩០,០ | ៩២,០ | ៩៤,០ | ៩៦,០ |
| ២១. | ចំនួនគ្រូមធ្យមសិក្សាបានទទួលការធ្វើវិក្រឹតការ | ចំនួន | ១ ៦៩១ | ១ ៧០០ | ១ ៧០០ | ១ ៧០០ | ១ ៧០០ | ១ ៧០០ |
| ២២. | ភាគរយសាលាមធ្យមសិក្សាទុតិយភូមិប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍សម្រាប់គាំទ្រការបង្រៀននិងរៀន | % | ៥,០ | ៩,០ | ១៣,០ | ១៧,០ | ២១,០ | ២៥,០ |
| ២៣. | ភាគរយគ្រូមធ្យមសិក្សាបឋមភូមិបញ្ចប់បរិញ្ញាបត្រផ្នែកអប់រំវិទ្យាស្ថានបណ្តុះបណ្តាលគ្រូ | % | ៦,៧ | ៨,៤ | ១០,០ | ១១,៧ | ១៣,៣ | ១៥,០ |
| គោលនយោបាយទី ២ ÷ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | | | |
| វត្ថុបំណងអនុវិស័យទី៣÷ ពង្រឹងភាពជាអ្នកដឹកនាំ និងគ្រប់គ្រងនៅមធ្យមសិក្សា | | | | | | | |
| ២៤. | ចំនួនគណៈគ្រប់គ្រងសាលាមធ្យមសិក្សាបានទទួលការបណ្តុះបណ្តាលលើការគ្រប់គ្រងតាមសាលារៀន | ចំនួន | ៦៧៨ | ១៧០ | ២០០ | ២០០ | ២០០ | ២០០ |
| ២៥. | ចំនួនសាលាមធ្យមសិក្សាអនុវត្តកម្មវិធីការគ្រប់គ្រងតាមសាលារៀនពេញលេញ | ចំនួន | ១៥០ | ១៦៥ | ១៩៥ | ២២៥ | ២៦០ | ៣០០ |

## អនុវិស័យ ការអប់រំឧត្តមសិក្សា

| សូចនាករស្នូល | | ឯកតា | ស្ថានភាព | ចំណុចដៅ | ចំណុចដៅ | ចំណុចដៅ | ចំណុចដៅ | ចំណុចដៅ |
|---|---|---|---|---|---|---|---|---|
| | | | ២០១៧-១៨ | ២០១៨-១៩ | ២០១៩-២០ | ២០២០-២១ | ២០២១-២២ | ២០២២-២៣ |
| គោលនយោបាយទី ១ ÷ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | | | | |
| វត្ថុបំណងអនុវិស័យទី១ ÷ លើកកម្ពស់ការចូលរៀន និងកែលម្អគុណភាពនៃកម្មវិធីបណ្តុះបណ្តាលនៅឧត្តមសិក្សា ឆ្ពោះទៅការទទួលស្គាល់គុណភាពកម្រិតជាតិ និងអន្តរជាតិ | | | | | | | | |
| ១. | អត្រារួមនៃការសិក្សានៅឧត្តមសិក្សា | % | ១១,៦ | ១២,៤ | ១៣,៣ | ១៤,២ | ១៥,១ | ១៦,០ |
| | *ប្រុស* | % | ១៣,២ | ១៤,៣ | ១៥,៥ | ១៦,៦ | ១៧,៨ | ១៨,៩ |
| | *ស្រី* | % | ១១,៣ | ១១,៦ | ១១,៩ | ១២,៣ | ១២,៧ | ១៣,០ |
| ២. | ភាគរយនិស្សិតចុះឈ្មោះចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលផ្នែកស្ទែម | % | ២៧,១ | ២៨,០ | ២៩,០ | ៣០,០ | ៣១,០ | ៣២,០ |
| | *ប្រុស* | % | ៣៦,៧ | ៣៧,១ | ៣៧,៥ | ៣៧,៨ | ៣៨,២ | ៣៨,៦ |
| | *ស្រី* | % | ១៧,៤ | ១៨,៤ | ១៩,៤ | ២០,៥ | ២១,៥ | ២២,៥ |
| ៣. | ចំនួនមជ្ឈមណ្ឌលឧត្តមភាព | ចំនួន | ០ | ១ | | ២ | | ៣ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៤. | ភាគរយបុគ្គលិកសិក្សាពេញម៉ោងមានគុណវុឌ្ឍិថ្នាក់បណ្ឌិត | % | ៣,៤ | ៣,៧ | ៤,០ | ៤,៤ | ៤,៧ | ៥,០ |
| | *ស្រី* | % | ១៤,៧ | ១៥,២ | ១៥,៦ | ១៦,១ | ១៦,៥ | ១៧,0 |
| ៥. | ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានធ្វើការសិក្សាពីស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា | ចំនួន | ០ | ២ | ៤ | ៦ | ៨ | ១០ |
| គោលនយោបាយទី ២ ÷ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | | | | |
| វត្ថុបំណងអនុវិស័យទី២÷ អភិវឌ្ឍប្រព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រងសម្រាប់គាំទ្រគ្រឹះស្ថានឧត្តមសិក្សាឱ្យទទួលបានស្វ័យភាពពេញលេញ | | | | | | | | |
| ៦. | ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង | ចំនួន | ០ | ៥ | ១០ | ១៥ | ២០ | ២៥ |
| ៧. | ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបានការទទួលស្គាល់គុណភាពអប់រំ | ចំនួន | ០ | ៥ | ១០ | ១៥ | ២០ | ២៥ |
| ៨. | ចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យឧត្តមសិក្សា | ចំនួន | ០ | ៨ | ១៦ | ២៤ | ៣២ | ៤០ |

## អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ

| សូចនាករស្នូល | | ឯកតា | ស្ថានភាព ២០១៧-១៨ | ចំណុចដៅ ២០១៨-១៩ | ចំណុចដៅ ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ចំណុចដៅ ២០២១-២២ | ចំណុចដៅ ២០២២-២៣ |
|---|---|---|---|---|---|---|---|---|
| គោលនយោបាយទី ១ ÷ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | | | | |
| វត្ថុបំណងអនុវិស័យទី១ ÷ បង្កើនចំនួនអក្ខរជន និងការចូលរៀនក្នុងកម្មវិធីអប់រំក្រៅប្រព័ន្ធសម្រាប់កុមារ និងយុវជនក្រៅសាលា ព្រមទាំងពេញវ័យដែលជាអនក្ខរជន ទទួលបានសេវាអប់រំក្រៅប្រព័ន្ធបានពេញលេញក្នុងក្របខណ្ឌការសិក្សាពេញមួយជីវិតប្រកបដោយវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា | | | | | | | | |
| ១. | ចំនួនប្រជាជនមិនចេះអក្សរបានបញ្ចប់ថ្នាក់អក្ខរកម្ម | ចំនួន | ១៦ ៨៥០ | ១៦ ០០០ | ១៥ ២០០ | ១៤ ៤០០ | ១៣ ៦០០ | ១២ ៨០០ |
| ២. | ចំនួនសិស្សចូលរៀនក្នុងកម្មវិធីសមមូល | ចំនួន | ៦ ៣៩៤ | ៧ ៣០០ | ៨ ៣០០ | ៩ ៣០០ | ១០ ៣០០ | ១១ ៣០០ |
| ៣. | ចំនួនម.ស.ស.ដែលប្រែក្លាយជាមជ្ឈមណ្ឌលសិក្សាពេញមួយជីវិត | ចំនួន | ០ | ៥ | ១៥ | ២៥ | ៤០ | ៥៥ |
| ៤. | ចំនួនកុមារបានបញ្ចប់កម្មវិធីចូលរៀនឡើងវិញ និងបានបញ្ជូនទៅក្នុងប្រព័ន្ធ | ចំនួន | ១០ ០៩៩ | ១០ ១០០ | ១០ ១៨០ | ១០ ២៦០ | ១០ ៣០០ | ១០ ៤០០ |
| ៥. | ចំនួនអ្នកបានបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញមុខរបរ | ចំនួន | ៩ ១៧០ | ១០ ១០០ | ១១ ១០០ | ១២ ១០០ | ១៣ ១០០ | ១៤ ១០០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| គោលនយោបាយទី ២ ÷ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | | | | |
| វត្ថុបំណងអនុវិស័យទី២÷ ពង្រឹងការអនុវត្តប្រព័ន្ធគ្រប់គ្រងអប់រំក្រៅប្រព័ន្ធផ្អែកលើកលទ្ធផលឱ្យមានដំណើរការបានពេញលេញ | | | | | | | | |
| ៦. | ចំនួនខេត្តដែលបានអនុវត្តក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃអប់រំក្រៅប្រព័ន្ធផ្អែកលើលទ្ធផល | ចំនួន | ០ | ៥ | ១០ | ១៥ | ២០ | ២៥ |
| ៧. | ចំនួនស្រុកដែលអនុវត្តបានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ | ចំនួន | ០ | ៣០ | ៦០ | ៩០ | ១២០ | ១៥០ |
| វត្ថុបំណងអនុវិស័យទី៣ ÷ ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់មន្ត្រីអប់រំក្រៅប្រព័ន្ធគ្រប់លំដាប់ថ្នាក់ | | | | | | | | |
| ៨. | ចំនួនមន្ត្រីអប់រំក្រៅប្រព័ន្ធទទួលការបណ្តុះបណ្តាលលើការធ្វើផែនការ និងការគ្រប់គ្រងសេវាអប់រំក្រៅប្រព័ន្ធ | ចំនួន | ០ | ១៣០ | ២៦០ | ៣៩០ | ៥២០ | ៦៥០ |

## អនុវិស័យ ការអភិវឌ្ឍយុវជន

| សូចនាករសួល | | ឯកតា | ស្ថានភាព ២០១៧-១៨ | ចំណុចដៅ ២០១៨-១៩ | ចំណុចដៅ ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ចំណុចដៅ ២០២១-២២ | ចំណុចដៅ ២០២២-២៣ |
|---|---|---|---|---|---|---|---|---|
| គោលនយោបាយទី ១ ÷ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | | | | |
| វត្ថុបំណងអនុវិស័យទី១ ÷ អភិវឌ្ឍកម្មវិធីឌីជីថល សហគ្រិនភាព ភាពជាអ្នកដឹកនាំ និងជំនាញទន់ផ្សេងៗទៀត សម្រាប់ការអភិវឌ្ឍយុវជន | | | | | | | | |
| ១. | ចំនួនយុវជនទទួលបានការបណ្តុះ-បណ្តាលរយៈពេលខ្លីស្តីពីជំនាញវិជ្ជាជីវៈ ឌីជីថល និងបច្ចេកទេស | ចំនួន | ១ ៦៤៤ | ១ ៦៤៤ | ១ ៦៤៤ | ១ ៦៤៤ | ១ ៦៤៤ | ១ ៦៤៤ |
| ២. | ចំនួនយុវជនទទួលបានការបណ្តុះ-បណ្តាលស្តីពី ការងារស្ម័គ្រចិត្ត | ចំនួន | ១ ២៤៤ | ១ ២៤៤ | ១ ២៤៤ | ១ ២៤៤ | ១ ២៤៤ | ១ ២៤៤ |
| ៣. | ចំនួនយុវជនទទួលបានការបណ្តុះ-បណ្តាលស្តីពី សហគ្រិនភាព ភាពជាអ្នកដឹកនាំ អក្ខរកម្មហិរញ្ញវត្ថុ ការសិក្សា និងការណែនាំការងារ | ចំនួន | ១០ ០៩២ | ៩ ៥១០ | ៩ ៥១០ | ៩ ៥១០ | ៩ ៥១០ | ៩ ៥១២ |
| ៤. | ចំនួនយុវជន និងកុមារទទួលបានប័ណ្ណសរសើរក្នុងការអនុវត្តចលនាប្រឡងប្រណាំង៣ល្អ "កូនល្អ សិស្សល្អ មិត្តល្អ" | ចំនួន | ៣១៩ | ៣១៩ | ៣១៩ | ៣១៩ | ៣១៩ | ៣១៩ |
| ៥. | ភាគរយក្រុមប្រឹក្សាកុមារកម្ពុជាដែលកំពុងដំណើរការ | % | ៩,៦ | ១១,៧ | ១៣,៨ | ១៥,៨ | ១៧,៩ | ២០,០ |
| ៦. | ភាគរយក្រុមប្រឹក្សាយុវជនកម្ពុជាដែលកំពុងដំណើរការ | % | ២២,៤ | ២៣,៩ | ២៥,៤ | ២៧,០ | ២៨,៥ | ៣០,០ |
| ៧. | ចំនួនយុវជនកាយរឹទ្ធិនៅបឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា និងសហគមន៍ចូលរួមចលនាកាយរឹទ្ធិ | ចំនួន | ១៥០ ៩៦៣ | ១៩០ ៧៧០ | ២៣០ ៥៧៨ | ២៧០ ៣៨៥ | ៣១០ ១៩៣ | ៣៥០ ០០០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៨. | ចំនួនយុវជនក្រៅសាលាចូលរួមសិក្សាក្នុងកម្មវិធីអប់រំសមមូលកម្រិតមូលដ្ឋាន "បីប" | ចំនួន | ២៥០ | ២៥០ | ២៥០ | ២៥០ | ២៥០ | ២៥០ |
| វត្ថុបំណងអនុវិស័យទី២ ÷ ពង្រឹងការអភិវឌ្ឍយុវជនតាមរយៈមជ្ឈមណ្ឌលយុវជន ទីកន្លែង និងបរិក្ខារទាន់សម័យ | | | | | | | | |
| ៩. | ចំនួនមជ្ឈមណ្ឌលយុវជនដែលកំពុងដំណើរការ | ចំនួន | ៦ | ៧ | ៧ | ៨ | ៨ | ៩ |
| គោលនយោបាយទី ២ ÷ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | | | | |
| វត្ថុបំណងអនុវិស័យទី៣÷ ពង្រឹងសមត្ថភាពស្ថាប័ននិងមន្ត្រីទទួលបន្ទុកការងារយុវជននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ | | | | | | | | |
| ១០. | ចំនួនមន្ត្រីទទួលបន្ទុកការងារយុវជនទទួលបានការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងគម្រោង | ចំនួន | ២០០ | ២០០ | ២០០ | ២០០ | ២០០ | ២០០ |
| ១១. | ចំនួនក្រុមប្រឹក្សាអភិវឌ្ឍយុវជនតាមក្រសួង ស្ថាប័ន ត្រូវបានបង្កើត | ចំនួន | ០ | ៣ | ៦ | ១០ | ១៣ | ១៦ |
| ១២. | ចំនួនក្រុមប្រឹក្សាអភិវឌ្ឍយុវជនតាមរាជធានី-ខេត្ត ត្រូវបានបង្កើត | ចំនួន | ០ | ២ | ៥ | ៧ | ១០ | ១២ |

## អនុវិស័យ ការអប់រំកាយ និងកីឡា

| សូចនាករស្នូល | | ឯកតា | ស្ថានភាព ២០១៧-១៨ | ចំណុចដៅ ២០១៨-១៩ | ចំណុចដៅ ២០១៩-២០ | ចំណុចដៅ ២០២០-២១ | ចំណុចដៅ ២០២១-២២ | ចំណុចដៅ ២០២២-២៣ |
|---|---|---|---|---|---|---|---|---|
| គោលនយោបាយទី ១ ÷ ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា | | | | | | | | |
| វត្ថុបំណងអនុវិស័យទី១ ÷ បង្កើនលទ្ធភាពទទួលបានការអប់រំកាយ និងកីឡានៅតាមគ្រឹះស្ថានសិក្សា និងសហគមន៍ | | | | | | | | |
| ១. | ទីលានកីឡា៥កន្លែងត្រូវបានកែលម្អ | | | | | | | |
| | *សៀមរាប* | % | ០ | ២០,០ | ៤០,០ | ៦០,០ | ៨០,០ | ១០០ |
| | *កំពត* | % | ០ | ២០,០ | ៤០,០ | ៦០,០ | ៨០,០ | ១០០ |
| | *កំពង់ចាម* | % | ០ | ២០,០ | ៤០,០ | ៦០,០ | ៨០,០ | ១០០ |
| | *បាត់ដំបង* | % | ០ | ២០,០ | ៤០,០ | ៦០,០ | ៨០,០ | ១០០ |
| | *ភ្នំពេញ* | % | ៥០,០ | ៦០,០ | ៧០,០ | ៨០,០ | ៩០,០ | ១០០ |
| ២. | ភាគរយសាលាបឋមសិក្សាអនុវត្តកម្មវិធីអប់រំកាយ និងកីឡា | % | ៦៥,០ | ៧២,០ | ៧៩,០ | ៨៦,០ | ៩៣,០ | ៩០ |
| ៣. | ភាគរយសាលាមធ្យមសិក្សាអនុវត្តកម្មវិធីអប់រំកាយ និងកីឡា | % | ៣០,០ | ៣៨,០ | ៤៦,០ | ៥៤,០ | ៦២,០ | ៧០ |
| ៤. | ចំនួនមេដាយក្នុងការប្រកួតអន្តរជាតិក្នុងមួយឆ្នាំ | ចំនួន | ៣២៩ | ៣៨៣ | ៤៣៧ | ៤៩២ | ៥៤៦ | ៦០០ |
| ៥. | ភាគរយប្រជាជនចូលរួមសកម្មភាពអប់រំកាយ និងកីឡា | % | ៧,០ | ១០,២ | ១៣,៤ | ១៦,៦ | ១៩,៨ | ២៣,០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| វត្ថុបំណងអនុវិស័យទី២ ÷ លើកកម្ពស់គុណផលក្រុមកីឡាជម្រើសជាតិ ដើម្បីដណ្តើមមេដាយមាសឱ្យបានច្រើននៅឆ្នាំ២០២៣ | | | | | | | | |
| ៦. | ចំណាត់ថ្នាក់ស៊ីហ្គេមនៅក្នុងប្រទេសអាស៊ាន | ចំណាត់ថ្នាក់ | ៨ | | | | | ៥ |
| ៧. | ចំនួនមេដាយមាសស៊ីហ្គេម ២០២៣ | ចំនួន | ៣ | ១១ | ២០ | ២៨ | ៣៧ | ៤៥ |
| គោលនយោបាយទី ២ ÷ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ | | | | | | | | |
| វត្ថុបំណងអនុវិស័យទី ៣÷ អភិវឌ្ឍស្ថាប័ន អ្នកគ្រប់គ្រង និងអ្នកបច្ចេកទេសទទួលបន្ទុកអនុវិស័យអប់រំកាយ និងកីឡាប្រកបដោយប្រសិទ្ធភាព និងគុណភាព | | | | | | | | |
| ៨. | ចំនួនកីឡាករ កីឡាការិនីបានទទួលការបណ្តុះបណ្តាលក្នុងមួយឆ្នាំ | ចំនួន | ៣៣ | ៥៣ | ៧៣ | ៩៣ | ១១៣ | ១៣៣ |
| ៩. | ចំនួនគ្រូបង្វឹកបានទទួលការបណ្តុះ-បណ្តាលក្នុងមួយឆ្នាំ | ចំនួន | ១០០ | ១១០ | ១២០ | ១៣០ | ១៤០ | ១៥០ |
| ១០. | ចំនួនគ្រូបង្វឹកបានទទួលការបណ្តុះ-បណ្តាលក្នុងមួយឆ្នាំ | ចំនួន | ៩១៥ | ១ ០១២ | ១ ១០៩ | ១ ២០៦ | ១ ៣០៣ | ១ ៤០០ |
| ១១. | ចំនួនចៅក្រមនិងអាជ្ញាកណ្តាលបានទទួលការបណ្តុះបណ្តាលក្នុងមួយឆ្នាំ | ចំនួន | ៩២៥ | ១ ០៣០ | ១ ១៣៥ | ១ ២៤០ | ១ ៣៤៥ | ១ ៤៥០ |
| ១២. | ចំនួនគ្រូបង្វឹកបានទទួលការបណ្តុះ-បណ្តាលបច្ចេកទេសកីឡា ផែនការយុទ្ធសាស្ត្រ និងការគ្រប់គ្រង | ចំនួន | ១៤៣ | ១៧៣ | ២០៣ | ២៣៣ | ២៦៣ | ២៩៣ |
| ១៣. | ចំនួនគ្រូអប់រំកាយនិងកីឡាបានទទួលការបណ្តុះបណ្តាល (វគ្គខ្លី/វិក្រឹតការ) | ចំនួន | ១៨០ | ២១៦ | ២៥២ | ២៨៨ | ៣២៤ | ៣៦០ |
| ១៤. | ចំនួនមន្ត្រីកីឡាបានទទួលការបណ្តុះបណ្តាលក្នុងមួយឆ្នាំ | ចំនួន | ១៨០ | ២១៦ | ២៥២ | ២៨៨ | ៣២៤ | ៣៦០ |
| ១៥. | ចំនួនអត្តពលិកកម្រិតខ្ពស់ | ចំនួន | ៧០៧ | ៧៦៦ | ៨២៤ | ៨៨៣ | ៩៤១ | ១ ០០០ |

# ឧបសម្ព័ន្ធទី ៣ ៖ ចំណោលចំនួនសិស្ស និងតម្រូវការអប់រំ

## *ចំណោលប្រជាជនក្នុងវ័យសិក្សា*

| ប្រជាជនដល់វ័យសិក្សា | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| អាយុ ៣-៥ឆ្នាំ | ៩៣៤ ២៩៧ | ៩៤៨ ៣៣៧ | ៩៥៩ ៣៨៩ | ៩៧០ ៧៣៧ | ៩៨២ ៣៨៤ |
| *ស្រី* | ៤៥៥ ១៧៣ | ៤៦១ ៥៧៥ | ៤៦៧ ១៦៦ | ៤៧២ ៨៦៣ | ៤៧៨ ៦៦៨ |
| អាយុ ៦-១១ឆ្នាំ | ១ ៩០២ ៣៧០ | ១ ៩២៩ ២១៥ | ១ ៩៥១ ១១៦ | ១ ៩៧២ ៨០៨ | ១ ៩៩៥ ១១៤ |
| *ស្រី* | ៩២១ ៩០០ | ៩៣៣ ៥៥៣ | ៩៤៥ ១៦៦ | ៩៥៦ ១៦០ | ៩៦៧ ៣៥៨ |
| អាយុ ១២-១៤ឆ្នាំ | ១ ០៧៧ ៣៥៨ | ១ ០៩២ ៩៧៩ | ១ ១០៤ ៤៨១ | ១ ១១៦ ៣៧៤ | ១ ១២៨ ៦៥៦ |
| *ស្រី* | ៥២០ ៩៨១ | ៥២៨ ០៣៨ | ៥៣៤ ១៤៩ | ៥៤០ ៣៧៤ | ៥៤៦ ៧១៤ |
| អាយុ ១៥-១៧ឆ្នាំ | ១ ១៤១ ៧៧៥ | ១ ១៥៨ ៦៥៣ | ១ ១៧០ ០៥៧ | ១ ១៨២ ០៦៣ | ១ ១៩៤ ៦៤៨ |
| *ស្រី* | ៥៤៩ ១៤១ | ៥៥៦ ៨៣២ | ៥៦៣ ៥៣៧ | ៥៧០ ៣៦៩ | ៥៧៧ ៣៣១ |
| អាយុ ១៨-២២ឆ្នាំ | ១ ៨២៨ ៤៧៥ | ១ ៨៥៧ ៣៥២ | ១ ៨៧៧ ១៤២ | ១ ៨៩៨ ១៣៧ | ១ ៩២០ ២៦៧ |
| *ស្រី* | ៨៩២ ១៩០ | ៩០៥ ៨៤៧ | ៩១៨ ០២៤ | ៩៣០ ៤៤១ | ៩៤៣ ១០៤ |

## *ចំណោលសិស្សតាមភូមិសិក្សា*

| ចំណោលសិស្ស | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| **ការអប់រំកុមារតូច** | **៣២១ ៥៦៧** | **៣៤២ ៥៣៦** | **៣៥៩ ២៤៦** | **៣៧៦ ៣៥៩** | **៣៩៣ ៨៨៨** |
| ស្រី | ១៣៧ ៧៦៤ | ១៦៩ ៤៤៣ | ១៧៦ ៧៤៦ | ១៨៤ ២០៣ | ១៩១ ៨១៧ |
| រដ្ឋ | ២១៥ ០៧៤ | ២២៨ ៥១៩ | ២៤០ ០៩៧ | ២៥១ ៩៨៥ | ២៦៤ ១៩៣ |
| ស្រី | ១០៦ ៨៧៥ | ១១២ ៦៣០ | ១១៧ ៨៣៩ | ១២៣ ១៨០ | ១២៨ ៦៥៨ |
| ឯកជន | ៣៩ ៣៨៩ | ៤២ ១១៦ | ៤៤ ០៥១ | ៤៦ ០២៣ | ៤៨ ០៣៥ |
| ស្រី | ១៩ ៣៩៤ | ២០ ៧៩២ | ២១ ៦៤៣ | ២២ ៥១០ | ២៣ ៣៩២ |
| សហគមន៍ | ៦៧ ១០៤ | ៧១ ៩០១ | ៧៥ ០៩៨ | ៧៨ ៣៥១ | ៨១ ៦៦០ |
| ស្រី | ១១ ៤៩៥ | ៣៦ ០២១ | ៣៧ ២៦៤ | ៣៨ ៥១៣ | ៣៩ ៧៦៧ |
| **ការអប់រំបឋមសិក្សា** | **២ ១៦៣ ១៤៣** | **២ ១៧២ ៣៦៩** | **២ ១៩៥ ១១៧** | **២ ២០៨ ៥៦៩** | **២ ២១៧ ៥៤៤** |
| ស្រី | ១ ០៣៩ ៩៣៦ | ១ ០៤២ ៨២១ | ១ ០៣៧ ៨៧៧ | ១ ០២៨ ៥១១ | ១ ០២៣ ៣៣៦ |
| រដ្ឋ | ២ ០៤០ ២៥៧ | ២ ០៥៨ ៦៥៥ | ២ ០៧៩ ៩៥៩ | ២ ០៩២ ៤៤៨ | ២ ១០០ ៦៩២ |
| ស្រី | ៩៧៨ ៨០០ | ៩៨៧ ៨១៣ | ៩៩៤ ៨៩៩ | ៩៩៧ ៩៥៣ | ៩៩៩ ៦៥១ |
| ឯកជន | ១២២ ៨៨៦ | ១១៣ ៧១៤ | ១១៥ ១៥៨ | ១១៦ ១២០ | ១១៦ ៨៥២ |
| ស្រី | ៦១ ១៣៦ | ៥៥ ៧៨៦ | ៥៦ ១៨៦ | ៥៦ ៣៥៨ | ៥៦ ៤៥៤ |
| **មធ្យមសិក្សាបឋមភូមិ** | **៦៣១ ០២៥** | **៦៤៦ ១៧២** | **៦៧២ ៨៥៣** | **៧១១ ១២៤** | **៧៥៧ ៦២០** |
| ស្រី | ៣២៧ ១៥៥ | ៣៣៥ ៣៥៣ | ៣៤៩ ៤៨០ | ៣៦៩ ៣៥៨ | ៣៩១ ៩៨៤ |

| | | | | | |
|---|---|---|---|---|---|
| រដ្ឋ | ៦០៥ ០៩៧ | ៦១៩ ៨១៨ | ៦៤៥ ៦១៥ | ៦៨២ ៥៥០ | ៧២៧ ៤០០ |
| ស្រី | ៣១៤ ៦៦៣ | ៣២២ ៥៤៨ | ៣៣៦ ១៣៥ | ៣៥៥ ២៥៤ | ៣៧៧ ០១៦ |
| ឯកជន | ២៥ ៩២៨ | ២៦ ៣៥៤ | ២៧ ២៣៨ | ២៨ ៥៧៤ | ៣០ ២២០ |
| ស្រី | ១២ ៤៩២ | ១២ ៨០៥ | ១៣ ៣៤៤ | ១៤ ១០៣ | ១៤ ៩៦៧ |
| **មធ្យមសិក្សាទុតិយភូមិ** | **៣២៣ ៣៨៥** | **៣៤៤ ៩២២** | **៣៧៣ ៣៦៤** | **៣៩៨ ៣៣៥** | **៤២៤ ៧៥៥** |
| ស្រី | ១៦៧ ៩៦៩ | ១៨២ | ២០០ ០៧៩ | ២១៤ ៩៧៥ | ២៣០ ៥៦៨ |
| រដ្ឋ | ៣០៥ ១៥៥ | ៣២៥ ៥៤៨ | ៣៥២ ៤១៦ | ៣៧៦ ០០០ | ៤០០ ៩៥២ |
| ស្រី | ១៥៩ ២២៥ | ១៧២ ៩៣៧ | ១៨៩ ៦៦៤ | ២០៣ ៧៨៤ | ២១៨ ៥៦៥ |
| ឯកជន | ១៨ ១៩០ | ១៩ ៣៧៤ | ២០ ៩៤៨ | ២២ ៣៣៥ | ២៣ ៨០៣ |
| ស្រី | ៨ ៧៤៤ | ៩ ៤៩៧ | ១០ ៤១៦ | ១១ ១៩១ | ១២ ០០៣ |
| **ការអប់រំឧត្តមសិក្សា** | **២២៦ ៧៣១** | **២៤៧ ០២៨** | **២៦៦ ៥៥៤** | **២៨៦ ៦១៩** | **៣០៧ ២៤៣** |
| ស្រី | ១០៣ ៤៩៤ | ១០៧ ៧៩៦ | ១១២ ៩១៧ | ១១៨ ១៦៦ | ១២២ ៦០៤ |
| រដ្ឋ | ៨១ ៨៥០ | ៩១ ១០៤ | ១០០ ៣៨៤ | ១១០ ១៧៦ | ១២០ ៥០១ |
| ស្រី | ៣៧ ២៥៨ | ៣៩ ៦៦៩ | ៤២ ៤៥៧ | ៤៥ ៣៧៦ | ៤៨ ០៦១ |
| ឯកជន | ១៤៤ ៨៨១ | ១៥៥ ៩២៤ | ១៦៦ ១៧៩ | ១៧៦ ៤៤២ | ១៨៦ ៧៤២ |
| ស្រី | ៦៦ ២៣៦ | ៦៨ ១២៧ | ៧០ ៤៦០ | ៧២ ៧៩០ | ៧៤ ៥៤៣ |

*ចំណោលតម្រូវការគ្រូបង្រៀន (រដ្ឋ)តាមភូមិសិក្សា*

| ចំនួនគ្រូបង្រៀន | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ការអប់រំបឋមសិក្សា (រដ្ឋ) | **៥៦ ៧៩០** | **៥៧ ៥២៥** | **៥៨ ៦០១** | **៥៩ ៦៤០** | **៦០ ៧៥១** |
| *គ្រូចេញថ្មី* | ១ ៦២៧ | ១ ៨០០ | ១ ៨០០ | ១ ៨០០ | ១ ៨០០ |
| *គ្រូចូលនិវត្តន៍និងលុបឈ្មោះ* | ៩៤២ | ៨៦៥ | ៥២៤ | ៥៦១ | ៤៨៩ |
| ការអប់រំមធ្យមសិក្សាបឋមភូមិ (រដ្ឋ) | **៤១ ៧៤០** | **៤២ ០៤៧** | **៤២ ៤៧៣** | **៤២ ៨៩០** | **៤៣ ៣១១** |
| *គ្រូចេញថ្មី* | ៧៨៦ | ៨២៦ | ៧៥០ | ៧៥០ | ៧៥០ |
| *គ្រូចូលនិវត្តន៍និងលុបឈ្មោះ* | ៥១០ | ៥១៩ | ៣២៤ | ៣៣៣ | ៣២៩ |
| ការអប់រំមធ្យមសិក្សាទុតិយភូមិ(រដ្ឋ) | **១៦ ៩២៤** | **១៧ ៨១៤** | **១៨ ៧៣០** | **១៩ ៦២០** | **២០ ៥១៥** |
| *គ្រូចេញថ្មី* | ៨១៧ | ១ ០០០ | ១ ០០០ | ១ ០០០ | ១ ០០០ |
| *គ្រូចូលនិវត្តន៍និងលុបឈ្មោះ* | ១០៥ | ១១០ | ៨៤ | ១១០ | ១០៥ |

# **ឧបសម្ព័ន្ធទី ៤ ៖ ការព្យាករណ៍ថវិកាសម្រាប់វិស័យអប់រំ**

## *ក. ការប៉ាន់ស្មានធនធានដែលមាន សម្រាប់វិស័យអប់រំ (គិតជាលានរៀល)*

| *ការប៉ាន់ស្មានធនធានដែលមាន* | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ផ.ស.ស ថ្លៃបច្ចុប្បន្ន | ១០៨ ៥៩០ ៤៤៤ | ១១៩ ០៣៣ ៥៤៨ | ១៣០ ៩១៥ ៨២២ | ១៤៤ ១៦៨ ៣៤៨ | ១៥៨ ៨៨៤ ៣៦៨ |
| អត្រាកំណើន ផ.ស.ស ពិត | ៧,១% | ៦,៥% | ៧,០% | ៧,០% | ៧,០% |
| ផ.ស.ស សម្រាប់ប្រជាជនម្នាក់ៗ | ៦,៨ | ៧,៤ | ៧,៩ | ៨,៧ | ៩,៥ |
| ចំណាយរាជរដ្ឋាភិបាលលើការអប់រំ | ៣ ២២៩ ៦០៤ | ៣ ៥៧៧ ៦៥៥ | ៣ ៩៧៥ ៩៨៨ | ៤ ៤២៣ ៨៤៧ | ៤ ៩២៥ ៤១៥ |
| *ចរន្ត* | *៣ ២១៩ ៦០៤* | *៣ ៥៦៧ ៦៥៥* | *៣ ៩៦៥ ៩៨៨* | *៤ ៤១៣ ៨៤៧* | *៤ ៩១៥ ៤១៥* |
| *មូលធន* | *១០ ០០០* | *១០ ០០០* | *១០ ០០០* | *១០ ០០០* | *១០ ០០០* |
| គិតជាភាគរយនៃផ.ស.ស | ២,៩៧% | ៣,០១% | ៣,០៤% | ៣,០៧% | ៣,១០% |
| ថវិកាអប់រំធៀបនឹងចំណាយរបស់រាជរដ្ឋាភិបាល | ១៨,៤% | ១៨,៦% | ១៨,៨% | ១៨,៩% | ១៩,១% |

## *ខ. តម្រូវការហិរញ្ញប្បទានតាមអនុវិស័យ (គិតជាលានរៀល)*

| ការព្យាករណ៍ចំណាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ការអប់រំកុមារតូច | ២៤៦ ៧៥១ | ២៧៤ ២៤២ | ២៩៦ ២៦១ | ៣០៦ ៩៤៧ | ៣៣៦ ៦៧៣ |
| ការអប់រំបឋមសិក្សា | ១ ៩៦៩ ៥០២ | ២ ១១០ ០៤៦ | ២ ២១៦ ៦៣៦ | ២ ៣៥៥ ៧៧៩ | ២ ៤៩៩ ៧២៤ |
| ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស | ១ ០៩៣ ៦៣០ | ១ ១៨៩ ៤១៥ | ១ ៣៦២ ៩៧៩ | ១ ៥០០ ៧៥២ | ១ ៦៦២ ១៨៤ |
| ការអប់រំឧត្តមសិក្សា | ៣៦៧ ៤៩៦ | ៤៣៨ ៧២២ | ៤៨១ ០០៥ | ៥២៤ ៧៣៦ | ៥៨៥ ៤១៨ |
| ការអប់រំក្រៅប្រព័ន្ធ | ៤២ ០១៦ | ៥៧ ០០៩ | ៦១ ១៥៧ | ៧៣ ៧៧៣ | ៨១ ១៤២ |
| ការអភិវឌ្ឍយុវជន | ២៦ ៥៩៦ | ៣២ ២៧៣ | ៣៤ ៧៧៦ | ៣៥ ៣៦៧ | ៣៨ ០៥៨ |
| ការអប់រំកាយ និងកីឡា | ៧១ ៨៩៤ | ៧៣ ៤៩៦ | ៧៦ ៥៣៥ | ៨០ ៤៨៤ | ៨៦ ៥៦៣ |
| **សរុប** | **៣ ៨១៧ ៨៨៥** | **៤ ១៧៥ ២០៣** | **៤ ៥២៩ ៣៤៩** | **៤ ៨៧៧ ៨៣៨** | **៥ ២៨៩ ៧៦២** |
| *ថវិកាចរន្ត* | ៣ ៥៣៧ ៨៨៥ | ៣ ៦៦០ ៨២៣ | ៣ ៩៧៧ ៤២៥ | ៤ ២៨៥ ៩៦២ | ៤ ៦៥៥ ៤០០ |
| *ថវិកាមូលធន* | ២៨០ ០០០ | ៥១៤ ៣៨០ | ៥៥១ ៩២៤ | ៥៩១ ៨៧៦ | ៦៣៤ ៣៦២ |

| ការព្យាករណ៍ចំណាយ (លានដុល្លាអាមេរិច) | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ការអប់រំកុមារតូច | ៦០,៨៧ | ៦៧,៦៥ | ៧៣,០៨ | ៧៥,៧១ | ៨៣,០៥ |
| ការអប់រំបឋមសិក្សា | ៤៨៥,៨២ | ៥២០,៤៨ | ៥៤៦,៧៨ | ៥៨១,១០ | ៦១៦,៦១ |
| ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស | ២៦៩,៧៧ | ២៩៣,៣៩ | ៣៣៦,២១ | ៣៧០,១៩ | ៤១១,០១ |
| ការអប់រំឧត្តមសិក្សា | ៩០,៦៥ | ១០៨,២២ | ១១៨,៦៥ | ១២៩,៤៤ | ១៤៤,៤១ |
| ការអប់រំក្រៅប្រព័ន្ធ | ១០,៣៦ | ១៤,០៦ | ១៥,០៩ | ១៨,២០ | ២០,០២ |
| ការអភិវឌ្ឍយុវជន | ៦,៥៦ | ៧,៩៦ | ៨,៥៨ | ៨,៧២ | ៩,៣៩ |
| ការអប់រំកាយ និងកីឡា | ១៧,៧៣ | ១៨,១៣ | ១៨,៨៨ | ១៩,៨៥ | ២១,៣៥ |
| **សរុប** | **៩៤១,៧៦** | **១ ០២៩,៩០** | **១ ១១៧,២៥** | **១ ២០៣,២២** | **១ ៣០៤,៨៣** |

| ការព្យាករណ៍ចំណាយ (ភាគរយ) | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ការអប់រំកុមារតូច | ៦,៥% | ៦,៦% | ៦,៥% | ៦,៣% | ៦,៤% |
| ការអប់រំបឋមសិក្សា | ៥១,៦% | ៥០,៥% | ៤៨,៩% | ៤៨,៣% | ៤៧,៣% |
| ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស | ២៨,៦% | ២៨,៥% | ៣០,១% | ៣០,៨% | ៣១,៤% |
| ការអប់រំឧត្តមសិក្សា | ៩,៦% | ១០,៥% | ១០,៦% | ១០,៨% | ១១,១% |
| ការអប់រំក្រៅប្រព័ន្ធ | ១,១% | ១,៤% | ១,៤% | ១,៥% | ១,៥% |
| ការអភិវឌ្ឍយុវជន | ០,៧% | ០,៨% | ០.៨% | ០.៧% | ០,៧% |
| ការអប់រំកាយ និងកីឡា | ១,៩% | ១,៨% | ១,៧% | ១,៦% | ១,៦% |
| **សរុប** | **១០០%** | **១០០%** | **១០០%** | **១០០%** | **១០០%** |

### *គ. កង្វះខាតថវិកា*

| បរិយាយ | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| ចំណាយរាជរដ្ឋាភិបាលលើការអប់រំ (លានរៀល) | ៣ ២២៩ ៦០៤ | ៣ ៥៧៧ ៦៥៥ | ៣ ៩៧៥ ៩៨៨ | ៤ ៤២៣ ៨៤៧ | ៤ ៩២៥ ៤១៥ |
| មូលនិធិក្រៅប្រទេស(ផែនការវិនិយោគវិស័យអប់រំ) | ៥៥៣ ៦៤០ | ៥៨៣ ៣៧១ | ៤៩២ ៥៦១ | ៤០២ ៥៦២ | ៣៣០ ៨០៦ |
| ធនធានដែលមានសរុប (លានរៀល) | **៣ ៧៨៣ ៣៨០** | **៤ ១៦១ ០២៦** | **៤ ៤៦៨ ៥៤៩** | **៤ ៨២៦ ៤០៩** | **៥ ២៥៦ ២២២** |
| *គិតជាលានដុល្លារ* | ៩៣៣,២៥ | ១ ០២៦,៤០ | ១ ១០២,២៦ | ១ ១៩០,៥៣ | ១ ២៩៦,៥៥ |
| តម្រូវការថវិកាក្នុងផែនការយុទ្ធសាស្ត្រ ESP | **៣ ៨១៧ ៨៨៥** | **៤ ១៧៥ ២០៣** | **៤ ៥២៩ ៣៤៩** | **៤ ៨៧៧ ៨៣៨** | **៥ ២៨៩ ៧៦២** |
| *គិតជាលានដុល្លារ* | ៩៤១,៧៦ | ១ ០២៩,៩០ | ១ ១១៧,២៥ | ១ ២០៣,២២ | ១ ៣០៤,៨៣ |
| គម្លាតថវិកា (លានរៀល) | -៣៤ ៥០៥ | -១៤ ១៧៧ | -៦០ ៨០០ | -៥១ ៤២៩ | -៣៣ ៥៤០ |
| *គិតជាលានដុល្លារ* | -៨,៥១ | -៣,៥០ | -១៥,០០ | -១២,៦៩ | -៨,២៧ |
| *កង្វះថវិកា (%)* | -០,៩១% | -០,៣៤% | -១,៣៦% | -១,០៧% | -០,៦៤% |

## ឧបសម្ព័ន្ធទី ៥ ៖ យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨-២០២៣

យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងអប់រំ ផ្តោតលើសមាសធាតុ ៤ គឺ ១)កំណែទម្រង់ការគ្រប់គ្រងការសិក្សា ២)កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល ៣)កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ និង ៤)កំណែទម្រង់ការគ្រប់គ្រង ធនធានមនុស្ស។ សមាសធាតុរងនៃយុទ្ធសាស្ត្រកំណែទម្រង់នីមួយៗមានដូចខាងក្រោម ៖

| **យុទ្ធសាស្ត្រគោលទី ១**<br>យុទ្ធសាស្ត្ររង ១.១ | **កំណែទម្រង់ការគ្រប់គ្រងការសិក្សា**<br>វាយតម្លៃការសិក្សារបស់សិស្សជាប្រចាំ |
|---|---|
| នីតិវិធី | បង្កើនការគាំទ្រគោលនយោបាយរាជរដ្ឋាភិបាលនិងបច្ចេកវិទ្យា និងលើកកម្ពស់សេដ្ឋកិច្ចសង្គមវប្បធម៌សម្រាប់រៀបចំយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងការសិក្សាដើម្បីវាយតម្លៃការសិក្សារបស់សិស្សជាប្រចាំ លើកកម្ពស់ភាពជាពលរដ្ឋមានគុណភាពនៅថ្នាក់ជាតិ និងសកលលោក ដោយផ្តោតលើចំណេះដឹង ជំនាញ និងបំណិនជីវិត ក៏ដូចជាការគោរពច្បាប់និងសណ្តាប់ធ្នាប់សហគមន៍និងការអភិវឌ្ឍប្រកបដោយចីរភាព និងការចូលរួមក្នុងសកម្មភាពនយោបាយ។ |
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ អនុវត្តក្របខណ្ឌវាយតម្លៃ ដែលមានប្រព័ន្ធប្រឡងថ្នាក់ជាតិ នៅថ្នាក់ទី៩ និងទី១២ វង្វាយតម្លៃនៅថ្នាក់ទី៣ ទី៦ ទី៨ និងទី១១ វង្វាយតម្លៃអំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ទី១ ទី២ និងទី៣ វង្វាយតម្លៃថ្នាក់រៀន និងសាលារៀន ក៏ដូចជាប្រព័ន្ធវង្វាយតម្លៃថ្នាក់អន្តរជាតិ (PISA) និងថ្នាក់តំបន់ ដើម្បីវាស់វែងលទ្ធផលសិក្សា និងកែលម្អការបង្រៀននិងរៀន ហើយកំណត់តួនាទី និងភារកិច្ចនៃរចនាសម្ព័ន្ធគ្រប់គ្រងក្នុងការវាយតម្លៃ<br>១.២ ពង្រឹងវង្វាយតម្លៃនៅថ្នាក់ទី៣ ទី៦ ទី៨ និងទី១១ លើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា<br>១.៣ រៀបចំឱ្យមានការចូលរួមក្នុងធ្វើតេស្តថ្នាក់តំបន់ និងអន្តរជាតិ<br>១.៤ កែលម្អគោលការណ៍ណែនាំ ស្តង់ដា និងប្រព័ន្ធពិនិត្យតាមដានការប្រឡងថ្នាក់ជាតិ<br>១.៥ កសាងសមត្ថភាពនិងធ្វើវិមជ្ឈការការទទួលខុសត្រូវលើការប្រឡងថ្នាក់ទី៩ ដល់ថ្នាក់ក្រោមជាតិ<br>១.៦ បង្កើតប្រព័ន្ធលើកទឹកចិត្ត និងការដាក់ពិន័យ ដើម្បីជំរុញការបង្រៀនរបស់គ្រូបង្រៀនឱ្យឆ្លើយតបនឹងស្តង់ដាជាតិ។ |
| | **២. នាយកដ្ឋានធានាគុណភាពអប់រំ**<br>២.១ កសាងសមត្ថភាពបុគ្គលិកអប់រំ ដើម្បីរៀបចំវង្វាយតម្លៃថ្នាក់ជាតិ ថ្នាក់តំបន់ និងអន្តរជាតិ និងវិភាគលទ្ធផលលើអំណានថ្នាក់ដំបូង និងគណិតវិទ្យាថ្នាក់ដំបូង<br>២.២ បង្កើតប្រព័ន្ធវង្វាយតម្លៃ និងការធ្វើតេស្តក្នុងថ្នាក់រៀន<br>២.៣ ធ្វើតេស្តស្តង់ដាថ្នាក់ជាតិលទ្ធផលសិក្សារបស់សិស្សថ្នាក់ទី៣ ទី៦ ទី៨ និងទី១១ តេស្តថ្នាក់តំបន់ និងអន្តរជាតិ<br>២.៤ អនុវត្តការធ្វើការអធិការកិច្ចតាមកាលកំណត់និងតាមប្រធានបទ ដើម្បីលើកកម្ពស់គុណភាពអប់រំ។ |

| | |
|---|---|
| | **៣. នាយកដ្ឋានបឋមសិក្សា**<br>៣.១ សហការជាមួយនាយកដ្ឋានធានាគុណភាពអប់រំ ធ្វើតេស្តអំណានថ្នាក់ដំបូង គណិតវិទ្យាថ្នាក់ដំបូង និង វង្វាយតម្លៃថ្នាក់ទី៣ និងទី៦ លើមុខវិជ្ជាភាសាខ្មែរ និង គណិតវិទ្យា<br>៣.២ ប្រើប្រាស់លទ្ធផលតេស្តអំណានថ្នាក់ដំបូង គណិតវិទ្យាថ្នាក់ដំបូង និងការវាយតម្លៃថ្នាក់ទី៣ និងទី៦ ដើម្បីកែលម្អគោលនយោបាយ និងចាត់វិធានការដោះស្រាយបញ្ហាដែលមានក្នុងរបាយការណ៍តេស្តអំណានថ្នាក់ដំបូង គណិតវិទ្យាថ្នាក់ដំបូង<br>៣.៣ សហការជាមួយនាយកដ្ឋានបណ្តុះបណ្តាល និងសហការជាមួយសាលារៀន វិទ្យាស្ថានគរុកោសល្យ និងសាលាគរុកោសល្យនិងវិក្រឹតការខេត្ត ដើម្បីអនុវត្តស្តង់ដាអំណានថ្នាក់ទី១ និងទី២ និងវិធីសាស្ត្របង្រៀនមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ និងភាសាបរទេស (អង់គ្លេស បារាំង)។ |
| | **៤. នាយកដ្ឋានមធ្យមសិក្សា**<br>៤.១ សហការជាមួយ នា.ធានាគុណភាពអប់រំ ធ្វើការវាយតម្លៃថ្នាក់ទី៨ និងទី១១ លើមុខវិជ្ជាភាសាខ្មែរ គណិតវិទ្យា និងរូបវិទ្យា<br>៤.២ ប្រើលទ្ធផលនៃវង្វាយតម្លៃនៅថ្នាក់ទី៨ និងទី១១ ដើម្បីកែលម្អគោលនយោបាយ។ |
| | **៥. សាលារៀន**<br>៥.១ នាយកសាលាសម្របសម្រួលការវាយតម្លៃសាលារៀនដែលឆ្លើយតបនឹងស្តង់ដា<br>៥.២ នាយកសាលាប្រមូល ចងក្រងទិន្នន័យ និងព័ត៌មាន សម្រាប់រៀបចំ និងបញ្ជូនរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសស្តីពីការវាយតម្លៃការសិក្សារបស់សិស្ស<br>៥.៣ នាយកសាលាប្រមូល ចងក្រងទិន្នន័យ និងព័ត៌មាន សម្រាប់រៀបចំ និងបញ្ជូនរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសស្តីពីការសម្រេចបានសូចនាករផលសម្រេច<br>៥.៤ នាយកសាលាបញ្ចូលលទ្ធផលសិក្សារបស់សិស្សទៅក្នុងរបាយការណ៍សាលារៀន<br>៥.៥ នាយកសាលាលើកទឹកចិត្តដល់មាតាបិតាសិស្សឱ្យតាមដានលទ្ធផលសិក្សារបស់សិស្ស។ |
| | **៦. គណៈកម្មការគ្រប់គ្រងសាលារៀន**<br>គណៈកម្មការគ្រប់គ្រងសាលារៀន ឯកភាពលើលទ្ធផលវាយតម្លៃការអនុវត្តរបស់សាលារៀន និងរបាយការណ៍សមិទ្ធកម្មនៃការសម្រេចបានសូចនាករ និងចំណុចដៅទាក់ទងនឹងលទ្ធផលសិក្សារបស់សិស្ស។ |
| | **៧. គ្រូបង្រៀន**<br>៧.១ គ្រូបង្រៀនប្រើប្រាស់វិធីសាស្ត្របង្រៀនថ្មីៗ ដើម្បីបង្កើនលទ្ធផលសិក្សារបស់សិស្ស រួមមានការសិក្សាគម្រោង ដែលទាក់ទងទៅនឹងមុខវិជ្ជាអាទិភាពសម្រាប់សិស្ស ធ្វើជាបុគ្គល ដៃគូ ឬជាក្រុម<br>៧.២ គ្រូបង្រៀនរៀបចំតេស្តចំណេះដឹង និងបំណិនរបស់សិស្ស ឱ្យមានសង្គតិភាពជាមួយនឹងក្របខណ្ឌវង្វាយតម្លៃជាតិ<br>៧.៣ គ្រូបង្រៀនជួយសិស្សរៀនយឺតជាប្រចាំ និងរៀបចំវិធីសាស្ត្របង្រៀន និងប្រព័ន្ធវាយតម្លៃ |

| | |
|---|---|
| | ៧.៤ គ្រូបង្រៀនលើកទឹកចិត្តសិស្សផ្ទើម។ |
| | **៨. សិស្ស**<br>ជាលទ្ធផល សិស្សនឹងមានសមត្ថភាពដូចខាងក្រោម៖<br>- ចេះអាន សរសេរ និងនិយាយបានត្រឹមត្រូវ<br>- ចេះគិតលេខ និងបង្ហាញការយល់ដឹងលើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រ<br>- ចេះគិត វិភាគស៊ីជម្រៅដោយខ្លួនឯង ប្រកបដោយការច្នៃប្រឌិត និងចេះដោះស្រាយបញ្ហា<br>- មានភាពជាម្ចាស់ និងទំនួលខុសត្រូវ<br>- គោរពអ្នកដទៃ រក្សាសេចក្តីថ្លៃថ្នូរ និងមានសីលធម៌ខ្ពស់<br>- ចូលរួមថែរក្សាបរិស្ថាន និងអនាម័យសាលារៀន<br>- ធ្វើការយ៉ាងមានប្រសិទ្ធភាពដោយខ្លួនឯង និងក្រុម<br>- ចូលរួមសកម្មភាពកីឡា<br>- អភិវឌ្ឍជំនាញសិល្បៈ និងតន្ត្រី។ |

| | |
|---|---|
| **យុទ្ធសាស្ត្រគោលទី ១**<br>យុទ្ធសាស្ត្ររង ១.២ | **កំណែទម្រង់ការគ្រប់គ្រងការសិក្សា**<br>កែលម្អវិធីសាស្ត្របង្រៀន |
| នីតិវិធី | បង្កើនការគាំទ្រគោលនយោបាយរាជរដ្ឋាភិបាល និងលើកកម្ពស់សេដ្ឋកិច្ចនិងបច្ចេកវិទ្យា សម្រាប់រៀបចំយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងការសិក្សា ក្នុងការកែលម្អវិធីសាស្ត្របង្រៀនដើម្បីលើកកម្ពស់ភាពជាពលរដ្ឋមានគុណភាពទាំងថ្នាក់ជាតិ និងសកលលោក។ |
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ អនុវត្តសេចក្តីណែនាំស្តីពីវិធីសាស្ត្របង្រៀនគ្រប់កម្រិតសិក្សារួមមាន មត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សា ក្នុងគោលបំណង ផលិតធនធានមនុស្សដែលមានសមត្ថភាពវិភាគគិតស៊ីជម្រៅ ដោះស្រាយបញ្ហា និងធ្វើការជាមួយគ្នា<br>១.២ អនុម័តសេចក្តីណែនាំស្តីពីការគ្រប់គ្រងថ្នាក់<br>១.៣ អនុម័ត និងអនុវត្តផែនការសកម្មភាពគោលនយោបាយស្តីពីបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងការអប់រំ និងផ្តល់ធនធានសម្រាប់រៀបចំហេដ្ឋារចនាសម្ព័ន្ធ និងគាំទ្របច្ចេកទេសដល់សាលារៀន គ្រូបង្រៀន និងការបណ្តុះបណ្តាលគ្រូបង្រៀន<br>១.៤ រៀបចំកម្មវិធីណែនាំគ្រូ ដើម្បីជួយដល់គ្រូបង្រៀនចេញថ្មី<br>១.៥ ណែនាំវិធីសាស្ត្រការរៀនផ្អែកលើគម្រោង សិស្សមជ្ឈមណ្ឌល និងវិធីសាស្ត្របង្រៀនតាមបែបរិះរក<br>១.៦ អនុវត្តស្តង់ដាអំណាន និងវិធីសាស្ត្របង្រៀនថ្នាក់ទី១ និងទី២ និងវិធីសាស្ត្រអានក្នុងបណ្ណាល័យ<br>១.៧ បញ្ចូលបច្ចេកវិទ្យាព័ត៌មាន ក្នុងការបង្រៀន<br>១.៨ កសាងសមត្ថភាពអង្គភាពជំនាញ ដើម្បីផ្តល់ការគាំទ្រនិងបណ្តុះបណ្តាលគ្រូបង្រៀន<br>១.៩ បង្កើតគណៈកម្មការអភិវឌ្ឍន៍គ្រូបង្រៀន ដើម្បីវាយតម្លៃគ្រូបង្រៀននិង សម្របសម្រួល |

| | |
|---|---|
| | ការអនុវត្តរបស់សហគមន៍រៀនសូត្រវិជ្ជាជីវៈ ដល់គ្រូបង្រៀន និងសហគមន៍នៃអ្នកអនុវត្ត ដល់នាយកសាលា។ |
| | ២. គណៈកម្មការអភិវឌ្ឍន៍គ្រូបង្រៀន<br>២.១ រៀបចំយន្តការអនុវត្ត និងគាំទ្រដល់ការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំជាប្រចាំ នៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ដោយផ្តោតលើការបណ្តុះបណ្តាលនៅនឹងកន្លែង<br>២.២ កំណត់ពេលវេលាជាក់លាក់ ដើម្បីធ្វើវិក្រឹតការគ្រូបង្រៀន<br>២.៣ រៀបចំប្រព័ន្ធវាយតម្លៃនិងទទួលស្គាល់ដល់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូលើសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈ ដើម្បីទទួលស្គាល់ជាផ្លូវការ ឬផ្តល់សញ្ញាបត្រសមមូល<br>២.៤ រៀបចំប្រព័ន្ធអភិវឌ្ឍគុណវុឌ្ឍិបុគ្គលិកអប់រំគ្រប់រូបភាព(បំប៉ននៅនឹងកន្លែង កម្មវិធីពន្លឿន ឬវគ្គបណ្តុះបណ្តាលខ្លីៗ សម្រាប់អ្នកដែលមានសញ្ញាបត្រ)<br>២.៥ រៀបចំនិងអភិវឌ្ឍគោលការណ៍ណែនាំស្តីពីសហគមន៍សិក្សាវិជ្ជាជីវៈ។ |
| | **៣ វិទ្យាស្ថានជាតិអប់រំ និងវិទ្យាស្ថានគរុកោសល្យ**<br>៣.១ កែលម្អការបណ្តុះបណ្តាលគ្រូបង្រៀន ដោយប្រើវិធីសាស្ត្របង្រៀនថ្មីៗ និងការប្រើបច្ចេកវិទ្យាព័ត៌មាន ក្នុងដំណើរការបង្រៀននិងរៀន<br>៣.២ បណ្តុះបណ្តាលដោយផ្អែកលើគម្លាតគុណវុឌ្ឍិរបស់គ្រូបង្រៀនក្នុងវិធីបង្រៀន<br>៣.៣ រៀបចំកម្មវិធីវិក្រឹតការគ្រូបង្រៀនរៀងរាល់ ៥ ឆ្នាំម្តង<br>៣.៤បញ្ចូលវិធីសាស្ត្របង្រៀនថ្មីៗ រួមមានការរៀនសូត្រសកម្ម ការរៀនបែបស្ថាបនា ការរៀនតាមបែបដោះស្រាយបញ្ហា ការរៀនតាមបែបស្រាវជ្រាវ និងការរៀនតាមបែបរិះរក ការគ្រប់គ្រងថ្នាក់រៀនក្នុងកម្មវិធីសិក្សាបណ្តុះបណ្តាលគ្រូបង្រៀន<br>៣.៥ជួយគ្រូថ្មីឱ្យចូលរួមយន្តការអនុវត្តឱ្យបានទៀងទាត់។ |
| | **៤ ក្រុមប្រឹក្សាស្រាវជ្រាវអប់រំ និងអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ**<br>៤.១ ផ្តល់អនុសាសន៍ដល់អ្នករៀបចំគោលនយោបាយ ដើម្បីធ្វើបច្ចុប្បន្នកម្មគោល-នយោបាយអប់រំទាក់ទងនឹងវិធីសាស្ត្របង្រៀន សហគមន៍សិក្សាវិជ្ជាជីវៈ និងសហគមន៍នៃអ្នកអនុវត្ត តាមរយៈអ្នកឯកទេស<br>៤.២ ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ស្ថាប័នស្រាវជ្រាវ និងការផ្សព្វផ្សាយ<br>៤.៣ ស្រាវជ្រាវដើម្បីចងក្រងមានុវត្តន៍ និងនវានុវត្តន៍ នៅក្នុងវិស័យអប់រំ<br>៤.៤ ព្រាងផែនទីបង្ហាញផ្លូវកំណែទម្រង់ និងអនុសាសន៍សម្រាប់កែលម្អគោលនយោបាយកំណែទម្រង់អប់រំ។ |
| | **៥ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ**<br>៥.១ ជួយសាលារៀនក្នុងការបង្កើត សហគមន៍សិក្សាវិជ្ជាជីវៈ និងសហគមន៍នៃអ្នកអនុវត្តសម្រាប់នាយកសាលា និងសង្គមដែលមានជំនាញវិជ្ជាជីវៈ<br>៥.២ ជួយសាលារៀនក្នុងការអនុវត្តគន្លងអាជីពគ្រូបង្រៀន។ |
| | **៦ សាលារៀន**<br>៦.១ ផ្តល់សម្ភារៈសម្រាប់គ្រូដើម្បីផលិតសម្ភារឧបទេស<br>៦.២ បណ្តុះបណ្តាលស្តីពី ការគ្រប់គ្រងមេរៀនប្រកបដោយប្រសិទ្ធភាព ការគ្រប់គ្រង |

| | |
|---|---|
| | ថ្នាក់រៀន និងការផ្តល់អារម្មណ៍របស់សិស្សក្នុងម៉ោងបង្រៀន<br>៦.៣ ផ្តល់បច្ចេកវិទ្យាដើម្បីឱ្យគ្រូបង្រៀនប្រើបច្ចេកវិទ្យាក្នុងការអនុវត្តវិធីសាស្ត្របង្រៀនថ្មីៗ។ |
| | **៧ គ្រូបង្រៀន**<br>៧.១ ទទួលបានការបំប៉នលើវិធីសាស្ត្របង្រៀនថ្មី<br>៧.២ ផលិតសម្ភារៈជំនួយការបង្រៀន និងអនុវត្តវិធីសាស្ត្របង្រៀនសមស្រប<br>៧.៣ ស្រាវជ្រាវលើវិធីសាស្ត្របង្រៀនដើម្បីកែលម្អគុណភាពការបង្រៀន និងចូលរួមកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈ<br>៧.៤ ផ្លាស់ប្តូរវិធីបង្រៀន ពីការរៀនបែបអកម្មដែលសិស្សជាអ្នករង់ចាំទទួលចំណេះដឹងទៅជាវិធីសាស្ត្រថ្មី ឬ ការរៀនបែបសកម្ម ដែលសិស្សជាអ្នកបង្កើតនូវចំណេះដឹងថ្មីៗ<br>៧.៥ បង្កើតសហគមន៍រៀនវិជ្ជាជីវៈ ដើម្បីចែករំលែកនូវការអនុវត្តល្អៗ ក្នុងការបង្រៀន<br>៧.៦ អនុវត្តបច្ចេកទេសគ្រប់គ្រងថ្នាក់រៀន ដើម្បីដឹងពីស្ថានភាពសិស្សទាំងអស់ច្បាស់លាស់<br>៧.៧ ធានាឱ្យសិស្សចេះប្រើទស្សនៈ ចេះវិភាគ ចេះដោះស្រាយបញ្ហា និងចេះធ្វើការជាក្រុម<br>៧.៨ ប្រើបច្ចេកវិទ្យាព័ត៌មាន (អ៊ីម៉ែល និងអ៊ិនធឺណិត) ដើម្បីលើកកម្ពស់វិធីសាស្ត្ររៀនថ្មី ការរៀនតាមបែបសហការ (ឧទាហរណ៍ បណ្តាញទំនាក់ទំនង) បង្កើតនិងសំយោគព័ត៌មានថ្មីៗ (ឧទាហរណ៍ បទបង្ហាញ) ដោះស្រាយបញ្ហា (ឧទាហរណ៍ កម្មវិធីដំណើរការទិន្នន័យដែលអាចបង្ហាញភាពខុសគ្នា ទិន្នន័យ តម្រៀប។ល។ ) និងវិធីសន្ទនា ការពិភាក្សា និងការជជែកវែកញែក ដែលនាំឱ្យ មានការស្ថាបនាសង្គម<br>៧.៩ អនុវត្តសកម្មភាពសំណួរនិងចម្លើយ ដើម្បីជួយសិស្សឱ្យឆ្លុះបញ្ចាំងពីបទពិសោធន៍ និងបរិបទថ្មីៗ ដើម្បីកសាងនូវគំនិតថ្មីមួយដែលអាចដោះស្រាយបញ្ហាជីវិតជាក់ស្តែង<br>៧.១០ ផ្តោតលើការបង្រៀនជំនាញការគិតនៅកំពូលទ្រឹស្តី Bloom រួមមានការវិភាគ ការសំយោគ និងការវាយតម្លៃ រំញោចសិស្សឱ្យផ្លាស់ប្តូរគំនិត តាមរយៈការពិភាក្សា លើកទឹកចិត្តសិស្សឱ្យចេះសំយោគគំនិតតែមួយគត់<br>៧.១១ លើកទឹកចិត្តសិស្សឱ្យរៀបចំបទបង្ហាញជាក្រុម ដែលផ្តល់សារៈប្រយោជន៍ដល់សិស្សធ្វើការជាមួយគ្នា ប្រកបដោយភាពច្នៃប្រឌិត និងចែករំលែកដល់សិស្សក្នុងថ្នាក់។ |

| **យុទ្ធសាស្ត្រគោលទី១**<br>យុទ្ធសាស្ត្ររង ១.៣ | **កំណែទម្រង់ការគ្រប់គ្រងការសិក្សា**<br>ដាក់បញ្ចូលភាពជាពលរដ្ឋមានគុណភាពក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល |
|---|---|
| នីតិវិធី | បង្កើនការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល និងលើកកម្ពស់សេដ្ឋកិច្ច បច្ចេកវិទ្យាសម្រាប់រៀបចំយុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងការសិក្សា ដោយដាក់ខ្លឹមសារភាពជាពលរដ្ឋល្អក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល សំដៅលើកកម្ពស់ភាពជាពលរដ្ឋមានគុណភាពទាំងថ្នាក់ជាតិ និងសកលលោក។ |
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ អនុវត្តក្របខណ្ឌកម្មវិធីសិក្សាជាតិ និងរៀបចំកម្មវិធីសិក្សាលម្អិត<br>១.២ អនុវត្តកម្មវិធីសិក្សាលម្អិត និងស្តង់ដាភាពជាពលរដ្ឋល្អ<br>១.៣ បញ្ចូលការអប់រំភាពជាពលរដ្ឋល្អ រួមមានភាពជាពលរដ្ឋកម្ពុជា និងភាពជាពលរដ្ឋ |

| | |
|---|---|
| | សកល ក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល<br>១.៤ រៀបចំសៀវភៅសិក្សាស្របតាមកម្មវិធីសិក្សាលម្អិត<br>១.៥ ផ្គត់ផ្គង់សៀវភៅសិក្សាគោលដល់សាលារៀនឱ្យបានគ្រប់គ្រាន់<br>១.៦ រៀបចំក្រុមប្រឹក្សាអាជីពនៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស<br>១.៧ ផ្តល់ធនធានថវិកាបន្ថែម សម្ភារៈបង្រៀន និងបំប៉នសមត្ថភាពគ្រូបង្រៀន និងនាយក ដើម្បីអនុវត្តកម្មវិធីសិក្សាថ្មី និងប្រើប្រាស់សៀវភៅសិក្សាគោល<br>១.៨ ផ្តល់ឱកាស និងគាំទ្រគ្រូបង្រៀនក្នុងការកសាងសមត្ថភាពដើម្បីអនុវត្តកម្មវិធីសិក្សាថ្មី និងសៀវភៅសិក្សាគោល<br>១.៩ បង្កើតគណៈកម្មការគ្រប់គ្រងសៀវភៅសិក្សាគោល<br>១.១០ ផ្តល់សៀវភៅសិក្សាគោលឱ្យបានគ្រប់គ្រាន់ដល់គ្រឹះស្ថានសិក្សា តាមមុខវិជ្ជា និងតាមកម្រិតថ្នាក់។ |
| | **២. នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ**<br>២.១ ធានាការអនុវត្តស្តង់ដាគុណវុឌ្ឍិគ្រូបង្រៀន ស្តង់ដានាយកសាលា ស្តង់ដាគ្រូឧទ្ទេស និងស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន<br>២.២ ពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំ លើការផ្តល់សេវាបណ្តុះបណ្តាលគ្រូបង្រៀនតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនទាំងអស់។ |
| | **៣. វិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ**<br>៣.១ រៀបចំកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនលម្អិត ស្របតាមកម្មវិធីសិក្សាថ្មី<br>៣.២ បណ្តុះបណ្តាលគ្រូឧទ្ទេស ផ្តោតលើបញ្ហាសកល<br>៣.៣ បណ្តុះបណ្តាលគរុសិស្ស និងគរុនិស្សិតស្របតាមកម្មវិធីសិក្សាថ្មី និងសៀវភៅសិក្សាគោល ដែលបានបញ្ជ្រាបភាពជាពលរដ្ឋកម្ពុជាល្អ និងភាពជាពលរដ្ឋសកលល្អនៅតាមវិទ្យាស្ថានគរុកោសល្យ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងវិក្រឹតការខេត្ត<br>៣.៤ បណ្តុះបណ្តាលគ្រូបង្រៀន ស្តីពីការប្រើប្រាស់កម្មវិធីសិក្សាថ្មី កម្មវិធីសិក្សាលម្អិត ស្តង់ដាលទ្ធផលសិក្សា និងសៀវភៅសិក្សាគោល ដើម្បីរៀបចំ (១) សកម្មភាពបង្រៀន និង (២) កិច្ចតែងការបង្រៀន ដើម្បីធានាការសិក្សារបស់សិស្ស តាមរយៈវិធីសាស្ត្រសកម្ម និងការងារគម្រោង។ |
| | ៤. សាលារៀន<br>៤.១ រៀបចំបន្ទប់ឧបករណ៍បច្ចេកវិទ្យា ដូចជាម៉ាស៊ីនបញ្ចាំង (LCD) កុំព្យូទ័រ និងសម្ភារបង្រៀនផ្សេងៗទៀត ដើម្បីបញ្ជ្រាបភាពជាពលរដ្ឋមានគុណភាពក្នុងការបង្រៀន<br>៤.២ កែលម្អបណ្ណាល័យឱ្យស្របតាមស្តង់ដាបណ្ណាល័យសតវត្សទី ២១ ដើម្បីផ្តល់ឱកាសដល់សិស្សសិក្សារៀនសូត្រ ស្រាវជ្រាវ និងជួយដល់ការវិភាគកាន់តែស៊ីជម្រៅ<br>៤.៣ រៀបចំប្រព័ន្ធគ្រប់គ្រងសៀវភៅសិក្សាគោលឱ្យមានប្រសិទ្ធភាព ដើម្បីធានាថាគ្រប់សិស្សទាំងអស់មាន សៀវភៅសិក្សាគោលសម្រាប់រៀនសូត្រតាមមុខវិជ្ជា និងតាមកម្រិតថ្នាក់។ |

| | |
|---|---|
| | **៥. គ្រូបង្រៀន**<br>៥.១ កែលម្អវិធីសាស្ត្របង្រៀន ដូចជាការដើរតួ ដើម្បីធានាថាសិស្សទទួលបានចំណេះដឹងលើបញ្ហាសកល<br>៥.២ ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងឧបករណ៍ឌីជីថល ដើម្បីអនុវត្តកម្មវិធីសិក្សាភាពជាពលរដ្ឋមានគុណភាពនៅក្នុងថ្នាក់រៀន<br>៥.៣ បង្រៀនបែបសិក្សាគម្រោង និងបំផុសគំនិត ឱ្យអនុវត្តកម្មវិធីសិក្សា ភាពជាពលរដ្ឋមានគុណភាព<br>៥.៤ លើកទឹកចិត្តសិស្សឱ្យរៀបចំសម្ភារៈសិក្សា ស្របតាមបរិបទភាពជាពលរដ្ឋ មានគុណភាព ដែលត្រូវធ្វើបទបង្ហាញដែលមានរូបភាព ក្រាហ្វិច គំនូសតាង និងដ្យាក្រាម<br>៥.៥ រៀបចំការប្រឡងសំណេរក្រោមប្រធានបទពាក់ព័ន្ធនឹងបញ្ហាប្រឈមនានា លើភាពជាពលរដ្ឋប្រកបដោយគុណភាព |

| | |
|---|---|
| **យុទ្ធសាស្ត្រគោលទី ២**<br>យុទ្ធសាស្ត្រង ២.១ | **កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល**<br>ធានាការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍មូលដ្ឋាន |
| **នីតិវិធី** | បង្កើនការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល និងលើកកម្ពស់សេដ្ឋកិច្ច សង្គម វប្បធម៌ និងបច្ចេកវិទ្យាដើម្បីរៀបចំយុទ្ធសាស្ត្រសម្រាប់ធានាការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រងសាលារៀន ដើម្បីលើកកម្ពស់ភាពជាពលរដ្ឋមានគុណភាពកម្រិតជាតិ និង សកលលោក ជាពិសេសផ្តោតលើចំណេះដឹង ជំនាញ និងបំណិនជីវិតដូចជា ការគោរពច្បាប់និងសណ្តាប់ធ្នាប់ សហគមន៍និងការអភិវឌ្ឍប្រកបដោយចីរភាព និងការចូលរួមក្នុងសកម្មភាពនយោបាយ។ |
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ ប្រែក្លាយគណៈកម្មការទ្រទ្រង់សាលារៀនទៅជាគណៈកម្មការគ្រប់គ្រងសាលារៀន ដើម្បីធានាឱ្យមានការចូលរួមកាន់តែច្រើនពីអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងសាលារៀន<br>១.២ រៀបចំនិងអនុម័តតួនាទីនិងភារកិច្ចរបស់គណៈកម្មការគ្រប់គ្រងសាលារៀន រួមទាំងតួនាទីនៅសាលារៀននិងថ្នាក់រៀន ក្នុងការពិនិត្យតាមដាននិងការផ្តល់ព័ត៌មានត្រឡប់<br>១.៣ អនុញ្ញាតិឱ្យមាតាបិតាសិស្សនិងសហគមន៍ប្រមូលមូលនិធិបន្ថែម និងពិនិត្យតាមដានការអនុវត្តរបស់សាលារៀននិងថ្នាក់រៀន ទៅតាមប្រតិទិនការងារសាលារៀន ម៉ោងចូលនិងចេញ ជាពិសេសវត្តមានរបស់គ្រូបង្រៀន<br>១.៤ អនុម័តសៀវភៅណែនាំស្តីពី ការគ្រប់គ្រងតាមសាលារៀន ដែលផ្តល់ឱកាសដល់មាតាបិតាសិស្ស សហគមន៍ និងអាជ្ញាធរមូលដ្ឋាន ដើម្បីបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន<br>១.៥ រៀបចំវគ្គបំប៉នស្តីពី ការគ្រប់គ្រងតាមសាលារៀន ដល់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត វិទ្យាស្ថានគរុកោសល្យ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ សាលាគរុកោសល្យនិងវិក្រឹតការខេត្ត |

| | |
|---|---|
| | ១.៦ ផ្សព្វផ្សាយគោលនយោបាយស្តីពី ការគ្រប់គ្រងតាមសាលារៀនដល់សហគមន៍ និងអាជ្ញាធរមូលដ្ឋាន។ |
| | **២. មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត**<br>បំប៉នការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ស្តីពី ការគ្រប់គ្រងតាមសាលារៀន ដោយផ្តោតលើការទទួលខុសត្រូវរបស់មាតាបិតាសិស្ស អាជ្ញាធរមូលដ្ឋាន និងសហគមន៍ចូលរួមក្នុងការគ្រប់គ្រងសាលារៀន។ |
| | **៣. សាលារៀន**<br>៣.១ នាយកសាលាផ្តួចផ្តើមបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន និងលើកទឹកចិត្តសហគមន៍ឱ្យចូលរួមក្នុងការគ្រប់គ្រងសាលារៀន<br>៣.២ នាយកសាលារៀបចំបរិយាកាសការងារនៅក្នុងប្រព័ន្ធគ្រប់គ្រងសាលារៀន ដើម្បីបង្កើនភាពជឿទុកចិត្ត និងការសហការ<br>៣.៣ សាលារៀនគ្រោងថវិកាសម្រាប់គាំទ្រជំនួបរវាងមាតាបិតាសិស្សនិងសហគមន៍មូលដ្ឋានជាមួយគ្រូបង្រៀននិងគាំទ្រសកម្មភាពប្រជុំក្រុមប្រឹក្សាកុមារ យុវជន។ |
| | **៤. គណៈកម្មការគ្រប់គ្រងសាលារៀន**<br>៤.១ រៀបចំនិងអនុម័តផែនការអភិវឌ្ឍសាលារៀននិងផែនការអភិវឌ្ឍថ្នាក់រៀន ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់រួមទាំងក្រុមប្រឹក្សាកុមារ យុវជន<br>៤.២ ប្រមូលផ្តុំធនធានបន្ថែមសម្រាប់ការអនុវត្តផែនការអភិវឌ្ឍសាលារៀន និងផែនការអភិវឌ្ឍថ្នាក់រៀន<br>៤.៣ ពិនិត្យឡើងវិញការបំពេញការងាររបស់សាលារៀន និងតម្លាភាព<br>៤.៤ រៀបចំកិច្ចប្រជុំទៀងទាត់ជាមួយមាតាបិតាសិស្ស និងចុះតាមខ្នងផ្ទះ។ |
| | **៥. គ្រូបង្រៀន**<br>ចូលរួមកិច្ចប្រជុំជាទៀងទាត់ជាមួយមាតាបិតាសិស្សនិងសហគមន៍មូលដ្ឋាន ដើម្បីកិច្ចសហការគាំទ្រ។ |
| | **៦. សិស្ស**<br>រៀបចំកិច្ចប្រជុំជាទៀងទាត់ជាមួយអ្នកពាក់ព័ន្ធ និងបង្ហាញទស្សនៈ ចំពោះគណៈកម្មការគ្រប់គ្រងសាលារៀនលើវិធីកែលម្អការផ្តល់សេវាអប់រំដល់សិស្ស។ |

| | |
|---|---|
| **យុទ្ធសាស្ត្រទី ២**<br>យុទ្ធសាស្ត្ររង ២.២ | **កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល**<br>អនុវត្តការគ្រប់គ្រងតាមសាលារៀន |
| នីតិវិធី | បង្កើនការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល និងលើកកម្ពស់សេដ្ឋកិច្ច សង្គម វប្បធម៌ និងបច្ចេកវិទ្យាដើម្បីបង្កើតយុទ្ធសាស្ត្រសម្រាប់ចៀសវាងការគំរាមកំហែង និងពង្រឹងភាពខ្លាំងនៃការអនុវត្តការគ្រប់គ្រងតាមសាលារៀន ដើម្បីលើកកម្ពស់ភាពជាពលរដ្ឋមានគុណភាពនៅកម្រិតជាតិ។ |

| | |
|---|---|
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ អនុម័តគោលនយោបាយ ក្របខណ្ឌ និងគោលការណ៍ណែនាំស្ដីពី ការគ្រប់គ្រងតាមសាលារៀន<br>១.២ ដាក់បញ្ចូលការគ្រប់គ្រងតាមសាលារៀន ទៅក្នុងកម្មវិធីបណ្តុះបណ្តាលនាយកសាលា និងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន<br>១.៣ បង្កើតរូបមន្តហិរញ្ញប្បទានសម្រាប់ការគ្រប់គ្រងតាមសាលារៀន<br>១.៤ បង្កើតក្របខណ្ឌទស្សនាទានស្តីពី គណនេយ្យភាពក្នុងការអប់រំ<br>១.៥ បំពេញតម្រូវការមូលដ្ឋានដល់សាលារៀន ដូចជាភាពជាអ្នកដឹកនាំនិងការគ្រប់គ្រង សមត្ថភាពបង្រៀននិងរៀន សម្ភារៈបង្រៀននិងរៀនត្រឹមត្រូវ និងហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានត្រឹមត្រូវ<br>១.៦ អភិវឌ្ឍយន្តការពិនិត្យតាមដាននិងវាយតម្លៃការគ្រប់គ្រងតាមសាលារៀន ជាពិសេសការធ្វើអធិការកិច្ចសាលារៀនជាប្រចាំ<br>១.៧ កសាងសមត្ថភាពដល់នាយកសាលាដើម្បីផ្តល់ការគាំទ្រផ្នែករដ្ឋបាល និងបច្ចេកទេសដល់គ្រូបង្រៀនក្នុងដំណើរការបង្រៀននិងរៀន<br>១.៨ ធានាការតែងតាំងនាយកសាលា ឆ្លើយតបនឹងស្តង់ដានាយកសាលារៀន<br>១.៩ រៀបចំនិងអនុម័តសៀវភៅណែនាំស្តីពី វិធីសាស្ត្រគ្រប់គ្រង ដោយអនុលោមតាមសាលារៀនល្អដែលត្រូវបានអនុម័តជាសាលារៀនគំរូ ដែលអាចជួយសាលារៀនទន់ខ្សោយ<br>១.១០ ផ្តល់ថវិកាដល់សាលារៀនល្អ សម្រាប់គាំទ្រ និងជួយដល់សាលារៀនដែលទន់ខ្សោយ ដើម្បីឱ្យឆ្លើយតបនឹងស្តង់ដាប្រសិទ្ធភាព។ |
| | **២. អគ្គនាយកដ្ឋានអប់រំ**<br>២.១ គាំទ្រនិងពង្រីកការអនុវត្តសាលារៀនជំនាន់ថ្មី និងសាលារៀនប្រសិទ្ធភាព<br>២.២ បង្កើតនិងពង្រីកកញ្ចប់ថវិកាសម្រាប់បណ្តុះបណ្តាលនាយកសាលាលើការគ្រប់គ្រងតាមសាលារៀន<br>២.៣ រៀបចំកម្មវិធីបំប៉ននៅតាមសាលារៀនស្តីពី ការគ្រប់គ្រងតាមសាលារៀន។ |
| | **៣. វិទ្យាស្ថានជាតិអប់រំ និងវិទ្យាស្ថានគរុកោសល្យ**<br>៣.១ បណ្តុះបណ្តាលស្តីពីការគ្រប់គ្រងតាមសាលារៀន ដល់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត និងនាយកសាលា<br>៣.២ បណ្តុះបណ្តាលស្តីពីការគ្រប់គ្រងតាមសាលារៀន ដល់ការិយាល័យអប់រំ យុវជន និង កីឡាក្រុង ស្រុក ខណ្ឌ។ |
| | **៤. សាលារៀន**<br>៤.១ នាយកសាលាសម្របសម្រួលជាមួយគណៈកម្មការគ្រប់គ្រងសាលារៀន ដើម្បីរៀបចំផែនការអភិវឌ្ឍន៍សាលារៀនរយៈពេល ៥ឆ្នាំ និងប្រចាំឆ្នាំ ដោយកំណត់សូចនាករធាតុចូល ធាតុចេញ និងផលសម្រេច ព្រមទាំងប្រភពហិរញ្ញប្បទាន ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ |

| | |
|---|---|
| | ៤.២ នាយកសាលាសម្របសម្រួលការរៀបចំសូចនាករផលសម្រេច និងចំណុចដៅរយៈពេល ៥ឆ្នាំ និង ផែនការកែលម្អសាលារៀននិងថវិកា<br>៤.៣ នាយកសាលាបញ្ជូនលទ្ធផលនៃការវាយតម្លៃលទការបំពេញការងាររបស់សាលារៀនដែលឆ្លើយតបនឹងស្តង់ដាសាលារៀនមានប្រសិទ្ធភាព ដល់គណៈកម្មការគ្រប់គ្រងសាលារៀន<br>៤.៤ នាយកសាលារៀបចំ និងសម្របសម្រួលសកម្មភាពប្រមូលមូលនិធិសម្រាប់អភិវឌ្ឍសាលារៀន<br>៤.៥ នាយកសាលាប្រមូលព័ត៌មានជាក់ស្តែង ពីការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សការវាយតម្លៃសមត្ថភាពរបស់គ្រូបង្រៀន និងការវាយតម្លៃការអនុវត្តរបស់សាលារៀន<br>៤.៦ សាលារៀនបង្កើតវប្បធម៌នៃការចែករំលែកព័ត៌មានដោយកំណត់បញ្ហាប្រឈមរួមគ្នាជាមួយភាគីពាក់ព័ន្ធសំខាន់ៗ ដើម្បីបង្កើនការជឿទុកចិត្តពីសហគមន៍បុគ្គលិកសាលារៀន និងមាតាបិតាសិស្សទៅលើគ្រូបង្រៀន និងសាលារៀន<br>៤.៧ សាលារៀនរៀបចំផែនការ គ្រោងថវិកា រៀបចំរបាយការណ៍ និងគ្រប់គ្រងការបំពេញ ការងាររបស់បុគ្គលិក<br>៤.៨ សាលារៀនអនុវត្តកម្មវិធីសិក្សាតាមការណែនាំ និងកម្មវិធីសិក្សាបន្ថែម<br>៤.៩ នាយកសាលាអនុវត្តប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងស្នើរង្វាន់ដល់បុគ្គលិកដែលបំពេញការងារបានល្អ ព្រមទាំងស្នើវិធានការរដ្ឋបាលសម្រាប់បុគ្គលិក អសកម្មការងារ<br>៤.១០ សាលារៀនផ្សព្វផ្សាយទិន្នន័យនិងព័ត៌មានរបស់សាលារៀនដល់សហគមន៍និងអាជ្ញាធរមូលដ្ឋាន។ |
| | **៥. គណៈកម្មការគ្រប់គ្រងសាលារៀន**<br>៥.១ គាំទ្រដល់ការបង្រៀន និងការរៀន ព្រមទាំងប្រមូលធនធាន និងរៀបចំរបាយការណ៍វាយតម្លៃសាលារៀន<br>៥.២ អនុម័តលើសូចនាករផលសម្រេចនិងចំណុចដៅរយៈពេល ៣ ឆ្នាំ ផែនការអភិវឌ្ឍសាលារៀនប្រចាំឆ្នាំនិងថវិកា វាយតម្លៃលទ្ធផលរបស់សាលារៀនធៀបនឹងស្តង់ដាសាលារៀន និង គាំទ្រនិងចូលរួមប្រមូលមូលនិធិសាលា<br>៥.៣ ឯកភាពលើរង្វាន់សម្រាប់បុគ្គលិកឆ្នើម ស្នើចាត់វិធានការរដ្ឋបាលចំពោះបុគ្គលិកអសកម្មទៅថ្នាក់ក្រោមជាតិនិងថ្នាក់ជាតិ និងឯកភាពលើការផ្តល់រង្វាន់ដល់នាយកឆ្នើម<br>៥.៤ អនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ និងរបាយការណ៍វឌ្ឍនភាព។ |

| **យុទ្ធសាស្ត្រទី ២**<br>យុទ្ធសាស្ត្រទី២.៣ | **កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល**<br>អនុវត្តគោលនយោបាយអប់រំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
|---|---|
| នីតិវិធី | ពង្រឹងគោលនយោបាយរាជរដ្ឋាភិបាលនិងសេដ្ឋកិច្ច និងបង្កើនការគាំទ្រដល់សង្គមវប្បធម៌ និងបច្ចេកវិទ្យា សម្រាប់រៀបចំយុទ្ធសាស្ត្រអនុវត្តគោលនយោបាយវិស័យអប់រំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ដើម្បីលើកកម្ពស់ភាពជាពលរដ្ឋជាតិនិងសកលប្រកបដោយគុណភាព។ |

| | |
|---|---|
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ ធ្វើបច្ចុប្បន្នកម្មគោលនយោបាយអប់រំឱ្យមានសង្គតិភាពទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤<br>១.២ រៀបចំផែនទីបង្ហាញផ្លូវ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ ស្តីពីការអប់រំនៅកម្ពុជា និង ឆ្លុះបញ្ចាំងពីចំណុចសំខាន់ៗនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣<br>១.៣ ខិតខំប្រឹងប្រែងអនុវត្តគោលនយោបាយសំខាន់ៗពីរ៖ (១) ធានាការអប់រំឱ្យមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា (២) ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់<br>១.៤ សម្របសម្រួលការអនុវត្តសូចនាករស្នូល និងសូចនាករផលសម្រេចតាមអនុវិស័យ<br>១.៥ ពិនិត្យតាមដាន និងពិនិត្យឡើងវិញការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំដោយផ្តោតលើការបំពេញការងារ ការអនុវត្តយុទ្ធសាស្ត្រ កម្មវិធី អនុកម្មវិធី និងកត្តាពាក់ព័ន្ធផ្សេងទៀត ដែលជាធាតុចូលសម្រាប់វិស័យអប់រំ<br>១.៦ ពង្រឹងប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃ ដើម្បីធានាសង្គតិភាពអាទិភាព និងលើកកម្ពស់ការអនុវត្តកម្មវិធីកំណែទម្រង់អាទិភាព ដោយកំណត់តួនាទីនិងភារកិច្ចលើការពិនិត្យតាមដាននិងវាយតម្លៃនៅគ្រប់កម្រិត<br>១.៧ ធានាថាគោលនយោបាយអប់រំ និងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ នាំមកនូវធនធានមនុស្សដែលមានសមត្ថភាពខ្ពស់ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ដោយពង្រឹងគុណភាពអប់រំគ្រប់កម្រិតទាំងអស់ និងលើកកម្ពស់ការអនុវត្តកម្មវិធីសិក្សាដោយរួមបញ្ចូលជំនាញទន់ រួមមានជំនាញទំនាក់ទំនងសង្គម បំណិនដោះស្រាយបញ្ហា ការងារក្រុម ការគោរពចំពោះវិន័យការងារ និងជំនាញបច្ចេកទេស ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍគ្រឹះឧស្សាហកម្ម<br>១.៨ អនុវត្តសសរស្តម្ភ ៥ នៃកំណែទម្រង់ការគ្រប់គ្រងអប់រំរួមមាន៖<br>- ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន និងផែនការសកម្មភាពអភិវឌ្ឍបុគ្គលិកអប់រំ ដោយគ្រោងថវិកាច្បាស់លាស់<br>- ការពិនិត្យតាមដាន និងអធិការកិច្ចសាលារៀន<br>- វង្វាយតម្លៃលទ្ធផលសិក្សា<br>- ការពិនិត្យឡើងវិញកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងកែលម្អហេដ្ឋារចនាសម្ព័ន្ធសាលារៀន<br>- កំណែទម្រង់ឧត្តមសិក្សា<br>១.៩ កសាងសមត្ថភាពលើភាពជាអ្នកដឹកនាំនិងការគ្រប់គ្រង ដោយផ្តោតលើគ្រឹះស្ថានអប់រំសាធារណៈ និងការចូលរួមពីអាជ្ញាធរមូលដ្ឋាន មាតាបិតាសិស្ស អ្នកអាណាព្យាបាលសិស្ស និងអ្នកពាក់ព័ន្ធទាំងអស់ |

| | |
|---|---|
| | ១.១០ ជានាថាអង្គភាពជំនាញនៅគ្រប់កម្រិត និងអធិការអប់រំ ផ្តល់ការគាំទ្រផ្នែករដ្ឋបាលនិងបច្ចេកទេសដល់សាលារៀនក្នុងដំណើរការបង្រៀននិងរៀនដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស<br>១.១១ វិភាគលើតម្រូវការសមត្ថភាពស្ថាប័ននិងវិជ្ជាជីវៈ ដើម្បីអនុវត្តរបៀបវារៈអប់រំឆ្នាំ២០៣០ នៅកម្ពុជា។ |
| | **២. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**<br>រៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ថ្នាក់រាជធានី ខេត្ត ស្របតាមគោលនយោបាយអប់រំនិងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ថ្នាក់ជាតិ |
| | **៣. សាលារៀន**<br>៣.១ រៀបចំផែនការអភិវឌ្ឍន៍សាលារៀនរយៈពេល ៥ ឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំដោយមានការចូលរួមពី គណៈគ្រប់គ្រងសាលា គ្រូបង្រៀន មាតាបិតាសិស្ស និងសហគមន៍<br>៣.២ លើកទឹកចិត្តឱ្យសហគមន៍ចូលរួមក្នុងការគ្រប់គ្រងសាលារៀន និងធានាការពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀនរយៈពេល ៥ឆ្នាំ ផែនការប្រតិបត្តិប្រចាំឆ្នាំ និងគោលនយោបាយអប់រំ ដើម្បី ៖<br>- ពង្រីកសេវាអប់រំឱ្យបានដល់ក្រុមកុមារងាយរងគ្រោះ និងកុមារជនជាតិភាគតិច<br>- កែលម្អគុណភាពសេវាអប់រំ<br>- បង្កើនអត្រាចូលរៀននិងអត្រាបញ្ចប់ការសិក្សានៅគ្រប់កម្រិត<br>- កាត់បន្ថយអត្រាបោះបង់ការសិក្សា និងអត្រាត្រួតថ្នាក់ ជាពិសេសនៅកម្រិតមធ្យមសិក្សា។ |
| | **៤. គ្រូបង្រៀន**<br>៤.១ កែលម្អវិធីសាស្ត្របង្រៀន ដោយផ្សារភ្ជាប់ការបង្រៀនទៅនឹងទស្សនកិច្ច ដើម្បីឱ្យសិស្សយល់ច្បាស់ពីបរិយាកាសជុំវិញនិងគោលបំណងនៃការអភិវឌ្ឍប្រកបដោយចីរភាព<br>៤.២ រៀបចំការប្រជុំទៀងទាត់ដល់គ្រូបង្រៀនតាមមុខវិជ្ជា ដើម្បីធ្វើថ្នាក់និទស្សន៍ ដោយផ្តោតលើវិធីសាស្ត្របង្រៀន។ |

| | |
|---|---|
| **យុទ្ធសាស្ត្រគោលទី៣**<br>យុទ្ធសាស្ត្រវង ៣.១ | **កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ**<br>បង្កើនស្វ័យភាពនិងគណនេយ្យភាពហិរញ្ញវត្ថុនៅសាលារៀន |
| នីតិវិធី | បង្កើនការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនិងបច្ចេកវិទ្យា និងលើកកម្ពស់សេដ្ឋកិច្ចនិងសង្គម វប្បធម៌ ដោយរៀបចំយុទ្ធសាស្ត្រវងសម្រាប់បង្កើន ស្វ័យភាពនិងគណនេយ្យភាពហិរញ្ញវត្ថុរបស់សាលារៀន ដើម្បីលើកកម្ពស់ ភាពជាពលរដ្ឋមានគុណភាពដោយផ្តោតលើចំណេះដឹង ជំនាញ និងបំណិនជីវិត ក៏ដូចជាការគោរពច្បាប់និងសណ្តាប់ធ្នាប់ សហគមន៍និងការអភិវឌ្ឍប្រកបដោយចីរភាព និងការចូលរួមក្នុងសកម្មភាពនយោបាយ។ |

| | |
|---|---|
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ រៀបចំគោលការណ៍ណែនាំស្តីពីស្វ័យភាព និងគណនេយ្យភាពហិរញ្ញវត្ថុនៅសាលារៀន ដូចមានចែងក្នុងឯកសារណែនាំស្តីពីមូលនិធិកែលម្អសាលារៀន<br>១.២ អនុម័តសៀវភៅណែនាំទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុនៃមូលនិធិកែលម្អសាលារៀន<br>១.៣ រៀបចំនិងអនុម័តគោលនយោបាយស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ការគ្រប់គ្រងបុគ្គលិក វង្វាយតម្លៃគ្រូបង្រៀន ការជ្រើសរើសនិងការបញ្ឈប់ការងារ និងការពិនិត្យតាមដាននិងវាយតម្លៃ<br>១.៤ រៀបចំឧបករណ៍សវនកម្មមូលនិធិកែលម្អសាលារៀន<br>១.៥ ពង្រឹងនិងពង្រីកការអនុវត្តថវិកាកម្មវិធី និងការត្រួតពិនិត្យថវិកា<br>១.៦ ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី ការកត់ត្រា និងប្រព័ន្ធរបាយការណ៍<br>១.៧ បណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ និងធានាការជួយគាំទ្រដោយផ្ទាល់នៅកម្រិតសាលារៀន (នាយកសាលា/ប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ) តាមរយៈកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំជាប្រចាំ<br>១.៨ ពង្រឹងសមត្ថភាពនាយកដ្ឋានជំនាញលើការគ្រប់គ្រងហិរញ្ញវត្ថុ<br>១.៩ សហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការកែលម្អការចំណាយថវិកាដើម្បីធានាការផ្តល់ការអប់រំប្រកបដោយគុណភាព។ |
| | **២. នាយកដ្ឋានហិរញ្ញវត្ថុ**<br>បំប៉ននាយកសាលាស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសម្រាប់ការអនុវត្តមូលនិធិកែលម្អសាលារៀនសាធារណៈ ដោយបង្កើន (i) ស្វ័យភាពក្នុងការគ្រប់គ្រងស្ថាប័នសាធារណៈ (ii) គណនេយ្យភាពនៃការគ្រប់គ្រងថវិកា និង(iii) ការឆ្លើយតបទៅនឹងលទ្ធផលសិក្សារបស់សិស្ស។ |
| | **៣. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**<br>៣.១ អនុម័តលើសំណើចំណាយថវិកាកែលម្អសាលារៀន ដែលស្នើដោយការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ<br>៣.២ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ពិនិត្យឡើងវិញនិងឯកភាពលើរបាយការណ៍ហិរញ្ញវត្ថុរបស់សាលារៀន ដែលបានបូកសរុបនិងបញ្ជូនមកដោយការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ។ |
| | **៤. ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ**<br>៤.១ ផ្តល់ការឯកភាពលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំ<br>៤.២ បូកសរុបរបាយការណ៍ហិរញ្ញវត្ថុរបស់សាលារៀន និងបញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តដើម្បីសុំការឯកភាព<br>៤.៣ គាំទ្រផ្នែកបច្ចេកទេសដល់សាលារៀន ដើម្បីអនុវត្តមូលនិធិកែលម្អសាលារៀន។ |

| | |
|---|---|
| | **៥. គណៈកម្មការគ្រប់គ្រងសាលារៀន**<br>៥.១ គណៈកម្មការគ្រប់គ្រងសាលារៀន នឹងត្រូវបង្កើតឡើង ដើម្បីអនុម័តបទបញ្ញា ដែលទាក់ទងទៅនឹងតួនាទីនិងការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងសាលារៀន មាតាបិតាសិស្សនិងសហគមន៍ក្នុងការគ្រប់គ្រងសាលារៀន<br>៥.២ អនុម័តផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន ផែនការប្រតិបត្តិប្រចាំឆ្នាំ និងដាក់សំណើមូលនិធិកែលម្អសាលារៀន ដើម្បីឆ្លងទៅការិ.អយក.ក្រុង ស្រុក ខណ្ឌ និងទទួលខុសត្រូវលើការពិនិត្យមើលការអនុវត្ត មូលនិធិកែលម្អសាលារៀន ដែលប្រតិបត្តិដោយសាលារៀន<br>៥.៣ ពង្រឹងការអនុវត្តយន្តការនិងឧបករណ៍ ដើម្បីលើកកម្ពស់គណនេយ្យភាព និងការទទួលខុសត្រូវ<br>៥.៤ បង្កើនតម្លាភាពថវិកា<br>៥.៥ បង្កើតប្រព័ន្ធគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផល តាមគោលការណ៍អភិបាលកិច្ចល្អ ការធានាភាពស័ក្តិសិទ្ធិនិងប្រសិទ្ធភាព និងការសម្រេចបាននូវវឌ្ឍនភាពនៃលទ្ធផលសិក្សាជាក់ស្តែងរបស់សិស្ស។<br>៥.៦ ផ្តល់តួនាទីសំខាន់ៗដល់គ្រូបង្រៀន សហគមន៍ អាជ្ញាធរ មាតាបិតាសិស្ស និងក្រុមប្រឹក្សាកុមារ ក្នុងការកសាងផែនការ និងចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំ ដោយបង្កើតឱ្យមានការពិនិត្យតាមដានការអនុវត្តថវិកាសាលារៀនប្រកបដោយតម្លាភាព។<br>៥.៧ បង្កើតយន្តការវាយតម្លៃការបំពេញការងារ និងពិនិត្យតាមដានលើគុណភាពអប់រំជាពិសេសលទ្ធផលសិក្សារបស់សិស្ស តាមរយៈការធ្វើតេស្តស្តង់ដា<br>៥.៨ ប្រជុំពិភាក្សាជាមួយគ្រូបង្រៀន មាតាបិតាសិស្ស សហគមន៍ និងអាជ្ញាធរមូលដ្ឋាន អំពីការកសាង និងអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន និងផែនការប្រតិបត្តិប្រចាំឆ្នាំ និងលើកវិធានការ ដើម្បីកែលម្អការបំពេញការងាររបស់សាលារៀនឱ្យកាន់តែប្រសើរឡើង។ |

| **យុទ្ធសាស្ត្រគោលទី៣**<br>យុទ្ធសាស្ត្រវង ៣.២ | **កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ**<br>ធ្វើសវនកម្មថវិកាអប់រំជាទៀងទាត់ |
|---|---|
| នីតិវិធី | បង្កើនការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនិងបច្ចេកវិទ្យា និងលើកកម្ពស់សេដ្ឋកិច្ចនិងសង្គម វប្បធម៌ ដោយរៀបចំយុទ្ធសាស្ត្រសម្រាប់ធ្វើសវនកម្មថវិកាអប់រំ ដើម្បីលើកកម្ពស់ភាពជាពលរដ្ឋមានគុណភាព ដោយផ្តោតលើចំណេះដឹង ជំនាញ និងបំណិនជីវិត ក៏ដូចជាការគោរពច្បាប់និងសណ្តាប់ធ្នាប់ សហគមន៍និងការអភិវឌ្ឍប្រកបដោយចីរភាព និងការចូលរួមក្នុងសកម្មភាពនយោបាយ។ |
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ អនុម័តផែនការសកម្មភាពស្តីពីសវនកម្មហិរញ្ញវត្ថុនៅសាលារៀន<br>១.២ រៀបចំ និងអនុម័តផែនការគោលស្តីពីសវនកម្មផ្ទៃក្នុង |

| | |
|---|---|
| | ១.៣ ពង្រឹងការរៀបចំផែនការនិងពិនិត្យតាមដានការប្រើប្រាស់ថវិកាអប់រំ តាមរយៈការពង្រីកប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុនៅគ្រប់កម្រិត និងការអនុវត្តផែនការសកម្មភាពគ្រប់គ្រងការផ្លាស់ប្តូរ ដើម្បីសម្របសម្រួលការប្តូរពីរបៀបគ្រប់គ្រងហិរញ្ញវត្ថុតាមទម្លាប់ ទៅជាការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មាន<br>១.៤ អភិវឌ្ឍសមត្ថភាពអធិការអប់រំ និងនាយកសាលាលើប្រព័ន្ធអធិការផ្ទៃក្នុង និងផ្ទៃក្រៅ<br>១.៥ កំណត់តួនាទី និងភារកិច្ចរបស់អធិការអប់រំ និងការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ក្នុងការធ្វើសវនកម្មហិរញ្ញវត្ថុអប់រំ<br>១.៦ បំប៉ននាយកសាលាលើការគ្រប់គ្រងហិរញ្ញវត្ថុ និងភាពជាអ្នកដឹកនាំ<br>១.៧ ពង្រឹងសមត្ថភាពការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ដើម្បីចូលរួមអនុវត្តផែនការអភិវឌ្ឍសាលារៀន<br>១.៨ រៀបចំវគ្គបំប៉នស្តីពី ការធ្វើសវនកម្មផ្ទៃក្នុងសាលារៀន ដើម្បីកសាងសមត្ថភាពការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ<br>១.៩ ពង្រឹងសមត្ថភាពនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដើម្បីធ្វើសវនកម្មហិរញ្ញវត្ថុសាលារៀនបានទៀងទាត់<br>១.១០ បង្កើតវប្បធម៌គណនេយ្យភាព និងតម្លាភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុ ដោយកែលម្អការទំនាក់ទំនងនិងការអនុញ្ញាតឱ្យគណៈកម្មការគ្រប់គ្រងសាលារៀនពិនិត្យតាមដានប្រតិបត្តិការហិរញ្ញវត្ថុរបស់សាលារៀន។ |
| | **២. នាយកដ្ឋានសវនកម្មផ្ទៃក្នុង និងអធិការដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ**<br>២.១ ធ្វើសវនកម្មសាលារៀនទៀងទាត់ ដើម្បីធានាថាធនធានថវិកាត្រូវបានប្រើប្រាស់ដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្ស និងផ្សារភ្ជាប់សវនកម្មទៅនឹងការគ្រប់គ្រងតាមសាលារៀន<br>២.២ អនុម័តស្តង់ដារបាយការណ៍ ស្តីពី ចំណូលនិងចំណាយ ដូចជារបាយការណ៍ហិរញ្ញវត្ថុរបស់សាលារៀន និងការអនុវត្តថវិកាប្រចាំឆ្នាំថ្នាក់សាលារៀន<br>២.៣ ធានាថាមូលនិធិត្រូវបានប្រើប្រាស់ដើម្បីគាំទ្រដល់សកម្មភាពគោលនិងសកម្មភាពរងដូចខាងក្រោម (១) ការគាំទ្រកិច្ចដំណើរការ៖ ដំណើរការរដ្ឋបាល ការពង្រឹងសមត្ថភាព គ្រឿងបរិក្ខារនិងគ្រឿងសង្ហារឹម ជួសជុលនិងការថែទាំ ទឹក អគ្គិសនី សេវាទូរស័ព្ទ និងអ៊ីនធឺណិត។ (២) ការកែលម្អគុណភាពអប់រំ៖ ការចូលរៀនប្រកបដោយសមធម៌ សម្ភារៈបង្រៀននិងរៀននិងការផលិតសម្ភារៈបង្រៀន សម្ភារៈពិសោធន៍និងការពិសោធន៍ សម្ភារៈបណ្ណាល័យ សៀវភៅនិងសម្ភារៈសម្រាប់អានការជួយសិស្សខ្សោយ ថ្នាក់បំប៉ននិងការទប់ស្កាត់ការបោះបង់ការសិក្សា កែលម្អបរិស្ថាននិងទីធ្លាកំសាន្ត បំណិនជីវិត កសិកម្ម រោងជាងនិងការវិនិយោគសុខភាពអនាម័យ ការអប់រំកាយ សិល្បៈនិងការលើកទឹកចិត្ត ការងារកុមារនិងយុវជន និងសំណង់ (៣) ដោះស្រាយបញ្ហាសង្គម៖ លើកកម្ពស់ការគោរពច្បាប់ចរាចរនិងការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀន ការប្រែប្រួលអាកាសធាតុ ...។ល។ |

| | |
|---|---|
| | **៣. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**<br>អនុម័តផែនការពិនិត្យតាមដាន ដើម្បីពិនិត្យតាមដានវឌ្ឍនភាពនៃការផ្តល់សេវាអប់រំនៅសាលារៀននីមួយៗ និងធានាប្រសិទ្ធភាព។ |
| | **៤. ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ**<br>រៀបចំផែនការពិនិត្យតាមដាន ដើម្បីពិនិត្យតាមដានវឌ្ឍនភាពនៃការផ្តល់សេវាអប់រំនៅសាលារៀននីមួយៗ និងធានាប្រសិទ្ធផល។ |
| | **៥ សាលារៀន**<br>៥.១ ពង្រឹងជំនាញគ្រប់គ្រងហិរញ្ញវត្ថុ រៀបចំនិងថែទាំប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុច្បាស់លាស់<br>៥.២ បង្កើតប្រអប់សំបុត្រតម្លាភាព ដើម្បីទទួលបានព័ត៌មានឬពាក្យបណ្តឹងពីអ្នកពាក់ព័ន្ធ<br>៥.៣ នាយកសាលាប្រើប្រាស់មូលនិធិកែលម្អសាលារៀន ដើម្បីការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំជាប្រចាំ និងកែលម្អវិធីសាស្ត្របង្រៀន ដែលត្រូវរៀបចំឡើង ដើម្បីលើកកម្ពស់ការគោរពជាតិសាសន៍ និងតម្លៃមនុស្ស<br>៥.៤ នាយកសាលារៀនកែលម្អការអនុវត្តរបស់សាលារៀន តាមរយៈការរកឃើញពីខាងក្រៅ និងលទ្ធផលសវនកម្ម។ |
| | **៦. គណៈកម្មការគ្រប់គ្រងសាលារៀន**<br>៦.១ លើកកម្ពស់គណនេយ្យភាពនៃការគ្រប់គ្រងនិងការពិនិត្យតាមដានការប្រើប្រាស់ធនធាន សុវត្ថិភាព ភាពជឿទុកចិត្ត និងតម្លាភាព ដោយតម្រូវឱ្យនាយកសាលាដាក់របាយការណ៍ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុជូនគណៈកម្មការគ្រប់គ្រងសាលារៀន<br>៦.២ ពង្រឹងប្រព័ន្ធធានាគុណភាពផ្ទៃក្នុង និងប្រព័ន្ធអធិការកិច្ច ដោយផ្អែកលើស្វ័យវាយតម្លៃសាលារៀន និងការត្រួតពិនិត្យជាប្រចាំ<br>៦.៣ ផ្តល់របាយការណ៍ជាប្រចាំ ស្តីពី ភាពពេញចិត្តនៃការគ្រប់គ្រង និងសំណូមពរ<br>៦.៤ ផ្សព្វផ្សាយរបាយការណ៍ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុដល់អ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីធានាបាននូវតម្លាភាព។ |
| | **៧. គ្រូបង្រៀន**<br>ផ្តល់យោបល់កែលម្អដល់នាយកសាលាលើការគ្រប់គ្រងសាលារៀន និងធានាថាមូលនិធិកែលម្អសាលារៀនត្រូវបានប្រើសម្រាប់ដំណើរការបង្រៀននិងរៀន សំដៅបង្កើនលទ្ធផលសិក្សារបស់សិស្ស។ |

| **យុទ្ធសាស្ត្រគោលទី ៣**<br>យុទ្ធសាស្ត្រវង ៣.៣ | **កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ**<br>បង្កើនការបែងចែកថវិកាផ្សារភ្ជាប់នឹងគោលនយោបាយអប់រំ |
|---|---|
| នីតិវិធី | បង្កើនការគាំទ្រសេដ្ឋកិច្ចនិងបច្ចេកវិទ្យា និងលើកកម្ពស់សង្គម វប្បធម៌ ដោយរៀបចំយុទ្ធសាស្ត្រសម្រាប់បង្កើនការបែងចែកថវិកាផ្សារភ្ជាប់នឹងគោលនយោបាយអប់រំ ដើម្បីលើកកម្ពស់គុណភាពជាពលរដ្ឋកម្រិតជាតិ និងសកលលោក។ |
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ អនុម័តគោលនយោបាយនិងសេចក្តីណែនាំស្តីពី ស្វ័យភាពនិងគណនេយ្យភាព |

| | |
|---|---|
| | ហិរញ្ញវត្ថុសាលារៀន<br>១.២ ដាក់អនុវត្ត ការគ្រប់គ្រងដោយផ្អែកលើលទ្ធផល ដោយផ្សារភ្ជាប់ជាតុចូលទៅនឹងសូចនាករលទ្ធផលកម្រិតជាតុចេញនិងផលសម្រេច ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងគោលនយោបាយអប់រំនិងជានាការពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំ និងផ្តល់របាយការណ៍ពិនិត្យតាមដានស្តង់ដាជាប្រចាំ<br>១.៣ កែលម្អសូចនាករស្នូលនៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ<br>១.៤ ផ្តល់ធនធានបន្ថែមដល់សាលារៀន<br>១.៥ ពិនិត្យឡើងវិញប្រចាំឆ្នាំស្តីពីការផ្សារភ្ជាប់គោលនយោបាយអប់រំទៅនឹងថវិកា<br>១.៦ ប្រមូលនិងចងក្រងទិន្នន័យនៅតាមសាលារៀនស្តីពី គម្លាតនៃជាតុប្រកបដោយគុណភាពនៅតាមសាលារៀន និងរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំដើម្បីផ្តល់ជាតុចូលដល់សាលារៀន។ |
| | **២. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**<br>២.១ ដាក់អនុវត្តការគ្រោងថវិកាផ្សារភ្ជាប់ទៅនឹងគោលនយោបាយអប់រំ និងការបំពេញការងារ<br>២.២ ប្រើប្រាស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងផែនការប្រតិបត្តិប្រចាំឆ្នាំ ដើម្បីគ្រោងថវិកាតាមអនុវិស័យ<br>២.៣ បែងចែកថវិកាដើម្បីអនុវត្តគោលនយោបាយកំណែទម្រង់ថ្មីៗសម្រាប់ការកែលម្អសាលារៀន។ |
| | **៣. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**<br>វាយតម្លៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី ខេត្ត  និងធានាថាធនធានហិរញ្ញវត្ថុបានធ្វើឱ្យសម្រេចសូចនាករស្នូល។ |
| | **៤. ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ**<br>៤.១ បូកសរុបមូលនិធិកែលម្អសាលារៀន និងវាយតម្លៃប្រសិទ្ធផលហិរញ្ញវត្ថុ ដោយផ្អែកលើសូចនាករថ្នាក់ក្រុង ស្រុក ខណ្ឌ (អត្រាចូលរៀន អត្រាបញ្ចប់ការសិក្សា និងអត្រាបោះបង់ការសិក្សា)<br>៤.២ គាំទ្រនិងណែនាំលើការអនុវត្តយុទ្ធសាស្ត្រនិងការឆ្លើយតបទៅនឹងតម្រូវការរបស់សាលារៀនទាន់ពេលវេលា។ |
| | **៥. សាលារៀន/នាយកសាលា/គ្រូបង្រៀន**<br>៥.១ នាយកសាលាត្រូវពង្រឹងវត្តមានរបស់គ្រូបង្រៀននៅតាមសាលារៀន<br>៥.២ នាយកសាលានិងគ្រូបង្រៀនត្រូវខិតខំអប់រំសិស្ស ឱ្យគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់សាលារៀន និងកាលវិភាគសិក្សា ការគោរពច្បាប់ និងសណ្តាប់ធ្នាប់សង្គម ដែលជាជំនាញគ្រប់គ្រងផ្ទាល់ខ្លួន និងលើកទឹកចិត្តសិស្សឱ្យរក្សាអនាម័យនិងធ្វើឱ្យសាលារៀនស្អាត<br>៥.៣ នាយកសាលាផ្តល់ការគាំទ្រផ្នែកបច្ចេកទេសនិងចំណេះដឹងដល់គ្រូក្នុងដំណើរការបង្រៀន និងរៀន |

| | |
|---|---|
| | ៥.៤ នាយកសាលាជំរុញការអនុវត្តច្បាប់ស្តីពីការអប់រំ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងកំណត់លក្ខខណ្ឌសម្រាប់ការអនុវត្តកម្មវិធីសិក្សារបស់គ្រូបង្រៀន<br>៥.៥ សាលារៀនណែនាំពីការធ្វើផែនការថវិកាដោយកំណត់តម្រូវការថវិកា ដើម្បីអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនតាមពេលវេលាជាក់លាក់<br>៥.៦ គណៈកម្មការគ្រប់គ្រងសាលារៀនរៀបចំរបាយការណ៍ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនដោយពិនិត្យតាមដាននិងវាយតម្លៃការអនុវត្តសកម្មភាពជាក់ស្តែង<br>៥.៧ សាលារៀនប្រើប្រាស់មូលនិធិកែលម្អសាលារៀនសម្រាប់គាំទ្រសកម្មភាពដូចជា<br>- បង្កើនការប្រើប្រាស់សម្ភារបរិក្ខានិងបរិយាកាសរៀនសូត្រ តាមរយៈសម្ភារៈនិងឧបករណ៍ និងការគាំទ្រសម្ភារបង្រៀននិងរៀន និងសកម្មភាពបង្រៀន<br>- ពង្រឹងសមត្ថភាពរបស់គ្រូបង្រៀន<br>- ជួយដល់កុមារងាយរងគ្រោះ សិស្សរៀនយឺត និងសិស្សមុខសញ្ញាបោះបង់ការសិក្សា<br>- បង្កើនអត្រាចូលរៀន អត្រាឆ្លងភូមិសិក្សា និងអត្រាបញ្ចប់ការសិក្សានៅគ្រប់កម្រិត<br>- ផ្តល់សេវាថែទាំសុខភាពដល់សិស្សគ្រប់កម្រិតទាំងអស់ (ថែទាំសុខភាព សុវត្ថិភាពចំណីអាហារ និងហានិភ័យផ្សេងៗ)<br>- ការរៀបចំវិធានការគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិ។ |

| | |
|---|---|
| **យុទ្ធសាស្ត្រគោលទី ៤**<br>យុទ្ធសាស្ត្ររង ៤.១ | **កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស**<br>បណ្តុះបណ្តាលដោយផ្តោតលើវិធីសាស្ត្របង្រៀន និងកម្មវិធីបំប៉ននៅនឹងកន្លែង |
| នីតិវិធី | បង្កើនការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល បច្ចេកវិទ្យា និងលើកកម្ពស់សេដ្ឋកិច្ច និងវប្បធម៌សង្គម សម្រាប់បង្កើតយុទ្ធសាស្ត្រកំណែទម្រង់អប់រំដើម្បីរៀបចំការបណ្តុះ-បណ្តាល សំដៅលើកកម្ពស់ភាពជាពលរដ្ឋមានគុណភាពទាំងថ្នាក់ជាតិ និងសកលលោក។ |
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ អនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំជាប្រចាំ ដោយផ្តោតលើវិធីសាស្ត្របង្រៀន និងកម្មវិធីហ្វឹកហាត់នៅនឹងកន្លែង<br>- ផ្តល់ក្របខណ្ឌអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំដល់បុគ្គលិកអប់រំ<br>- ផ្តល់ការបណ្តុះបណ្តាលជាប្រចាំដល់បុគ្គលិកអប់រំ<br>- ធានាការផ្សារភ្ជាប់ការអភិវឌ្ឍវិជ្ជាជីវៈ និងគន្លងអាជីពគ្រូបង្រៀន<br>- រៀបចំប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំ<br>១.២ កែលម្អ និងអនុម័តផែនការគោលស្តីពីការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំ និងនីតិវិធីលម្អិតសម្រាប់ការអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈ<br>១.៣ រៀបចំនិងអនុម័តផែនការគោលនិងផែនការសកម្មភាព ស្តីពីការសិក្សាពេញមួយជីវិតសម្រាប់គ្រូបង្រៀន និងនាយកសាលា<br>១.៤ អនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ដែលជាផែនទីបង្ហាញផ្លូវសម្រាប់កំណែទម្រង់គ្រូបង្រៀន៖ (១) ការកែលម្អការជ្រើសរើសគ្រូបង្រៀន និង |

| | |
|---|---|
| | នាយកសាលា (២) ការភ្ជាប់ការដំឡើងឋានៈទៅនឹងការអភិវឌ្ឍវិជ្ជាជីវៈ (INSET / ONSET) និងការវាយតម្លៃការអនុវត្តការងារ (៣) ការរៀបចំគន្លងអាជីពគ្រូបង្រៀន ដោយផ្អែកលើរចនាសម្ព័ន្ធច្បាស់លាស់ (៤) ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និង វាយតម្លៃគ្រូបង្រៀន<br>១.៥ សាកល្បងបង្កើតមូលនិធិសម្រាប់កម្មវិធីវិក្រឹតការជាប្រចាំ និងសាកល្បងបង្កើត ប្រព័ន្ធវិក្រឹតការបង់ប្រាក់ ដែលគ្រូបង្រៀននីមួយៗអាចជ្រើសរើសវគ្គវិក្រឹតការ តាមតម្រូវការ<br>១.៦ ផ្តល់ប្រាក់លើកទឹកចិត្តដល់គ្រូបង្រៀន ដែលមានស្តង់ដាវិជ្ជាជីវៈខ្ពស់<br>១.៧ ពិនិត្យមើលតួនាទី និងភារកិច្ចរបស់នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹត្យការ ដែល ពាក់ព័ន្ធនឹងវិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យ និងមជ្ឈមណ្ឌល គរុកោសល្យភូមិភាគ<br>១.៨ ផ្តល់ថវិកាបន្ថែមដល់សាលារៀនដើម្បីអនុវត្តវិធីសាស្រ្តបង្រៀនថ្មី<br>១.៩ អភិវឌ្ឍផែនការគោលស្តីពី កំណែទម្រង់គ្រូបង្រៀន (២០២០-២០៣០) ដើម្បី រៀបចំការទទួលខុសត្រូវរបស់អង្គភាពជំនាញ ក្នុងការកសាងសមត្ថភាពគ្រូបង្រៀន និងនាយកសាលា<br>១.១០ រៀបចំយុទ្ធសាស្រ្តដាក់ចំណាត់ថ្នាក់សាលារៀន<br>១.១១ រៀបចំវេទិកាផ្តល់ពានរង្វាន់គ្រូបង្រៀនល្អ និងនាយកសាលាល្អ និងចែករំលែក បទពិសោធន៍។ |
| | **២. គណៈកម្មការអភិវឌ្ឍន៍គ្រូបង្រៀន**<br>២.១ ធ្វើសុពលភាពឯកសារបណ្តុះបណ្តាល ផ្តោតលើវិធីសាស្រ្តបង្រៀន និងកម្មវិធី បណ្តុះបណ្តាល<br>២.២ រៀបចំប្រព័ន្ធគ្រប់គ្រងការបណ្តុះបណ្តាលពាក់ព័ន្ធគ្រប់ប្រភេទ<br>២.៣ គាំទ្រដល់គ្រូបង្រៀនចេញថ្មី តាមរយៈ ការអនុវត្តកម្មវិធីហ្វឹកហាត់<br>២.៤ លើកកម្ពស់គុណវុឌ្ឍិគ្រូបង្វឹក និងប្រធានក្រុមបច្ចេកទេសនៅតាមសាលារៀន<br>២.៥ រៀបចំ ពង្រឹង និងអនុវត្តយន្តការសម្រាប់ការគាំទ្របុគ្គលិកអប់រំនៅនឹងកន្លែង ដើម្បីបំពេញតម្រូវការ និងអភិវឌ្ឍជំនាញវិជ្ជាជីវៈ<br>២.៦ រៀបចំកម្មវិធីចែករំលែកបទពិសោធន៍ និងនវានុវត្តន៍ពីបុគ្គលិកអប់រំឆ្នើម<br>២.៧ អភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនតាមរយៈជម្រើសបណ្តុះបណ្តាល ដូចជា ការបណ្តុះបណ្តាលតាមប្រព័ន្ធក្រេឌីតនៅនឹងកន្លែង ការសិក្សាពីចម្ងាយ វគ្គបណ្តុះបណ្តាលរយៈពេលខ្លី វគ្គបណ្តុះបណ្តាលរយៈពេលវែង អាហារូបករណ៍ ការបណ្តុះបណ្តាលដែលមានលិខិតបញ្ជាក់ និងកម្មវិធីបណ្តុះបណ្តាលពន្លឿន។<br>២.៨ អភិវឌ្ឍប្រព័ន្ធក្រេឌីត ដើម្បីលើកទឹកចិត្តបុគ្គលិកអប់រំឱ្យអនុវត្តគន្លងអាជីព គ្រូបង្រៀន។ |
| | **៣. នាយកដ្ឋានបុគ្គលិក**<br>៣.១ លើកកម្ពស់គុណវុឌ្ឍិមន្ត្រីបង្គោលទទួលបន្ទុកការងារធនធានមនុស្សនៅថ្នាក់ជាតិ |

| | |
|---|---|
| | និងថ្នាក់ក្រោមជាតិ ដើម្បីបញ្ចូលការងារវិក្រឹតការ ក្នុងផែនការអភិវឌ្ឍធនធានមនុស្ស<br>៣.២ ផ្សារភ្ជាប់ការវាយតម្លៃគ្រូបង្រៀន ទៅនឹងការងារវិក្រឹតការ និងការដំឡើងថ្នាក់<br>៣.៣ បង្កើនគុណវុឌ្ឍិបុគ្គលិកអប់រំ និងគណៈកម្មាធិការគ្រប់គ្រងអប់រំនៅថ្នាក់កណ្ដាល យ៉ាងហោចណាស់សញ្ញាបត្រអនុបណ្ឌិត |
| | **៤. វិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ វិទ្យាស្ថានអប់រំពិសេស និងវិទ្យាស្ថានកំពង់ឈើទាល**<br>៤.១ រៀបចំកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដែលត្រូវបានផ្សារភ្ជាប់ជាមួយគន្លងអាជីពគ្រូបង្រៀន និងប្រព័ន្ធវាយតម្លៃគ្រូបង្រៀន<br>៤.២ ធ្វើវិក្រឹតការគ្រូបង្រៀន ដោយផ្ដោតលើវិធីសាស្ត្របង្រៀនថ្មី និងបំប៉នសមត្ថភាពនៅនឹងកន្លែង<br>៤.៣ ធ្វើវិក្រឹតការនាយកសាលា ដោយផ្ដោតលើភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងប្រកបដោយនវានុវត្តន៍<br>៤.៤ ផ្ដល់ឱកាសដល់គ្រូបង្រៀនជ្រើសរើសកម្មវិធីបណ្ដុះបណ្ដាលតាមតម្រូវការរបស់ខ្លួន។ |
| | **៥. សាលារៀន**<br>៥.១ រៀបចំវេទិកាសម្រាប់គាំទ្រ (INSET/ONSET) និងបញ្ចូលទៅក្នុងវេទិកាដំណើរការសាលារៀន<br>៥.២ នាយកសាលារៀបចំសហគមន៍សិក្សាជំនាញ ដើម្បីចែករំលែកចំណេះដឹងអំពីការគ្រប់គ្រងសាលារៀន<br>៥.៣ នាយកសាលារៀនសម្របសម្រួលកិច្ចប្រជុំជាប្រចាំជាមួយគ្រូបង្រៀន និងលើកកម្ពស់វប្បធម៌នៃការចែករំលែកឧត្តមានុវត្តន៍ជាមួយគ្រូបង្រៀនទាំងអស់។ |
| | **៦. គ្រូបង្រៀន**<br>ទទួលបានការបណ្ដុះបណ្ដាលស្ដីពី ការរៀបចំសហគមន៍សិក្សាវិជ្ជាជីវៈ ដើម្បីចែករំលែកបទពិសោធន៍បង្រៀនដល់សមាជិកក្នុងសមាគម។ |

| **យុទ្ធសាស្ត្រគោលទី៤**<br>យុទ្ធសាស្ត្ររង ៤.២ | **កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស**<br>បង្កើនការបណ្ដុះបណ្ដាលគ្រូបង្រៀន |
|---|---|
| នីតិវិធី | បង្កើនការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល សង្គម វប្បធម៌ និងលើកកម្ពស់សេដ្ឋកិច្ច និងបច្ចេកវិទ្យា សម្រាប់បង្កើតយុទ្ធសាស្ត្រកំណែទម្រង់អប់រំ ដើម្បីបង្កើនការបណ្ដុះបណ្ដាលគ្រូបង្រៀន សំដៅលើកកម្ពស់ភាពជាពលរដ្ឋប្រកបដោយគុណភាពទាំងថ្នាក់ជាតិ និងសាកលលោក។ |
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ ពិនិត្យឡើងវិញកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតបឋមសិក្សា និងគ្រូបង្រៀនកម្រិតមូលដ្ឋានបង្រៀននៅអនុវិទ្យាល័យនៅកម្រិតបរិញ្ញាបត្រ<br>១.២ ពិនិត្យឡើងវិញគោលនយោបាយ និងលក្ខណៈវិនិច្ឆ័យសម្រាប់ជ្រើសរើសគ្រូបង្រៀន<br>១.៣រៀបចំតម្រូវការ និងការផ្គត់ផ្គង់គ្រូបង្រៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ |

| | |
|---|---|
| | ១.៤ កែលម្អនីតិវិធីពង្រាយគ្រូបង្រៀន និងការពង្រាយគ្រូបង្រៀនឡើងវិញ<br>១.៥ លើកកម្ពស់ជីវភាពរស់នៅរបស់បុគ្គលិកអប់រំដោយបង្កើនប្រាក់ឈ្នួល និងប្រាក់ឧបត្ថម្ភ<br>១.៦ កែលម្អប្រាក់ឧបត្ថម្ភដល់គ្រូបង្រៀននៅតំបន់ជួបការលំបាក<br>១.៧ រៀបចំគណៈកម្មការអភិវឌ្ឍន៍គ្រូបង្រៀនសម្រាប់ទទួលស្គាល់គុណភាពគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និងរៀបចំផែនការមេស្តីពីការអភិវឌ្ឍវិទ្យាស្ថានគរុកោសល្យ<br>១.៨ រៀបចំជំនាញសម្រាប់វិទ្យាស្ថានជាតិអប់រំ វិទ្យាស្ថានគរុកោសល្យ និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីបណ្តុះបណ្តាលគ្រូបង្រៀន និងនាយកសាលា<br>១.៩ លើកទឹកចិត្តក្នុងការផ្លាស់ប្តូរបទពិសោធន៍បង្រៀន រវាងគ្រូឧទ្ទេសនៅសាលាគរុកោសល្យ ជាមួយអ្នកឯកទេសអប់រំដែលបម្រើការងារតាមអង្គភាពជំនាញ<br>១.១០ រៀបចំគោលនយោបាយដែលផ្តល់លទ្ធភាពដល់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន បណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់សាលារៀនឯកជនតាមចំនួនកំណត់ផ្អែកលើតម្រូវការរបស់សាលាឯកជន<br>១.១១ រៀបចំគោលនយោបាយដែលផ្សារភ្ជាប់ការអប់រំគ្រូបង្រៀនទៅនឹងការវាយតម្លៃការបំពេញការងាររបស់គ្រូបង្រៀន និងគន្លងអាជីពគ្រូបង្រៀន<br>១.១២ ដាក់សំណើសុំថវិកាទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបង្កើនគុណវុឌ្ឍិគ្រូបង្រៀនពី (១២+២) ទៅ (១២+៤)<br>១.១៣ អនុវត្តសាកល្បងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន (បរិញ្ញា+១) តាមស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ដើម្បីដោះស្រាយបញ្ហាខ្វះគ្រូបង្រៀន<br>១.១៤ កែលម្អលក្ខណៈវិនិច្ឆ័យ និងដំណើរការជ្រើសរើសនាយកសាលា ការបណ្តុះ-បណ្តាល និងការតែងតាំងដែលជានានាយកសាលាបានតែងតាំងដោយផ្អែកលើស្តង់ដានាយកសាលា និងបុគ្គលិកលក្ខណៈ។ |
| | **២. គណៈកម្មការអភិវឌ្ឍន៍គ្រូបង្រៀន**<br>បង្កើនគុណវុឌ្ឍិ និងបទពិសោធន៍វិជ្ជាជីវៈរបស់សាស្ត្រាចារ្យ និងគ្រូឧទ្ទេសមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យ និងវិក្រឹតខេត្ត ដើម្បីឱ្យឆ្លើយតបនឹងស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន ។ |
| | **៣. នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ**<br>៣.១រៀបចំផែនការរយៈពេលមធ្យម សម្រាប់ពង្រឹងសមត្ថភាពគ្រូឧទ្ទេស និងផែនការស្តីពីការអនុវត្តកម្មវិធីពន្លឿនថ្នាក់បរិញ្ញបត្រអប់រំ ដើម្បីដោះស្រាយបញ្ហាខ្វះគ្រូបង្រៀន<br>៣.២ រៀបចំកម្មវិធីបណ្តុះបណ្តាលនាយកសាលា។ |
| | **៤. វិទ្យាស្ថានគរុកោសល្យ វិទ្យាស្ថានជាតិអប់រំពិសេស និងវិទ្យាស្ថានកំពង់ឈើទាល**<br>៤.១វិទ្យាស្ថានគរុកោសល្យ និងមហាវិទ្យាល័យអប់រំនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ កែសម្រួលកម្មវិធីសិក្សាបណ្តុះបណ្តាលគ្រូបង្រៀន (១២+៤) កម្មវិធីសិក្សាលម្អិត និងសម្ភារៈ<br>៤.២លើកកម្ពស់គុណវុឌ្ឍិគ្រូឧទ្ទេស និងគ្រូបំណិនជីវិត<br>៤.៣គាំទ្រនិងចែករំលែកធនធានដល់មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ |

| | |
|---|---|
| | ៤.៤ លើកកម្ពស់គុណវុឌ្ឍិគ្រូឧទ្ទេសសម្រាប់សិស្សមានពិការភាព។ |
| | **៥. វិទ្យាស្ថានជាតិអប់រំ**<br>៥.១ បង្កើនស្តង់ដាគ្រូឧទ្ទេសដល់ បរិញ្ញាបត្រជាន់ខ្ពស់+១<br>៥.២បង្កើនគុណវុឌ្ឍិគ្រូឧទ្ទេស<br>៥.៣អនុវត្តកម្មវិធីពន្លឿន (B.Ed)<br>៥.៤បណ្តុះបណ្តាលនាយកសាលា<br>៥.៥ បណ្តុះបណ្តាលអធិការអប់រំ<br>៥.៦ រៀបចំវគ្គសុក្រឹតការមន្ត្រីអប់រំជាន់ខ្ពស់ ចាប់ពីអគ្គនាយកដល់ប្រធានមន្ទីរ។ |
| | **៦. សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**<br>សាកលវិទ្យាល័យភូមិន្ទភ្នំពេញ រៀបចំកម្មវិធីលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀនឆ្ពោះទៅកម្រិតបរិញ្ញាបត្រ។ |

| **យុទ្ធសាស្ត្រគោលទី៤**<br>យុទ្ធសាស្ត្រង ៤.៣ | **៤. កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស**<br>អនុវត្តការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ |
|---|---|
| **នីតិវិធី** | បង្កើនការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាល សង្គម វប្បធម៌ និងលើកកម្ពស់សេដ្ឋកិច្ច និងបច្ចេកវិទ្យា សម្រាប់បង្កើតយុទ្ធសាស្ត្រកំណែទម្រង់អប់រំ ដើម្បីអនុវត្ត ការវាយតម្លៃការបំពេញការងាររបស់គ្រូ លើកកម្ពស់ភាពជាពលរដ្ឋមានគុណភាព ទាំងថ្នាក់ជាតិ និងសាកលលោក ផ្អែកលើចំណេះដឹង ជំនាញ និងបំណិនជីវិត ការគោរពច្បាប់និងមានសណ្តាប់ធ្នាប់ សហគមន៍និងការអភិវឌ្ឍប្រកបដោយចីរភាព ការចូលរួមក្នុងសកម្មភាពនយោបាយ ក៏ដូចជាការយល់ដឹងពីស្ថានភាពសាកលលោក ការគោរពជាតិសាសន៍ និងតម្លៃមនុស្ស ការធ្វើឱ្យពិភពលោកក្លាយជាកន្លែងល្អប្រសើរ និងមានទំនួលខុសត្រូវខ្ពស់។ |
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ រៀបចំនិងអនុម័តសៀវភៅណែនាំស្តីពីការវាយតម្លៃបុគ្គលិកអប់រំ និងគន្លងអាជីពគ្រូបង្រៀន និងបង្កើតនីតិវិធីអនុវត្ត<br>១.២កែលម្អនីតិវិធីវាយតម្លៃបុគ្គលិក ដោយកំណត់លក្ខណៈវិនិច្ឆ័យច្បាស់លាស់សម្រាប់ការលើកកម្ពស់ឬការតែងតាំង អភិវឌ្ឍប្រព័ន្ធក្រេឌីតនិងជានាការបំពេញការងាររបស់គណៈកម្មការវាយតម្លៃបុគ្គលិកអប់រំតាមរយៈគោលនយោបាយស្តីពី គន្លងអាជីពគ្រូបង្រៀន និងផ្សព្វផ្សាយគន្លងអាជីពគ្រូបង្រៀន និងប្រព័ន្ធ ក្រេឌីត<br>១.៣ដំណើរការការិយាល័យគាំទ្រ និងវាយតម្លៃគ្រូបង្រៀន នៅក្នុងនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ និងនាយកដ្ឋានបុគ្គលិក<br>១.៤អនុវត្តសាកល្បងវាយតម្លៃការបំពេញការងារនៅតាមសាលារៀន (ផ្អែកលើលទ្ធផលសិក្សារបស់សិស្ស)<br>១.៥អនុវត្តសាកល្បងគោលនយោបាយពង្រាយគ្រូបង្រៀននិងនាយកសាលា ៖ គ្រូបង្រៀន និងនាយកសាលាគួរផ្លាស់ប្តូរកន្លែងធ្វើការក្នុងខេត្តរៀងរាល់ ៥ឆ្នាំ ម្តង<br>១.៦ សម្របសម្រួលរៀបចំកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈបុគ្គលិកអប់រំ |

| | |
|---|---|
| | ១.៧វាយតម្លៃសាកល្បងការបំពេញការងាររបស់បុគ្គលិកនៅថ្នាក់កណ្តាល មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ និងសាលារៀន<br>១.៨ លើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងស្មារតីដល់គ្រូបង្រៀន ដើម្បីកែលម្អការបំពេញការងារ<br>១.៩ បង្កើតសំណុំបេក្ខភាពជានាយកសាលា និងអ្នកឯកទេសអប់រំ<br>១.១០ រៀបចំការប្រឡងជ្រើសរើស និងបណ្តុះបណ្តាលបេក្ខភាពជានាយកសាលា ស្តីពីការគ្រប់គ្រងសាលារៀន<br>១.១១ ផ្តល់កញ្ចប់ហិរញ្ញវត្ថុពិសេសដល់គ្រូបង្រៀនថ្មើម និងនាយកសាលាថ្មើម ដើម្បីកែលម្អការផ្តល់សេវាអប់រំ។ |
| | **២. នាយកដ្ឋានបុគ្គលិក**<br>២.១ ពង្រឹងប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស<br>២.២ អនុវត្តសាកល្បងការវាយតម្លៃបុគ្គលិកអប់រំក្នុងនាយកដ្ឋានចំនួនបី (នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ និងនាយកដ្ឋានហិរញ្ញវត្ថុ) និងបន្តវាយតម្លៃអង្គភាពផ្សេងៗទៀត<br>២.៣ អនុវត្តសាកល្បងវាយតម្លៃការអនុវត្តរបស់បុគ្គលិកអប់រំ នៅតាមមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តដែលបានជ្រើសរើស<br>២.៤រៀបចំប្រព័ន្ធដើម្បីកត់ត្រាការបំពេញការងាររបស់គ្រូបង្រៀន។ |
| | **៣. សាលារៀន**<br>៣.១នាយកសាលាវាយតម្លៃការបំពេញការងាររបស់បុគ្គលិកបង្រៀន និងបុគ្គលិកមិនបង្រៀន ដោយផ្តោតលើលទ្ធផលការសិក្សារបស់សិស្ស និងការវាយតម្លៃ ដោយក្រុមប្រឹក្សាកុមារ យុវជន និងសេវាកម្មសិស្ស<br>៣.២ សាលារៀនអនុវត្តប្រព័ន្ធការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ ដោយលើកទឹកចិត្តបុគ្គលិកដែលបំពេញការងារល្អ និងចាត់វិធានរដ្ឋបាលចំពោះបុគ្គលិកអសកម្ម<br>៣.៣ សាលារៀនរៀបចំផែនការ និងប្រព័ន្ធអភិវឌ្ឍន៍សមត្ថភាពបុគ្គលិកអប់រំ<br>៣.៤ កែលម្អប្រព័ន្ធស្វ័យប្រកាសស្តីពី ការប្រើប្រាស់បុគ្គលិកអប់រំ ដើម្បីពង្រឹងការគ្រប់គ្រងបុគ្គលិកអប់រំឱ្យមានប្រសិទ្ធភាព ដោយរកឱ្យឃើញការលើសនិងខ្វះបុគ្គលិកអប់រំដែលបម្រើការនៅតាមសាលារៀន<br>៣.៥សាលារៀនលើកទឹកចិត្តគ្រូបង្រៀនតាមរយៈការគ្រប់គ្រងការបំពេញការងាររបស់បុគ្គលិក<br>៣.៦នាយកសាលាផ្តល់ធាតុចូលទាំងអស់ដែលជាតម្រូវការរបស់សាលា<br>៣.៧ នាយកសាលាវាយតម្លៃថ្នាក់រៀនជាប្រចាំផ្តោតលើលទ្ធផលសិក្សារបស់សិស្សស្របតាមកម្មវិធីសិក្សារបស់សាលារៀន។ |
| | **៤. គ្រូបង្រៀន**<br>៤.១ ផ្តល់ផែនការការងារប្រចាំឆ្នាំ |

| | |
|---|---|
| | ទៅនាយកសាលាសម្រាប់ការវាយតម្លៃលទ្ធផលការងារ<br>៤.២ដាក់សំណើតាមតម្រូវការដល់នាយកសាលាសម្រាប់តម្រូវការបណ្តុះបណ្តាល។ |

## យុទ្ធសាស្ត្រកំណែទម្រង់ឧត្តមសិក្សា

### កំណែទម្រង់ទី១៖ ការលើកកម្ពស់គុណភាពនៃការបង្រៀន និងការរៀន

- រៀបចំគោលការណែនាំស្តីពីការអភិវឌ្ឍសមត្ថភាពបុគ្គលិកបង្រៀននៅតាមគ្រឹះស្ថានឧត្តមសិក្សា
- បង្កើតមជ្ឈមណ្ឌលបង្រៀន និងរៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញដើម្បីលើកកម្ពស់ការបង្រៀន និងរៀននៅឧត្តមសិក្សា
- គ្រឹះស្ថានឧត្តមសិក្សាត្រូវមានបុគ្គលិកបង្រៀនពេញម៉ោងយ៉ាងតិច ២៥ ភាគរយ នៃចំនួនបុគ្គលិកបង្រៀនសរុប
- គ្រឹះស្ថានឧត្តមសិក្សាត្រូវមានបុគ្គលិកបង្រៀនមានសញ្ញាបត្រថ្នាក់បណ្ឌិតយ៉ាងតិច ១៥ ភាគរយ នៃចំនួនបុគ្គលិកបង្រៀនសរុប
- រៀបចំប្រកាសស្តីពី បុគ្គលិកបង្រៀនពេញម៉ោងនៅតាមគ្រឹះស្ថានឧត្តមសិក្សាដោយតម្រូវឱ្យបុគ្គលិកបង្រៀននៅគ្រឹះស្ថានឧត្តមសិក្សាតែ១ និងបំពេញការងារស្នូល ៖ ១) បង្រៀន ២) ស្រាវជ្រាវ និង ៣) ផ្តល់សេវាកម្ម
- អភិវឌ្ឍសមត្ថភាពមន្ត្រីរដ្ឋបាល និងមន្ត្រីគ្រប់គ្រង
- ជំរុញការអនុវត្តព្រះរាជក្រឹត្យស្តីពី ឋានៈសាស្ត្រាចារ្យ។

### កំណែទម្រង់ទី២៖ ការលើកកម្ពស់គុណភាពនៃការសាវជ្រាវ

- ជំរុញនិងលើកទឹកចិត្តការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវឧត្តមភាពនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈយ៉ាងហោចណាស់ចំនួន ០៣
- បង្កើតមូលនិធិជាតិសម្រាប់ការស្រាវជ្រាវនៅឧត្តមសិក្សា
- បង្កើតយន្តការលើកទឹកចិត្តការប្រកួតប្រជែងស្នាដៃ
- ជំរុញការការពារនិងធ្វើអាជីវកម្មស្រាវជ្រាវ
- បង្កើតភាពជាដៃគូជាមួយសហគ្រាស ឧស្សាហកម្ម។

### កំណែទម្រង់ទី៣ ៖ ការអភិវឌ្ឍកម្មវិធីសិក្សា

- រៀបចំក្របខណ្ឌកម្មវិធីសិក្សាឱ្យឆ្លើយតបទៅនឹងការវិវត្តឧស្សាហកម្ម
- អនុវត្តសាកល្បងក្របខណ្ឌកម្មវិធីនេះជាមួយគ្រឹះស្ថានឧត្តមសិក្សាយ៉ាងតិចចំនួន០៥
- ពង្រឹងនិងពង្រីកការបង្កើតកម្មវិធីសិក្សាអន្តរជាតិនៅតាមគ្រឹះស្ថានឧត្តមសិក្សា
- ជំរុញក្នុងការចូលរួមកម្មវិធីចល័តនិស្សិតអន្តរជាតិអាស៊ាន។

### កំណែទម្រង់ទី៤ ៖ ការពង្រឹងប្រព័ន្ធធានាគុណភាពអប់រំ

- រៀបចំស្តង់ដារស្តីពីការគ្រប់គ្រងប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង និងការទទួលស្គាល់ការវាយតម្លៃគុណភាពអប់រំនៅតាមគ្រឹះស្ថានឧត្តមសិក្សា

- រៀបចំគោលការណ៍ណែនាំសម្រាប់ការវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង និងការវាយតម្លៃគុណភាពអប់រំ នៅតាមគ្រឹះស្ថានឧត្តមសិក្សា
- បណ្តុះបណ្តាលមន្ត្រីគ្រប់គ្រង និងមន្ត្រីវាយតម្លៃគុណភាពអប់រំផ្ទៃក្នុង។

**កំណែទម្រង់ទី៥ ៖ ការគ្រប់គ្រងហិរញ្ញវត្ថុ**

- ជំរុញការប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈទៅជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈរដ្ឋបាល
- ផ្តល់ស្វ័យភាពដល់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុតាមរយៈការអនុវត្តសាកល្បងប្រព័ន្ធថវិកាជាកញ្ចប់ និងថវិកាផ្អែកលើលទ្ធផល
- រៀបចំប្រកាសអន្តរក្រសួង ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបប្រព័ន្ធថវិកាជាកញ្ចប់ និងថវិកាផ្អែកលើលទ្ធផលនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ
- រៀបចំសៀវភៅណែនាំស្តីពី ការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបប្រព័ន្ធថវិកាជាកញ្ចប់ និងថវិកាផ្អែកលើលទ្ធផលនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ។

**កំណែទម្រង់ទី៦ ៖ ការគ្រប់គ្រងធនធានមនុស្ស**

- ពង្រីកការគ្រប់គ្រងធនធានមនុស្សនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ
- ផ្តល់ស្វ័យភាពដល់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ក្នុងការគ្រប់គ្រងធនធានមនុស្សតាមរយៈការអនុវត្តសាកល្បងប្រព័ន្ធនិយោជន៍
- រៀបចំប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងធនធានមនុស្ស តាមបែបប្រព័ន្ធនិយោជន៍នៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ
- រៀបចំសៀវភៅណែនាំស្តីពី ការគ្រប់គ្រងធនធានមនុស្សតាមបែបប្រព័ន្ធនិយោជន៍នៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ
- លើកទឹកចិត្តនិងទាក់ទាញធនធានមនុស្សដែលមានគុណវុឌ្ឍិខ្ពស់ពីបរទេស។

**កំណែទម្រង់ទី៧ ៖ ការពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានវិទ្យាឧត្តមសិក្សា**

- បញ្ចប់ការរៀបចំស្តង់ដារស្តីពី ការគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានវិទ្យាឧត្តមសិក្សាសម្រាប់គ្រឹះស្ថានឧត្តមសិក្សា
- រៀបចំគោលការណ៍ណែនាំសម្រាប់អនុវត្តប្រព័ន្ធគ្រប់គ្រងទិន្នន័យព័ត៌មានវិទ្យាឧត្តមសិក្សា
- បណ្តុះបណ្តាលមន្ត្រីគ្រប់គ្រង និងមន្ត្រីទទួលបន្ទុកប្រមូលទិន្នន័យព័ត៌មាន
- ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃនៅឧត្តមសិក្សា
- បណ្តុះបណ្តាលមន្ត្រីពិនិត្យតាមដាន និងវាយតម្លៃ និងធ្វើផែនការនៅឧត្តមសិក្សា។

**កំណែទម្រង់ទី៨ ៖ ការជំរុញការចូលរៀនរបស់និស្សិតនៅឧត្តមសិក្សា**

- រៀបចំគោលនយោបាយស្តីពីការផ្តល់អាហារូបករណ៍ និងឥណទានសម្រាប់និស្សិតនៅឧត្តមសិក្សា
- បង្កើនអន្តេវាសិកដ្ឋានសម្រាប់និស្សិតនារី។

## យុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍយុវជន

| យុទ្ធសាស្ត្រគោលទី១ | កំណែទម្រង់កម្មវិធីអភិវឌ្ឍយុវជន |
|---|---|
| យុទ្ធសាស្ត្ររង ១.១ | ផ្តល់ឱកាសឱ្យយុវជនទទួលបានការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ប្រកបដោយគុណភាពនិង សមធម៌ |
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ ផ្តល់សេវាកម្មព័ត៌មានយុវជនច្រកតែមួយ<br>១.២ សម្របសម្រួលសេវាកម្មអភិវឌ្ឍន៍យុវជន ការបង្កើតកម្មវិធី និងគំនិតផ្តួចផ្តើម អភិវឌ្ឍយុវជននៅក្នុងក្រសួង ស្ថាប័នទាំងអស់<br>១.៣ សម្របសម្រួលសេវាកម្មការអភិវឌ្ឍយុវជន និងសម្ភារៈ មធ្យោបាយ ការបង្កើតកម្មវិធី និងការផ្តួចផ្តើម អភិវឌ្ឍយុវជននៅកម្រិតថ្នាក់ក្រោមជាតិ<br>១.៤ សម្របសម្រួលជាមួយសង្គមស៊ីវិល<br>១.៥ ពិនិត្យ កែសម្រួល និងរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារយុវជន<br>១.៦ អភិវឌ្ឍសមត្ថភាពអ្នកធ្វើការងារយុវជននិងមន្ត្រីគាំទ្រយុវជន<br>១.៧ ពង្រឹងពង្រីកមជ្ឈមណ្ឌលយុវជន ដើម្បីផ្តល់សេវាយុវជនជាពិសេសការបណ្តុះ-បណ្តាលវិជ្ជាជីវៈ យោងទៅតាមតម្រូវការតំបន់ និងជាពិសេសជំនាញព័ត៌មានវិទ្យា។ |
| | **២. អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនកម្ពុជា**<br>២.១ ធ្វើបច្ចុប្បន្នកម្មផែនការសកម្មភាពជាតិស្តីពី ការអភិវឌ្ឍយុវជនកម្ពុជា<br>២.២ ស្រាវជ្រាវអំពីបញ្ហាយុវជន<br>២.៣ កៀរគរធនធានសម្រាប់ការអភិវឌ្ឍយុវជន។ |
| | **៣. គ្រឹះស្ថានសិក្សា**<br>៣.១ បង្កើនការចូលរៀនរបស់យុវជននៅកម្រិតមធ្យមសិក្សានិងឧត្តមសិក្សា។ |
| | **៤. គ្រឹះស្ថានអប់រំបច្ចេកទេសនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**<br>៤.១ បែងចែកកម្មវិធីនិងស្ថាប័នអប់រំជំនាញ ដើម្បីបម្រើតាមតម្រូវការរបស់យុវជនមានពិការភាព<br>៤.២ ធានាតម្រូវការរបស់យុវជនទាំងផ្នែកសង្គមនិងបរិស្ថាននៅក្នុងប្រព័ន្ធអប់រំនិងបណ្តុះបណ្តាលត្រូវបានឆ្លើយតប<br>៤.៣ ផ្តល់ឱកាសទទួលបានការអប់រំលើកទី ២ តាមរយៈកម្មវិធីអក្ខរកម្មអប់រំក្រៅប្រព័ន្ធ<br>៤.៤ អភិវឌ្ឍលទ្ធភាពទទួលបានការសិក្សាបន្ត ឬ ការសិក្សាពេញមួយជីវិត<br>៤.៥ គាំទ្រយុវជននៅពេលពួកគេកំពុងឈានចូលពេញវ័យ<br>៤.៦ ពង្រីកកម្មវិធីអប់រំក្រោយមធ្យមសិក្សា និងមជ្ឈមណ្ឌលយុវជនសម្រាប់យុវជនក្រៅសាលា។ |
| | **៥. ក្រសួងពាក់ព័ន្ធ**<br>៥.១ ផ្តល់សម្ភារៈនិងមធ្យោបាយបម្រើឱ្យយុវជនក្នុងសហគមន៍។ |

| | |
|---|---|
| | **៦. ផ្នែកឯកជន**<br>៦.១ ផ្តល់ការឧបត្ថម្ភធនដល់សិស្ស និស្សិតសម្រាប់ការអប់រំបន្ត។ |
| | **៧. មន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត**<br>៧.១ រៀបចំរចនាសម្ព័ន្ធ និងពង្រឹងយន្តការការទទួលខុសត្រូវកម្មវិធីអភិវឌ្ឍយុវជន<br>៧.២ កសាងកម្មវិធីប្រចាំឆ្នាំ និងតម្រូវការថវិកា<br>៧.៣ សហការយ៉ាងជិតស្និទ្ធជាមួយដៃគូ អ្នកពាក់ព័ន្ធគ្រប់ផ្នែក ដើម្បីធានាការអនុវត្តកម្មវិធីប្រកបដោយប្រសិទ្ធភាព<br>៧.៤ គ្រប់គ្រងព័ត៌មានពាក់ព័ន្ធឱ្យបានរឹងមាំនិងអាចទុកចិត្តបាន<br>៧.៥ ពង្រឹងទំនាក់ទំនងរវាងអ្នកពាក់ព័ន្ធ តាមរយៈកសាងក្រុមការងារ និងប្រជុំជាទៀងទាត់ដើម្បីកែលម្អ និងជំរុញការងារ។ |
| **យុទ្ធសាស្ត្រវងទី២** | **លើកទឹកចិត្តយុវជនឱ្យមានគំនិតផ្តួចផ្តើម គំនិតច្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព** |
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ បង្កើតលទ្ធភាពទទួលបានបច្ចេកវិទ្យាព័ត៌មានដើម្បីគាំទ្រដល់ការអប់រំនិងបណ្តុះ-បណ្តាលពីចម្ងាយ<br>១.២ បង្កើតលទ្ធភាពសម្រាប់ការតស៊ូមតិនិងភាពជាតំណាងយុវជននៅក្នុងស្ថាប័នរដ្ឋបាលនានា<br>១.៣ កៀរគរធនធានដើម្បីគាំទ្រដល់ការបោះជំរំវិទ្យាសាស្ត្រ បច្ចេកវិទ្យា<br>១.៤ ការផ្តួចផ្តើមការអភិវឌ្ឍយុវសហគ្រាសជាតិ។ |
| | **២. គ្រឹះស្ថានសិក្សា**<br>២.១ បង្កើនភាពជាតំណាងយុវជន នៅឧត្តមសិក្សា និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ<br>២.២ លើកកម្ពស់បណ្តាញការងារ និងគំរូនៅក្នុងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា<br>២.៣ ផ្តល់ការប្រឹក្សាយោបល់ស្តីពី មុខរបរនៅតាមសាលារៀន<br>២.៤ បង្កើនការអប់រំយុវសហគ្រិនភាព។ |
| | **៣. មជ្ឈមណ្ឌលយុវជន**<br>៣.១ ផ្តល់ការប្រឹក្សាយោបល់ និងព័ត៌មានដល់យុវជននៅក្រៅប្រព័ន្ធអប់រំ<br>៣.២ បង្កើតវេទិកាសម្រាប់ការអភិវឌ្ឍគោលនយោបាយនិងកម្មវិធី ដែលផ្តោតលើស្ថានភាពការងារ តម្រូវការបណ្តុះបណ្តាល និងសហគ្រាសរបស់យុវជន<br>៣.៣ គាំទ្រយុវជននៅក្នុងអភិវឌ្ឍសហគ្រិនភាព។ |
| **យុទ្ធសាស្ត្រវងទី៣** | **អភិវឌ្ឍយុវជនឱ្យមានកាយសម្បទា ចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅល្អ ចេះរួមរស់ជាមួយគ្នា ដោយសន្តិភាពនិងសុខដុមនីយកម្ម** |
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ កែលម្អសេវាកម្មនិងព័ត៌មានសុខភាព រួមទាំងសុខភាពបន្តពូជ ដែលបម្រើដល់យុវជនឱ្យបានគ្រប់ ជ្រុងជ្រោយ |

| | |
|---|---|
| | ១.២ បង្កើនការយល់ដឹងរបស់យុវជនអំពីជំងឺកាមរោគ មេរោគអេដស៍ និងជំងឺអេដស៍<br>១.៣ ការប្រឹក្សាយោបល់ស្តីពីសុខភាពយុវជន<br>១.៤ ការអភិវឌ្ឍសុខភាពផ្លូវចិត្តយុវជន។ |
| | **២. គ្រឹះស្ថានសិក្សា**<br>២.១ គាំទ្រយុវតីមានគភ៌ និងវត្តមានសិស្ស<br>២.២ បង្កើនការងារស្ម័គ្រចិត្ត<br>២.៣ លើកកម្ពស់ការផ្តួចផ្តើមសហគមន៍។ |
| **យុទ្ធសាស្ត្រទី៤** | **បង្កឱកាសឱ្យយុវជនចូលរួមបញ្ចេញមតិ ទស្សនៈ និងធ្វើសេចក្តីសម្រេចចិត្តនានា នៅក្នុងការអភិវឌ្ឍសហគមន៍និងសង្គមជាតិ** |
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ ផ្តល់ឱកាសសម្រាប់យុវជនដើម្បីធ្វើវិភាគទាន រួមចំណែកឆ្ពោះទៅរកការអភិវឌ្ឍប្រទេសកម្ពុជា<br>១.២ កសាងកម្មវិធីគាំទ្រមួយដែលលើកកម្ពស់ការជួយខ្លួនឯង ការផ្តួចផ្តើមការអភិវឌ្ឍយុវជននៅតាម សហគមន៍ និងការផ្តួចផ្តើមការងារស្ម័គ្រចិត្ត<br>១.៣ រៀបចំផែនការយុទ្ធសាស្ត្រកាយរឹទ្ធិកម្ពុជា។ |
| | **២. គ្រឹះស្ថានសិក្សា**<br>២.១ ពង្រឹងនិងពង្រីកក្រុមប្រឹក្សាកុមារនិងក្រុមប្រឹក្សាយុវជន។ |
| **យុទ្ធសាស្ត្រទី៥** | **ពង្រឹងយន្តការគ្រប់គ្រង និងពិនិត្យតាមដានកម្មវិធីអភិវឌ្ឍយុវជន** |
| | **១. អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីអភិវឌ្ឍយុវជន**<br>១.១ រៀបចំនិងប្រមូលផ្តុំផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពជាតិ<br>១.២ រៀបចំគម្រោងថវិកាប្រចាំឆ្នាំ<br>១.៣ រៀបចំនិងបង្កើតកម្មវិធីនិងសេវានានា<br>១.៤ សម្របសម្រួលលើកកម្ពស់អន្តរកម្មនិងការងារជាបណ្តាញក្នុងចំណោមស្ថាប័នពាក់ព័ន្ធ។ |
| | **២. ក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រសួង ស្ថាប័ន**<br>២.១ សម្របសម្រួលសកម្មភាពទាំងឡាយដែលពាក់ព័ន្ធទៅនឹងការងារយុវជននៅក្នុងក្រសួង ស្ថាប័ន<br>២.២ រៀបចំផែនការសកម្មភាព កម្មវិធី សេវាកម្ម និងសកម្មភាពផ្សេងៗដើម្បីឧត្តមប្រយោជន៍របស់យុវជន<br>២.៣ ពិនិត្យតាមដាន វាយតម្លៃលើការអនុវត្ត។ |
| | **៣. ស្ថាប័នថ្នាក់ក្រោមជាតិ**<br>៣.១ ពង្រឹងដំណើរការក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនរាជធានី ខេត្ត<br>៣.២ ពង្រឹងដំណើរការក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនក្រុង ស្រុក ខណ្ឌ<br>៣.៣ ពង្រឹងដំណើរការក្រុមប្រឹក្សាដើម្បីអភិវឌ្ឍយុវជនឃុំ សង្កាត់។ |

## យុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា

| យុទ្ធសាស្ត្រគោលទី១ | កំណែទម្រង់ការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា |
|---|---|
| យុទ្ធសាស្ត្ររង ១.១ | អភិវឌ្ឍក្របខណ្ឌច្បាប់ និងគតិយុត្តិ |
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ រៀបចំលិខិតបទដ្ឋានគតិយុត្ត ស្តីពី ការគ្រប់គ្រងវិស័យកីឡា<br>១.២ រៀបចំកែលម្អលិខិតបទដ្ឋាននានាស្តីពី ពង្រឹងការងារបច្ចេកទេសអប់រំកាយ និងកីឡា<br>១.៣ រៀបចំកែលម្អ អនុក្រឹត្យ និងប្រកាស ស្តីពី របបបំប៉ន ប្រាក់ឧបត្ថម្ភ និងប្រាក់រង្វាន់ នៃការប្រមូលផ្តុំហាត់ហ្វឹកហ្វឺន និងការប្រកួតជាតិ-អន្តរជាតិ។ |
| យុទ្ធសាស្ត្ររង ១.២ | អភិវឌ្ឍកីឡាកម្រិតខ្ពស់ |
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ រៀបចំសាលាថ្នាលនិស្សិតកីឡា<br>១.២ បញ្ជូនកីឡាករជម្រើសជាតិទៅហ្វឹកហ្វឺននៅក្រៅប្រទេស<br>១.៣ អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡាគ្រប់ប្រភេទ និងកីឡាជនពិការ<br>១.៤ បន្តរៀបចំព្រឹត្តិការណ៍កីឡាជាតិ រៀងរាល់ ២ ឆ្នាំ<br>១.៥ រៀបចំការប្រកួតកីឡាស៊ីហ្គេម ឆ្នាំ២០២៣<br>១.៦ បន្តលើកទឹកចិត្តកីឡាករឆ្នើម<br>១.៧ ប្រឆាំងនឹងការប្រើប្រាស់ដូប៉ាក្នុងវិស័យកីឡា<br>១.៨ អភិវឌ្ឍមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡាឱ្យដល់ស្តង់ដា។ |
| | **២. សហព័ន្ធកីឡាជាតិ**<br>២.១ ពង្រឹងសមត្ថភាពអង្គការសង្គមកីឡា រួមមានសហព័ន្ធកីឡាជាតិ និងគណៈកម្មាធិការកីឡាជាតិនានា<br>២.២ ជ្រើសរើសយុវជន ដែលមានឧបនិស្ស័យខ្ពស់ ដើម្បីជាថ្នាលអភិវឌ្ឍកីឡាកម្រិតខ្ពស់<br>២.៣ អភិវឌ្ឍសមត្ថភាពគ្រូបង្វឹក អាជ្ញាកណ្តាល ចៅក្រម កីឡាករ កីឡាការិនី និងមន្ត្រីជំនាញផ្សេងៗ<br>២.៤ ជំរុញ និងលើកទឹកចិត្តការអភិវឌ្ឍកីឡាជនពិការគ្រប់ប្រភេទ<br>២.៥ ពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការប្រកួតកីឡាជ្រើសរើសជើងឯកប្រចាំឆ្នាំតាមប្រភេទកីឡា ដោយគុណផលជៀបក្នុងតំបន់។ |
| យុទ្ធសាស្ត្ររង ១.៣ | ការអភិវឌ្ឍកីឡាសម្រាប់ទាំងអស់គ្នា |
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ ជំរុញការងារអប់រំកាយ និងកីឡាក្នុងជួរសិស្ស និស្សិត និងមហាជន<br>១.២ រៀបចំផែនការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអប់រំកាយ និងកីឡាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>១.៣ លើកកម្ពស់និងផ្សព្វផ្សាយក្រមសីលធម៌កីឡា<br>១.៤ បញ្ចូលសកម្មភាពអប់រំស្តីពី តម្លៃសីលធម៌កីឡាទៅក្នុងកម្មវិធីសិក្សា<br>១.៥ ផ្សារភ្ជាប់ទំនាក់ទំនងកីឡាសង្គម និងវប្បធម៌។ |

| | |
|---|---|
| | **២. រាជធានី ខេត្ត**<br>២.១ ចូលរួមលើកកម្ពស់ការងារអប់រំកាយ និងកីឡា<br>២.២ លើកទឹកចិត្តប្រជាជនឱ្យចូលរួមក្នុងសកម្មភាពកីឡាសម្រាប់ទាំងអស់គ្នា<br>២.៣ កៀរគរផ្នែកឯកជនឱ្យជួយគាំទ្រសកម្មភាពកីឡាសម្រាប់ទាំងអស់គ្នា<br>២.៤ ពង្រឹងការគ្រប់គ្រងសមាគម និងក្លឹបកីឡា។ |
| **យុទ្ធសាស្ត្រវង ១.៤** | **អភិវឌ្ឍវិស័យអប់រំកាយនិងកីឡានៅគ្រប់គ្រឹះស្ថានសិក្សានិងសហគមន៍** |
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ ដំឡើងកម្រិតបណ្ដុះបណ្ដាលគ្រូអប់រំកាយនិងកីឡាទៅជាកម្រិតឧត្តម<br>១.២ បង្កើនចំនួនគ្រូអប់រំកាយ និងកីឡា។ |
| | **២. គ្រឹះស្ថានសិក្សារដ្ឋ និងឯកជន**<br>២.១ ពង្រឹងការអនុវត្តមុខវិជ្ជាអប់រំកាយក្នុងម៉ោងសិក្សា និងកីឡាក្រៅម៉ោងសិក្សា<br>២.២ សាងសង់ទីលានកីឡាខេត្តមួយវិទ្យាល័យតម្រង់ទិសកីឡាមួយ<br>២.៣ ជំរុញសកម្មភាពអប់រំកាយនិងកីឡា ដើម្បីគាំទ្រគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព<br>២.៤ លើកកម្ពស់ការចូលរួមរបស់យុវជនក្នុងសកម្មភាពអប់រំកាយនិងកីឡា<br>២.៥ ពង្រឹងសកម្មភាពប្រកួតកីឡាក្រៅម៉ោងសិក្សា<br>២.៦ កែទម្រង់ការប្រកួតកីឡាសិស្ស និស្សិត។ |
| | **៣. សហប្រតិបត្តិការអន្តរជាតិ**<br>៣.១ អនុវត្តផែនការសកម្មភាពកីឡានៅក្នុងសហគមន៍សង្គម វប្បធម៌អាស៊ាន<br>៣.២ ពង្រឹងសន្តិភាព មិត្តភាព សាមគ្គីភាព និងការគោរពគ្នាទៅវិញទៅមកតាមរយៈសកម្មភាពប្រកួតកីឡា<br>៣.៣ ពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ។ |
| **យុទ្ធសាស្ត្រវង ១.៥** | **អភិរក្សនិងអភិវឌ្ឍកីឡាគ្រប់ប្រភេទ** |
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ ស្រាវជ្រាវនិងចងក្រងឯកសារវិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រអប់រំកាយនិងកីឡា<br>១.២ ស្រាវជ្រាវនិងចងក្រងឯកសារដើម្បីអភិរក្ស និងអភិវឌ្ឍកីឡាប្រពៃណី<br>១.៣ លើកទឹកចិត្តការផលិតសម្ភារៈកីឡានៅក្នុងប្រទេស<br>១.៤ ពង្រឹងនិងពង្រីកសហព័ន្ធកីឡាជាតិ ដោយប្រតិភូកម្មមុខងារ និងគាំទ្រថវិកាដើម្បីពន្លឿនការអភិវឌ្ឍ។ |
| **យុទ្ធសាស្ត្រវង ១.៦** | **អភិវឌ្ឍឧស្សាហកម្មកីឡា** |
| | **១. ក្រសួងអប់រំ យុវជន និងកីឡា**<br>១.១ លើកកម្ពស់ការធ្វើវិនិយោគលើវិស័យអប់រំកាយនិងកីឡា<br>១.២ ផ្ដល់អាជ្ញាបណ្ណផលិតសម្ភារៈនិងបរិក្ខារកីឡាគ្រប់ប្រភេទ<br>១.៣ លើកកម្ពស់ចលនុបត្ថម្ភ និងសិទ្ធិផ្សព្វផ្សាយព្រឹត្តិការណ៍កីឡា។ |

# ឧបសម្ព័ន្ធទី ៦ ៖ ម៉ាទ្រិកសកម្មភាពគោលនយោបាយ

| | ២០១៩ | ២០២០ | ២០២១ | ២០២២ | ២០២៣ |
|---|---|---|---|---|---|
| **អនុវិស័យ ការអប់រំកុមារតូច** | | | | | |
| ***គោលនយោបាយទី១*** *៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា* | • រៀបចំសៀវភៅណែនាំស្តីពីការអនុវត្តកម្មវិធី អប់រំមាតាបិតានៅឆ្នាំ២០១៩ (អកត)<br>• រៀបចំប្រកាសស្តីពីការអនុវត្តសាលាមត្តេយ្យសិក្សារដ្ឋនៅឆ្នាំ ២០១៩ (អកត/នក)<br>• រៀបចំសេចក្តីណែនាំស្តីពីការផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់គ្រូមត្តេយ្យសិក្សាបង្រៀនពីរវេននៅឆ្នាំ២០១៩ (អកត/បល)<br>• រៀបចំសេចក្តីណែនាំស្តីពីការបង្កើតថ្នាក់មត្តេយ្យក្នុងសាលាបឋមសិក្សានៅឆ្នាំ២០១៩ (អកត/នក) | • រៀបចំអនុក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅតាមស្ថាប័នរដ្ឋ រោងចក្រ សហគ្រាស នៅឆ្នាំ ២០២០ (អកត/នក) | | | |
| ***គោលនយោបាយទី២*** *៖ ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រី អប់រំគ្រប់លំដាប់ថ្នាក់* | • រៀបចំលក្ខខណ្ឌការងារស្តីពីតួនាទី និងការទទួលខុសត្រូវរបស់មន្ត្រីអប់រំកុមារតូចគ្រប់លំដាប់ថ្នាក់នៅឆ្នាំ២០១៩ (អកត/បល)<br>• រៀបចំសេចក្តីណែនាំស្តីពីស្តង់ដាអប្បរមាសាលាមត្តេយ្យសិក្សា និងថ្នាក់មត្តេយ្យសិក្សារដ្ឋនៅឆ្នាំ២០១៩ (អកត) | | | | |

| | | | | | |
|---|---|---|---|---|---|
| | • រៀបចំសេចក្តីណែនាំស្តីពីការប្រែក្លាយមត្តេយ្យសិក្សាសហគមន៍ដែលមានស្តង់ដាទៅជាឧបសម្ព័ន្ធនៃគ្រឹះស្ថានសិក្សាសាធារណៈនៅឆ្នាំ២០១៩ (អកត/នក) | | | | |
| **អនុវិស័យ ការអប់រំបឋមសិក្សា** | | | | | |
| ***គោលនយោបាយទី១ ៖*** *ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា* | • រៀបចំលក្ខន្តិកៈស្តីពីការបង្កើតគ្រឹះស្ថានបឋមសិក្សាសាធារណៈនិងឯកជននៅឆ្នាំ ២០១៩ (នក)<br>• ពិនិត្យឡើងវិញនូវការគ្រប់គ្រងនិងការបែងចែកសៀវភៅសិក្សាគោលនៅឆ្នាំ២០១៩ (បស)<br>• អភិវឌ្ឍក្របខណ្ឌជាតិស្តីពីអាហារូបករណ៍ ២០១៩ (បស/គនប)<br>• រៀបចំគោលនយោបាយស្តីពីអាហារូបករណ៍នៅឆ្នាំ២០១៩ (គនប/បស)<br>• រៀបចំផែនការសកម្មភាពស្តីពីការអប់រំពហុភាសា ២០១៩-២០២៣ នៅឆ្នាំ២០១៩ (អព)<br>• រៀបចំផែនការសកម្មភាពស្តីពី ការអប់រំបរិយាបន្ន ២០១៩-២០២៣ នៅឆ្នាំ២០១៩ (អព) | • អភិវឌ្ឍស្តង់ដាអេកូមេត្រីសម្រាប់មត្តេយ្យសិក្សា បឋមសិក្សានិងមធ្យមសិក្សានៅឆ្នាំ២០២០ (សណ)<br>• រៀបចំសេចក្តីណែនាំស្តីពីការបង្រៀននិងរៀនពេញមួយថ្ងៃនៅសាលាបឋមសិក្សានៅឆ្នាំ២០២០ (បស)<br>• អភិវឌ្ឍគោលនយោបាយស្តីពីសាលាបឋមសិក្សាជំនាន់ថ្មីឱ្យឆ្លើយតបនឹងស្តង់ដាសាលាបឋមសិក្សានៅឆ្នាំ២០២០ (គនប/បស)<br>• រៀបចំកែលម្អគោលនយោបាយស្តីពីកម្មវិធីសាលាកុមារមេត្រីផ្សារភ្ជាប់ទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤ នៅឆ្នាំ២០២០ (បស/គនប) | • រៀបចំឯកសារណែនាំស្តីពីការកែលម្អការរៀននិងបង្រៀនភាសាបរទេសនៅឆ្នាំ២០២១ (បស)<br>• រៀបចំឯកសារណែនាំស្តីពីការកែលម្អការរៀននិងបង្រៀនបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ នៅឆ្នាំ២០២១ (បស) | • អភិវឌ្ឍគោលនយោបាយស្តីពីនីតិវិធីការពារសុវត្ថិភាពកុមារ សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា នៅឆ្នាំ ២០២២(បស) | |

| | | | | | |
|---|---|---|---|---|---|
| | | • រៀបចំគោលនយោបាយស្តីពីស្បៀងអាហារតាមសាលារៀន និងអាហារូបត្ថម្ភប្រើប្រាស់កសិផលសហគមន៍ (គនប/បស)<br>• រៀបចំគោលការណ៍ណែនាំស្តីពីការប្រើប្រាស់គ្រូបង្រៀន និងការរៀបចំថ្នាក់មុខវិជ្ជាសម្រាប់ការបង្រៀនភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មានថ្នាក់ទី ៤ ដល់ ៦ នៅឆ្នាំ២០២០ (បស)<br>• រៀបចំឯកសារណែនាំស្តីពីការកែលម្អការរៀននិងបង្រៀន មុខវិជ្ជាគោល (៤មុខវិជ្ជា) នៅឆ្នាំ ២០២០ (បស) | | | |
| ***គោលនយោបាយទី២ ៖*** *ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់* | | • កែសម្រួលគោលនយោបាយស្តីពីគន្លងអាជីពគ្រូបង្រៀននៅឆ្នាំ ២០២០ (បវ)<br>• រៀបចំសេចក្តីណែនាំស្តីពីការបង្កើតនិងដំណើរការមុខងាររបស់ក្រុមប្រឹក្សាភិបាលសាលាបឋមសិក្សា នៅឆ្នាំ២០២០ (បស) | | | |

| | | | | | |
|---|---|---|---|---|---|
| | | • ពិនិត្យគោលនយោបាយ និងផែនការសកម្មភាពរបស់សាលាកុមារមេត្រីនៅក្នុងបរិបទគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព-ការអប់រំ ដោយពង្រឹងក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុងស្រុក ខណ្ឌ និងកម្រងសាលារៀន (បស)<br>• រៀបចំសេចក្តីណែនាំស្តីពីសៀវភៅបញ្ជាក់អាជីព និងប្រព័ន្ធក្រេឌីតនៅឆ្នាំ២០២០ (បវ) | | | |
| **អនុវិស័យ ការអប់រំមធ្យមសិក្សា និងអប់រំបច្ចេកទេស** | | | | | |
| *គោលនយោបាយទី១ ៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា* | • រៀបចំលិខិតបទដ្ឋានគតិយុត្តនិងយន្តការស្តីការពង្រីកមធ្យមសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេសនៅឆ្នាំ២០១៩ (តទវ/នក)<br>• រៀបចំនិងពិនិត្យឡើងលិខិតបទដ្ឋានគតិយុត្តដើម្បីគាំទ្រការអនុវត្តការងារប្រឹក្សាយោបល់នៅតាមសាលារៀនក្នុងឆ្នាំ២០១៩ (តទវ)<br>• រៀបចំនិងពិនិត្យឡើងលិខិតបទដ្ឋានគតិយុត្តដើម្បីគាំទ្រការអនុវត្តកម្មវិធីបំណិននៅតាមសាលារៀនក្នុងឆ្នាំ២០១៩ (តទវ/នក) | • រៀបចំលិខិតបទដ្ឋានគតិយុត្តនិងយន្តការ និងក្របខណ្ឌការងារសម្រាប់ផ្តល់ឱកាសដល់សិស្សដែលបោះបង់ការសិក្សានៅមធ្យមសិក្សាទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈនៅសាលាមធ្យមសិក្សាចំណេះទូទៅនិងសាលាបច្ចេកទេសនៅឆ្នាំ២០២០ (តទវ/នក)<br>• ធ្វើបច្ចុប្បន្នភាពផែនការគោលសម្រាប់អភិវឌ្ឍន៍ការអប់រំបច្ចេកទេសនៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំ២០២០ (តទវ) | • អភិវឌ្ឍក្របខណ្ឌធានាគុណភាពតាមរយៈការផ្តល់សេវាអប់រំបច្ចេកទេសនៅឆ្នាំ២០២១(តទវ)<br>• រៀបចំគោលនយោបាយស្តីពីការផ្តល់ប្រឹក្សាយោបល់នៅតាមសាលារៀនក្នុងឆ្នាំ២០២១ (តទវ) | | |

| | | | | | |
|---|---|---|---|---|---|
| | | • រៀបចំសេចក្តីណែនាំសម្រាប់អនុវត្តស្តង់ដាមធ្យមសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេសនៅឆ្នាំ២០២០ (តទវ)<br>• រៀបចំសេចក្តីណែនាំស្តីពីស្វ័យភាពនិងគណនេយ្យភាពសម្រាប់សាលាមធ្យមសិក្សាក្នុងឆ្នាំ២០២០ (មចទ)<br>• រៀបចំសេចក្តណែនាំស្តីការគ្រប់គ្រងនិងការប្រើប្រាស់សៀវភៅសិក្សាគោលនៅឆ្នាំ២០២០ (អសក)<br>• រៀបចំឯកសារណែនាំស្តីពីការអនុវត្តនៃការបង្រៀន និងរៀនសម្រាប់គ្រប់មុខវិជ្ជាឱ្យស្របតាមកម្មវិធីសិក្សានៅឆ្នាំ២០២០(អសក) | • រៀបចំលិខិតបទដ្ឋានគតិយុត្តនិងយន្តការស្តីពីការរៀបចំ និងការប្រព្រឹត្តទៅការប្រឡងនៅវិទ្យាល័យចំណេះ-ទូទៅ និងបច្ចេកទេសនៅឆ្នាំ២០២១(តទវ/នក) | | |
| ***គោលនយោបាយទី២ ៖*** *ធានាភាពស័ក្តសិទ្ធិនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់* | • រៀបចំសេចក្តីណែនាំស្តីពីអភិបាលកិច្ចល្អនៅតាមសាលាមធ្យមសិក្សាចំណេះទូទៅ និងសាលាអប់រំបច្ចេកទេសក្នុងឆ្នាំ២០១៩ (នក)<br>• ធ្វើបច្ចុប្បន្នភាពគោលនយោបាយស្តីពីសៀវភៅសិក្សាគោល និងសៀវភៅគ្រូដើម្បីអភិវឌ្ឍសៀវភៅសិក្សាគោលក្នុងឆ្នាំ២០១៩ (អកស) | • រៀបចំសេចក្តីណែនាំសម្រាប់ការអនុវត្តប្រព័ន្ធគ្រប់គ្រងសិស្សតាមរយៈបច្ចេកវិទ្យាព័ត៌មានក្នុងឆ្នាំ២០២០ ( មចទ )<br>• ទស្សនាទាននិងសេចក្តីណែនាំស្តីពីប្រភេទគ្រឹះស្ថានសិក្សា ក្នុងឆ្នាំ ២០២០ (នក) | • រៀបចំសេចក្តីណែនាំប្រតិបត្តិស្តីពីការអនុវត្តការគ្រប់គ្រងតាមសាលារៀនក្នុងឆ្នាំ២០២១ ( មចទ )<br>• កែសម្រួលប្រកាសស្តីពីសញ្ញាបត្របច្ចេក-ទេស និងវិជ្ជាជីវៈកម្រិត ៣ នៅឆ្នាំ ២០២១ (តទវ/នក) | • រៀបចំប្រកាសស្តីពីការផ្តល់និងលុបស្តីពីវិញ្ញាបនបត្រនៅតាមសាលាមធ្យមសិក្សាក្នុងឆ្នាំ២០២២ (មចទ)<br>• រៀបចំប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សាលាមធ្យមសិក្សាក្នុងឆ្នាំ២០២២(មចទ) | • រៀបចំប្រកាសស្តីពីការគ្រប់-គ្រងគ្រឹះស្ថានមធ្យមសិក្សាក្នុងឆ្នាំ ២០២៣ ( មចទ ) |

| | | | | | |
|---|---|---|---|---|---|
| **អនុវិស័យ ការអប់រំឧត្តមសិក្សា** | | | | | |
| ***គោលនយោបាយទី១ ៖*** *ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា* | • បង្កើតគោលការណ៍ណែនាំស្តីពីការអនុវត្តភាពជាដៃគូឧត្តមសិក្សាសម្រាប់កែលម្អសមត្ថភាពនៅគ្រឹះស្ថានឧត្តមសិក្សានៅឆ្នាំ២០១៩ (ឧស)<br>• រៀបចំប្រកាសស្តីពីបុគ្គលិកសិក្សាពេញម៉ោងនៅតាមគ្រឹះស្ថានឧត្តមសិក្សានៅឆ្នាំ២០១៩ (ឧស/បល) | • រៀបចំប្រកាសអន្តរក្រសួងស្តីពីការបង្កើតមូលនិធិស្រាវជ្រាវសម្រាប់ឧត្តមសិក្សានៅឆ្នាំ២០២០ (ឧស)<br>• បង្កើតគោលការណ៍ណែនាំស្តីពីការអនុវត្តមូលនិធិស្រាវជ្រាវសម្រាប់ឧត្តមសិក្សានៅឆ្នាំ ២០២០ (ឧស) | | • រៀបចំប្រកាសអន្តរក្រសួងស្តីពីមូលនិធិអាហារូបករ-ណ៍សម្រាប់និស្សិតនៅឧត្តមសិក្សានៅឆ្នាំ២០២២ (ឧស/ហវ) | |
| ***គោលនយោបាយទី២ ៖*** *ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់* | • រៀបចំគោលការណ៍ណែនាំស្តីពីការតវ៉ា ការប្តឹង និងការដោះស្រាយសម្រាប់និស្សិតនៅក្នុងគ្រឹះស្ថានឧត្តមសិក្សានៅឆ្នាំ ២០១៩(ឧស/នក) | | • រៀបចំសេចក្តីណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាគ្រប់ជ្រុងជ្រោយនៅឆ្នាំ២០២១ (ឧស/ហវ/អគផ) | • រៀបចំប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុតាមបែបប្រព័ន្ធថវិកាជាកញ្ចប់នៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនៅឆ្នាំ២០២២ (ឧស/ហវ)<br>• រៀបចំប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងធនធានមនុស្ស នៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈនៅឆ្នាំ២០២២ (ឧស/បល) | • រៀបចំព្រះរាជក្រឹត្យស្តីពីអភិបាលកិច្ច និងការគ្រប់គ្រងនៅឧត្តមសិក្សានៅឆ្នាំ ២០២៣ (ឧស/នក) |
| **អនុវិស័យ ការអប់រំក្រៅប្រព័ន្ធ** | | | | | |
| ***គោលនយោបាយទី១ ៖*** *ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិត* | • កសាងគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត នៅឆ្នាំ ២០១៩ (អកប/គនប) | • រៀបចំផែនការសកម្មភាព ដើម្បីអនុវត្តគោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិត នៅឆ្នាំ ២០២០ (អកប/នក/អគផ) | • រៀបចំសេចក្តីណែនាំស្តីពីការរៀបចំប្រឡងសម្រាប់កម្មវិធីសមមូលមធ្យមសិក្សាទុតិយភូមិ | | |

| | | | | | |
|---|---|---|---|---|---|
| *សម្រាប់ទាំងអស់គ្នា* | • រៀបចំសេចក្ដីណែនាំស្ដីពីការអនុវត្តកម្មវិធីអក្ខរកម្មនៅឆ្នាំ២០១៩ (អកប)<br>• រៀបចំលក្ខណវិនិច្ឆ័យចំណាត់ថ្នាក់មជ្ឈមណ្ឌលសិក្សាសហគមន៍ នៅឆ្នាំ២០១៩ (អកប)<br>• រៀបចំសេចក្ដីណែនាំស្ដីពីការអនុវត្តកម្មវិធីក្រោយអក្ខរកម្ម នៅឆ្នាំ ២០១៩ (អកប)<br>• រៀបចំសេចក្ដីណែនាំស្ដីពីការរៀបចំប្រឡងសម្រាប់កម្មវិធីសមមូលមធ្យមសិក្សាបឋមភូមិនៅឆ្នាំ២០១៩(អកប)<br>• រៀបចំលក្ខណៈវិនិច្ឆ័យចំណាត់ថ្នាក់មជ្ឈមណ្ឌលសិក្សាសហគមន៍ នៅឆ្នាំ២០១៩ (អកប) | • រៀបចំបណ្ណាល័យ និងបណ្ណាល័យចល័ត នៅឆ្នាំ២០២០ (អកប)<br>• រៀបចំសេចក្ដីណែនាំស្ដីពីការអនុវត្តកម្មវិធីសមមូលមធ្យមសិក្សាទុតិយភូមិ នៅឆ្នាំ ២០២០ (អកប) | នៅឆ្នាំ២០២១ (អកប/កប្រឡ) | | |
| ***គោលនយោបាយទី២ ៖*** *ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់* | • រៀបចំសេចក្ដីណែនាំស្ដីពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធ នៅឆ្នាំ២០១៩ (អកប)<br>• រៀបចំសេចក្ដីណែនាំស្ដីពីការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធនៅឆ្នាំ២០១៩ (អកប)<br>• រៀបចំសេចក្ដីណែនាំស្ដីពី ការគ្រប់គ្រងសាលា/ថ្នាក់ឯកជនបណ្ដុះ-បណ្ដាលភាសាបរទេសឬជំនាញងាយៗ នៅឆ្នាំ ២០១៩ (អកប) | | | | |

| **អនុវិស័យ ការអភិវឌ្ឍយុវជន** | | | | | |
|---|---|---|---|---|---|
| ***គោលនយោបាយទី១ ៖*** *ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា* | • អភិវឌ្ឍគោលការណ៍ណែនាំស្តីពីវេទិកាការងារស្ម័គ្រចិត្តនៅឆ្នាំ២០១៩ (អយវ)<br>• ធ្វើបច្ចុប្បន្នកម្មសេចក្តីណែនាំស្តីពីចលនាប្រឡងប្រណាំងពាល្អរបស់ក្រុមប្រឹក្សាយុវជន និងកុមារកម្ពុជានៅឆ្នាំ២០១៩ (យវ) | • អភិវឌ្ឍគោលនយោបាយ និងគោលការណ៍ណែនាំស្តីពីសុវត្ថិភាពពីការគ្រប់គ្រងគ្រោះថ្នាក់និងហានិភ័យ នៅឆ្នាំ២០២០ (អយវ)<br>• រៀបចំសេចក្តីណែនាំស្តីពីក្របខណ្ឌទទួលស្គាល់ការងារស្ម័គ្រចិត្តយុវជននៅឆ្នាំ២០២០ (អយវ)<br>• ធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពជាតិស្តីពី ការអភិវឌ្ឍយុវជនកម្ពុជានៅឆ្នាំ២០២០ (អយវ) | | • រៀបចំសេចក្តីណែនាំស្តីពីក្រុមប្រឹក្សាជាតិកាយរឹទ្ធិនៃកាយរឹទ្ធិជាតិនៅឆ្នាំ ២០២២ (សករ) | |
| ***គោលនយោបាយទី២ ៖*** *ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់* | | • រៀបចំព្រះរាជក្រឹត្យនិងអនុក្រឹត្យស្តីពីក្រុមប្រឹក្សាជាតិកាយរឹទ្ធិនៃកាយរឹទ្ធិជាតិកម្ពុជានៅឆ្នាំ២០២០ (អយវ/នក)<br>• ធ្វើបច្ចុប្បន្នកម្មសេចក្តីណែនាំស្តីពីដំណើរការនៃមជ្ឈមណ្ឌលយុវជន និងការបណ្តុះបណ្តាលវិជ្ជាជីវៈនិងជំនាញទន់នៅឆ្នាំ២០២០ (មយវ) | • រៀបចំប្រកាសអន្តរក្រសួងស្តីពី របបហិរញ្ញវត្ថុរបស់មន្ត្រីទទួលបន្ទុកការងារយុវជននៅឆ្នាំ២០២១ (អយវ/ហវ)<br>• ធ្វើបច្ចុប្បន្នកម្ម គោល-នយោបាយនិងផែនការបណ្តុះបណ្តាលជាតិនៃកាយរឹទ្ធជាតិនៅឆ្នាំ ២០២១ (សករ) | | • ធ្វើបច្ចុប្បន្នកម្មគោលនយោ-បាយធនធានមនុស្សពេញវ័យនិងការស្ម័គ្រចិត្តកាយរឹទ្ធិនៃកាយរឹទ្ធិជាតិនៅឆ្នាំ២០២៣ (អយវ) |

| អនុវិស័យ ការអប់រំកាយ និងកីឡា | | | | | |
|---|---|---|---|---|---|
| *គោលនយោបាយទី១ ៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា* | • កែសម្រួលអនុក្រឹត្យនិងប្រកាសស្តីពីគម្រោងផ្តល់អាហារូបត្ថម្ភបន្ថែមនិងប្រាក់ឧបត្ថម្ភនៃការបណ្តុះបណ្តាលនិងការប្រកួតថ្នាក់ជាតិនិងអន្តរជាតិនៅឆ្នាំ២០១៩ (អកឡ/នក)<br>• រៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងកីឡានៅឆ្នាំ២០១៩ (អកឡ/នក)<br>• កែសម្រួលស្តង់ដាបច្ចេកទេសស្តីពីការអប់រំកាយនិងកីឡានៅឆ្នាំ ២០១៩ (អកឡ)<br>• រៀបចំលិខិតបទដ្ឋានគតិយុត្តស្តីពីការបង្កើតមជ្ឈមណ្ឌលកីឡាភូមិភាគដើម្បីគាំទ្រដល់ការប្រមូលផ្តុំប្រកបដោយប្រសិទ្ធភាពនិងគុណភាពខ្ពស់នៅឆ្នាំ២០១៩ (អកឡ/នក)។ | | | | |

| ឈ្មោះនាយកដ្ឋាន/អង្គភាព | អក្សរកាត់ | ឈ្មោះនាយកដ្ឋាន/អង្គភាព | អក្សរកាត់ |
|---|---|---|---|
| នាយកដ្ឋានអប់រំកុមារតូច | អកត | នាយកដ្ឋាននីតិកម្ម | នក |
| នាយកដ្ឋានបឋមសិក្សា | បស | នាយកដ្ឋានធានាគុណភាពអប់រំ | ធគអ |
| នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ | មចទ | នាយកដ្ឋានកិច្ចការប្រឡង | កប្រឡ |
| នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ | អកប | អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ | អគផ |
| នាយកដ្ឋានអប់រំពិសេស | អព | នាយកដ្ឋានគោលនយោបាយ | គនប |
| នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | តទវ | នាយកដ្ឋានផែនការ | ផក |
| នាយកដ្ឋានឧត្តមសិក្សា | ឧស | អគ្គនាយកដ្ឋានកីឡា | អកឡ |
| នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ | បវ | អគ្គនាយកដ្ឋានយុវជន | អយវ |
| នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា | អកស | នាយកដ្ឋានយុវជន | យវ |
| នាយកដ្ឋានបុគ្គលិក | បល | នាយកដ្ឋានគ្រប់គ្រងមជ្ឈមណ្ឌលយុវជន | គមយ |
| នាយកដ្ឋានហិរញ្ញវត្ថុ | ហវ | នាយកដ្ឋានសហប្រតិបត្តិការកាយរឹទ្ធិ | សករ |